## សិក្សា

លាង ហាប់អាន

# ប្រវត្តិអក្សរសាស្ត្រខ្មែរ

## សម័យនគរភ្នំដល់សម័យឧដុង្គ
## ( សតវត្សទី ១ដល់ ១៨៥៩)

### សំរាប់កម្មវិធីថ្មី

- សិក្សាមធ្យមភូមិ
- ឧត្តមសិក្សា
- ការស្រាវជ្រាវរបស់អ្នកអក្សរសាស្ត្រ

CA29

លាង ហាប់ អាន

# សិក្សា
# ប្រវត្តិអក្សរសាស្ត្រខ្មែរ

## សម័យនគរភ្នំដល់សម័យឧដុង្គ
## សតវត្សទី ១ ដល់ ១៨៥៩

ការផ្សាយរបស់

បណ្ណាគារ គិម-អេង លេខ ១២២

វិថីទេមិរភូមិន្ទ ភ្នំពេញ

(អ្នកនិពន្ធរក្សាសិទ្ធិគ្រប់យ៉ាង)

ព.ស. ២៥១១ គ.ស. ១៩៦៧

## អារម្ភបទ

សៀវភៅ សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ នេះជាកម្រងអត្ថបទមេរៀនផ្នែកប្រវត្តិអក្សរសាស្ត្រខ្មែរ ដែលខ្ញុំបានរៀបរៀងបង្រៀននិស្សិតអប់រំអក្សរសាស្ត្រថ្នាក់ទី ២ នៃសមាគមអ្នកនិពន្ធខ្មែរ (ឆ្នាំសិក្សា ១៩៦៦–៦៧) ។ មេរៀននេះបានទាញពុម្ពចែកចំពោះនិស្សិតពីទំព័រ ១ ដល់ ៩២ រួចមកហើយ ។ ខ្ញុំនឹងប្រារព្ធបញ្ចប់មួយផ្នែកខាងចុងដែលបន្តពីសម័យឧដុង្គ គឺពីឆ្នាំ ១៨៥៩ រហូតដល់បច្ចុប្បន្នកាលទៀត ។ ចំពោះផ្នែកទី ១ នេះខ្ញុំបានប្រគល់ជូនសហជីវិន «ឌៀប-ហាក់-គាង» ដើម្បីយកទៅបោះពុម្ពផ្សាយជាសៀវភៅ ដោយមានភ្ជាប់គ្រឿងអត្ថបទសិលាចារឹកខ្លះជាគំរូ ព្រមទាំងលក្ខណៈអក្សរខ្មែរយើងទាំង ១០ ជំនាន់ តាមបែបនៃការស្រាវជ្រាវរបស់លោកអ្នកប្រាជ្ញ «ម៉ៅស៊ំ-រេស្ត៊ី» ។ ខ្ញុំស្តាយដោយរកឃើញរូបអ្នកនិពន្ធ ឬកវីខ្លះទៀត គ្មានជំនាន់ឧដុង្គពុំបានដើម្បី

ផ្តិតចុះជូនជាសំគាល់ ៗ នៅពេលបោះពុម្ពលើកទី ២ ខ្ញុំនឹង
ខិតខំរករូបថតអស់លោកអ្នកនិពន្ធទាំងឡាយនេះ មក
ចុះបំពេញបំណងអស់លោកអ្នកអានសិក្សាទុកជាកស្តុតាងខ្លះៗ

ខ្ញុំសង្ឃឹមថា សៀវភៅដែលខ្ញុំសន្មតត្រឹមតែ "ការសាក
ល្បង" នេះនឹងមានប្រយោជន៍ច្រើនចំពោះការស្រាវជ្រាវ
សិក្សាអំពីលក្ខណៈនិងផលនាអក្សរសាស្ត្រយើង ក្នុងកាលៈ
ទេសៈដែលខ្វះខាតនូវក្បួនខ្នាតបែបនេះនៅឡើយ ៗ រួមជាមួយ
នឹងការសិក្សាស្រាវជ្រាវផ្សាយរួចហើយ នូវសៀវភៅប្រវត្តិ
អក្សរសាស្ត្របែបនេះរបស់អស់លោកជារៀមច្បង សៀវភៅ
«**សិក្សាប្រវត្តិអក្សរសាស្ត្រ**» ខ្មែររបស់ខ្ញុំនេះ មុខ
ជានឹងបានជាឧបករណ៍បន្ថែមមួយទៀត របស់អស់លោកអ្នក
ដែលស្នេហាអក្សរសាស្ត្រជាតិ ដង្ហែតាមព្រះមាគ៌ាលើក
ស្ទួយឧបត្ថម្ភ វប្បធម៌ អារ្យធម៌ជាតិរបស់ **សម្តេចព្រះ
ប្រមុខរដ្ឋ ព្រះបិតាជាតិ** ជាទីស្នេហាស្មើដោយជីវិត

របស់យើងគ្រប់ៗគ្នាជាពុំខាន ។

សូមអក្សរសាស្ត្រខ្មែរបានគង់វង្ស លូតលាស់ចំរើនជានិរន្តរ៍ ។

ភ្នំពេញ, ថ្ងៃទី ២០ សីហា ២៥១១ / ១៩៦៧

**លាវ ហាប់ អាន**

សាស្ត្រាចារ្យខាងភាសាខ្មែរ

"ប្រើគេឲ្យមានប្រណី ដេរស្ដីឲ្យមានមេត្តា
ចាប់ធ្វើការឲ្យចំប្រឹង បើខ្វះទឹងឲ្យខំអត់" ។
"ចង់ឈ្នះឲ្យចាញ់
ចង់ទាញឲ្យស្ងប់
ចង់ប្រសប់ឲ្យល្ងង់"
"ចង់បេះឲ្យមើលក្បួន ចង់ម៉ាំមួនឲ្យចំប្រឹង
បើបន្ដឹងភនឹងដាច់ ចង់បានសំរេចឲ្យចិតទំ" ។

ល.ហ.អ.

# អក្សរសាស្ត្រខ្មែរពីសម័យ
# បុរាណមកសម័យបច្ចុប្បន្ន (១)

## ១– ផ្ដើមសេចក្ដី

មុននឹងលើកយកនូវមេរៀនមកសិក្សារៀបរាប់ គប្បីដឹងជាមុនសិននូវកម្មវិធីសំរាប់ឆ្នាំសិក្សាទី ២ ស្ដីអំពីអក្សរសាស្ត្រខ្មែរសម័យបច្ចុប្បន្ន ដែលចែកជាផ្នែកលំដាប់លំដោយគ្នាដូច

---

(១) សៀវភៅនិងអត្ថបទសំរាប់សិក្សាជាជំនួយមានដូចតទៅ :

— មើលឡើងវិញនូវមេរៀនទី ១០-១១-១២ របស់ ល.ហ.អ. ឈ្មោះ "ប្រភេទអត្ថបទ" ទំព័រ ៤៨ ដល់ ៨៦ ឆ្នាំសិក្សា វ.អ.ស. ឆ្នាំ ១៩៦៥-៦៦ សំរាប់ឆ្នាំទី១ ។

— អត្ថបទសន្និសីទរបស់ សហ. ទ្រឹញ-ភ៉ាញ ប្រធានសមាគមអ្នកនិពន្ធខ្មែរឈ្មោះ "អំពីសមាគមអ្នកនិពន្ធខ្មែរ" ១៥-១១-៦៥ ។

— សៀវភៅ "អក្សរសាស្ត្រខ្មែរ" របស់ លី-ធាមតេង បោះពុម្ពលើកទី ២ ឆ្នាំ១៩៦០ ចាប់ពីទំព័រ ៩២ តទៅ ។

— ទស្សនាវដ្ដី "កម្ពុជសុរិយា" ពិសេសពីឆ្នាំ ១៩៦៥-៦៦ ត្រង់អត្ថបទ "ឯកសារសាស្ត្រស្លឹករឹត និងក្រាំងរបស់លោក ញ៉ុក ថែម និង "ឯកសារកម្ពុជសុរិយា" ប្រមូលរៀបរៀងដោយ សហ. ឌិក-គាម ។

(ធ្វគ)

គ.ទៅ (១) =

— ការរៀនសារឡើងវិញ ដោយសង្ខេបអំពីប្រវត្តិអក្សរ-សាស្ត្រខ្មែរ - លក្ខណៈនៃអក្សរសាស្ត្រសម័យដើម ។

—ពីអក្សរសាស្ត្រដើមមកអក្សរសាស្ត្រសម័យ-លក្ខណៈនៃអក្សរសាស្ត្រដើមដែលនៅសព្វថ្ងៃនិងការផ្លាស់ប្តូរផ្សេងៗ ។

— ដំណាក់តាំង ២ នៃអក្សរសាស្ត្រសម័យបច្ចុប្បន្ន: ពេលអាណាព្យាបាលនិងក្រោយឯករាជ្យ - ការកត់បំណាំអំពីការជ្រើសរើសវិជ្ជានិពន្ធ ។

---

— ទស្សនាវដ្ដី ឈ្មោះ «វិជ្ជាឋាន គរុកោសល្យ» លេខ ១ និង ២ ឆ្នាំ ១៩៥៨ ខែវិច្ឆិកា និងខែឧសភា ១៩៥៩ ត្រង់អត្ថបទពាក្យអ្នកនិពន្ធខ្មែររបស់លោក ញឹក-ថែម ។

—អត្ថបទរបស់លោក កេង-វ៉ាន់សាក់ ផ្សាយពីមហាវិទ្យាល័យអក្សរសាស្ត្រ ឈ្មោះ «ទិដ្ឋភាពខ្លះនៃអក្សរសិល្ប៍ខ្មែរ» តែងជាភាសាបារាំង ។

— ទស្សនាវដ្ដី «អក្សរសាស្ត្រខ្មែរ» លេខ ១៩ ឆ្នាំ ទី៣ ខែវិច្ឆិកា ១៩៦៤ ពិសេសអត្ថបទ សហ. អ៊ុង-ម៉ុង និង ម៉ា ឡាយខេម ។

(១) គឺជាកម្មវិធីបង្រៀនអក្សរសាស្ត្រខ្មែរ នៅវិជ្ជាឋានអប់រំអក្សរសាស្ត្រ ឆ្នាំ ១៩៦៥-៦៦ និង ១៩៦៦-៦៧ របស់សមាគមអ្នកនិពន្ធខ្មែរ ។

— អ្នកនិពន្ធសម័យថ្មី (អ្នកនិពន្ធប្រលោមលោក កវី និងអ្នកនិពន្ធរឿងល្ខោន) និងគោលគំនិតថ្មីៗ - ការសិក្សាអំពីគួរឿង វិជ្ជានិពន្ធ ស្ប្រាយ - ការសិក្សាអំពីទំនើមគុបទ :

របៀបតែងនិងបែបសរសេរ ដោយមានរៀបរាប់ឈ្មោះអ្នកនិពន្ធផង - ការសិក្សាប្រៀបធៀបនឹងសម័យមុនៗ ឬនឹងអក្សរសាស្ត្របរទេស - សម័យបច្ចុប្បន្នដទៃទៀត ។

— ការរិះគន់ជាទូកល់លើអក្សរសាស្ត្រសម័យបច្ចុប្បន្ន (រឿងប្រលោមលោក កំណាព្យ រឿងល្ខោន) ។ ទុសថដែលត្រូវស្នើដើម្បីកែទូវគោលគំនិត ព្រមទាំងរបៀបតែងរឿង ។ សារសំខាន់នៃការរិះគន់ខាងអក្សរសាស្ត្រ ។

— បញ្ហានានាដែលកើតចំពោះអ្នកនិពន្ធសម័យថ្មី : ការបេះដឹងទូទៅ ការជុះគំនិត ការជ្រើសរើសវិជ្ជានិពន្ធ ការលំបាកខាងផ្លូវសម្ភារៈ (បោះពុម្ពផ្សាយសៀវភៅ ។ល។) មធ្យោបាយនានា សំរាប់ដោះស្រាយបញ្ហាទាំងនោះ ។

— កត្តានៃការចំរើនរបស់អក្សរសាស្ត្រ : សមាគមអ្នក

និពន្ធខ្មែរ និងសកម្មភាពរបស់សមាគមនេះ មានការប្រជុំអក្សរសាស្ត្រ ការផ្សាយតាមវិទ្យុ សន្និសីទសាធារណៈ ប្រឡងអក្សរសាស្ត្រ ។ល។

– សកម្មភាពនៃរាជរដ្ឋាភិបាលក្នុងវិស័យអក្សរសាស្ត្រ។

– មធ្យោបាយដើម្បីផ្សាយអក្សរសាស្ត្រ : ការសំរួលជារឿងភាពយន្ត រឿងល្ខោន និងរឿងផ្សាយតាមវិទ្យុ ។

– នេត្រាទស្សន៍ទៅអនាគត : តើត្រូវណែនាំអ្នកនិពន្ធក្នុងការបង្កើតអក្សរសាស្ត្រ(១) ឬទេ តាមមធ្យោបាយណា (រង្វាន់អក្សរសាស្ត្រ សិក្ខាសន្និបាតអក្សរសាស្ត្រ វិជ្ជាអប់រំខាងអក្សរសាស្ត្រ ។ល។)

## ២– ឃ្លាភ្ជាប់សេចក្ដី

មុននឹងចូលទៅក្នុងការសិក្សាអំពីអក្សរសិល្ប៍ប្រវត្តិ ទៅតាមកាលសម័យនីមួយៗ យើងលើកយកកាលប្រវត្តិក្នុងប្រវត្តិ

(១) ការដាក់ជាអក្សរសាស្ត្រនេះ គឺដោយសារសេរតាមកម្មវិធីរបស់វិជ្ជាឋានទេ ។ តាមន័យត្រឹមត្រូវនៃពាក្យ = littérature (œuvre littéraire) ក្នុងទីនេះ គួរប្រើសព្ទថា «អក្សរសិល្ប៍» វិញ ។

វិជ្ជាខ្មែរយើងមកលាតត្រដាងជាពន្លឺនៃការសិក្សាសិន ។

## ៣– កាលប្រវត្តិតាមប្រវត្តិវិជ្ជា

តាមប្រវត្តិវិជ្ជា គេចែកសម័យកាលធំជា ៤ ផ្នែក (១) គឺ:

### សម័យកាលទី ១

សម័យនគរភ្នំ (Période du «Royaume de la montagne» ពីសតវត្សទី ១ ដល់ទី ៦

### សម័យកាលទី ២

សម័យមុនអង្គរ (Période pré-angkorienne) :

ចាប់ពីគ.ស. ៥៥០ ដល់ ៨០២

ព្រះមហាក្សត្រសំខាន់ៗ ខ្លះក្នុងសម័យកាលនោះមាន:

– ព្រះបាទភវវរ្ម័នទី ១ (គ.ស. ៥៥០-៦០០) = Bhava-Varman 1er

---

(១) យកតាមលំនាំប្រវត្តិវិជ្ជា របស់ សហ ឌួង-សារិន មេរៀនសំរាប់មហាវិទ្យាល័យអក្សរសាស្ត្រ និងសៀវភៅប្រវត្តិវិជ្ជា ឈ្មោះ Histoire du Cambodge របស់ Mlle M. Giteau, របស់ A. Leclère, A. Dauphin Meunier, អត្ថបទនានាជាស្នាព្រះហស្តសម្តេចព្រះន.សីហនុ។

–ព្រះបាទមហេន្ទ្រវរ្ម័ន ចិត្រសេន (គ.ស.៦០០-៦១៥)=
Mahendra-Varman Chitrasena

– ព្រះបាទឥសានវរ្ម័ន ទី ១ (គ.ស. ៦១៥-៦៣៥) =
Içana-Varman 1er

– ព្រះបាទភវវរ្ម័ន ទី ២ (គ.ស.៦៣៥-៦៥៥) =
Bhava-Varman II

– ព្រះបាទជ័យវរ្ម័ន ទី ១ (គ.ស. ៦៥៥-៦៨១) =
Jayavarman 1er

## សម័យកាល ទី ៣

សម័យអង្គរ (Période angkorienne)

គ្រិស្តសតវត្ស ទី ៩ ដល់ទី ១៤ (គ.ស. ៨០២ ដល់ ១៣៣៦)

ព្រះមហាក្សត្រសំខាន់ៗ ក្នុងសម័យកាលនេះមាន :

– ព្រះបាទជ័យវរ្ម័ន ទី ២ (គ.ស. ៨០២-៨៥០) ដែលកសាងប្រាសាទដំបូងនៅភ្នំគូលេន : Jayavarman II

– ព្រះបាទជ័យវរ្ម័ន ទី ៣ (គ.ស. ៨៥៤-៨៧៧)=
Jayavarman III

– ព្រះបាទឥន្ទ្រវរ្ម័ន ទី ១ (គ.ស. ៨៧៧-៨៨៩) = Indravarman 1er

– ព្រះបាទយសោវរ្ម័ន ទី ១ (គ.ស. ៨៨៩-៩០០) = Yaçovarman 1er

– ព្រះបាទហសវរ្ម័ន ទី ២ (គ.ស. ៩៤១-៩៤៤) = Harshavarman II

– ព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស. ៩៤៤-៩៦៨) = Rajendravarman

– ព្រះបាទជ័យវរ្ម័ន ទី ៥ (គ.ស. ៩៦៨-១០០១) = Jayavarman V

– ព្រះបាទសូរ្យវរ្ម័ន ទី ១ (គ.ស. ១០០២-១០៥០) = Sûryavarman 1er

– ព្រះបាទឧទយាទិត្យវរ្ម័ន ទី ២ (គ.ស. ១០៥០-១០៦៦) = Udayàdityàvarman II

– ព្រះបាទហស៌វរ្ម័ន ទី ៣ (គ.ស. ១០៦៦-១០៨០) = Harshavarman III

– ព្រះបាទជ័យវរ្ម័ន ទី ៦ (គ.ស. ១០៨២-១១០៧) = Jayavarman VI

—ព្រះបាទធរណិន្ទ្រវរ័ន ទី១ (គ.ស. ១១០៧-១១១២)= Dharanindravarman 1er

— ព្រះបាទសូរ្យវរ័ន ទី ២ (គ.ស. ១១១៣ ១១៥០)= Sùryavarman II

— ព្រះបាទជ័យវរ័ន ទី ៧ (គ.ស. ១១៨១-១២០១) = Jayavarman VII

— ព្រះបាទជ័យវរ័ន ទី ៩ (គ.ស. ១៣២៧-១៣៣៦)= Jayavarman IX

## សម័យកាលទី ៤

សម័យក្រោយអង្គរ (Période Post-angkorienne) ចុង គ្រិស្តសតវត្សទី ១៤ ដល់សព្វថ្ងៃ ។ សម័យកាលនេះចែកបាន ជា ៣ ផ្នែកសំខាន់ គឺ :

ផ្នែកទី ១.— សម័យលង្វែក (Pèriode de Lovék) គឺពីចម្បាំង ជាមួយសៀម មកទល់ការបាត់បង់លង្វែក (Des premières guerres siamoises à la prise de Lovék) (គ.ស. ១៣៣៦-១៥៩៣) គឺចាប់ពីសម័យ បាត់បង់អង្គរក្នុងរជ្ជកាលព្រះបាទ លំពង់ (១៣២៦- ១៣៥១) មកដល់រជ្ជកាលព្រះ សត្ថា (Preah Satha)

ផ្នែកទី ២.– សម័យក្រុងឧដុង្គឫជ័យ (Période de Oudong)
(គ.ស. ១៦១៨-១៨៥៩) ពីរជ្ជកាលព្រះបាទជ័យ-
ជេដ្ឋា (Chey Chettha, គ.ស. ១៦១៨-១៦២៨)
មកដល់រជ្ជកាលព្រះបាទ អង្គ ឌួង (Preah Ang
Duong, គ.ស. ១៨៤៥-១៨៥៩)

ផ្នែកទី ៣.– សម័យក្រុងភ្នំពេញ (Période de Phnom-Penh)
ចាប់ពី គ.ស. ១៨៥៩ មកទលសព្វថ្ងៃ ។
សម័យនេះចែកជា ៣ កាលគឺ :

កាលទី ១.– សម័យអាណានិគម : Période sous protectorat
(ពីរជ្ជកាលព្រះបាទ នរោត្តមទី ១ (Preah Noro-
dom 1er) គ.ស. ១៨៥៩-១៩០៤ មកដល់រជ្ជ
កាលខាងដើម នៃព្រះករុណាព្រះបាទ សម្តេចព្រះ
នរោត្តម - សីហនុវរ្ម័ន (S. M. Preah
Norodom Sihanouk Varman) ថ្ងៃ៩វិច្ឆិកា១៩៥៣។

កាលទី២.–សម័យកាលឯករាជ: Période de l'Indépendance

តាំងពីថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ មកដល់ថ្ងៃទី ២ មីនា ១៩៥៥ (គឺក្នុងរជ្ជកាលព្រះបាទ នរោត្តម-សីហនុ វរ្ម័ន និងព្រះករុណាព្រះបាទសម្តេចព្រះ សុរាម្រិត)

កាលទី៣.— *សម័យសង្គមរាស្ត្រនិយម* : Période du Sangkum Reastr Niyum (តាំងពីកើត "សង្គមរាស្ត្រនិយម" ដែលសម្តេចព្រះ បិតាឯករាជ្យ ឯកភាពជាតិ ព្រះ នរោត្តម-សីហនុ ឧបយុវរាជទ្រង់បង្កើតឡើង គឺ ទី ២ មីនា ១៩៥៥ មកទល់សព្វថ្ងៃ)

ចុងរជ្ជកាលព្រះបាទសម្តេចព្រះសុរាម្រិត កាញ្ចន- កោដ - និងសម័យសម្តេចព្រះមហាក្សត្រិយានី ព្រះ ស៊ីសុវត្ថិ កុសុមៈនារីរ័តន៍ ព្រះមាតាជាតិ និង ព្រះ នរោត្តម-សីហនុ ព្រះប្រមុខរដ្ឋ ។

សំគាល់

*សម័យទី ៤ នេះអាចចែកនិងហៅបានទៀតថា:*

ក) ពីគ.ស. ១៨៥៩-១៩៥៣ បុនវុឌ្ឍិសម័យ :

Période de la « Renaissance Nationale »

ខ) ពីថ្ងៃ ៩ វិច្ឆិកា ១៩៥៣ ដល់ថ្ងៃទី ២ មីនា ១៩៥៥ សម័យគណៈបក្ស ( Période des partis )

គ) ពីថ្ងៃ ២ មីនា ១៩៥៥ មក សម័យឯកភាពជាតិ :

Période d'Unité Nationale (ឬសម័យសង្គម : Période du Sangkum )

## ៤- អ្នកនិពន្ធនិងស្នាដៃក្នុងសម័យកាលនីមួយៗ

## ទី១- សម័យកាលទី ១

(សម័យនគរភ្នំ គ្រិស្តសតវត្សទី ១ ដល់ទី ៦[១] គ.ស. ១

(១) សូមអានសៀវភៅ G. Coedès, Histoire ancienne des Etats hindouisés d'Extrême-Orient; — P. Pelliot, Le Founan; — A. Bergaigne, Inscriptions de Vo-Canh XX Notices et Extraits de manuscrit. XXVII; — G. Coedès, Inscriptions de Vo—Canh, BEFEO T. XX; —G. Coedès, Inscription du Cambodge T. IV p. 96; —សៀវភៅពុទ្ធសាសនា ២៥០០ (ទំព័រ ៩ ដល់ ១១០); Histoire du Cambodge de A· Lecler និង M. Giteau ។

ដល់ ៥៥០)

## ១– ក្សត្រក្នុងសម័យកាលទី ១

ក្នុង គ.ស. ៥០ ព្រះបាទ កៅណ្ឌិន្យ : Kaundinya និងនាងសោមា Soma (ឬ កៅណ្ឌិន្យ-នាគីសោមា គឺព្រះថោង នាងនាគី ជាបឋមក្សត្រិយ៍) – ទីក្រុងឈ្មោះវ្យាធបុរៈ Vyàdhapura នៅបាភ្នំ Ba Phnom ) ;

– មុនគ្រិស្តសតវត្សទី៣ គឺព្រះបាទ ហួន-ហ្វាន់-ហ្វាង: (Houen Phan-Houang) (ចូលទីវង្គតក្នុងព្រះជន្ម ៩០ ឆ្នាំ) ;

– តមកព្រះរាជបុត្រ នាម ហ្វាន់-ហ្វាន់ Phan-Phan (សោយរាជ្យបាន ៣ ឆ្នាំ កាន់សីវៈសាសនា គោរពឥស្សូរជាធំ)

– បន្ទាប់មកគឺព្រះបាទ ស្រីមារ: (Çri-Màra Sùrya Varman) ឬ ហ្វាន់-ចេ-ម័ន = Phan Tche-Man ;

–ព្រះបាទធរណិន្ទ្រវរ័ន (Dharnindra- Varman) ដែលបានឡើងសោយរាជ្យ បានប្រហារព្រះរាជបុត្រច្បងរបស់ព្រះស្រីមារ: ប៉ុន្តែក្រោយនោះក្នុង គ.ស. ២៤០ ត្រូវរាជបុត្រព្រះ

ស្រីមារៈមួយព្រះអង្គទៀតសងសឹកសម្លាប់ព្រះអង្គវិញ ;

– ចុងសតវត្សទី ៤ ព្រះបាទកៅណ្ឌិន្យវរ្ម័ន = Kaundinyavarman កាន់សិវសាសនានិងមហាយានសាសនាបានគ្រងរាជ្យ ។

– រាជបុត្រនាម ស្រីឥន្ទ្រវរ្ម័ន= Çri Indravarman បានសោយរាជ្យស្នង បានផ្ញើរាជទូត ៣ លើកទៅប្រទេសចិនក្នុងវង្សកាលសុង= dynastie des Song គឺ គ.ស. ៤៣៤, ៤៣៥ និង ៤៣៨;

– ព្រះបាទ ជ័យវរ្ម័ន = Jaya-Varman (គ.ស. ៤៨០-៥១៤);

– ព្រះបាទ រុទ្រវរ្ម័ន= Rudra-Varman (គ.ស. ៥១៤-៥៥០) បានផ្ញើរាជទូតពីរលើកទៅប្រទេសចិន គឺគ.ស.៥១៧ និង ៥៣៩ ។

## ២– សាសនាក្នុងសម័យកាលទី ១

សាសនាដែលសំខាន់ក្នុងសតវត្សទី ១ ដល់ ៣ គឺ

ព្រហ្មញ្ញសាសនា ។ គេគោរពព្រះឥសូរជាធំ គឺសិវៈនិយម = Çivaïsme ។ ចាប់ពីចុងសតវត្សទី ៤ គេកាន់ព្រហ្មញ្ញសាសនាខាងសិវៈផងទៀត និងពុទ្ធសាសនាបែបមហាយាន ។

## ៣– លក្ខណៈនិងវិវត្តន៍នៃអក្សរខ្មែរពីសម័យបុរាណមកដល់បច្ចុប្បន្ន :

មុននឹងចូលទៅដល់ផ្នែកអក្សរសាស្ត្រ ក្នុងសម័យកាលនីមួយៗតាមប្រវត្តិសាស្ត្រ គប្បីដឹងនិងស្គាល់ខ្លះនូវលក្ខណៈវិវត្តន៍អក្សរខ្មែរយើងតាំងពីបុរាណកាល មកទល់បច្ចុប្បន្នកាលនេះ ។

តាមការសិក្សារបស់លោក ហ្ស៊ក-ម៉ាស់ប៉េរ៉ូ ( Georges Maspéro ) ក្នុងសៀវភៅលោកឈ្មោះវេយ្យាករណ៍នៃភាសាខ្មែរ ( Grammaire de langue khmère ) (១) អក្សរខ្មែរតាំងពីដើមកំណើតមកទល់បច្ចុប្បន្នកាលនេះ មានការផ្លាស់ប្តូររូប

(១) សូមមើល grammaire de langue khmère របស់លោក George Maspéro, Paris, Imprimerie nationale, Ernest Leroux, Editeur, Rue Bonaparte, 28, 1915 ទំព័រ 48-49

លក្ខណៈចំនួន ១០ លើកហើយ ហើយក្នុងមួយលើកៗ មាន លក្ខណៈរូប ឈ្មោះ ជំនាន់និងឆ្នាំ ឬសតវត្សដូចតាងតទៅ.

លក្ខណៈទី ១ អក្សរបែបសិលាចារឹកហាន់ជ័យ, កើតក្នុងសតវត្សប្រមាណជាទី៦ នៃគ.ស.;

លក្ខណៈទី២ អក្សរបែបសិលាចារឹក វាលកន្តែល កើតក្នុងចុងសតវត្សទី ៦ ឬដើមសតវត្សទី ៧ នៃគ.ស.;

លក្ខណៈទី ៣ អក្សរបែបសិលាចារឹក អង្គជំនីក (លោកសឺដែស ហៅថា សិលាចារឹក «ភ្នំអង្គ») ក្នុងឆ្នាំ គ.ស. ៦៦៧;

លក្ខណៈទី ៤ អក្សរបែបសិលាចារឹក ព្រះឥន្ទ្រ កោសីយ ក្នុងឆ្នាំ គ.ស. ៩៧០;

លក្ខណៈទី ៥ អក្សរបែបសិលាចារឹក ព្រះកែវ (លោកសឺដែស ហៅថាសិលាចារឹក «តាកែវ») ក្នុងគ.ស. ១០១២;

បែបទី១... [illegible]

បែបទី២... [illegible]

បែបទី៣... [illegible]

បែបទី៤... [illegible]

បែបទី៥... [illegible]

បែបទី៦... [illegible]

បែបទី៧ [illegible]

បែបទី៨... [illegible]

បែបទី៩... [illegible]

បែបទី១០... [illegible]

លក្ខណៈទី៦ អក្សរបែបសិលាចារឹកព្រះនគរ, ក្នុង
ប. ១០៦៥;

លក្ខណៈទី៧ អក្សរបែបសិលាចារឹកបន្ទាយឆ្មារ
បតវត្សរ៍ទី ១២ ឬដើមសតវត្សរ៍ទី ១៣ នៃគ.ស.;

លក្ខណៈទី ៨ អក្សរបែបសិលាចារឹក អង្គរវត្ត
បតវត្សរ៍ទី ១៣ នៃគ.ស.;

លក្ខណៈទី ៩ អក្សរបែបមហាសិលាចារឹកអង្គរ,
ាំ ១៧០២ នៃគ.ស.;

លក្ខណៈទី ១០ អក្សរបែបបច្ចុប្បន្ននេះ ។

## តារាងបង្ហាញនូវគំរូអក្សរខ្មែរ (១)

(តាមស្រាវជ្រាវរបស់លោកហ្ស៊ក-ម៉ាសពេរ៉ូ)

## ៥– អក្សរសាស្ត្រក្នុងសម័យកាលទី ១ (២)

(១) សូមមើលតារាងជាប់ខាងដើមនេះ ។

(២) សូមអាន Bart — Bergaigne, ISCC, N° 191 — L.
t, BEFEO, XX, II, 3; G.Coedès, IHQ, XVI, 484;
GIS, IV, 117; — BEFEO, XXXI P1 និងពុទ្ធសាសនា ២៥០០
ន៧ ។



សិលាចារឹកនៅភូមិកំរៀង (សម័យចិនឡា សតវត្សទី ៧) (គ.ស. ៦៨៥)

តាមអ្នកប្រាជ្ញ បស្ចិមប្រទេស មានលោក Barth, លោក Bergaigne, លោក Louis Finot, លោក Georges Coedès, យើងកត់សំគាល់បាននូវសិលាចារឹក ៤ កន្លែង ដែលទុកជាគោលនៃអក្សរសាស្ត្រ គឺ:

ទី ១— សិលាចារឹក នៅ វ៉ូកាញ់ ខេត្តញ៉ាត្រាង វៀតណាមខាងត្បូង;
ទី ២— —ដ— នៅ អ្នកតាដំបងដែក ខេត្តតាកែវ;
ទី ៣— —ដ— នៅ ប្រាសាទប្រាំល្វែង ក្នុងដែនកូសាំងស៊ីន កម្ពុជាក្រោម ក្នុងស្រុកទឹកខ្មៅ ខេត្តព្រៃឫស្សី;
ទី ៤— —ដ— នៅទន្លេបាទី ខេត្តតាកែវ ប្រាសាទតាព្រហ្ម;

## ៥– លក្ខណៈសិលាចារឹកក្នុងសម័យកាលទី ១.–

### ទី ១- សិលាចារឹកនៅ វ៉ូកាញ់(១)

### ក) ប្រភេទនិង លក្ខណៈ.–

ជាសិលាចារឹក ចាស់ជាងគេនៅដែនដីអាស៊ីភាគអាគ្នេយ៍ ។ គេអាចប្រដូចអក្សរក្នុងសិលាចារឹកនេះទៅនឹងសិលាចា-

(១) តាមការសិក្សា អត្ថាធិប្បាយរបស់ព្រះតេជៈព្រះគុណ ព្រះមហាវីរិយៈបណ្ឌិតោ ប៉ាង-ខាត់ ចុះក្នុង "ពុទ្ធសាសនា ២៥០០" ទំព័រ ៩ ដល់ ១១០ ។

រឹក រុទ្រទាមន៑ = Rudra Dàman នៅគីនារ Girnar ឬ សា-តករណិវាសិស្ឋិបុត្រៈ = Satakarni Vàsisthiputra នៅកាន-ហេរី Kanheri ក្បែរទន្លេគោទាវរី Godàvari និងទន្លេក្រិស្ណា Krishnà ក្នុងប្រទេសឥណ្ឌា ប៉ែកខាងត្បូង ។

សិលាចារឹកនេះ ថ្វែងពីព្រះបាទ ស្រីមារៈ Cri Màra ... ព្រះបាទ ហ្វាន់ចេ-ម័ន ទ្រង់ជ្រះថ្លាចំពោះព្រះពុទ្ធសាសនា ។

សិលាចារឹកនេះ នាំឲ្យអ្នកប្រាជ្ញជាន់មុនប្រឡំថាជារបស... ចាម ពីព្រោះស្រុកវ៉ូកាញ់នេះ ពីដើមនៅក្នុងដែនដីចា... ចុពណា ។ លោកLouis Finot យល់ថា ស្រុកវ៉ូកាញ់ កាល... អតីតជាដែនដីចំណុះរបស់ប្រទេសនគរភ្នំទេ ។

លោក Barth និង Bergaigne សន្និដ្ឋានថាសិលាចារឹ... វ៉ូកាញ់ ទំនងកើតឡើងក្នុងត្រិស្តសតវត្ស ទី ៣ (ឬក្នុង សតវត្... ទី ២ ផង ក៏ពុំដឹង) ។

១) អត្ថបទដើម .—

. . . ប្រជាន់ . . . ប្រឋមវិជយ ... ណ្ណមស្យាម ។ ...

បិតំ សទសិកជវរណា...រាជគណ...វគម្មតំ បិពន្ធុ ស្រី
មារ...រាជកុល...ផ...ន ស្រីមារ...លោ...ន
កុលនន្ទនេន|គាថា បិតំ សូជន...ស...មទ្ធៀ វាក្យំ ប្រ
វហិតករំ តរិណោការ្យ៍រណ|| លោកស្យាស្យ គតាគតិ រិ...ន
សិង្ហា សនាឡ្ញា សីនេន បត្រេ ត្រាតរិ នាន្ត្រេក សូសមីករ-
ណាធនេនូនត្ថ្រេម្ម យត កិញ្ចូព្រជតំ សុវណ៌្ណមបិ វា សស្ថាវ-
រេញ្ឆ្នមកោង្ឋាគារិក...ទំ ប្រីយហិតេ សវ៌្វំ វិសូ្ឋំ មយា តទេ
វំ មយានុជ្ញាតំ កុវៃស្យបេ រាជភិទេន្ទប្យ វិទិតមស្តុ.បមេក្តុ្ត.
ស្យ វិស្យ... ។

គ) សេចក្ដីប្រែសម្រួល.–

... សេចក្ដីករុណាចំពោះសត្វសត្វទាំងឡាយ ...ប្រ
ថមជ័យ ... ថ្ងៃពេញបុណ្ណមី (?) ព្រះរាជាទ្រង់បានប្រកាស
កន្ទិកដសកាថា "ចូរប្រជាជនក្រេបផឹកនូវទឹកអម្រឹត ពោលគឺ
ព្រះរាជបន្ទូល ព្រះបាទ ... ជាវង្សនៃព្រះបាទស្រីមារៈ ទ្រង់
បានជាកិត្តិយសនៃរាជវង្សស្រីមារៈ ទ្រង់បានប្រកាសកន្ទិ

តណ្ហាលជំនុំជន នូវព្រះរាជបន្ទូល ស្សរសីហនាទជាប្រយោជន៍ដល់ប្រជាជនទាំងឡាយ ទ្រង់ជាករុណាទាំងពីរដ៏ប្រសើរទ្រង់ប្រថាប់លើសិង្ហាសនៈ (ព្រះរាជបល្ល័ង្កស្វេតច័ត្រ?) ហើយទ្រង់ឈ្វេងយល់នូវគតាគតិ គឺការអន្ទោលស្លាប់កើតនៃមនុស្ស-លោក ទើបត្រាស់ថា "កាលបើកូនខ្ញុំក្តី បងប្អូនខ្ញុំក្តីមិនមែនអ្នកគន្ទៀតទេ បានសម្រេចបំណងខ្លួនហើយ (បានសោយរាជ្យតទៅ?) (ខ្ញុំសូមឲ្យយក) សម្បត្តិខ្ញុំទាំងអស់ ប្រាក់មាសសង្ហារិមក្តី អសង្ហារិមក្តី ទៅប្រើជាវត្ថុសម្រាប់ជាទីរកកាយនិងជាប្រយោជន៍ដល់សត្វលោកទាំងឡាយ ៗ នេះជាសេចក្តី[illegible]ញ្ញារបស់ខ្ញុំ ៗ សូមព្រះរាជាទាំងឡាយនៅក្នុងអនាគត ប្រតិបត្តិតាមព្រះរាជបញ្ញាខ្ញុំនេះ កុំបីខាន ៗ ហើយបូរប្រឹក្សាជាមួយសេវកាមាត្យឈ្មោះវីរ...របស់ខ្ញុំ ៗ

ឃ) សិលាចារឹកនេះបញ្ជាក់ថា សម័យកាលរបស់ព្រះ[illegible] ស្រីមារៈកាន់ព្រះពុទ្ធសាសនា ៗ ព្រះរាជប្រកាសនេះបង្ហាញនូវការយកព្រះទ័យទុកដាក់របស់ព្រះរាជា ចំពោះប្រ-

យោជន៍សត្វលោក (គឺប្រជារាស្ត្រ) តាមគន្លងប្រពៃណីក្នុងពុទ្ធសាសនា គឺការធ្វើបុណ្យ សុទ្ធទានដល់ជនទុគ៌ត ហើយធ្វើចិត្តឲ្យស្រាល ចាកនូវមច្ឆរិយៈជាដើម ។

## ទី ២– សិលាចារឹកនៅអ្នកតាដំបងដែក(១)

សិលាចារឹកនេះនៅខេត្តតាកែវ ចែងពីអគ្គមហេសីព្រះបាទកៅណ្ឌិន្យជយវរ្ម័ននាមព្រះនាង កុលប្រភាវតី ទ្រង់ប្រាថ្នាចេញចាកលោក ហើយបានកសាងទេវាល័យដកល់បដិមាករព្រះវិស្ណុធ្វើពីមាសសុទ្ធ ព្រមទាំងលំនៅសំរាប់ព្រាហ្មណ៍និងស្រះ ។

(ព្រះនាងកុលប្រភាវតី ជាពជជនទីពជកុមារគុណវរ្ម័ន ។ ព្រះបាទកៅណ្ឌិន្យជយវរ្ម័នទ្រង់សោយទិវង្គតក្នុងព.ស.១០៥៧ “គ.ស.៥១៤”) ។

(១) យើងសុំមិនយកអត្ថបទដើមមកកត់ត្រាប្រែទេ ព្រោះកុំឲ្យមេរៀនវែងពេក ខុសគោលបំណងកម្មវិធី ។ សូមអានពុទ្ធសាសនា ២៥០០ ទំព័រ ៥២ ។



សិលាចារឹក ព្រាសាទព្រាំល្វែង (សតវត្សទី ១ ដល់ ទី ៦)

## ទី ៣– សិលាចារឹកប្រាសាទប្រាំល្វែង(១)

សលាចារឹកនេះនិយាយថា ព្រះរាជកុមារគុណវរ្ម័នរាជបុត្រនៃព្រះរាជា ''ព្រះច័ន្ទនៃរាជវង្សកៅណ្ឌិន្យ'' ទ្រង់ត្រាស់បញ្ជាឲ្យចារឹកទុកថា ទីនេះព្រះវរបិតាព្រះអង្គយកបានមកពី ''ទឹកកក់'' ហើយតែងតាំងទ្រង់ឲ្យត្រួតត្រា ។

## ទី ៤– សិលាចារឹកនៅទន្លេបាទី (២)

សិលាចារឹកនេះនៅប្រាសាទតាព្រហ្ម ទន្លេបាទី សរសេរក្នុងពុទ្ធសករាជ្យទី ១១ (គ្រិស្តសករាជ្យទី ៦) និយាយថា ព្រះបាទរុទ្រវរ្ម័ន ជាព្រះរាជបុត្រព្រះបាទកៅណ្ឌិន្យជ័យវរ្ម័នទ្រង់កាន់ពុទ្ធសាសនា ហើយគោរពព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ។

ក្នុងរជ្ជកាលនៃព្រះបាទរុទ្រវរ្ម័ន យើងមានព្រះបរមសា-

(១) មើល ''ពុទ្ធសាសនា ២៥០០,, ទំព័រ ៥១ និង G· Coedès, BEFEO XXX, pl ។

(២) មើល ''ពុទ្ធសាសនា ២៥០០,, ទំព័រ ៥៣ G· Coedès, BEFEO, XXXI, p8

រិកធាតុ គឺព្រះកេសមួយសរសៃសម្រាប់ជាទីសក្ការៈបូជា តែព្រះចៅចិន កដវៃងត្រៀ (T si) ខាងត្បូង មកយកបាត់ទៅ ។

## ៥– យោបល់រួម.–

តាមសេចក្ដីសង្កេតខាងលើនេះ យើងអាចសន្និដ្ឋានបានថា អក្សរសាស្ត្រខ្មែរបានបដិសន្ធិនិងមានរូបរាងជាឯកសារកត់ត្រានូវហេតុការណ៍ វប្បធម៌និងអរិយធម៌ខ្មែរ ប្រកបដោយលក្ខណៈ ភស្តុតាងពិតប្រាកដមកតាំងពីសតវត្សទី ២ នៃគ្រិស្តសករាជម្ល៉េះ ។ តទៅ យើងនឹងលើកយកអក្សរសាស្ត្រសម័យកាលទី ២ មកពិនិត្យសិក្សាទៀត ។

# អត្ថបទវិជ្ជានៃអក្សរសាស្ត្រសម័យ

## ភាគទី ២

### ឃ្លាភ្ជាប់សេចក្តី.–

រួចមកហើយ ក្នុងមេរៀនទី ១ យើងបានឃើញនូវលក្ខណៈសិលាចារឹកបួនកន្លែង គឺ :

សិលាចារឹក នៅ វ៉ូកាញ់

–ដ– នៅ អ្នកតាដំបងដែក

–ដ៏– នៅ ប្រាសាទប្រាំល្វែង

និង –ដ– នៅ ប្រាសាទតាព្រហ្ម ។

តទៅនេះ យើងនឹងពិនិត្យមើលអំពីអត្ថបទវិជ្ជា (វិជ្ជាសិក្សាអំពីអត្ថបទ) នៃសិលាចារឹកទាំងនោះ ដែលឋិតនៅលើគោលសិក្សា ៣ យ៉ាងដូចតទៅ :

### ១– អំពីអត្ថន័យនៃអត្ថបទសិលាចារឹក.–

បើយកអត្ថបទសិលាចារឹកនៅ វ៉ូកាញ់ មួយមកពិនិត្យជា

គោល, យើងឃើញថា គោលបំណងរបស់អ្នកតែងនិងកត់ត្រា គឺលោកគ្រូដាងបង្ហាញនូវប្រវត្តិវិជ្ជា ស្តីអំពីព្រះមហាក្សត្រនៃ សម័យកាលដែលទ្រង់សព្វព្រះរាជហឫទ័យ ចំពោះជំនឿក្នុង ពុទ្ធសាសនា ដូចជា ព្រះរាជប្រកាសរបស់ព្រះបាទស្រីមារៈ ដែលថែងអំពីការអន្ទោលកើតស្លាប់នៃមនុស្សលោក ។

គឺតាមរយៈគំនិត ពាក្យសំដី ជាព្រះរាជបណ្តាំផ្សេងៗ របស់សិលាចារឹកនេះហើយ ដែលជាសក្ខីភាព ព្រមទាំងជាឯក សារបញ្ជាក់ថា ប្រទេសនគរភ្នំកាន់ពុទ្ធសាសនា ។ ដោយសារ សិលាចារឹកនេះទៀត ដែលយើងដឹងថាព្រះពុទ្ធសាសនាចូល មកប្រតិស្ឋានទៅក្នុងប្រទេសកម្ពុជាយើង តាំងពីពុទ្ធសតវត្ស ទី ៣ ម្ល៉េះ ។ ប៉ុន្តែព្រះពុទ្ធសាសនានេះមានឫសគល់រឹងប៉ឹង ខ្លាំង គឺក្នុងរជ្ជកាលព្រះបាទស្រីមារៈ គ្រិស្តសតវត្សទី ២ ។

សិលាចារឹកនៅអ្នកតាដំបងដែក បានបញ្ជាក់អំពីទឹកព្រះ ទ័យរបស់ព្រះមហាក្សត្រជឿជាក់ចំពោះគុណធម៌ នៃព្រហ្មញ្ញ សាសនា ។ សិលាចារឹកនេះបញ្ជាក់ថា ព្រះអគ្គមហេសី

ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន នាមព្រះនាងកុលប្រភាវតី ដែលពេញព្រះទ័យចេញចាកលោក ក៏ទ្រង់បានសាងទេវាល័យ ដកល់បដិមាករព្រះវិស្ណុ ធ្វើអំពីមាសសុទ្ធ ហើយព្រះនាងចាត់ឲ្យសាងលំនៅសម្រាប់ព្រាហ្មណ៍ ព្រមទាំងឲ្យជីកស្រះជាគុណប្រយោជន៍ចំពោះប្រជារាស្ត្រ ។

សិលាចារឹកនៅប្រាសាទប្រាំល្វែង បានបញ្ជាក់អំពីព្រះរាជបុត្ររបស់ព្រះបាទកៅណ្ឌិន្យជ័យវរ្ម័ន និងព្រះនាងកុលប្រភាវតី ព្រះនាមព្រះរាជកុមារគុណវរ្ម័ន ដែលត្រូវបានព្រះរាជបិតាតែងតាំងទ្រង់ឲ្យគ្រប់គ្រា ស្រុកទឹកខ្មៅ ក្នុងខេត្តព្រៃឫស្សី ហៅ "ទឹកភក់" ក្នុងកម្ពុជាក្រោម ។

ឯសិលាចារឹកនៅប្រាសាទតាព្រហ្ម ខេត្តបាទី ក្នុងខេត្តតាកែវវិញ ក៏បានបញ្ជាក់ថា ព្រះបាទរុទ្រវរ្ម័នជាព្រះរាជបុត្រព្រះបាទ កៅណ្ឌិន្យជ័យវរ្ម័ន (រាជបុត្រអង្គនេះ មានមាតាជាព្រះស្នំរបស់ព្រះបាទកៅណ្ឌិន្យ បានធ្វើគតព្រះមកុដរាជកុមារនាម គុណវរ្ម័ន ហើយឡើងសោយរាជ្យក្នុង គ.ស. ៥១៤ នៅ

ឆ្នាំដែលព្រះរាជបិតាទ្រង់សោយទិវង្គត ទ្រង់កាន់ពុទ្ធសាស-នាដែរ ។ ព្រះរាជាអង្គនេះ គោរពព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ។ សេចក្ដីសង្ខេបនៃការប្រែសិលាចារឹកនេះ គឺមានលំនាំដូចតទៅ : (១)

"ព្រះជិនស្រីទ្រង់ឈ្នះឲ្យសឹកសត្រូវ ពោលគឺកិលេសព្រមទាំងវាសនា ទ្រង់ប្រកបដោយសម្បត្តិគ្រប់ប្រការ មានពោធិញ្ញាណឥតទើសទាល់សល់ជំពាក់អ្វីឡើយ មានព្រះទ័យប្រកបដោយករុណាចំពោះសព្វសត្វ មានព្រះយសធំទូលំទូ-លាយ ឥតមានមោះមន្ទិលឡើយ ហើយផ្សាយទូទៅគ្រប់ទិសានុទិស ។ ព្រះអង្គស្រោចស្រង់សត្វលិចលង់ក្នុងភពវដ្ដសង្សារ គឺត្រៃភព ហើយបានដល់ត្រើយត្រាណឋានព្រះនិព្វានដ៏ឧត្ដមឥតអ្វីប្រៀបបានឡើយ ។ ព្រះស្រីធាតុ (គឺព្រះបរមសារីរិកធាតុ) ព្រះអង្គដែលតែងតែផ្ដល់ប្រយោជន៍ធំដល់

---

(១) ស្រង់ពីសេចក្ដីប្រែរបស់ព្រះតេជៈព្រះគុណ ប៉ាង-ខាត់ ក្នុងពុទ្ធសាសនា ២៥០០ ទំព័រ ៥៣ ៥៤ ។

សព្វសត្វទាំងឡាយ   ក៏នៅតែផ្តល់ប្រយោជន៍ដល់សព្វសត្វលុះរហូតមកដល់សព្វថ្ងៃនេះ... ។ អំពើជាព្រះរាជកុសលដែលទ្រង់ (ព្រះបាទវរ្ម័នទី៧) បានបំពេញចំពោះព្រះធម៌ហើយ មិនមែនដើម្បីតែព្រះរាជករណីយកិច្ចប៉ុណ្ណោះទេ  គឺទ្រង់បំពេញដើម្បីអនុគ្រោះដល់លោកទាំងមូលផង ។ ទ្រង់គោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ... ទ្រង់បានតាំងព្រះអង្គពេញជាឧបាសកដែលឥតមានអំពើបាបលាមក..." ។

សារុបសេចក្តីទៅ  គឺក្នុងរជ្ជកាលព្រះកៅណ្ឌិន្យជ័យវរ្ម័ន និងព្រះបាទវរ្ម័នទី៧  ព្រះពុទ្ធសាសនា  ចំរើនដុះដាលខ្លាំងណាស់ ។

គឺដោយសារសិលាចារឹកទាំងឡាយនេះហើយ  ដែលបញ្ជាក់អំពីសន្ធុះនៃពុទ្ធសាសនា និងការគសាងសរណៈវត្តសំរាប់ជាគ្រឿងសក្ការៈបូជា  ។ អ្នកសិក្សាខាងសល្ប បានរកឃើញនូវពុទ្ធរូបសម័យនគរភ្នំដែលធ្វើពីថ្ម សំរិទ្ធ និងឈើ ។ សំណាកនៃពុទ្ធរូបទាំងឡាយក្នុងសម័យនេះ មាននៅភ្នំដា ក្នុង

ស្រុកអង្គរបូរី ខេត្តតាកែវ ដែលមានក្បាច់ចនាតាមខ្មែរ ដោយយកបែបពុទ្ធរូបនៅឥណ្ឌាជាគោលខ្លះ គឺតាមបែបអមរាវតី គុប្តៈ គន្ធារៈ មថុរ ឬអជន្តា ជាដើម ៗ

## ២– អំពីអក្សររូបនៃអត្ថបទសិលាចារឹក :–

ពិតមែនតែក្នុងសម័យកាលទី ១ នេះ ព្រះពុទ្ធសាសនាកាន់ថេរវាទបំរើនរុងរឿងណាស់ក៏ដោយ ក៏អ្នកនិពន្ធកត់ត្រាសិលាចារឹកពេលនោះ នៅរក្សាពាក្យពេចន៍សំស្ក្រឹតជាច្រើនសំរាប់សរសេរ ៗ បុព្វហេតុនេះ គឺមកអំពីអរិយធម៌ និងវប្បធម៌ បែបព្រហ្មញ្ញសាសនា (ដូចជារឿងព្រះឥសូរ និងព្រះវិស្ណុ) នៅមានបំពាយឥទ្ធិពលខ្លាំងក្លានៅឡើយ ៗ ឧទាហរណ៍:–

សិលាចារឹកនៅវ៉ូកាញ សរសេរថា

"ប្រជាន់ ... ប្រថមវិន័យ ... ណ្ដំមស្យាម ៗ រាគម្ពត៌ បិពន្ធស្រីមារ..."

ក្នុងវិធីតែងអត្ថបទ គេមាន :

១– សេចក្ដីផ្ដើម : ដែលបញ្ជាក់នូវពេលវេលា គឺ

កាលបរិច្ឆេទនៃការតែង និងឈ្មោះអ្នកបញ្ជាឲ្យតែង ។

២- តួសេចក្តី : ដែលរៀបរាប់អំពីគោលបំណង (គឺអត្ថន័យនៃអត្ថបទ) របស់អ្នកបញ្ជា ។ ក្នុងតួសេចក្តីនេះមានបញ្ជាក់អំពីទឹកព្រះទ័យព្រះមហាក្សត្រដែលទ្រង់ជាប់ជំពាក់ព្រះហឫទ័យទៅលើពុទ្ធសាសនា ទៅលើការកសាងសមិទ្ធិនានា ដើម្បីជាប្រយោជន៍ដល់ត្រៃសរណគមន៍ ហើយនិងព្រហ្ម វិហារធម៌ចំពោះសព្វសត្វ ពោលគឺអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ ។

៣- សេចក្តីបញ្ចប់ : ដែលជាយោបល់នៃអត្ថបទ មានបែបបទជាជំបូន្មាន ណែនាំប្រជានុរាស្ត្រឲ្យតាំងនៅក្នុងសច្ចៈសុចរិត យុត្តិធម៌ ឲ្យប្រកាន់ខ្ជាប់នូវធម៌សន្តោស មានមេត្តា ករុណាជាគាទ៍ ។

សិលាចារឹកខ្លះ (ឧទាហរណ៍ សិលាចារឹកប្រាសាទតាព្រហ្ម : បានបញ្ជាក់ដោយបញ្ជា គឺ "ព្រះមហាក្សត្រ") សូមអធិដ្ឋានអានិសង្សកើតមកពីបុណ្យ និងការកសាងនានា ដើម្បី

សំរេចប្រយោជន៍ទៅបរលោកនាយ ដូចជាសុំតាំងខ្លួនជាឧបាសក សុំឲ្យប្រោសបាកបាបកម្មនានា ហើយបានសំរេចមគ្គផលផល់ត្រើយព្រះនិព្វានជាដើម ។

សាររូបសេចក្ដីទៅ ឃ្លាប្រយោគនៃអត្ថបទសិលាចារឹកច្រើនកាត់ៗមិនអស់សេចក្ដីទេ (អក្សរខ្លះរលប់បាត់ ដោយមកពីការបាក់ផុកនៃសិលា) ហើយរបៀបយល់នូវគំនិតត្រូវតែពិនិត្យមើលឯកសារខាងប្រវត្តិវិជ្ជានានា ដើម្បីប្រៀបធៀបនូវឆ្នាំតាមព្រះមហាក្សត្រ និងសម័យកាលពិតប្រាកដផង ។

## ៣– អំពីអត្ថរសនៃអត្ថបទសិលាចារឹក

តម្លៃជាមូលដ្ឋាននៃអត្ថបទសិលាចារឹក គឺបិតនៅលើ **សង្គមរស** = Le social ពីព្រោះទាំងអ្នកកត់ត្រាក្ដី គឺ គោលទៅលើហេតុការណ៍ច្បាស់លាស់ នៃការរស់នៅ (កប់ តាំងពីទឹកចិត្ត ជំនឿនៃការកសាងនានា សមិទ្ធិដែលកើតមាន) ព្រឹត្តិនានា ដែលមនុស្សជាតិក្នុងសម័យកាលនោះបានជួបប្រទះ ។

គឺដោយសារសង្គមរសនេះទៀត ដែលអ្នកសិក្សាប្រវត្តិវិជ្ជាអាចយកសិលាចារឹកមកធ្វើជាសេចក្ដីប្រមាណសិក្សា ក្នុងការស្រាវជ្រាវ ពិនិត្យ វិនិច្ឆ័យអំពីជីវភាព ការរស់នៅរបស់ខ្មែរក្នុងសម័យកាលនោះនោះ ដែលកន្លងទៅហើយ ។

## ៤- យោបល់រួម

ដូច្នេះ យើងឃើញថា សិលាចារឹកជាអត្ថបទអក្សរសាស្ត្រដ៏ចំណាស់មួយ ហើយមានប្រយោជន៍សំខាន់ដែលធ្វើឲ្យអនុជន (អ្នកប្រវត្តិវិជ្ជា អ្នកសិក្សាស្រាវជ្រាវ) បានយល់ បានដឹងនូវកម្រិតសមត្ថភាពនៃវប្បធម៌ អរិយធម៌ខ្មែរ ដែលប្រជាជនខ្មែរ (ខេមរជន) បានរក្សា ទ្រទ្រង់ ពង្រីក ឲ្យលូតលាស់តាំងពីបុរាណកាលមកម៉្លេះ ។

## ទី២. សម័យកាលទី ២

# សម័យមុនអង្គរ គ.ស. ៥៥០-៨០២

## ១- ក្សត្រសំខាន់ៗខ្លះក្នុងសម័យកាលទី ២ (១)

*សម័យកាលទី ២ នេះ អាចហៅបាន ២ យ៉ាងទៀតគឺ:*

*— សម័យមុនអង្គរ :*

*— ឬ សម័យចេនឡា :*

*ក៏បាន*

*ឯព្រះមហាក្សត្រដ៏ល្បីខ្លះក្នុងសម័យកាលទី២នេះគឺមាន:*

*— ព្រះបាទភវវរ្ម័នទី ១ (គ.ស. ៥៥០-៦០០)*

*— ព្រះបាទមហេន្ទ្រវរ្ម័ន ចិត្រសេនា (គ.ស. ៦០០-៦១៥)*

---

(១) ឯកសារខ្លះសំរាប់សិក្សាសម័យកាលនេះ គឺ :

— P. Pelliot : Le Founan ; — L. Finot, BEFEO, XXVIII, P. 44;

— G. Coedès, les Etats hindouïsé, S. P. 130; — G. Coedès, Inscriptions du Csmbodge, Vol. V. P. 23;

— A. Barth, Inscription du Cambodge, P. 60; — G. Coedès, Histoire ancienne des Etats hindouïsés d'Extrême-Orient, P. 90 .

— ឥសានវរ្ម័នទី ១ (គ.ស. ៦១៥-៦៣៥)

— ភវវរ្ម័នទី ២ (គ.ស. ៦៣៩-៦៥៥)

— ជ័យវរ្ម័នទី ១ (គ.ស. ៦៥៥-៦៨១) ។

## ២– សាសនាក្នុងសម័យកាលទី ២

ក្នុងសម័យកាលនេះ ពុទ្ធសាសនាថេរវាទចំរើនរុងរឿងនៅឡើយទេ ។ នៅខាងដើមពុទ្ធសតវត្សទី ១២ (គ្រិស្តសតវត្សទី ៧) ពុទ្ធសាសនាលទ្ធិមហាយានបានចូលមកក្នុងប្រទេសកម្ពុជាយើងជាមុនដំបូង ។

## ៣– អក្សរសាស្ត្រក្នុងសម័យកាលទី ២

ក្នុងសម័យកាលនេះ អត្ថបទនៃអក្សរសាស្ត្រ ចារឹកនៅក្នុងផែនសិលាដដែល គឺសិលាចារឹកនេះឯង ។

សិលាចារឹកសំខាន់ៗ មាន ៤ កន្លែង គឺ :

ទី ១.– សិលាចារឹកនៅសម្បូណ៌ព្រៃគុក (ក្នុងដែនឥសានបុរៈ) ខេត្តកំពង់ធំ សរសេរក្នុង ព.ស.១១៦៩ (គ.ស.

៦២៦) ក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័នទី ១

ទី ២.- សិលាចារឹកនៅភូមិ ខាវ៉ាំង ជិតអរញ្ញប្រទេស ពីដើម (ប្រទេសសៀមឥឡូវនេះ) ក្នុងរជ្ជកា[...] បាទភវវរ្ម័នទី ២ ព.ស. ១១៨២ (គ.ស. ៦៣៩)

ទី ៣.- សិលាចារឹកក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ១ [...] ៦៥៥-៦៨១) ដែលមានពីរ គឺ :

ក- សិលាចារឹកនៅវត្តព្រៃវៀរ ស្រុកកំពង់[...] ខេត្តព្រៃវែង (ពីដើមហៅថា ខេត្តបាភ្នំ) ក្នុ[...] ១២០៦ (គ.ស. ៦៦៤) (៣) ។

ខ- សិលាចារឹកនៅវត្តប្រាសាទ ក្នុងស្រុកកំពង់[...]

---

(១) មើល — L. Finot, BEFEO, XXVIII, p. 44..;

(២) មើល —G. Coedès, Inscription du Cam[...] Vol. V, p. 23

(៣) មើល —A. Barth, Inscription du Camb[...] p. 60.. ;

(សូមមើលពុទ្ធសាសនា ២៥០០ អត្ថបទព្រះតេជៈព្រះគុណ ជា[...] ទំព័រ ៥៣ ដល់ ៦២)

ខេត្តព្រៃវែង ។ លោក Aymonier បញ្ជាក់ថា សិលាចារឹកនេះ សរសេរក្នុងគ្រិស្តសតវត្សទី៦ ឬទី៧ ហើយសរសេរជាភាសាខ្មែរ ។

ទី ៤.— សិលាចារឹកនៅប្រាសាទ (តាកៀម ឬតាតាំ) ក្នុងខេត្តសៀមរាប ព.ស. ១៣៣៤ (គ.ស. ៧៩១) (១) ។

## ៤— លក្ខណៈសិលាចារឹកក្នុងសម័យកាលទី២

### ទី ១- សិលាចារឹកនៅសម្បូណ៌ព្រៃគុក

ក- អត្ថបទ (អត្ថបទនៅទំព័រ ៤០)

ទី ១—. អត្ថបទមួយនៅមេបញ្ឈរនៃទ្វារបន្ទប់ ទិសខាងត្បូង (ហៅ Piédroit sud)

១...វៃជយតិ ស ស្រីប្រហសិ គេ សូរ៉ស យស្រាន្ត

---

(១) សេចក្ដីបញ្ជាក់ថា សិលាចារឹកមាន៤កន្លែងសំខាន់នេះ មិនមែនបាន
សេចក្ដីថា មានសិលាចារឹកតែ ៤ ប៉ុណ្ណោះទេ ។ ក្នុងសម័យនោះ មានសិលា
ចារឹកច្រើនជាងនេះទៅទៀត ដែលខ្ញុំមិនអាចនាំយកមករៀបរាប់ទេ ។ ខ្ញុំនឹងធ្វើ
យឈ្មោះបញ្ជីសិលាចារឹកតាំងពីដើមមក កាលណាចប់មេរៀនទាំងអស់ ស្ដីពី
សិលាចារឹកនេះ ។



សិលាចារឹក សំប៉ូរ

(គ.ស. ៦២៦)

ភាសា មគនេវ ទ្រុតហេមាម្ពោ មហី ។

២–ស្រីមតំអវនីន្ទ្រាណាំ អន្វយាម្ពរភាស្វតស មណ្ឌ-
លេ មធ្យមស្យាបិ ប្រតាបោ យស្យ ទុស្សហស ។

៣– យ័ម កាន្ត វបុស័ម ទ្រិស្តា វិស្មិ តេ ភកវទ្ធ-
តិស័ អរហា នុ មិថ្យា វៃធវ្យ វញ្ចិតាស្មិ ចិរាទ ឥតិ ។

៤– ស្រីត រុណ្យាបរិស្វក៏ត កាមប្សូរោ យុវា បិយ័ស
កុក្តាសុ វ្ង៉ៃទូរវ្យិទ្យាសុ រក្ត បរិណតាស្វ អបិ ។

៥– ស្វយាំ... ន. មយិតា បិយ័ស កក្តវិក្យូល យុ...
ស្វរិកិស័ ។

៦– រវិត្ថុរ ១.១ន្វាន ឥវយ បរិបូរណាម្យ អន្ទុ
តិស័ បាតា:...រ...ឥ. បក្សានត្រូរ អបិ មហ័ត្ម ត់ ។

៧– បរស៌ វក្តកុរសុ យស្យ ណាំកោ នភស្វទស
ស្ថិត កេវលម កាបារៈ សុក្ឫតា ភក្តតិសុ ។ (១)

---

(១) អត្ថបទនេះនៅក្នុង (Inscription du Cambodge) របស់ G. oedès T. 4 page 7 មានផល់ទៅ១ពីវគ្គ ស្រង់សំរួលមកបង្ហាញជាតាង។

ទី ២-. អត្ថបទមួយនៅមេបញ្ជរនៃទ្វារបន្ទប់ទិសខាងជើង

(ហៅ Piédroit nord)

១៨... មា វ៉ុស្កាតិ...

១៩...ប្រភូ តិប្រតព្យាយាទេស គុណាវ្ធ័ន្យាគមាទិ-

តាស៍ សុទិតិ ស សត្ថុ វិទ្យា ប បទ... យស្យ... ។

២០...យ...យោ...យ ទ្យតា ស្វគ៌ញ ផតិសុណា

យេន និវ្ឫដិតស៍ សក្រវរណាស៍ (១) ........

ខ- សេចក្ដីប្រែ

ទី ១-· ជ័យជំនះ មានដល់ព្រះស្រីប្រហសិតេស្វរដែលមាន

ព្រះកាយក្ដី គឺព្រះធរណី ដែលប៉ិតនៅក្នុងសាគរ

ទឹកមាស ។

— អំពីព្រះកជា ដែលជាព្រះកាទិត្យនៃវេហាស៍នេះ

គឺព្រះវិន្យានៃមហាក្សត្រ ជាទីគោរពលើកពនែនដី

---

(១) T. 4 page 8 មានធនលំនៅ ១៣ វគ្គដែរ គឺពីវគ្គទី ១៨ ដល់៣៤ ។

ចេញមកអំពីចំហាយដែលពុំអាចអត់អោនបាន ពោះ
បើ ព្រះអង្គសណ្ឋិតនៅឰដ៏កណ្ដាលវង្គទាំងឡាយ
របស់ទ្រង់ក្ដី ។

– ដោយយល់ឃើញនូវព្រះកាយ យ៉ាងល្អ ស្រស់
ព្រះរតិភ្ញាក់ស្មារតី ហើយបន្ទូលថា "ពិតណាស់ខ្ញុំ
យល់ខុសសោះថា អំពីកាលមុន ខ្ញុំស្មានថាខ្លួន មេ
ម៉ាយសោះ" ។

– ពិតមែនតែទ្រង់នៅក្មេង ប្រកបដោយព្រះចំណង់
តែសោភណភាពនៃយុវវ័យ មិនអាចផ្ទឹមនឹងព្រះអង្គ
បានឡើយ ។ ព្រះអង្គសព្វព្រះទ័យតែនូវវិទ្យាសាស្ត្រ
ជ្រៅជ្រះ ហើយដែលមានតែបាស់ ១ ប៉ុណ្ណោះទើប
យល់បាន ។

.......................---------

– ពិតមែនតែទ្រង់ប្រកបដោយអលង្ការ ដូចជាចំហាំ

នៃសាគរ... ព្រះកដិ ទោះបីរបស់ព្រះរាជានៃបពិតក៏ បរិបូណ៌ដូច្នោះដែរ ។

— ព្រះរូបនោមព្រះអគ្គ ពុំមានស្ត្រីឯណាមួយ ឬមនុស្សផ្សេងៗ ប្រៀបប្រដូចបានឡើយ ។ ព្រះរូបនេះមានពិសេសតែចំពោះទ្រង់ គឺចំពោះព្រះអាកប្ប-កិរិយា ព្រះសកម្មភាពដ៏ល្អ ... និងព្រះចេស្តាព្រះអគ្គ ។ . . . . . . . . . . . . . . . . . .

ទី ២.—

— លំអរបស់ទ្រង់រកអ្វីផ្ទឹមគ្មានទេ

— បរិបូណ៌ទៅដោយចំណេះវិជ្ជា សំរាប់គ្រប់គ្រងរដ្ឋ ពេញពោរទៅដោយការពិសោធន៍ ការប្រុងប្រយ័ត្ន មានគុណធម៌ បុណ្យភាព ចំណេះវិជ្ជាបូរមបូរាណ និងវៃឆ្លាតខាងនយោបាយនិងវេយ្យាករណ៍ ។

—... ព្រះរាជាអគ្គនេះ សមរម្យនឹងទទួលនូវឋានសួគ៌

ទ្រង់បានឈ្មោះដំរីឰរាវ័ណរបស់ព្រះឥន្ទ្រ ។ (១)

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

## គ- អត្ថបទដទៃទៀត

ក្រៅពីសិលាចារឹកនៅនាមេទ្វារបញ្ជរទាំងពីរ ទិសខាងត្បូងនិងខាងជើងនេះ នៅមានសិលាចារឹក ៤ ទៀតនៅនាកម្រាលមណ្ឌប= dalle du mandapa នៃប្រាសាទហៅត្រែខាងត្បូងនៃទ្វារចូលខាងលិច បិតនៅក្នុងកំផែងក្រៅផ្នែកខាងត្បូង ដែលសរសេរជាភាសាសំស្ក្រឹតដែរ នៅមេបញ្ជរខាងត្បូងនៃប្រាសាទមុខ (la tour F) ដែលសរសេរអំពីព្រះបារមីព្រះបាទឥសានវរ្ម័ន ចាប់ពីវគ្គទី ២ ដល់ទី ៦; សិលាចារឹកផ្សេងៗ នៅ S. ; នៅមេបញ្ជរខាងត្បូងនៃទ្វារខាងកើត ក្នុងកំផែងក្រៅផ្នែកក្នុងពួកខាងជើង ដែលសរសេរបារមីព្រះឥស្វរ ព្រះនីលកណ្ឋ, ព្រះវិណ្ណុបង្កផនាក និងព្រះព្រហ្ម ហើយនិងសរសេរអំពីព្រះបាទរាជេន្ទ្រវរ្ម័ន ចាប់ពីវគ្គទី ៥ ដល់ទី ១៣; នៅមេ

(១) សេចក្តីប្រែនេះមានវែងទាំង ៣៤ វគ្គនៃមេទ្វារខាងត្បូងនិងខាងជើង ។

បញ្ជរនៃប្រាសាទខាងជើង គេសរសេរដោយអក្សរក្នុងសតវត្សទី ៧ ជាភាសាសំស្ក្រឹតនិយាយពីព្រះបារមីរបស់ព្រះបាទឥសានវរ្ម័នទី ១ ប្រកបដោយព្រះបរមនាមថា សាការមញ្ជរី; នៅមេបញ្ជរនៃបង្អួចខាងត្បូងនៃប្រាសាទខាងជើង សរសេរជាភាសាខ្មែរសរសើរអំពីតេជៈរបស់ព្រះបាទភវវរ្ម័នទី ១, ព្រះបាទមហេន្ទ្រវរ្ម័ន និងព្រះបាទឥសានវរ្ម័នដែលទ្រង់បូជាទាសៈចំពោះព្រះអាទិទេពត្រៃស្វរៈ ដោយព្រះអាចារ្យមានគោរមងារជាព្រះកម្រតាញ; នៅមេបញ្ជរនៃប្រាសាទខាងជើងដែលនិយាយអំពីរជ្ជកាលព្រះបាទភវវរ្ម័នទី ២; នៅមេបញ្ជរនៃផ្នែកខាងត្បូងប្រាសាទខាងជើងជាដើម ។

## ឃ – អត្ថន័យទូទៅ

បើពិនិត្យមើលន័យសេចក្តីនៃសិលាចារឹកទាំងឡាយ នៅសម្បូណ៌ព្រៃគុកនេះ យើងអាចយល់បានថា ក្នុងសម័យសត-វត្សទី ៧ នៃគ្រិស្តសករាជ ជំនឿរបស់ខ្មែរជន គឺមានចំពោះព្រះសិវៈ (ឥសូរ ព្រះវិស្ណុ ព្រះព្រហ្មជាដើម) ។ ឯព្រះពុទ្ធ

សាសនាក្នុងសម័យនោះ ក៏មានឥទ្ធិពលខ្លាំងណាស់ដែរ ។ គេគោរពនាគរាជមុចលិន្ទដែលគ្របដណ្ដប់ជាមួយចំពោះព្រះពុទ្ធ ។ គេនិយាយពីព្រាហ្មណ៍រាជបុរោហិត ឈ្មោះបសុបតិ = Pasu-pati មានងារជាវិទ្យាវិសេស: ជាអ្នកប្រាជ្ញចេះដឹងវិជ្ជាជ្រៅជ្រះ ចេះអត្ថ័ន គឺវិជ្ជាសាស្ត្រខាងក្បួនវេយ្យាករណ៍ ចេះវិជ្ជាខាងវៃសេសិកៈ ន្យាយៈ សមីក្ស ប្រុសំខ្យា ក្នុងព្រហ្មញ្ញទ្រឹស្ដី ព្រមទាំងវិជ្ជាក្នុងពុទ្ធសាសនាថែមទៀត ។

ដោយឡែកពីការបញ្ជាក់នូវជំនឿ សិលាចារឹកបានរំលឹកអំពីរូបសម្ផស្ស សោភណភាពខាងរាងកាយរបស់ព្រះរាជា ព្រមទាំងតេជៈបារមី និងព្រះជំនឿរបស់ព្រះបាទភវវរ្ម័ន ឥសាវរ្ម័ន មហេន្ទ្រវរ្ម័ន ដែលបានឲ្យកសាងរាជនិវេស្ថាន សក្ការបាន មានរូបសំណាក ទេវៈ ពុទ្ធរូបសំរាប់គោរពបូជា ជាដើម ។

ក្នុងសម័យកាលនោះ មនុស្សមានចំណេះចេះដឹងខាងវិជ្ជាផ្លូវលោក និងផ្លូវធម៌ច្បាស់លាស់ណាស់ ។ ការរស់នៅប្រកបដោយរបៀបរបប មានសម្ភារៈប្រើប្រាស់បរិបូណ៌ ដោយ

សារមានឃើញការរៀបចំអំពីផ្កាយផ្សេងៗ របស់ព្រះមហាក្សត្រ ចំពោះទេវរូប ឬពុទ្ធរូប មានទាំងសត្វពាហនៈផង ដូចជាគោ ក្របីជាដើម ។

## ខ – របាយលំរួម

ដូចសេចក្ដីរៀបរាប់មកហើយខាងលើ សិលាចារឹកនៅសម្បូណ៌ព្រៃគុក (គ.ស. ៦២ ) មានចំនួនដល់ទៅ ១៧ គឺ –

– ផ្នែកកណ្ដាលហៅ groupe central ( C ) រកមិនទាន់ឃើញ,

– ផ្នែកខាងត្បូងហៅ groupe sud ( S ) សរសេរជាភាសាសំស្ក្រឹត ក្នុងសម័យសតវត្សទី ៧ នៃគ.ស. ដែលគេរកឃើញនៅ និងមេបញ្ជរនៃបង្អួច ២ កន្លែង នៅទា្វរទិសខាងកើតនៃកំផែងខាងក្រៅ (គឺសិលាចារឹករបស់ព្រះបាទឥសានវរ្ម័នទី ១) ហើយនិងនៅមេបញ្ជរទិសខាងត្បូងនៃទា្វរកំផែងក្រៅផ្នែកខាងលិច ។

– ផ្នែកខាងជើងហៅ groupe N. ដែលសរសេរជា

ប់ស្រុកផង ខ្មែរផង (ដូចជាសិលាចារឹករបស់ព្រះបាទឥសាន
វ៉ែនទី ១ នៅលើមេបញ្ជរនៃទ្វារប្រាសាទខាងជើង) ។

ផ្នែកផ្សេងៗ នៃសិលាចារឹកសម្បូណ៌ព្រៃគុក បញ្ជាក់ជា
ជូន កាលក្នុង គ.ស. ១៨៩៤ ដោយលោក **Adhémar**
**eclère** ។ នៅគ.ស. ១៩០០ លោក **L. de Lajonquière,**
ានរកឃើញខ្លះ ហើយលោក G. Morand រកឃើញគ្រប់
ពញលេញនៅគ.ស. ១៩០៤ ។ លោក H. Parmantier
ានយកសិលាចារឹកទាំងនេះមកសិក្សាតាមផ្នែកម៉ត់ចត់ នៅឆ្នាំ
៩១១ និង ១៩២៨ ។ ជាបញ្ចប់គឺលោក V. Goloubew
ផលស្រាវជ្រាវបន្ថែមដល់ ១៧ សិលាចារឹកនៅឆ្នាំ ១៩២៧ ។

## ទី២- សិលាចារឹកនៅភូមិខាវរាំង (១)

### ក) សេចក្ដីសង្កេត.–

សិលាចារឹកនេះនៅក្នុងក្រុមសិលាចារឹកនៅលើភ្នំនៃដំបន់អរញ្ញ ។ ភ្នំនេះមានបីគឺឈ្មោះ ខាវរ៉ាំង Khau Ràng, ខាវណូយ Khàu Nôi, និងខាវចម្ពូ Khàu C'-omp'u ឋិតនៅក្នុងដែនសៀម ត្រង់តម្បន់ព្រំប្រទល់អរញ្ញ ។ គេដឹងអំពីសិលាចារឹកនេះ ដោយសារឃើញសំណាកដែលផ្ដិតទុកនៅនាបណ្ណាល័យជាតិនៅក្រុងបាងកក ។

### ១) លក្ខណៈ.–

សិលាចារឹកនៅខាវជម្ពូ ប្រើការពុំបានទេ ។ គេគ្រាន់តែដឹងថា អក្សរខសិលាចារឹកនេះសរសេរជាសំស្ក្រឹត មាន ចំនួន ២៨ បន្ទាត់ ។

សិលាចារឹកនៅខាវណូយមាន ៩ បន្ទាត់ សរសេរជាសំ-

---

(១) ស្រង់ពី Inscription du Camdobge, G. Coedès, vol. V ពីទំព័រ ២៣ ដល់ ២៤ ។

ស្រុក ហើយ ២៦ បន្ទាត់សរសេរជាខ្មែរ ។ អ្នកនិពន្ធសិលាចារឹក នោះនាម ប្រតញ្ញាញាណជេស្ឋបុរៈ ដែលបានធ្វើពិធីបូជាចំពោះព្រះសមរេស្វរៈ ក្នុងគ.ស. ៦៣៧ ។

ឯសិលាចារឹក នៅខាងកំផែងវិញ គឺសរសេរលើថ្មតូចមានទំហំប្រមាណជាបីតឹក ។ សិលាចារឹកនេះ សរសេរជាសំស្ក្រឹតចំនួន ១ ស្លោកមាន ២ បន្ទាត់ បញ្ជាក់អំពីឆ្នាំកត់ត្រា គឺមហាសករាជ ៥៦១ ឬ គ.ស. ៦៣៩ ។ ឯ ២៩ បន្ទាត់សរសេរជាខ្មែរ គឺគេរៀបរាប់អំពីអំណោយផ្សេង ៗ របស់ឈ្មោះ សិនាហ្វ វេរទៅឲ្យព្រះវិហារ ។ គឺជាសិលាចារឹកនិយាយពីកំណើតពុទ្ធសាសនា ។

គ) អត្ថបទ.—

១– ឥសត្រយោទសទាន ក្រិស្ណ ចន្ទ្រសេន្ទ្រៃយស់,

២– កុរុក្ក សកបតេរ អត្ត ហស្តនុរ ឬសកោទយស ។

៣– ខ្ញុំអំណោយ សិនាហ្វ ប្រគត អាយ (៤) ត វិហារ

ទូហ គេ ក សារ កន្ត (៥) កុ យោង គោន កុ លាង សិ ក បារ

(៦) កន្តៃ ព កុ សោល កោន កុ លាង តៃ (៧) វ រណោហ កុ
ចិហ ព ផោង កន្តៃ (៨) ព កុ មាស កុ ចូ កោន កុ ទេវ តៃ
លា (៩) ង តៃ ផៅ តៃ កុ ស្រ លាញ កោន កុ លាង តៃ ពៀ
តៃ ចំ ទ ក ព ថ រ ព (១១) ទិន ព ធម៌ មលាក ទំ រង អាយ
(១២) គ្នោន ស្វា ត គុ ១០០-៥ គោង ត្នំ ២០ ប៉ុ (១៣) គុ
ព មេន កន្តៃ ព កុ លហ កោន កុ លា (១៤) ង សី ផៅ សី
ទំរង អាយ ញៀង វិហារ (១៥) រ ស្វា ត គុ រទ្ន ១០០-២០ ៣
គោង រទ្ន ១០០-២០-ប៉ុ (១៦) គុ ព ក្លោក ស្វ វិរិណ្ឌ សពល្វ
(១៧) ទូ ខ្ញុំ ផោង ស្រោង ប៉ុ ទំរង្វ ២០-១០-២ (១៨) គួង វិ-
ហារ គូស សំរែត ៤ ប៉ាស ២ (១៩) ស្រគេហ ២០ បល្វន្ត
កន្តោង កំពោ (២០) ណា បន្ទេក ឧលទូ ជ្ជូ យោ ៧ កំពរ (២១)
យោ ៧ គាបជ ជ្វីយោ ២០-៧ ក្សួច (២២) យោ ១០-២ កំ ព.
រ យោ ១០ ប្នង ត្រិធា (២៣) វ្ត ប... អាយ បរ កុ ស (២៤)
ស្រេ១ កន្ទុហ តិ... ប្របិត្នែ (២៥) ៥ ពោញ វុ... (២៦) ខ្ញុំ
អំណោយ សិនាហ្វ អញ ឯ ត វិហារ (២៧) រ... កន្តៃ ព កុ

...ន គោន (២៨)... លាង សីពៅ តៃ ថា (២៩)... ចំរើង

...ស្វា ត្នំ (៣០)... ត្នំ គុំ ១០ គុំសំ (៣១)...

## ឃ) សេចក្ដីប្រែ.–

(១-២-) នៅក្នុងឆ្នាំនៃព្រះពជ់ាសកៈកន្លងផុតទៅ ដែល
...ានបញ្ជាក់តាម (៥) អាយតនានាមាន (៦) សេនិងព្រះចន្ទ នា
...ថ្ងៃ ១៣ កេចនៃឥសៈ (អាស្វិន) ព្រះចន្ទ ឋិតនៅក្នុង ហស្តទ្រង់
...តាចឡើងលើ ឧសភមណ្ឌល ។ (៣-១១)- ពពួកតាសតាំង
...កយដែល សិនាហ្ ផ្ដល់ពីមុនទៅឲ្យវិហារ ។ (កយបញ្ជី
ឈ្មោះតាសៈតាំងនេះ) ។ (១១-១៤)- ការដាំដំណាំនៅក្នាន
...ដើមស្វា ១០៥, ដើមដូង ២០ ។ កប់ឈ្មោះឆ្នាំ (តាមបញ្ជី)។

(១៤-១៦)– ដំណាំនៅជិតវិហារគឺ ដើមស្វា ១២៣ ដើម
...ង ១២០ ។ កយឈ្មោះឆ្នាំ ក់ក្មេក ។

(១៦-១៧)– ម្រួសារបុព្វកតាសៈ តាស់និងក្មេង ព្រម
...ងឆ្នាំគេប្រដំណាំ មានចំនួន ៣២ ។

(១៨-២៣)– ឃ្លាំងទ្រព្យធននៅវិហារគឺ: ក្លស់ ផ្តើត

សំរិទ្ធ ៤, ថាស ២, ស្រគេហ ២០, គ្រែ ១... ។

(២៣-២៤)- នៅចុះ កុ ស្រែ ១ កល... គោ ៥ ទឹម ។ បោញ រុ ។

(២៦-៣១)- ទាសៈ ដែលខ្ញុំឈ្មោះ សិកហ្ វេរថ្វាយ ទៅព្រះវិហារ (កប់ចំនួនអំពេកាយ) ។ ដំណាំ... ដើមស្វាៈៈ. ឈើ ១០ ដើម... ទៅព្រះវិហារ រុណ ។

## ង) អត្ថន័យទូទៅ.—

សិលាចារឹកនេះ និយាយពីឧបាសកម្នាក់ងារជា សិនាហ្ បានសាងព្រះវិហារមួយឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ព្រមទាំងថ្វាយទ្រព្យសម្រាប់ព្រះវិហារមានទាសាក្មេងចាស់ ចំនួន ៣២ នាក់ កប់ទាំងឆ្នាំចំការដូងស្វាផង ។

គឺតាមរយៈ សិលាចារឹកនេះ ដែលយើងដឹងនូវអារិយ-ធម៌ខ្មែរ ព្រមទាំងនយោបាយកសិកម្ម ក្នុងសម័យសតវត្សទី ៧ នៃគ.ស. ។

# ទី៣-សិលាចារឹករជ្ជកាលព្រះបាទជ័យវរ្ម័នទី១

សិលាចារឹកនៅក្នុងខេត្តព្រៃវែងនេះមាន ២ គឺ៖

## ១- សិលាចារឹកនៅវត្តព្រៃវៀរ.–

(នៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង: ក្នុងព.ស. ១២០៦, គ.ស. ៦៦៤)(១)

### ក) លក្ខណៈ.–

ជាសិលាចារឹកសរសេរលើផ្ទាំងថ្មកក់បានកំពស់ ០ម៥២, ទទឹង ០ម៣៥, ក្នុង ម.ស. ៥៨៦ គ.ស. ៦៦៤ ។

តាំងអស់មាន ១៧ បន្ទាត់ គឺ ១០ បន្ទាត់ជាភាសាសំស្រ្កឹត, ឯ ៧ បន្ទាត់ទៀតជាភាសាខ្មែរ ។ អក្សរសរសេរស្អាតល្អណាស់ មានលំនាំគ្នានឹងអក្សរសម័យ គ.សតវត្សទី ១១ ។

### ខ) អត្ថបទ.–

១– ជិតំ វុទ្ធិសោរេណ ភាជា ស្រីជយវរ្មណ

(១) មើល Inscription sanskrite du Cambodge par A· Barth, 1er fascicule ទំព័រ ៦០ តទៅ ។

ពាចលាចិ សតី យត្រ ស្តិក លក្សឹ . . . ។

២– គូយិស្តទ្រិស្តិរយោ្យា ជតទ្រក្សណាទិក្សីណស

សាក្យាត សហស្រាក្ស ឥតិ ប្រាជ្យតីកិ . . . ។

៣– វក្សត័ស តស្យ ប្រិថីវី ប្រិថុរិក្រមនិវ្ឃត៌

ភវេជ្យ តិក្សវិរស្តៅ ស្ត័ស សោទរេ ស្តិរ . . . ;(២)

## គ) សេចក្តីប្រែ.–

១– ព្រះបាទស្រី ជយវរ្ម័ន ជំមានជោគ មានវិរិយភា

យ៉ាងមហិមា ទ្រង់ឋិតនៅជិតព្រះលក្ស្មី ទ្រង់គង់នៅក្នុ

កម្រើក ។

២– ទ្រង់មានព្រះនេត្រទតវែងឆ្ងាយ . . . មានព្រះបញ្

វាងវៃក្នុងកិច្ចការពារលោក ហើយទ្រង់ត្រូវបានអ្នកប្រាជ្ញសហ

ស្រាស្ក្រ លើកដំកើងឡើង ។

៣– ក្នុងពេលដែលទ្រង់គ្រប់គ្រងទឹកដីបានមកពីការរ

(២) មានតទៅទៀត តែខ្ញុំមិនយកមកកត់ត្រាទាំងអស់ទេ ដើម្បីកុំឲ្យ

វៀនវែងពេក ។

ទីដ៏វែងឆ្ងាយ, ក្នុងខណៈនោះមានព្រះភិក្ខុដ៏ជំនាញ ២ អង្គគង់នៅក្នុងព្រះរាជាណាចក្រព្រះអង្គ ។ ភិក្ខុនេះមានព្រះមាតាវរមខេរ, ម៉ុងម៉ាក់កុង ... ។

២— ទាំងពីរអង្គប្រកបដោយគុណធម៌ទ្រទ្រង់សីល មានចំណេះវិជ្ជា សភាពស្ងប់ស្ងៀម សេចក្ដីអំណត់អត់ធន់ មានខន្តីធ្ងន់ហើយ មានករុណា សមាធិប្រុងប្រយ័ត្នជានិច្ច ហើយព្រះអង្គមានព្រះគោត្រជាវត្ត ដែលនាមចុងក្រោយទាំងពីរ គឺមួយអង្គនាម ភានុ ហើយមួយអង្គទៀត នាម សិង្ហ ។

៤—បុត្រនៃកូនស្រីដែលជាបងនៃភិក្ខុទាំង ២ រូបនេះមានព្រះកិត្តិនាមខ្ពស់ គឺព្រះ វិសុទ្ធ សុកត្តិ ដែលមានព្រះសកម្មភាពយ៉ាងបរិសុទ្ធ ។

៦— តាមការគ្រប់គ្រងជាហូរហែ នៃព្រះញាតិវង្សាមក ហើយតាមព្រះបញ្ជារបស់ព្រះមហាក្សត្រ ព្រះរាជបុត្រនេះត្រូវបានទទួលពេញបន្ទុកនូវគ្រឿងទាំងអស់ ដែលព្រះអង្គមានបុព្វសិទ្ធិនឹងទទួលពេញសមត្ថភាព ។

៧– មានសត្វទ្វេបាទ, ចតុប្បាទ, សួនឧទ្យាន, ដំរី, ព្រៃព្រឹក្សា, ចំការក្ស៊ី ហើយនិងអស់ទាំងអ្វីដែលឋិតនៅក្នុងព្រះរាជអាណាចក្រ ត្រូវបានមកទ្រង់ ហើយគ្មាននរណាដទៃម្នាក់អាចមកទាមទារបានទេ ។ នេះគឺជាព្រះរាជបណ្ដាំ និងព្រះរាជបញ្ញារបស់ព្រះមហាក្សត្រ ។

៨– សេចក្ដីនេះសំរេចឋិតនៅក្នុងសម័យព្រះចៅនៃសក: ដែលទ្រង់បានទទួលហើយនូវសេ:, នូវសុទិនត្ត របស់អាយតន:, ជាថ្ងៃទី ២ កើតខែមាឃ ។ ព្រះរាជបញ្ញានេះប្រគល់ទៅព្រះសង្ឃដែលគង់នៅក្នុងឆានីរបស់ព្រះមហាក្សត្រ ។ គឺសេចក្ដីនេះកប់ឬ នៅជា ព្រះរាជគម្រិះរបស់ព្រះមហាក្សត្រ ព្រះអង្គឯងប្រកបដោយព្រះវិបៈណាត្រូវ... ។

## ឃ) អត្ថន័យទូទៅ.–

តាមន័យនៃសេចក្ដីរបស់សិលាចារឹកនេះ យើងដឹងថា ក្នុងគ្រិស្ដសតវត្សទី ៧ មានភិក្ខុ ២ អង្គជាបងប្អូនបង្កើត ជាជាតិក្សត្រដែលបានយាងបព្វជា ហើយទ្រង់គង់នៅក្នុងវត្តព្រៃវៀរ

នេះ សឹងមានសេចក្ដីសម្រួលបន្ថែមថាៈ(១)

"ក្នុងដែនដីដែលទ្រង់គ្រប់គ្រងនេះ មានភិក្ខុពីរអង្គជាបង
ប្អូនបង្កើត ទាំងពីរអង្គ មានសីលជាពហុស្សូត្រ សុភាព មាន
ខន្តី មានខ្លួនខ្ពង់ខ្ពស់ហើយ មានករុណា មានសមាធិចិត្តជា
ហើយទ្រព្យ មាននាមខាងដើមថា តេនៈដូចគ្នា ហើយខាងចុង
មួយជាភាណុ មួយទៀតជាសិង្ហៈ គឺភិក្ខុតេនភាណុ ១ ភិក្ខុតេន
បិង្ហៈ១" ។

តាមសិលាចារឹកនេះទៀត យើងឃើញថា សម័យនោះ
ពុទ្ធសាសនាចំរើន មានភិក្ខុសង្ឃកាន់ត្រៃវិន័យ មានសមគ្គ-
ភាពបរិបូណ៌ ។ ទាំងបុត្រព្រះមហាក្សត្រ ក៏ចូលបួសក្នុង
សាសនា ហើយព្រះរាជាមានព្រះសទ្ធាណាស់ក្នុងកិច្ចទំនុក
បម្រុងវត្តអារាមសមណៈព្រាហ្មណ៍ ។ ភោគផលខាងសម្បត្តិ
ទ្រព្យនគរ ក៏បរិបូណ៌ឥតខ្វះ មានតាំងពីគ្រឿងប្រើប្រាស់

(១) តាមសេចក្ដីប្រែសំរួលរបស់ព្រះតេជៈព្រះគុណ ប៉ាង ខាត់ ក្នុងសៀវភៅ
ពុទ្ធសាសនា ២៥០០ ទំព័រ ៥៩ ។

ផលដំណាំដាំដុះនិងសត្វពាហនៈផង ។

## ២– សិលាចារឹកនៅវត្តប្រាសាទ.–

*(នៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង)* (១)

### ក) លក្ខណៈ

ជាសិលាចារឹកសរសេរលើផ្ទាំងថ្មសំប៉ែតមានសណ្ឋានកង់ដូចជាទេវរូបនៃព្រះវិស្ណុគៀស មានត្រឹមតែកង់កាយមួយប៉ុណ្ណោះ ។ គ្មាននាមព្រះមហាក្សត្រទេក្នុងសេចក្ដីនៃសិលាចារឹកនេះ ។ តែបើតាមថ្ងៃខែដែលបញ្ជាក់ (គឺក្រោយសិលាចារឹកមុន ៦ថ្ងៃនោះ) ពិតជាសិលាចារឹកនេះឋិតក្នុងរជ្ជកាលព្រះបាទជយវរ្ម័ន ។ សករាជក្រាំងនោះ គឺឆ្នាំ ៥៨៩ នៃសកៈ ឬ គ.ស. ៦៦៧ ។

អក្សរមានលំនាំដូចគ្នា នឹងសម័យទី ៦ ឬ ទី ៧ នៃគ.ស. ។

ទំហំសិលាចារឹកនេះមានកំពស់ ០ម៉ុ០៨, ទទឹង ០ម៉ុ៧៤ ។

(១) មើល Inscriptions sanskrites du Cambobge, par M. A. Barth, Ier fascicule ទំព័រ ៧៣ តទៅ ។

## ១) អត្ថបទ—.

—នៅខាងស្តាំសិលាចារឹក មានពាក្យដាច់ៗគ្នា ដូចតទៅ៖

យា

ទំ

ន

យំ

—នៅខាងឆ្វេងវិញ មានពាក្យដូចតទៅ៖

យោកាគស្របទ ម

ប យ

យោ កាគេស្រគនបៈ

—អត្ថបទតាំងស្រុងមាន ដូច្នេះ៖

យាគេ កាល សកាន់ នវគន្ធិសវៃយ័រ ម្ហូបវេសាទ-
ហាមហាជរស សា មេជស្មូវេរា ក្រិតុសសិតនយោគាវុកខ្យ
លយគ្នូសោពេ មីនេទ្រូយាយី, ក្សិតិត នយយុគេ គរក្កុជមៃត្រំ
ន្ទុរ វិស្ញីសាវផតម្បុគី កតលិតយមិនា ស្តាបិតាវ អគ្រេយុក្តាៗ

## គ) សេចក្ដីប្រែ.–

សម័យកាលនៃសកៈកន្លងផុតទៅនោះយន្តប៉ុន្មានប្រាំបួន
កាយ និងវត្តនៃកាយគន., ក្នុងខែមាឃ (វិសាខ) នៃថ្ងៃ
ជីវៈ (គឺផ្កាយព្រហស្បតិ៍)[១] ឋិតនៅក្នុងធនុរាសី[២] ព្រះអាទិ
ឋិតនៅក្នុង មេសរាសី[៣] បុត្រនៃក្រិត្ត និងបុត្រនៃព្រះប
(គឺផ្កាយព្រះសុក្រ)[៤] និងផ្កាយព្រះពុធ[៥] ឋិតនៅក្នុងស
ដែលមានឈ្មោះហៅថា តាវុរ (ឬ វុសភរាសី)[៦] ដែល
លេចឡើង; បុត្រនៃព្រះអាទិត្យដែលឡើងទៅដល់មីនរា
កក្កដរាសី[៨] មានការទាក់ទងទៅនឹងបុត្រនៃព្រះធរណី (

---

(១) ផ្កាយព្រហស្បតិ = Jupiter, (Jīva)
(២) ធនុរាសី = Le Sagitaire
(៣) មេសរាសី = Le Bélier
(៤) ផ្កាយព្រះសុក្រ = Le Vénus
(៥) ផ្កាយព្រះពុធ = Le Mercure
(៦) វុសភរាសី ឬ ព្រឹសភរាសី = Le Taureau
(៧) មីនរាសី = Les Poissons
(៨) កក្កដរាសី = Le Cancer

ដាយអង្គារ = mars), ហើយព្រះចន្ទបានទៅដល់វិច្ឆិកាសី (ឬព្រឹស្ចិកាសី = maitra ou le scorpion) ។ គឺក្នុងខណៈនោះហើយដែលព្រះវិស្ណុ និង ឥសី បានរួបរួមជាអង្គមួយក្នុងការស្ថាបនាជារូបសំណាកឧទ្ទិសចំពោះព្រះសាសនាដោយការ-ប៉ិតយមិន ។

## ឃ) អត្ថន័យទូទៅ.–

សិលាចារឹកនេះ បង្ហាញនូវជំនឿរបស់ព្រះមហាក្សត្រចំពោះព្រហ្មញ្ញសាសនាម៉្យាង ហើយម៉្យាងទៀតនូវចំណេះដ្ឋខាងហោរាសាស្ត្រ គាំពារសាស្ត្រយ៉ាងជំនាញរបស់បណ្ឌ-ណ្ឌិតរបស់ព្រះរាជានាសម័យ កាលសតវត្សទី ៧ នោះ ។

## ៤– សិលាចារឹកនៅប្រាសាទតាមកៀម:–(១)

(នៅខេត្តសៀមរាប, ក្នុង ព.ស. ១៣៣៤ គ.ស. ៧៩១) ។

---

(១) មើល Inscriptions du Cambodge, Tome III, G. Coedès, (ទំព័រ ៨៩ ដល់ ៩៣) ឬហៅប្រាសាទ ។



សិលាចារឹកតាកៀមធំ (សតវត្សទី ៦ ទៅទី៧)

ក) លក្ខណៈ :–

សិលាចារឹកនេះមាន ២ គឺមួយសរសេរជាភាសាសំស្ក្រឹត មាន ២ បន្ទាត់ ឋិតនៅនាមេបញ្ជរនៃទ្វាររបស់ប្រាសាទ ហើយមួយទៀតសរសេរជាភាសាខ្មែរមាន ៣៩ បន្ទាត់ នៅនាមេបញ្ជរនៃទ្វារខាងត្បូងកន្ទុប្រាសាទអម ។

តាមសិលាចារឹកទី១ គេឃើញឆ្នាំនៃកាលបរិច្ឆេទថាសកៈ ៧១៣ គឺ គ.ស. ៧៩១ ។

១) អត្ថបទ –

សិលាចារឹកទី ១:--

១– សមគុណសស៌នគសាគេ

ប្របិតោ យស សុប្រតិស្ឋិតោ ភគវ៉ន៍

២– ជគទិស្វរ ឥតិ ខាម្នា

ស ជយតិ លោកេស្វរប្រតិបៈ ។

សិលាចារឹកទី ២:--

(១)... សក ទសម៌ កេត មាឃ អាទិត្យវ៉ារ ទុ

(២) មានព្រះ បាទ តបរមតបវិត្រ តិ ពេះហ ព្រះ សាស

(៣) ន ធូលិ ព្រះ បាទ កំម្រតេង កំតួន់អញ ស្រិសូរ្យ

(៤) វ្រ្មទេវ ម៉ឞ ទុយ ត គ៉ូន សិទ្ធិ យ៉ត វាំ លេយ ៗ

(៥) ៨៨៤ សក វ្យរ កេត ថ្ងៃសាខ នុ ម្រតាញ ស្រី

(៦) សក្ខិការ ហោ អញ ចុញ អំវិ លេ ទៅ លំវាង

(៧) ថ្ងៃ ណា ចៅ តជ្មោះ មេសោក ណា សវះ

(៨) ត អញ ហៅ្យត អញ លេង ជា អាធិបតិ គ្រហ

(៩) ទុយ សេះ ក្យប ឥ វ័ត ឥ ត អញ ល្មោះ ត តិ

(១០) ទសមី កេត ថ្ងៃសាខ នោះហ ទុយ ចៅ នោះ

(១១) ត អញ ... ចត្រ្តុ ប៉ួន បិ ម្រ តាញ ស្រីគុណ

(១២) បន្ទិត ត វិប្រ អញ បិ មេ នេះមេ សោក

(១៣) ទៅ សំវះ ផ្កាស័ ជ្មោះ មេ មណិ – លេង សំ នុ

(១៤) អញ ប្រេ អញ ទុក លេ ឞម្រេ លេង ឧក ខ្ញោញ

(១៥) ត នុ ម៉ាន ទៅ វេ្ទក និ អញ ថ្ងៃ គោយ វ្យ៉ត

(១៦) មន ល្មោះ ត តិ វាជ្យ ព្រះ បាទ ត សុប ទៅ

(១៧) បរមើរ លោក អញ ស្មេន ថ្មោ សរ៉ លិង្គ ផ

(១៨) សិត៌ វ្រះ វ្រហ្ម ផ សិត៌ វ្រះ កំម្រតេង អញ

(១៩) នាកយន គុរុ ទក់ហាន ផ សិត៌ វ្រះ កំប្រ

(២០) តេង អញ គៅរិបត៌ស្វរ ផ វ្រះសកក់ហ

(២១) ន អញ អញ្ជេញ កំម្រតេង អញ វ្រះ

(២២) គុរុ ស្តាបនា អញ ទុយ តំម្រ្យ សេះ ទក្សិណ

(២៣) នេរ វ្រះ នេះ ផោង តិ អញ ទុយ ត កូ៌ន អញ

(២៤) ត បិ នក វ្រះ វ្រហ្ម វ្រះ កំម្រតេង អញ

(២៥) គៅរិបត៌ស្វរ តិ អញ ទុបេ ក តាញ … ក៌ប ប

(២៦) វ្រែត ផៃកត ត កូ៌ន អញ វ្រះ កំម្រតេង អញ

(២៧) សិវលិង្គ តិ អញ ទុយ តេង វ្រះ កំម្រតេ

(២៨) ង អញ នាកយន តិ អញ ទុយ ក៌ប យ៌ត

(២៩) មន អញ ទុយ សំនូត៌ បិ អញ ទុយ វ្រះ នេះ

(៣០) នុ ឧបាយ ត កូ៌ន អញ ត បិ នក នៅ គេ

(៣១) កំ រថ្ងុ ប្រការ បិ ចលុយ បិ សក វ្រះ នេះ

(៣២) គ កូ៌ន អញ គ បំ ទក គេ បាត ក្រៃត្រី

(៣៣) សទគេ យ័ត កាល ញស គេ ទា ពជកយ

(៣៤) អំពិ ឥហលោក ត់រោះ បរលោក លេង នានា

(៣៥) ប្រការ ។

## គ) សេចក្ដីប្រែ.–

### សិលាចារឹកទី ១:–

"ជ័យជំនះ ចូរមានដល់ព្រះបរមរូបនៃព្រះលោកេស្វរ

ដ៏មាននាមថា ជគទីស្វរៈ ដែលកសាងឡើងក្នុង (ឆ្នាំ) នៃសាក

(បញ្ជាក់ដោយ) បព៌ត (ចាំង ៧), ព្រះច័ន្ទ (=១), និងគុណ

ពម៌ ៣" (គឺ សកៈ ៧១៣=គ.ស. ៧៩១) ។

### – សិលាចារឹកទី ២ : (ប្រែសម្រួល)

(១-៤)... នៅថ្ងៃអាទិត្យ ២ កើត ខែមាឃ, ព្រះបា

ស្រីសូរ្យវរ្ម័ទេវ ទ្រង់ព្រះរាជានុញ្ញាត ដល់អាណាប្រជានុកព្រ

នូវសិទ្ធិជាពិសេស ។

(៥-៩) នៅក្នុងសកៈ ៨៨៦ ជាថ្ងៃ ២ កើត ខែពិសា

ម្រតាញ ស្រីសរាជិការ ទ្រង់ប្រោសឲ្យតាកសិក្ខាបទ ។

ពេលមួយនោះ ចៅស្រីម្នាក់របស់ (ម្រតាញ) នាំមមេសោកបានមករកខ្ញុំ បន្ទំខ្ញុំឲ្យធ្វើជាស្វាមី ហើយបានផ្តល់ឲ្យខ្ញុំនូវសេះមួយ កែបសេះមួយ និងវត្ថុពុទ្ធបូជាផ្សេង ៗ ។

(១០-១៥) នៅថ្ងៃ ២ កើត ខែពិសាខដដែលនេះ (ម្រ-តាញ) បានប្រទានចៅស្រីព្រះអង្គដល់ខ្ញុំ,... ចំគ្រា ៤ (?) បាំងជូន ម្រតាញ ស្រី គុណបណ្ឌិត, បិតាខ្ញុំហើយនិងស្ត្រីនេះគឺមេសោកដើម្បីទៅធ្វើការកិច្ច ។ លោកផ្លាស់ឈ្មោះថាជាមេមនិ ... ហើយបានរៀបចំឲ្យខ្ញុំ ដោយបញ្ញាឲ្យជាអធិបតីលើពាសពាសី គឺត្រួតមើលពួកមេនំឲ្យប្រព្រឹត្តទៅបានល្អ ។

(១៦-២៨) នៅក្នុងរជ្ជកាលព្រះបាទបរមវីរលោក ខ្ញុំជ្រើសរើសបានសិលាមួយដុំដើម្បីសាង សិវលិង្គ, ខ្ញុំសាងបដិមាព្រះព្រហ្មមួយអង្គ, ខ្ញុំបានបញ្ចុះព្រះគម្តែងអញនារាយណគង់លើគ្រុឌមួយ, ខ្ញុំបានបញ្ចុះព្រះគម្តែងអញមួយ ។ គេរីកេស្វរៈគង់លើគោឧសភ ។ ខ្ញុំបានអញ្ជើញគម្តែងអញព្រះ

ត្រូវឲ្យទិមន្តមកក្នុងពិធីតាំងបដិមានេះ ហើយខ្ញុំបានបូជាលោក
នូវដំរី និងសេះជាកិត្តិយស ។ គឺព្រះទេវៈទាំងឡាយនេះដែល
ខ្ញុំឧទ្ទិសចំពោះកូនខ្ញុំទាំងបីនាក់ៈ ព្រះព្រហ្ម និងព្រះគម្តែងអញ។
គោរ៉បតីស្វរៈ ខ្ញុំបញ្ជូនឲ្យទៅតាញ ...ហើយនិងទៅកំបបរិត្រ
នៃដៃកគ (ជាឈ្មោះនគរមួយ) ដែលជាកូនរបស់ខ្ញុំ ។ ព្រះ
គម្តែងអញ សិវលិង្គខ្ញុំបញ្ជូនឲ្យទៅគេង... ។ ព្រះគម្តែងអញ
នារាយណៈខ្ញុំបញ្ជូនឲ្យទៅកំប អគ៌ក ។

(២៩-៣០) ខ្ញុំបួមឧទ្ទិសពាក្យសុំនេះ ដើម្បីផ្តល់នូវទេវ.
ទាំងឡាយនេះ ហើយនិងមធ្យោបាយរំដោះទុក្ខ ចំពោះកូនខ្ញុំ
ទាំង ៣ នាក់ ។

(៣១-៣៤) នរណាហ៊ានធ្វើឲ្យខាន ឬ បង្ខាញទេវៈ
ទាំងឡាយដែលខ្ញុំឧទ្ទិសចំពោះកូនខ្ញុំទាំង៣រូប នរនោះនឹងត្រូ
ធ្លាក់ទៅរងទុក្ខទោសនៅឋាននរក ៣៣ ជាន់ ដោយគ្មានឱ-
កាសនឹងមកចាប់កំណើតវិញឡើយ ។ នរៈទាំងនោះនឹងត្រូ
ទទួលទណ្ឌកម្មគ្រប់បែបយ៉ាងអំពីព្រះកជាតាំងពីកពនេះ រហូ

ល់បរណេក ។

## ឃ) អត្ថន័យទូទៅ

សិលាចារឹកនេះ និយាយពីការកសាងរូបពោធិសត្វអវ លោកិតេស្វរៈ ទុកដើម្បីគោរពបូជា (តាមបែបពុទ្ធសាសនា ហាយាន) ព្រមទាំងអំពីជង្ហាយ និងជំនឿតាមពុទ្ធនិយម ។

## លក្ខណៈរួមនៃអត្ថបទសិលាចារឹកសម័យ កាលទី ២

តាមការលើកយកនូវសិលាចារឹកទាំង ៤ កន្លែង ក្នុង ម័យកាលទី ២ មកអធិប្បាយបញ្ជាក់ខាងលើ ហើយអាច ឃើញនូវបែបបទ គោលគំនិតនិពន្ធ និងបច្ចេកវិធីដូចតទៅ៖

### ក) ផ្នែកអត្ថន័យ.–

អ្នកកត់ត្រានិពន្ធអត្ថបទ យោលទៅលើហេតុការណ៍ កសាង សមិទ្ធផលផ្សេងៗ មានបូរាណដ្ឋាន ទេវរូប ព្រមទាំង លាតត្រដាងអំពីជំនឿ ទំនៀមទម្លាប់ ប្រពៃណីក្នុងសម័យកាល ប្រកបដោយវឌ្ឍនភាពខាងវប្បធម៌ សង្គមធម៌រុងរឿង ៗ គឺ

តាមរយៈការលាតត្រដាងនូវហេតុផលពិតប្រាកដ បែបក្នុងសិលាចារឹកនេះហើយ ដែលយើងអាចបានដឹងនូវ កម្រិតជីវភាពរបស់ប្រជាកស្រ្ត និងការគ្រប់គ្រងប្រទេសប្រកបដោយការរៀបរយយ៉ាងសំខាន់ ។

### ១) ផ្នែកអត្ថរូប.-

ដូចគ្នានឹងសិលាចារឹកសម័យទី ១ ដែរ សិលាចារឹកសតវត្សទី ៧ ដល់ ៩ នេះ ក៏មានបែបផែនទិពន្ធ ត្រឹមត្រូវទៅតាមលក្ខណៈនៃវិធីសាស្រ្តបច្ចេកទេស គឺមាន ៖

១– សេចក្ដីផ្ដើម: ដែលប្រាប់នូវកាលបរិច្ឆេទ នៃការតែង;

២-- តួអត្ថបទ: ដែលនិយាយអំពីគំនិតសំខាន់ ៗ ដូចជាការបញ្ជារបស់ព្រះមហាក្សត្រ, ការសំរេចផលនៃការកសាងទេវដ្ឋាន ទេវរូប និងជំនឿសំខាន់ ៗ;

៣– សេចក្ដីបញ្ចប់: ការឧទ្ទិសផលកើតមកពីកុសលកម្ម និងសេចក្ដីព្រមាន ឬ បណ្ដាសារនានាចំពោះជនណាដែលប៉ះពាល់ចំពោះរាជបណ្ដាំ លើបូជនដ្ឋាន ឬទេវរូប ជាដើម ។

ឯពាក្យពេចន៍ប្រើ គឺនៅមានភាសាសំស្ក្រឹត សឹងតែគ្រប់អន្លើ ៗ បើពាក្យខ្មែរវិញ ក៏នៅជាបូរាណ ពិបាកយល់ ពិបាកន័យសេចក្ដី ហើយសរសេរខុសអក្ខរាវិរុទ្ធ សព្វថ្ងៃសឹងតែទូទៅ ៗ

## គ) ផ្នែកអត្ថរស.—

តម្លៃសំខាន់ថិតនៅលើ **អច្ឆរិយហេតុ** (ដោយផ្ដោតគំនិតជំនឿទៅលើអច្ឆរិយវត្ថុ ជឿកម្មផល ឬការដាក់បណ្ដាស្ថានអធិដ្ឋានឲ្យបានសំរេចមគ្គផល ពីជាតិនេះទៅដល់បរលោកនាយជាដើម) ៗ សារៈសំខាន់មួយទៀត គឺ **សង្គមរស** ដែលជាតម្លៃគ្របដណ្ដប់ទៅលើបញ្ហារស់នៅ បញ្ហាជំនឿរបស់មនុស្សចាប់ពីក្សត្រិយវង្ស អ្នកកាន់សាសនា រហូតទៅដល់ប្រជានុរាស្ត្រនោះឯង ៗ

## ទី៣– សម័យកាល ទី៣

## សម័យមហានគរ

## គ្រិស្តសតវត្សទី ៩ ដល់ ១៤,

## គ.ស. ៨០២ ដល់ ១៣៣៦ (១)

### ១– ក្សត្រសំខាន់ៗ ក្នុងសម័យកាលទី ៣.–

សម័យកាលទី៣ ឬសម័យមហានគរនេះមានរយៈពេលដល់ទៅ៦សតវត្ស ហើយជាឱកាសដ៏វែងដែលព្រះមហាក្សត្រខ្មែរច្រើនបានកសាងវប្បធម៌. អារ្យធម៌ខ្មែរសំរាប់ទុកកេរ្តិ៍ដំណែលបង្ហាញនូវកម្លាំងពលំ សមត្ថភាពរបស់ខេមរជនយើងៗ បានសេចក្តីថា វិស័យវប្បធម៌ ស្ថាបនកម្ម បានទុកនូវកស្តុ-តាន៍នៃបុរាណដ្ឋាន ប្រាសាទនានាដ៏មានល្បីឈ្មោះដូចជាអង្គរវត្ត បាយ័ន បាពួន បន្ទាយស្រី ។ល។ ហើយផ្នែកអក្សរ

---

(១) ក្នុងសៀវភៅពុទ្ធសាសនា ២៥០០, អត្ថបទប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែររបស់ព្រះតេជៈព្រះគុណ ប៉ាង-ខាត់ ទំព័រ ៦២ ថា «សម័យមហានគរ តាំងពី ព.ស. ទី១៤ ដល់ ២០ (គឺ គ.ស. ៨០២ ដល់ ១៤៣២)» ។

សាស្ត្រ យើងមានអត្ថបទជាលាយលក្ខណ៍អក្សរកត់ត្រាលើផ្ទាំងថ្មប្រមាណជិតបីរយកន្លែងប្លែកៗគ្នា ។

ក្នុងសម័យកាលនោះ ព្រះមហាក្សត្រដែលទ្រង់ជាស្ថាបនករ មានដូចតទៅ :

– ព្រះបាទជ័យវរ្ម័នទី ២ (គ.ស. ៨០២–៨៥០) ដែលតាំងព្រះរាជធានីនៅលើមហេន្ទ្របព៌ត គឺភ្នំគូលេន; ទ្រង់សាងព្រះបរមរាជវាំងមួយនៅបឹងមាលា (ចម្ងាយ ៣គ.ម ពីភ្នំគូលេន) – ទ្រង់សាងប្រាសាទព្រះខ័ន (នៅជិតនគរធំ) និងបន្ទាយឆ្មា ខាងជើងបាត់ដំបង ជាប្រាសាទគូ,

– ព្រះបាទជ័យវរ្ម័នទី ៣ (គ.ស. ៨៥០–៨៧៧);

– ព្រះបាទឥន្ទ្រវរ្ម័នទី ១ (គ.ស. ៨៧៧–៨៨៩) : ទ្រង់កសាងប្រាសាទបាគោ និងបាគង ។ សេនារបស់ព្រះអង្គម្នាក់បានសាងប្រាសាទ បព្យាក្ដ ឬបាយ័ន។

– ព្រះបាទយសោវរ្ម័នទី ១ (គ.ស. ៨៨៩–៩០០) :

ទ្រង់បានសាងបន្ទាយយ៉ាងធំ សំរាប់ការពារសត្រូវ ឈ្មោះយសោធរៈបុរៈ ឬកន្ទុបក្តមហានគរ ឬអង្គរធំ;

– ព្រះបាទហស៌វរ្ម័នទី ២ (គ.ស. ៩៤១–៩៤៤);

– ព្រះបាទរាជេន្ទ្រវរ្ម័នទី ១ (គ.ស. ៩៤៤–៩៦៨);

– ព្រះបាទជ័យវរ្ម័នទី ៥ (គ.ស. ៩៦៨–១០០១);

– ព្រះបាទសូរ្យវរ្ម័នទី ១ (គ.ស. ១០០២–១០៥០): ទ្រង់បានសាងប្រាសាទ ២ នៅភ្នំជីសូរ (ក្នុងស្រុកបាទី) និងមួយទៀតនៅភ្នំសន្ទុក;

– ព្រះបាទឧទយាទិត្យវរ្ម័នទី២ (គ.ស. ១០៥០–១០៦៦);

– ព្រះបាទហស៌វរ្ម័នទី ៣ (គ.ស. ១០៦៦–១០៨០);

– ព្រះបាទជ័យវរ្ម័នទី ៦ (គ.ស. ១០៨២–១១០៧);

– ព្រះបាទធរណិន្ទ្រវរ្ម័នទី១ (គ.ស. ១១០៧–១១១២);

– ព្រះបាទសូរ្យវរ្ម័នទី២ (គ.ស. ១១១៣–១១៥០); ទ្រង់បានសាងប្រាសាទអង្គរវត្ត ឬនគរវត្ត;

– ព្រះបាទជ័យវរ្ម័នទី ៧ (គ.ស. ១១៨១–១២០១);

ទ្រង់បានបង្ក្រាបស្តេចប្រទេសុកពជ ជាបច្ចាមិត្រនៅទិសខាងជើង គឺក្នុងប្រទេសសៀមនិងលាវ ដែលបះបោរគឺបង្ក្រាបដល់ល្វឹងព្រះបាង (សិរី ធមិ គិរី), យាងនៅនគរពជ (គូ៉ត) បង្ក្រាបសៀមរហូតដល់ក្រុងសុខោទ័យ;

- ព្រះបាទជ័យវរ្ម័នទី ៩ (គ.ស. ១៣២៧-១៣៣៦)។

## ២- សាសនាក្នុងសម័យកាលទី ៣.-

ក្នុងសម័យកាលនេះ ប្រទេសកម្ពុជាកាន់ព្រហ្មញ្ញសាសនា និងពុទ្ធសាសមហាយាន ។

## ៣- អក្សរសាស្ត្រក្នុងសម័យកាលទី ៣.-

ក្នុងសម័យកាលនេះ អត្ថបទអក្សរសាស្ត្រនានានៅគង់ត្រាក្នុងផ្ទាំងថ្មដែល ដែលមានឈ្មោះថា សិលាចារឹក ។ អត្ថបទខ្លះវែង ខ្លះទៀតខ្លីមានទំហំតែបន្ទាត់មួយបន្ទាត់ ឬពីរគត់ ត្រានៅនឹងមេទ្វារ នៅនឹងក្រម្រាបេថ្ម ឬនៅនឹងវត្ថុប្រើប្រាស់ ដូចជានៅនឹងជើងទ្រកញ្ចក់ នៅនឹងថូជាដើម (សូមកាន់គាត

ឈ្មោះអត្ថបទសម័យកាលទី៣ នេះក្នុងមេរៀនទី ៥ ខាងមុខ)។

## ៤– អ្នកប្រាជ្ញនិងអ្នកនិពន្ធសំខាន់ក្នុងសម័យកាលទី ៣–

អ្នកប្រាជ្ញ គត់ត្រាសិលាចារឹកដែលមានបញ្ជាក់ឈ្មោះច្បាស់ក្នុងសម័យសតវត្សទី ៩ ដល់ ១៤ មានដូចតទៅ :

### ទី ១- បណ្ឌិតសិវសោម = Paṇḍita Çivasoma

បណ្ឌិត សិវសោម រស់នៅក្នុងសតវត្សទី ៩ នៃគ.ស. គឺក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ័នទី ១ (គ.ស. ៨៧៧–៨៨៩)។

បណ្ឌិតរូបនេះ ជាអ្នកមានចំណេះខាងក្បួនច្បាប់ផ្សេងៗក្នុងអក្សរសាស្ត្រ និងមន្តវិជ្ជាគាថាខាងសាសនា (ពិសេសខាងព្រហ្មញ្ញសាសនា) ។ លោកបាននិពន្ធរឿងមហាការកៈ និងក្បួនវេយ្យាករណ៍ ព្រមទាំងសិលាចារឹកទៅ :

– ប្រាសាទគណ្ឌាលដើម ដែលជាអត្ថបទថ្លែងសរសើរព្រះកជបារមីនៃព្រះបាទឥន្ទ្រវរ័ន ដ៏ជាក្សត្រមានឫទ្ធានុភាពធ្វើ

បត្រូវគ្រប់ទិសទីខ្ទប់ខ្ទាប់ព្រះចេស្តាព្រះអង្គ ។ ព្រះបាទ
វរ្ម័នទី ១នេះ ទ្រង់មានព្រះនាមល្បីល្បាញ ជាក្សត្រស័កៗ
បានកសាងប្រាសាទបាគោនិងបាគង ដែលជាបូពណ-
ល្អអស្ចារ្យ ។ សេនាព្រះអង្គបានកសាងប្រាសាទបាយ័ន ។
-សិលាចារឹកពង់តេងកង់នៅកំពូលេខ (គ.ស.១០៧៤)
Inscriptions du Cambodge ភាគ ៥) ។

# សិលាចារឹកនៅមេបញ្ជរទ្វារ
# នៃប្រាសាទកណ្តាលដើម (ខាងជើង)

## ក- ទីកន្លែង.-

ប្រាសាទកណ្តាលដើម (ខាងជើង) នេះឋិតនៅចម្ងាយ
០ម នាខាងលិចកំផែងក្រៅប្រាសាទព្រះគោ ។

## ១- លក្ខណៈនិងន័យទូទៅ.-

សិលាចារឹកនេះពីដំបូងត្រូវបានលោកវរសេនីយ De

---

(១) នៅក្នុង Inscriptions du Cambodge របស់ G. Cœdès
e I ទំព័រ ៣៧ ដល់ ៤៦ ។

Lajonquière បញ្ជាក់ហើយ នៅឆ្នាំ ១៩៣៤ ទៀត, លោក G. A. Trouvé បានផ្តិតយកមករក្សាទុក ។ ផ្នែកមេបញ្ជរ ខាងត្បូង មានសរសេរជាអក្សរសំស្ក្រឹតចំនួន ៤៨ បន្ទាត់ (ស្លោកដើមនិងខាងចុងលប់អស់ខ្លាំង) ហើយផ្នែកមេបញ្ជរ ខាងជើងសរសេរជាខ្មែរមាន៤៩បន្ទាត់ នៅច្បាស់ល្អណាស់ ។

— តាមសិលាចារឹកនេះ បណ្ឌិតសិវសោម ជាគរុ (គ្រូ) របស់ព្រះបាទឥន្ទ្រវរ្ម័ន ដែលមានបញ្ជាក់នៅក្នុងសិលាចារឹក ស្តុកកក់ធំ ។ អត្ថបទនេះសរសើរព្រះបាទឥន្ទ្រវរ្ម័ន និងខ្ទ សិវសោមនេះឯង ។ បណ្ឌិតនេះជាចៅរបស់ព្រះបាទជ័យេន្ទ្រា-ធិបតីវរ្ម័ន ដែលត្រូវជាបាខាងមាតានៃព្រះបាទជ័យវរ្ម័នទី២ ។ គ្រូរបស់សិវសោម គឺភគវត្រុទ្រៈ Bhagavat Rudra ។ លោក បានរៀនអក្សរសាស្ត្រអំពីព្រះគ្រូភគវតសង្ករ : Bhagava Çankara ។ សិលាចារឹកនេះជាអក្សរខ្មែរ ។ ឆ្នាំច្បាក់ដឹកក រវាង គ.ស. ៨៧៨ និង ៨៨៧ ។

## គ- អត្ថបទ.-

### ទី១_ នៅមេបញ្ជរទ្វារខាងត្បូង

១– ៧– (លុបអស់)

៨– សែលេ...

៩– ផ្កាតាំ ...

១០– កាសិទ កជ ...

ស្រី ទ្រូវ ...

១១– វិសុទ្ធក្យត្រេសន្ទាន...

១២– យោ ហ្ឫត្រើលកន្ទស្យ

១៣– កាមំ ហរហតៈ កាមោ យស្មិ...

មូណាកូ . . . គឺ អយំ គឺ អសោ រ ឥតិ ៗ

១៤– អគ្ឫិ បីតំ អាសា·នេត្រៃស សុកគតា ម្ញុំ យេន

ហា សកយេនេរ ជគតាំ ហ្ញុទយេ ឬប្បិតំ ៗ . . . (១)

---

(១) មានប្រើតគទៅទៀត ផល់ស្លោកទី ៤៧ ក្នុងទំព័រ ៤០ ។

## ទី២_ នៅមេបញ្ជរទ្វារខាងជើង(១)

១– ស្រី សិទ្ធិ នមសៈ ស្រី កម្រតេង (ពយ)

. . . . . (ក)រ សតកិសន ក្សត្រ ទុ ម្រតេ

(២) ញ សិវកេម ស្វាបនា ព្រះ កម្រ តេង អញ . .

(ក្ស) ណា ប្រសាទ ធូលិ ជេណ ព្រះ (៣) កម្រ តេង អញ

ស្រី ឥន្ទ្រវម ទេវ បិ ជូ (ទេ កុំ អ្នក បំរេ គោយ ក្នុង) គ្មា

ស្រុក សិវគុរុ ឥ ប (៤) មេក សី . . . សី បន្ទស ឥ . . . ង

តៃ បន្ទស ឥ តៃ វសន្ត ឥ (៥) បមស តៃ ប . . . ឥ តៃ . .

តៃ ក្រៅ ឥ តៃ កន្ទី ឥ តៃ ប៉ុ ឥ បំ (៦) ព្រយង់ តៃ ក្លាប

ឥ តៃ ប៉ុ ឥ តៃ កញ្ចុះ ឥ តៃ កន . . . ឥ តៃ ករេទង ឥ តៃ

ល ឥ គ្ន (៧) ង តៃ ក្រៅ ឥ បញ សី កំបិត ឥ សី ក្រៅ

សី គ្រល . . . ឥ តៃ គន្ធ ឥ តៃ ពៅ ឥ តៃ តរេក្ត (៨) រ ឥ ស

ផៅ ឥ ចាំ ព្យរ សី ករេទង ឥ តៃ កំ វាង . . . (អ្នក) ស្រេ ឥ

ស្រុក បាណា ឥ សំរះ កទ្រោក ឥ (៩) ឃោ កុង ទ្រង ឥ ឃោ

---

(១) ពីទំព័រ ៤១ ដល់ ៤២ ។

កន្តោញ ត៌ យោ កញ្ចា ត៌ យោ . . . អ្នកកន្ទោង ត៌ យោ ច្កេ
ឯ តៃ កន្ទីត៌ (១០) តៃ ពៅ ត៌ តៃ កំម ត័ ត៌ ពៅ តៃ អនង្គ ត៌
តៃ ពៅ ត៌ តៃ ធន្វ ត៌ តៃ . . . ប ត៌ តៃ ព្រះ ស្រីយ ត៌ តៃ ក កៃ
ត៌ តៃ អ ពា ច ក (១១) ក្សាល សំ-អប ត៌ តៃ អ្ដក ត៌ តៃ ចន្ទាន
ត៌ ក្សាល ប្រេន វិទ្យុ ត ត៌ គិ ស្រុក សិន្ធូរ ត៌ អំរះ កញ្ចាញ ត៌
(១២) យោ កពេល ត៌យោ កុន្ធូ ត៌យោ ត្តប ក្សាល កុំ ព្រះ ត៌តៃ
កញ្ចូ ត៌ តៃ កទ្រុក-ត៌ ក្សាល បន្ទុន ត៌ សី ពៅ ត៌ (១៣) . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . .

X X

## ទី២- បណ្ឌិត យតិអមរភាវៈ Paṇḍita Yati Amara Bhàva

ជាអ្នកប្រាជ្ញដ៏សំខាន់មួយរូប ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន (គ្រិស្តសតវត្សទី ៩ និងដើមទី ១០ គឺ ៨៨៩-៩០៨)។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យ តាំងបណ្ឌិតនេះជាអធិបតីនៃបណ្ឌិតទាំងឡាយ ហើយលើកឲ្យមានឋានន្តរស័ក្តិជាសង្ឃរាជលើវត្ត ឥន្ទ្រាស្រម (ផ្នែកសាសនាព្រាហ្មណ៍) ។

បណ្ឌិតយតិអមរគោរ: បាននិពន្ធសិលាចារឹកទុកនៅ

បាយគ្គ ។ ក្នុងសិលាចារឹករបស់លោក បណ្ឌិតយតិអមរគោរ

អួតសរសើរព្រះឥសូរ ហើយសំបូងសង្រួងសុំឲ្យព្រះឥសូរជួយ

ថែរក្សាប្រជានុរាស្ត្រឲ្យប្រកបដោយសេចក្ដីសុខ ។

សូមបញ្ជាក់ថា ព្រះបាទយសោវរ្ម័នទ្រង់បានសាងអគ្គ

ធំក្នុង គ.ស. ៩០០ ។ ទ្រង់បានកសាងបន្ទាយយ៉ាងធំមួយ

ឈ្មោះយសោធរៈបុរៈ ឬ ឥន្ទបត្តមហានគរដើម្បីការពារសត្រូ

(គឺអង្គរធំនេះឯង) ។

ក្នុងសម័យរជ្ជកាលព្រះមហាក្សត្រអង្គនេះ ប្រទេស

កម្ពុជា មានទឹកដីធំណាស់ គឺខាងជើងដល់ព្រំប្រទេសចិន

ខាងលិចដល់នឹងទន្លេសាលូអេន (ក្នុងប្រទេសភូមា) ។

## សិលាចារឹកបាយគ្គ (១)

### ក) ទីកន្លែង.–

---

(១) នៅក្នុង Inscriptions du Cambodge របស់ G. Cœdès Tome I ទំព័រ ២៥៦ ដល់ ២៦០ ។



សិលាចារឹកភ្នំបយ័ង្គ

(សតវត្សទី ៧)

សិលាចារឹកនេះឋិតនៅក្នុងស្រុកទ្រាំង ខេត្តតាកែវ ។ ទាំងអស់មាន ២ ផ្ទាំង ។

## ១) លក្ខណៈ និងន័យទូទៅ ._

សិលាចារឹកទាំង ២ នេះមានកាលបរិច្ឆេទនៅក្នុង គ.ស. ៦០៤ និង ៦២៤ ។

ឯសិលាចារឹកដែលមានឈ្មោះ ឥសី យតិអមរការៈជាអកតែង គឺសរសេរលើបង្កក់ មួយផ្ទាំងភ្ជាប់នៅត្រង់ជញ្ជាំងកំពែងនៅផ្នែកខាងត្បូង គឺនៅត្រង់ទ្វារចូលខាងកើតនៃប្រាសាទធំ ។ សិលាចារឹកនេះសរសេរជាភាសាសំស្ក្រឹតមាន ១៨ បន្ទាត់ចែកជាស្លោក១ ៗ អត្ថបទនៅពេញល្អណាស់ ព្រោះមានការរក្សាទុកយ៉ាងត្រឹមត្រូវ ។ ក្នុងវគ្គទី ២ ដល់ ៥ មានបញ្ចូលបរម-នាមនៃព្រះករុណាយសោវរ្ម័នទី ១ ។ ក្នុងវគ្គទី ៧ និង ៨ អ្នកនិពន្ធបញ្ជាក់អំពីឋានន្តរសក្តិជាច្រើន ដែលខ្លួនទទួលអំពីព្រះរាជា ៗ ជាបឋម ឥសីនេះបានទទួលការតែងតាំងអំពីព្រះបាទឥន្ទ្រាវរ្ម័ន ជាអធិបតីនៃឥន្ទ្រាស្រមខាងជើង (វគ្គទី ១០) ហើយ

នៅវគ្គទី ១២ លោកបញ្ជាក់ថា លោករើសបានមណ្ឌលៈ ដែលជាចិញ្ចៀនមាសមួយរបស់ព្រះរាជគ្រូ នៅពេលជីកស្រះមួយ ។ លោកបានបញ្ជាឲ្យសាងបដិមាព្រះសិរៈមួយ មានលក្ខណៈរូបជា ឧត្យរម៉ិត សំរាប់ទុកបូជាក្នុងពិធីផ្សេងៗ (វគ្គទី ១៣ដល់១៤)។ គោលបំណងនៃសិលាចារឹកនេះគឺសំរាប់រំលឹកដល់ការស្ថាបនាសាលាមួយបិតនៅទីវាលមួយជិតក្ពុំខាងត្បូង ។

គ) អត្ថបទ .—

១— ស្រិយម័ រ៉ា ធ្វជដ៏ះ បាតុ យស្រាគ្គ ហ្ម៉ះការប៉េ-
ទយា វិធើ ក្មតស្ររ៉ាស៌ាន ទសា សេ្រា វ្យ ក្មត ស៊្យពន៍ ។

២— ក្មុជាធិបតី ពជ៉ំ ម៉្មិទស្យ ពហិតសា សង៉ះ ស្រ៉-
នទ្រាវេត្ថិ ពជា យោ ទិក្យ ខ្យាតបពក្រមះ ។

៣— សោរ៉ា ពជសមាហារ មៅលិគ្នាឆ្យ ឆិគ្រតមៃះ រក្ក
សំផ្ហា សទំ យស្រា ទ្វគុណីក្ម តសោកន៍ ។

៤— ឯកែកាស្កសិតាំប្ត—ពជ្យស្រីស ស្រីយសោនិធេ្ទះ

ស្រីយសោវម៌្មាសិត៍ តស្យ បុត្រះ ប្រតា ប វា ន៑ ។

៥– ធម្មិ វិយោគិភ្យស្យ កាជ្យយស្យ ភុក្ត យុតម៑

បរោក្ស អប្យ អតិប្រិត្យា វត្តិ មានំ អក្ខុទ ឥវ ។

៦– យតោ និយ្យាយ សក្តី តំ តេរ ភូយសី បរោ

ទិសះ ខូពទ ស្រមត ហេវ បស្យេ សាហ្មោ មហេទាទរេធះ ។ (១)

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

X X

## ទី ៣– បណ្ឌិត ទិវាករ Pandita Divàkara

ជាអ្នកប្រាជ្ញឯកក្នុងសម័យព្រះបាទរាជេន្ទ្រវរ្ម័នទី១ (គ្រិស្តសតវត្សទី ១០ គ.ស. ៩៤៤-៩៦៨) ។ បណ្ឌិតរូបនេះ ចេះចាំត្រៃវេទស្ទាត់ ។ ព្រះមហាក្សត្រសព្វព្រះទ័យព្រះរាជទានរាជបុត្រីមួយអង្គនាម (ឥន្ទ្រលក្ស្មី) ឲ្យធ្វើជាភរិយាបណ្ឌិតទិវាករនេះ ។

បណ្ឌិតទិវាករបាននិពន្ធសិលាចារឹក នៅប្រាសាទកំភីស

(១) អត្ថបទនេះមានតរហូតដល់ទី ១៨ ( ទំព័រ ២៥៦ និង ២៥៧) ។

សំពង់សរសើរព្រះបារមីនៃព្រះបាទជ័យវរ្ម័នទី ៥ ដែលត្រូវជាព្រះរាជបុត្រនៃព្រះបាទរាជេន្ទ្រវរ្ម័នទី ១ (សោយរាជ្យក្នុង គ.ស. ៩៦៨ ដល់ ១០០២) ។

## សិលាចារឹកប្រាសាទកំពីស (១)

### ក) ទីកន្លែង –

សិលាចារឹកនេះឋិតនៅនាប្រាសាទកំពីស ដែលលោក H. Parmentier រកឃើញនៅក្នុងខែឧសភា គ.ស. ១៩២៩។ ប្រាសាទនេះ ឋិតនៅក្នុងឃុំយាង (ម្លូព្រៃ) ចម្ងាយ ១៦ គ.ម នាខាងត្បូងភ្នំសណ្ដុក គឺ ៧គ.ម ពីជាន់ស្រម ហើយ២៥ គ.ម ពីកោះកែរ ។

### ខ) លក្ខណៈ និងន័យទូទៅ.–

មេបញ្ជរទ្វារ ២ នៅទិសប្រាសាទធំ មានសិលាចារឹក

(១) មើល Inscriptions du Cambodge របស់ G. Cœdès, ទំព័រ ១៥៩ ដល់ ១៨៦ ។

ដែលលេចៗ គឺមេត្តាខាងត្បូងមាន ៥៥ បន្ទាត់ និងមេត្តាខាងជើងមាន ៣៣ បន្ទាត់ ។ សិលាចារឹកទាំង ២ នេះ រៀបរាប់អំពីវត្ថុនានាសំរាប់ជាគ្រឿងបូជា ហើយនិងបញ្ជីបូជា ។

សិលាចារឹកនៅកុកទីក្ដា គឺនៅចន្លោះហោត្រៃ មានប្រវែង ១,១៥ម×០,៦២ម×០,២៩ម ។ នៅជ្រុងទាំងបួន ម្ខាងៗ មានអក្សរចារឹកដូចតទៅ :–

— ជ្រុងក មាន ២៩ បន្ទាត់ សរសេរជាភាសាសំស្ក្រឹតចែកជា ២៧ វគ្គ;

— ជ្រុង ខ មាន ៣៩ បន្ទាត់ ជាភាសាខ្មែរ និង ៧ បន្ទាត់ជាភាសាសំស្ក្រឹត;

— ជ្រុង គ មាន ៥៩ បន្ទាត់ ដែលលាយឡំភាសាខ្មែរ និងសំស្ក្រឹត (សំស្ក្រឹតមាន ៧ វគ្គ);

— ជ្រុង ឃ មាន ២៧ បន្ទាត់ ជាភាសាខ្មែរ ។

សិលាចារឹកនេះមានកាលបរិច្ឆេទ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៥ ដែលរៀបរាប់អំពីព្រាហ្មណ៍ឈ្មោះ ទិវាករភត្ត

បានសាងប្រាសាទនៅមតុវន ឬ មតុគានន (ជាខ្មែរថា ត្រៃ
យុំ) គឺកសាងប្រាសាទ កំភីសនេះឯង ។

អត្ថបទសំស្ក្រឹតនៅប្រាសាទកំភីស មានលក្ខណៈប្រ
ហាលគ្នាមួយផ្នែកធំ នឹងសិលាចារឹកនៅព្រះឥន្ទ្រកោសីយ ។

ឯសេចក្តីក្នុងសិលាចារឹកនេះ មានន័យសង្ខេបដូចតទៅ ៖

— ជ្រុង ក (ជាភាសាសំស្ក្រឹត) រៀបរាប់ពីការសរសើរ
ព្រះឥស្វរ (វគ្គទី ១ ដល់ ទី ៥) — ពលាទិត្យជាព្រះរាជានៃ
អនិន្ទិតបុរៈ (វគ្គទី ៦-៧) — គេសរសើរព្រះបាទរាជេន្ទ្រវរ្ម័ន
សោយរាជ្យជាបក្នុង ម.ស. ៨៦៦ (វគ្គទី៨ ដល់ ២០) — គេ
សរសើរព្រះបាទជ័យវរ្ម័នទី ៥ រាជបុត្រព្រះបាទរាជេន្ទ្រវរ្ម័ន
សោយរាជ្យពី ម.ស.៨៩០ (វគ្គទី ២១ ដល់ ៤០) — ព្រាហ្មណ៍
ទិវាករ (ភត្ត) ស្វាមីនាង ឥន្ទ្រលក្ស្មី — ការកសាងនានារបស់
ព្រាហ្មណ៍នេះនៅទ្វិជេន្ទ្របុរ (៤១ ដល់ ៤៤) បុត្រព្រាហ្មណ៍
នេះបានកសាងប្រាសាទសំរាប់ឧទ្ទិសដល់មាតានាម ឥន្ទ្រលក្ស្មី
(៤៥ ដល់ ៤៦) — ទិវាករៈបានកសាងទេវៈបឹអគ្គ នៅមតុវនៈ

ដើម្បីឧទ្ទិសចំពោះភទ្រេស្វរៈ (វគ្គទី ៤៧) ។

— ផ្ទាំង ១ សេចក្តីឧទ្ទិសរបស់ព្រះបាទជ័យវរ្ម័នទី ៥ ក្នុង ម.ស. ៨៩៤ រៀបរាប់ពីភូមិដែលថ្វាយចំពោះទេវៈក្បាលព្រៃឃ្មុំ របស់ព្រះបាទរាជេន្ទ្រវរ្ម័ន (បន្ទាត់ទី១ ដល់ទី ១៨) — បញ្ជីពួកពាសៈ (បន្ទាត់ទី ១៩ ដល់ ៣៩) — ការរៀបរាប់អំពីពាក្យឧទ្ទិសជាសំស្រ្កឹតធ្វើរួមគ្នា ទៅទិវាជេន្ទ្របុរៈ (ព្រះឥន្ទ្រកោសីយ) និងទៅមធុកានន: (ប្រាសាទកំកីស) (បន្ទាត់ទី ៤៨–៥២) ។

— ផ្ទាំង គ ការសរសើរចំពោះព្រះឥស្វរ (ជាភាសាសំស្រ្កឹត) (វគ្គទី ៥៣) គេរាប់ឈ្មោះគ្រឿងអលង្ការ ទេវរូបផ្សេងៗ ជាភាសាខ្មែរ នៅព្រៃឃ្មុំ ដូចជា : ទិវាជេន្ទ្រស្វាមី (បន្ទាត់ទី ២ ដល់ ៥), សិវលិង្គ (ប-ទី ៥ ដល់ ៦), ព្រះរូបនៃព្រះសពព្រះនាងក្សត្រិយានី ជាមាតាព្រះបាទរាជេន្ទ្រវរ្ម័ន (ប- ទី ៦.៩), ព្រះរូបនៃព្រះអង្គម្ចាស់ក្សត្រី ឥន្ទ្រលក្ស្មី មហេសីព្រាហ្មណ៍ទិវាករៈ (ប-ទី ៩ ដល់ ១១) គគរតី (ប-ទី១១-១២), សិវលិង្គនៅខាងជើង (ប-ទី១២-១៣) — គេរៀបរាប់ពីរតស់ ។

ពប់បូជាចំពោះព្រះវិហារ (ប-ទី១៣-២៧) – តមកស្រាប់តែមាន វគ្គសំស្ក្រឹតមួយកាត់ (ប-ទី២២ វគ្គទី ៥៤) និយាយពីព្រះរាជអំណោយជាខ្ទោះប្រទានពួកមន្ត្រីធ្វើការនៅមធុកាននៈ ។ គេបញ្ជាក់ជាភាសាសំស្ក្រឹត អំពីព្រំប្រទល់នៃមធុវនៈ ដែលបូជាចំពោះទេវៈដោយព្រះបាទរាជេន្ទ្រវរ្ម័ន ព្រះអំណោយដែលបញ្ជាក់ដោយព្រះបាទជ័យវរ្ម័នទី ៥ (វគ្គទី ៥៥-៥៩) ។ បញ្ជីទាសៈបូជាចំពោះ ទេវៈនៅព្រៃឃ្មុំដោយ ទិវាករៈ និងមហេសីព្រះនាងឥន្ទ្រលក្ស្មី (ប-ទី៣១-៤២) ។

– ជ្រុង ឃ ជាបញ្ជីបន្តពីជ្រុងមុន (ប-ទី១-២៥) – គ្រឿងបូជាផ្សេងៗ ដែលព្រះមហាក្សត្រិយានីបានឧទ្ទិសចំពោះបដិមាករ (ប-ទី២៦-៣៦) និងចំពោះបដិមាព្រះនាងឥន្ទ្រលក្ស្មី (ប-ទី៣៧-៤៦) ។

តាមរយៈអត្ថបទនេះ ការកសាងប្រាសាទកំពឹស ហៅជាភាសាសំស្ក្រឹតថា មធុវនៈ និងជាភាសាខ្មែរថា ព្រៃឃ្មុំឋិតនៅក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន ហើយបដិមាសំខាន់គឺសិវ

មាននាមថា គម្រោងស្វរៈ ដែលកើតនៅក្នុងប្រាសាទចំកណ្ដាល ។

គ) អត្ថបទ.–

– ក្រុម ក

១– ឯកោ ម វហ៊ុបនាក្ក វិសប្បិតា ករ ឱ្យគីថ វណ្ណិ-
វណ្ណិតស្វរសង្គតកៈ មាត្រា . . . កា ផ ករ ហ្ស ក . . . កាត
ស . . . កាម្ម . . . ន្យ ។

២– បាតុ រ៉េ វហុផែកាម . . . យា . . . អេសក្ខុម វិស្វ
ទីរ រស៊ ។

៣– វិរន្ទុ ន ហ . . . ន ត . . . ឯន . . . ។ . . .
កុលា វិ ស្វ សិនៈ រក សាម វិថីស . . . ។

៤– បាយាម កិន្នរស្ស សម្មស ស្តិរយោគោ ចំរ៉េ
ក្ខុសម រតៅ វីកដាក្ស វិរក្សបវញ្ចរតា រយា មហ័ក ស្វំ ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . (១)

– ក្រុម ខ:

(១) នៅអានតទៅដល់វគ្គទី ៥៣ (គឺពីទំព័រ ១៦៣ ដល់ ១៦៧) ។

១– ៨៩៤ សក បណ្ណំ មី ផល្គុណ នុ វ្រះ កម្រតេង៑ អញ ទិវាករ[១] (២) ត្ក នវេទន ត ធូលី វ្រះ បាទ ធូលី ជេង៑ វ្រះ កម្រតេង៑ (អញ ស្រី) (៣) ជយវម៌្មទេវ កាល សម្រាប ហោម ទ្វាទសកត្រី វ្រះ បាទ (វ្រះអា) (៤) ជា កន្មាង៑ កម្រតេង៑ អញ វយ ស្រុក កន្ទិន នុ ស្រុក សុបុពណ៌ (៥) ប្រមានបូ-វ៉ិស ត គិ ធូលី វ្រះបាទ ធូលី ជេង៑ វ្រះ កម្រតេង៑ អញ (៦) ស្ដាច ទៅ សិវលោក ឲយ វ្រះ ករុណា ប្រសាទ ត វ្រះ កម្រតេង៑ អញ (ទិវាក) (៧) រគ្គ នេះ ស្រុក ត បន្ទ ២ គិបិ វ្រះ កម្រតេង៑អញ . . .[២] ។

X X

ទី ៤. បណ្ឌិត កវីន្ទ្រៈ Pandita Kavindra

ជាអ្នកប្រាជ្ញយ៉ាងធំក្នុងរជ្ជកាល ព្រះបាទសូរ្យវរ្ម័នទី ១ (គ្រិស្តសតវត្សរ៍ទី ១១ គ.ស.១០០ ដល់ ១០៤៩) ។ លោក

---

(១) នៅមានតទៅទៀតដល់ជ្រុង គ និង ឃ (គឺពីទំព័រ ១៦៩ ដល់ ១៧៣)។

(២) នៅមានតទៅដល់ គ និង ឃ (គឺពីទំព័រ ១៦៩ ដល់ ១៧៣) ។

បេះតាំស្អាត់ទូវ គម្ពីរក្បួនខ្នាតវេជ្ជ ៗ ដោយបានបាន:

ប្រើក្បាំនៃព្រះមហាក្សត្រផ្ទាល់ ។

លោកបាននិពន្ធសិលាចារឹកនៅប្រាសាទខ្នា សំកប់

សើរទូវតេជ:បារមីរបស់ព្រះបាទសូរ្យវរ្ម័ន ជាក្សត្រសឹកដ៏

ហាន មុះមុតក្នុងចម្បាំង ។

## សិលាចារឹកប្រាសាទខ្នា(១)

### ក) ទីកន្លែង.—

ប្រាសាទខ្នាឋិតនៅក្នុងខែត្រម្លូព្រៃ ។ លោក Aymon

និងលោកសេនីយ De Lajonquiére បានរកឃើញសិលាចារឹ

នៅទីនេះ ។ ក្នុងខែ មិថុនា គ.ស. ១៩២៩ លោក Parment

បានរកឃើញអត្ថបទថ្មី ១ ២ ទៀត ។

### ១) លក្ខណៈ និង ន័យទូទៅ.—

គឺជាសិលាចារឹកចាស់ជាងគេ សរសេរធ្លាក់នៅលើ

---

(១) មើល Inscriptions du Cambodge របស់លោក G. C

dès, Tome I ទំព័រ ១៩៥ ដល់ ២១៩ ។

ទ្វារបញ្ចរខាងជើង ផ្នែកទ្វារខាងត្បូង មាន ១១ បន្ទាត់ ។

ផ្នែកដើមជាភាសាសំស្ក្រឹតបាត់អស់ នៅសល់តែ ៣ បាទនៃវគ្គខាងចុងចប់ ដែលក្នុង ១ បាទ ៗ មានមួយបន្ទាត់ ។ បន្ទាត់ ៨ បន្ទមកជាភាសាខ្មែរ នៅសល់ល្អទាំងអស់ ។

អត្ថបទនេះ ចារក្នុង ម.ស. ៩៦៣ (គ.ស. ១០៤១) ដែលរៀបរាប់អំពីគ្រឿងរបស់ផ្សេង ៗ បូជាចំពោះទេវៈនាម សកព្រហ្មណ៍ ដែលសម្ដេចស្រីកុរនាទិត្យ អនុជនៃមហេសី ព្រះបាទសូរ្យវរ្ម័នទី ១ គឺព្រះនាងក្សត្រិយានី វីរលក្ស្មី បានធ្វើ ។

— សិលាចារិកទី ២ គេឃើញដោយលោក Parmentier សរសេរចារលើថ្មយ៉ាងល្អ កប់ក្នុងដីនៅស្ពានគោបុរៈខាងជើង មានទំហំ ១,៤៤ម + ០,១៤ម + ០,៣៣ម ។ សិលាចារិកនេះជាភាសាសំស្ក្រឹតទាំងអស់ ។ ឆ្នាំបញ្ចូលក្នុងនោះជា ម.ស. ៩៨២ (គ.ស. ១០៦០) គឺបិតក្នុងរជ្ជកាលព្រះបាទ ឧទយាទិត្យ ័នទី ២ (បញ្ចូលក្នុងផ្នែកខាងចុង វគ្គទី ១២០) ។

វគ្គ ៦ ខាងដើមអួតសរសើរពីព្រះឥស្សូរ (១ ដល់ ៦), វិស្ណុ

(៥) និងព្រហ្ម (៦) ។ ការសរសើរអំពីព្រះបាទសូរ្យវរ្ម័នទី ១ ដែលមានរៀបរាប់សឹងតែពេញផ្ទៃមុខទាំង ៣ នៃសិលាចារឹក (៧ ដល់ ៨៣) ដោយមានបង្ហាញរាជបំរើព្រះអង្គម្នាក់ឈ្មោះ សាល: (Çāla) ទទួលងារពីស្តេចជា ជេយេន្ទ្របណ្ឌិត ដែលមានមុខងារជាសាស្ត្រាចារ្យខាងវេយ្យាករណ៍ (៨៤) ហើយក្រោយមកជាសាស្ត្រាចារ្យខាងបិដក (១០២) ។ អ្នកប្រាជ្ញនេះមានសិស្សឈ្មោះ ផលប្រិយ = Phalapriya ដែលទទួលបាន: ជាកវីន្ទ្របណ្ឌិត = Kavīndrapandita (១០៦-១១៤)។បណ្ឌិតកវីន្ទ្រនេះ ជាកវីដែលចារកំណាព្យនេះលើសិលាចារឹកតែម្តងៗ

គោលបំណងនៃសិលាចារឹកនេះ គឺគេបញ្ជាក់អំពីការរៀបរាប់ឲ្យដឹងអំពីព្រះរាជអំណោយនៃព្រះបាទ ឧទយាទិត្យវរ្ម័នទី២ ឱ្យសញ្ញាមុខងារជាអ្នកកាន់ផ្លិតស្តេច (វ្យជនធរ:) ដែលធ្វើអំពីមាស ហៅថា លក្ស (១២២) ។ មុខងារនេះរក្សាទុកហូតដល់ ១៣ ពង្សបន្តបន្ទាប់គ្នា សំរាប់គ្រួសារតែមួយផ្តាច់មុខ (១២១)។

ត្រសារនេះផែលមានបុគ្គលម្នាក់ឈ្មោះ ភគីស ។ ប្រហែល
ជាអ្នកបង្កើតឲ្យចារនូវសិលាចារឹកនេះ (១២០) ។

គ) អត្ថបទ :—

— នាមសំ សិវាយ យសោ្វាង្រាស សទា សព៌្វ ទិល-
ក្យណះ និរយោគ្រាគាទិកា វេន វេទិតវ្យា មុមុក្សុភិះ ។

២— នាមស៍ សិវាយយេនាន្តៈ—ប្រធាន គ្រិណ្ដិវាសិ-
នាម ជានានវោធគោ វិន្ទមោក្សាយេសោ និយុជ្យតេ ។

(១)

X X

ទី ៥— បណ្ឌិត ភូបេន្ទ្រៈ = Pandita Bhūpendra

ជាអ្នកប្រាជ្ញល្បីល្បាញក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧
(គ្រិស្តសតវត្សទី១២ និងដើមទី១៣ គ.ស.១១៦២-១២០១)។

បណ្ឌិតភូបេន្ទ្រៈ ត្រូវព្រះមហាក្សត្រតាំងជាអធិបតីលើ

(១) អត្ថបទនេះតទៅរហូតដល់វគ្គទី ១២២ (ទំព័រទី ១៩៨ ដល់ ២០៣)។



សិលាចារឹកវត្តភ្ន

(សម័យអង្គរ សតវត្សទី ១២ គឺរវាងឆ្នាំ ១១១៨ និង ១១៣៩)

គណៈអ្នកប្រាជ្ញ និងមានទាំងហោរាក្រុមល្បី ខាងបំណេះនិតិសាស្ត្រ ។

លោកបាននិពន្ធអត្ថបទសិលាចារឹក នៅប្រាសាទទ័រ សំរាប់សរសើរព្រះកិត្តិគុណរបស់ព្រះបាទជ័យវរ្ម័នទី ៧ ព្រមទាំងសមិទ្ធិធំៗ ជាស្នាព្រះហស្តនៃព្រះមហាវីរក្សត្រអង្គនេះ ។

## សិលាចារឹកប្រាសាទទ័រ(១)

### ក) ទីកន្លែង ._

ប្រាសាទនេះឋិតនៅក្នុងតំបន់វត្តកូ (ក្នុងប្រទេសលាវ)។

### ខ) លក្ខណៈ និងន័យទូទៅ ._

សិលាចារឹកនេះជាភាសាសំស្ក្រឹត ត្រូវលោក G.Trouvé រកឃើញកាលពីថ្ងៃទី ៣ កញ្ញា ១៩៣១ ។ នៅជ្រុងទីមួយៗ នៃជ្រុងទាំង ៣ មានចំនួន ៣៦ បន្ទាត់ ។ ឯជ្រុងទី ៤ មាន

---

(១) មើល Inscriptions du Cambodge របស់ G. Cœdès Tome I ទំព័រ ២២៧ ដល់ ២៤៩ ។

តែ ៣២ បន្ទាត់ ។ បើចូលរួមមាន ១៤០ បន្ទាត់ គិតជាវគ្គ
មាន ៦១ វគ្គ ។

វគ្គ ៣ ខាងដើមអ្នកសរសើរពីព្រះឥស្វរ វិស្ណុ ព្រហ្ម
គង្គា និងភូបេន្ទ្របណ្ឌិត ។ បណ្ឌិតនេះជាអ្នកធ្វើទេវបូជាទី ១
ដែលមានបញ្ជាក់នៅជ្រុងទី ៤ ។

ពីវគ្គទី ៦ ដល់ ៤៥ គេសរសើរពីព្រះបាទជ័យវរ្ម័នទី ៧
(ស្ដេចជ័យវរ្មទេវ) ។ វគ្គទី ៦១ បញ្ជាក់ពីកាលបរិច្ឆេទក្នុងរជ្ជ
កាលព្រះបាទជ័យវរ្ម័នទី ៧ (ម.ស. ១១១១ គ.ស ១១៨៩ ឬ
ម.ស. ១១១៧ គ.ស ១១៩៥) ។ អ្នកនិពន្ធសិលាចារឹក គឺ
ជាចៅរបស់មន្ត្រីម្នាក់ ដែលបានបំរើព្រះមហាក្សត្រ៣ព្រះអង្គ
មក គឺព្រះបាទជ័យវរ្ម័ន ធរណិន្ទ្រវរ្ម័ន និងសូរ្យវរ្ម័ន (គោល
គឺព្រះបាទជ័យវរ្ម័នទី ៦ ព្រះបាទធរណិន្ទ្រវរ្ម័ន និងព្រះបាទសូរ្យ
វរ្ម័នទី ២ ដែលសោយរាជ្យមុនព្រះបាទជ័យវរ្ម័នទី ៧) ។ អ្ន
ប្រាជ្ញនេះជាពូជត្រកូលព្រាហ្មណ៍អំពីប៉ុណ្ណមួយ ។

បើកប់អំបូរដើមរៀងមករបស់បណ្ឌិត. ភូបេន្ទ្រ. យើ

អាចគូសតាងដូចតទៅ ៖

កវី ស្វរ:

↓ វិជយេន្ទ្រសូរិ

↓ គុណរត្នសិន្ធុ

↓ តិលកា

(ភគីសូរី កគរតី) ធមសព្រាយ

↓

សុភទ្រ មូរស៊ីរ

(កូរបេន្ទ្រ បណ្ឌិតទី១) កគរតី

↓

កូរបេន្ទ្របណ្ឌិតទី ២ (តទ្រីករម្មាក់) កូរបេន្ទ្របណ្ឌិតទី៣

(កវេន្ទ្របណ្ឌិត សូរ្យបណ្ឌិត) (នៃកុសស្តលី)

គ) អត្ថបទ ._

(១) ហ៊ុំ

១– យស្យាប្យ អចិត្យ៌ក្ន ត៌ក៖ ប្រក្ន ត៌រ គុណាគ្នា រក្យា ណាំបគេរ តរ៍ ករេក ក៏រ អផា ឲ្យ លោទិះ (២) ស្វរិក្រ សា តរ៍តិ វស្តុបយាយ បស្វាក៏ កន៏ នន្ទ មីម ជគតាំ បតី តសម៏ ឡើឡំ ។

២– (៣) វរទ្ម កុសេសយខ្ញុំ សទ្រុំ សិរេន សំ ប្រែត្យ យេន មហតា មហសាំ មហិម្នា (៤) សទ្ធេន្ទុ តារិបុសា សុរសាធតេន ប្រាប្តាម្ភិកាគ្គំ ឥវ យស្យ សរីរំ ឯក្យំ ។(១)

. . . . . . . . . . . . . . . . . . . . . . . . . . . . . . .

X X

## ទី៦- ព្រះនាងឥន្ទ្រទេវី = Indra Devi

ព្រះនាងជាព្រះអគ្គមហេសីទី២នៃព្រះបាទជ័យវរ្ម័នទី៧ ។ ព្រះនាងជាអគ្គសាឧបត្ថម្ភខាងព្រះពុទ្ធសាសនា ។ ព្រះនាង[illegible]កសាងវប្បធម៌ អក្សរសាស្ត្រជាតិឲ្យបានចំរើនលូតលាស់ ក្នុងសតវត្សទី ១២ និង ១៣ នៃគ.ស. ដោយបានបង្កើត

(១) អត្ថបទនេះមានក្នុងក្រាំងពីរ វគ្គទី ៦១ (ទំព័រ ២៣១ ដល់ ២៣៨) ។

ទៀមានសាលាបាលីជាន់ខ្ពស់និងបង្កើត វង់ភ្លេង ជាដើម ។

ព្រះនាងឥន្ទ្រទេវីបាននិពន្ធសិលាចារឹក នៅប្រាសាទភិ-មានអាកាស សរសើរអំពីព្រះទ័យបរិសុទ្ធ មានភក្តីភាពរបស់ព្រះនាង ជយរាជទេវី Jaya Ràja Devī ជាព្រះរាជកនិដ្ឋានិងជាអគ្គមហេសីទី ១ របស់ព្រះបាទជ័យវរ្ម័នទី ៧ មុននាងចូលទីវង្គតទៅ ។

## សិលាចារឹកភិមានអាកាស (១)

### ក) ទីកន្លែង :–

សិលាចារឹកនេះមាន ២ គឺ ៖

– សិលាចារឹកធំ រកឃើញនៅខឿនខាងជើង នាជណ្តើរខាងកើត

– សិលាចារឹកតូច បែកនៅនាជ្រុងអគ្នេយ៍ប្រាសាទ ។

(១) មើលក្នុង Inscriptions du Cambodge, Tome II របស់លោក Coedès ទំព័រ ១៦១ ដល់ ១៨១ និងទំព័រ ១៨៦ ។

សិលាចារឹកភិមានអាកាស (សតវត្សទី ១២)





## ៖) លក្ខណៈ និងន័យទូទៅ .-

សិលាចារឹកនេះ ត្រូវបានលោក H. Marchal រកឃើញក្នុងឆ្នាំ ១៩១៦ សរសេរជាភាសាសំស្រ្កឹត (គេច្រើនស្គាល់ថា សិលាចារឹក តោធិព្រឹក្ស) ។

សិលាចារឹកធំនេះ ធ្វើពីថ្មកក់កំពស់ ១,៧០ម , ទទឹង ០,៤៧ម ។ តាមលក្ខណៈអក្សរ គឺប្រហែលជាឋិតក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ។ សិលាចារឹកនេះបែកជា ៧០ កាត តែលោក H. Marchal ផ្គុំបានល្អវិញ ។

សិលាចារឹកទាំងមូលនេះសរសេរជាសំស្រ្កឹត ។ ជ្រុង ៣ មានចំនួនមួយជ្រុងៗ ៥២ បន្ទាត់ ឯជ្រុងទី ៤ មាន ៤៤ បន្ទាត់ ។ បូករួមទាំងអស់មាន ១០២ វគ្គ ។

អត្ថបទនេះជាពាក្យគាព្យ ដែលមានព្រះនាងឥន្ទ្រទេវី ជាអ្នកនិពន្ធ ។ ព្រះនាងបានឡើងជាអគ្គមហេសីព្រះបាទជ័យវរ្ម័នទី៧ ក្រោយដែលព្រះកនិដ្ឋាបងនាមព្រះនាង ជយរាជទេវី សុគតទៅ ។ សិលាចារឹកនេះរៀបរាប់អំពីជីវប្រវត្តិផ្ទាល់ របស់

ព្រះនាងរាជក្សត្រី ព្រមទាំងកុសលកម្មសំខាន់ៗរបស់ព្រះនាង ដូចជាការទិញមាសពីលើប្រាសាទមួយ គប្រាសាទភិមានអាកាសនេះឯង ។

សិលាចារឹកនេះគ្មានបញ្ជាក់កាលបរិច្ឆេទទេ តែបើប្រមាណទៅ គឺកើតក្រោយពេលព្រះនាង ជ័យរាជទេវីសុគតទៅ ។ គេអាចបញ្ជាក់ថា ព្រះនាងជ័យរាជទេវីសុគតក្រោយការសម្ពោធប្រាសាទតាព្រហ្ម (គ.ស.១១៨៦) និងប្រាសាទព្រះខ័ន (គ.ស ១១៩១) ពីព្រោះក្នុងសេចក្តីនោះ មានបញ្ជាក់នូវឈ្មោះពីរ គឺ ជ័យរាជចូឡាមនី (វគ្គទី ៨២) និងជ័យស្រី (វគ្គទី ៨៣) ហើយដែលព្រះរាជក្សត្រី ជ័យរាជទេវី បានប្រារព្ធធ្វើនូវវត្ថុពីការនានា ។ ការរៀបចំសិលាចារឹកនេះ ប្រហែលក្នុងរយៈពេលចំនួនដប់ឆ្នាំខាងចុងសតវត្សទី ១២ នេះឯង ។

អត្ថបទចាប់ផ្តើមសរសើរ (ក្នុងវគ្គទី៣ ខាងដើម) អំពីត្រៃកាយ ព្រះពុទ្ធនិងលោកេស្វរៈ ។ ២៦ វគ្គបន្ទាប់ (ពី ៤ ដល់ ២៩) សរសើរអំពីព្រះបាទជ័យវរ្ម័ន ទី ៧ ។ ចាប់ពីវគ្គ

ទី៣០ ដល់ ៩៤ សរសើរអំពីព្រះនាងក្សត្រី ជ័យរាជទេវី ។

តាមរយៈវគ្គទី ៣១ ដល់ ៣៤ ដែលរៀបរាប់អំពីលំអនាង ជ័យរាជទេវី យើងឃើញខ្សែរាជវង្សរបស់ព្រះនាងក្សត្រី ឥន្ទ្រទេវី ដូចសង្ខេបតទៅ (វគ្គ ៣៣ ដល់ ៣៤) ។




ក្នុងវគ្គទី ៣៥ មានបញ្ជាក់អំពីនាមព្រះអយ្យកាខាងមាតា (តែរលប់បាត់នាមទៅ) ។ វគ្គទី ៣៦ និយាយពីបញ្ហាតាម ដែលជាមូលហេតុនាំឲ្យព្រះបាទជ័យវរ្ម័នយាងទៅប្រទេសចម្ប៉ា គឺ នគរវិជ័យ Vijaya (ហៅប៊ិញ ឌិញ Binh-Dinh) ។

នៅពេលដែលព្រះស្វាមីយាងបាត់ទៅ ព្រះនាងក្សត្រី ទិតទំរក្សានូវភក្តីភាពយ៉ាងខ្ជាប់ ។ ព្រះនាងកាន់ក្រិត្យវិន័យ តាមបែបសាសនាព្រាហ្មណ៍ រហូតដល់ពេលដែលព្រះកនិដ្ឋាប្អូន គឺព្រះនាង ឥន្ទ្រទេវី ណែនាំឲ្យត្រឡប់មកកាន់ពុទ្ធសាសនាវិញ (វគ្គទី ៥៩–៦០) ។ ព្រះនាងប្រារព្ធធ្វើពិធីបុណ្យបួនសួងចំពោះបរមរូបនៃព្រះស្វាមី (វគ្គទី ៦១ ដល់ ៦៤) ។

វគ្គតពីនេះមានលក្ខណៈខាងប្រវត្តិសាស្ត្រសំខាន់ណាស់ ដូចជារៀបរាប់ពីដំណើរយាងនិវត្តន៍យ៉ាងរហ័ស របស់ព្រះបាទជ័យវរ្ម័នដែលជ្រាបអំពីដំណឹងមិនស្រួលក្នុងប្រទេស ស្ដីពីរឿងប្រមាថចំពោះព្រះរាជាសោយរាជ្យ គឺព្រះបាទយសោវរ្ម័នទី ២ (វគ្គទី ៦៥), អំពីការចូលទីវង្គតនៃក្សត្រអង្គនេះ (វគ្គទី ៦៦) អំពីសេចក្ដីអំណត់របស់ព្រះបាទជ័យវរ្ម័ន និង ព្រះជាយាក្នុងពេលដែលជនក្បត់គ្រប់គ្រងប្រទេស (វគ្គទី ៦៦ ដល់ ៦៧), អំពីការរាយលុកនៃព្រះជ័យវរ្ម័នទី ៤ ជាស្ដេចចម្ប៉ា (វគ្គទី ៦៨) ហើយនិងអំពីមរណភាពនៃជនក្បត់ (វគ្គទី ៦៩) ។ នៅចុង

បញ្ចប់គឺជ័យជំនះរបស់ព្រះបាទជ័យវរ្ម័ន លើពួកចាម ព្រមទាំង ពិធីរាជាភិសេករបស់ព្រះអង្គ (វគ្គទី ៧០) ។ កាលបានជួប ព្រះស្វាមីហើយ ព្រះនាងឥន្ទ្រទេវី បានខិតខំធ្វើកុសលធម៌ និង បុណ្យទានយ៉ាងទូលាយ (វគ្គទី៧១ដល់៩៣)។ក្នុងកុសល-កម្មនេះ គេអាចរាប់បាននូវការសំដែងរឿងល្ខោន ដែលដកស្រង់ពីក្នុងជាតក (វគ្គទី ៧៣) ។ ការបង្កើតមន្ទីរសង្គ្រោះដែលប្រមូលផ្តុំនូវក្មេងស្រីអនាថា (វគ្គទី ៧៩ ដល់ ៨០), ការធ្វើអំ-ណោយទាន និង គ្រឿងបូជាសំខាន់ៗ ដល់វិហារក្នុងព្រះរាជា-ណាចក្រ (វគ្គទី ៨១ ដល់ ៩១), ព្រមទាំងបដិមារូបមួយចំនួននៃរាជវង្សព្រះនាងនិងមិត្តភក្តិខ្លះ (វគ្គទី ៩២ ដល់ ៩៣) ។

ក្រោយមរណភាពនៃរាជកនិដ្ឋាប្អូន (វគ្គទី ៩៤) ព្រះនាងឥន្ទ្រទេវីបានទទួលភារៈបង្ហាត់បង្រៀនវិជ្ជាខាងពុទ្ធសាស-នានៅក្នុងសាលាវត្ត (វគ្គទី ៩៨–៩៩) ។

គ) អត្ថបទ.

១– (១) ស្រីធម្មកាយំ ជនយ័ន្ត យ ឯកស

សំរេ្ដាត និម៌ាំណាគនុញ បពុ្ញា

(២) កំរន្ទា ធំមោកែ្យស សុគតា ទំសាម្បាត៌

សាធ្យន៌ គម៌ទេ្វ ជគទេកកាយំ ។

២– (៣) ជីនាយ សារត្យស្វរស្វ័រវ ទិរន

យថាថ៌... ទរត ប្រកវ៌្ត

(៤) ជគទ្វិតំ សង្ឃំ អរកទ្យមានសន៌

ត្រិកិន្ទ...ផ្លាត្នេន នមៈ

............................................(១)

X X

ទី ៧– បណ្ឌិតយោគី ស្វរបណ្ឌិត - Yogīsvarapandita

យោគីស្វរបណ្ឌិតនេះ ជាគ្រូរបស់ព្រះបាទសូរ្យវរ្ម័នទី ១

(គ.ស. ១០០២–១០៤៩) ។

យោគីនេះ បាននិពន្ធសិលាចារឹកនៅប្រាសាទតាកែវ

(១) មានតទៅដល់វគ្គទី ១០២ (ទំព័រ ១៦៤ ដល់ ១៧៣) ក្នុង Inscriptions du Cambodge, Tome II ។

(ខេត្តសៀមរាប) គឺនៅក្នុងគោបុរៈ – (Gopura) – ខាងក្រៅ ដែលសរសេរនៅមេទ្វារខាងត្បូង នៃទ្វារខាងក្នុង ទិសខាងកើត ។

X X

## ទី ៨– បណ្ឌិត សិវាចារ្យ– Çivācārya

បណ្ឌិតសិវាចារ្យ ជាអធិការត្រួតត្រាខាងសីលធម៌ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៥ (គ.ស. ៩៦៨–១០០២) និងព្រះបាទសូរ្យវរ្ម័នទី ១ (គ.ស. ១០០២–១០៤៩) ។ លោកបណ្ឌិតនេះបានតែងសិលាចារឹកជាភាសាសំស្ក្រឹតនៅប្រាសាទតាកែវដែរ គឺសិលាចារឹកនៅគោបុរៈ = Gopura ខាងក្នុង ។

## សិលាចារឹកប្រាសាទតាកែវ(១)

### ១– លក្ខណៈ និង ន័យទូទៅ.–

សិលាចារឹកប្រាសាទតាកែវ មានចំនួនទាំងអស់ ៧ ដែល

(១) មើល Inscriptions du Cambodge របស់ G. Coedés, Tone IV (ទំព័រ ១៥២ ដល់ ១៦០) ។

បិតនៅក្នុងគោបុរៈ = Copura សំរាប់ចូលពីរ នាទិសខាងកើតប្រាសាទ ។

– ស្នាដៃរបស់បណ្ឌិតយោគីស្វរៈ បិតនៅក្នុង គោបុរៈខាងក្រៅ ដែលសរសេរនៅមេទ្វារខាងត្បូង នៃទ្វារខាងក្នុងទិសខាងកើត ។ សិលាចារឹកនេះជាភាសាសំស្រ្កឹត មាន ៣៨ បន្ទាត់ ។ សិលាចារឹកនេះរៀបរាប់អំពីអំណោយរបស់យោគីស្វរៈបណ្ឌិតដែលធ្វើចំពោះវត្តនានា ដូចជាវត្តលិង្គបុរៈ, អន្ទ្វទន្ទេ, វត្តឯក, ចាម្បេស្វរៈ, កំពូត ទឹក, ជ័យក្សេត្រ នៅបាត់ដំបង, កុម្បូរិ, ច្បារវើរ, ហេមស្រឹង្គ និងនរេន្ទ្រគ្រាម ។

– ស្នាដៃរបស់បណ្ឌិត សិលាចារឹកជាភាសាសំស្រ្កឹតដែរ ។

២– អត្ថបទ.–

១– នម នម័ស សិវទិគ្យោ គុរុភ្យះ ទេវស្រី យោគីស្វរៈបណ្ឌិត សេវ្យាទយសិទ្ធរ អស ។

២– ដំឆ្នូន វ្រះ កម្រតេង អញ ស្រី យោគីស្វរបណ្ឌិត ស្រុក វ្រះ កំឡាក រី (៣) សប ព្រាធបុរៈ ត កម្រតេង ជគត

ន្គិបុរៈ មុខ វែស ម្ចាយ ព្រះ ត្រីស្វ (៤) ល លង្គោ ម្ចាយ ការ

ស្ថាបនា គិ ឥសាន ។ (១)

## សេចក្តីសង្កេត.–

ការលើកយកនាមអ្នកនិពន្ធ សិលាចារឹកចំនួន ៨ រូបមក ញាក់នេះ មិនមែនថា ក្នុងសម័យមហានគរយើងមានតែ ណ្ឌិតប៉ុណ្ណោះទេ ។ ការពិត សិលាចារឹកដែលមានចំនួនជិត ០០ កន្លែង ក្នុងសម័យសតវត្សទី ៩ ដល់ ១៤ នោះគឺត្រូវតែ មានអ្នកនិពន្ធប្រមាណប៉ុណ្ណោះដែរ ។ តែជាអកុសលបន្តិច ព្រោះអ្នកនិពន្ធពុំបានបញ្ជាក់នាមខ្លួនផង (បើមាន គឺត្រឹមព្រះ មហាក្សត្រដែលអត្ថបទសិលាចារឹកអួតសរសើរ និងថ្វាយព្រះ ពរ) ។ និងជាព្រះមហាក្សត្រដែលមានព្រះនាមក្នុងសិលាចា- រឹកជាអ្នកនិពន្ធ ឬម្ចាស់សិលាចារឹក នោះក៏ពុំមែនជាដាច់ខាតពី ព្រោះជាព្រះរាជទ្រង់គ្រាន់តែព្រះរាជបញ្ជាដល់អ្នកប្រាជ្ញ ឲ្យ តែង កត់ត្រាតែប៉ុណ្ណោះ ។

---

(១) មានតទៅដល់វគ្គទី ២៥ (ទំព័រ ១៥៣ ដល់ ១៥៤) ។

# លក្ខណៈ អក្ខបទសិលាចារឹក សម័យមហានគរ

## ១_អំពីអត្ថន័យ._

អក្ខបទសិលាចារឹកក្នុងសម័យមហានគរ គឺសុទ្ធតែជាកំណត់កត់ត្រា នូវហេតុការណ៍ក្នុងប្រទេស ក្នុងសង្គមជាតិ ពោលគឺការគ្រប់គ្រងប្រទេស ការទាក់ទងនានា ព្រមទាំងជីវភាព ជំនឿសំខាន់ ៗ របស់ព្រះមហាក្សត្រ ជាដើម (ជំនឿចំពោះព្រហ្មញ្ញសាសនា និងពុទ្ធសាសនា មហាយាន) ។

## ២_អំពីអក្ខរូប._

គេប្រើភាសាសំស្ក្រឹតជាភាគច្រើន ព្រមទាំងភាសាខ្មែរ (ខ្មែរ បុរាណ) សំរាប់កត់ត្រា តែងសិលាចារឹក ។

អក្ខបទសឹងតែទូទៅមាន

_ ផ្ដើមសេចក្ដី ដែលបញ្ជាក់នាមអ្នកនិពន្ធកត់ត្រា សករាជ (ច្រើនជាសកៈ គឺ មហាសករាជ) ឬការ

សរសើរគុណព្រះឥស្សូរ វិស្ណុ ព្រហ្ម ឬ ទេវតា ជាដើម,

- **តួសេចក្តី** និយាយពីបញ្ហាសំខាន់ៗ ដូចជាការគ្រប់គ្រងប្រទេស ជំនឿ ពិធីផ្សេងៗ ក្នុងសាសនា ការបូជាចំពោះវត្ត ឬបូកណដ្ឋានជាដើម,
- **សេចក្តីបញ្ចប់** : គេបញ្ចប់ដោយឧទ្ទិសសុំភាគផលកុសលបានមកពីការធ្វើកុសលនានា ឬ គេដាក់បណ្តាសារចំពោះនរណាដែលបំផ្លាញទេវបូជា ឬអាកមដ្ឋាន ៗ

## សេចក្តីសង្កេត.-

សិលាចារឹកតិចណាស់ ដែលមានបញ្ជាក់នាមអ្នកនិពន្ធ ព្រោះហេតុដែលគ្មានឈ្មោះនេះមកពី ៖

ទី ១- អ្នកនិពន្ធពុំបានដាក់ឈ្មោះ (ប្រហែលជាមាន ានៈតូចទាប) ដូច្នេះបើព្រះករុណាទ្រង់បញ្ជា នោះខ្ញុំពុំហ៊ាន ញ្ជាក់ឈ្មោះទេ គឺក្នុងគោលបំណងគោរពចំពោះព្រះកិត្តិយស នព្រះមហាក្សត្រជាទីគោរពរបស់ខ្ញុំ,

ទី ២– បើមានបញ្ហាកវីញ គឺអ្នកនិពន្ធមានឋានន្តរស័ក្តិ កើតឈ្មោះធំៗ ដូចជារាជគ្រូ ជារាជបុរោហិត ជាឧត្តមទីប្រឹក្សាផ្ទាល់ព្រះអង្គ ជារាជសុណាសារបស់ព្រះរាជា ឬជាព្រះមហេសី ដូចព្រះនាងឥន្ទ្រទេវីជាដើម ។

## ៣– អំពីអត្ថរស.–

តម្លៃសំខាន់ឋិតនៅលើសង្គមរស = Le social ពោលគឺការយកបញ្ហារបស់សង្គមជាគតិនិងអច្ឆរិយរស = le merveilleux ពោលគឺការរៀបរាប់ជំនឿចំពោះទេវទេវ: បដិមាករជាដើម មកនិយាយ ។

# អត្ថបទសិលាចារឹកនានា ក្នុងសម័យ ទី១, ទី២ និង ទី៣ នៃ អក្សរសាស្ត្រខ្មែរ

## សេចក្ដីសង្កេត.—

យើងបានបញ្ជាក់រួចមកហើយក្នុងមេរៀនទី ២, ទី ៣ និង ទី៤ ថាការដែលលើកយកអត្ថបទសិលាចារឹកខ្លះមកធ្វើជាឧទាហរណ៍នៃការសិក្សាតាមសម័យកាលនីមួយ ៗ នោះ មិនមែនបានសេចក្ដីថា ក្នុងសម័យកាលនីមួយ ៗ មានសិលាចារឹកតែបន្តិចបន្តួចប៉ុណ្ណោះទេ ៗ ការពិត ក្នុងសម័យទាំង ៣ នៃអក្សរសាស្ត្រខ្មែរ ដែលកត់ត្រាអត្ថបទលើផ្ទាំងថ្ម យើងមានសិលាចារឹករាប់ពុំអស់ទេ ៗ

តទៅនេះ ខ្ញុំស្រង់យកឈ្មោះសិលាចារឹកតាមសម័យមួយ ៗ មកបញ្ជាក់ សង្កេតជាគោលគំនិតដោយដកស្រង់អំពីសៀវភៅរបស់លោក G. Cœdès ឈ្មោះ Inscriptions du Cambodge ពីភាគ ១ ដល់ ៦ មកបញ្ជាក់ (ការប្រែឈ្មោះ

ខុសខ្លះ តាមកពីអក្សរសេរសេរជាឡាតាំង មានលក្ខណៈពិបាក ដោយហេតុថា យើងគ្មានឯកសារជាជាតិយើងផ្ទៀងផ្ទឹមឲ្យត្រូវ)ៗ

## ប្រភេទវិភាគ និង អត្ថបទតាឌា.–

១- អត្ថបទសម័យទី ១ (សតវត្សទី ១ ដល់ទី៦ នៃគ.ស.) (គ.ស. ១ ដល់ ៥៥០) –

១– សិលាចារឹក ភ្នំដា (ឆ្នាំ?)

២– សិលាចារឹកវត្តគោក (ជាវត្តមួយក្នុងស្រុកបាទី (តាកែវ) ប្រហែលក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ១);

៣– សិលាចារឹកនៅវត្តភូ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ១;

៤– សិលាចារឹកវត្តបាទី (ក្នុងប្រាសាទតាព្រហ្ម ខេត្តតាកែវ ពាក់កណ្ដាលដើមសតវត្សទី ៦)

៥– សិលាចារឹកសិរ្បោខ នៅតាគុបាចេង បែកនៅក្រោយ ខាងជើងទន្លេមេគង្គ នាប្រមាណជា ១០០ ម. នៅខាងត្បូងស្ទឹងសេសាន (ឆ្នាំ?) (១)

---

(១) អត្ថបទទី ១ ដល់ទី ៥ នេះមាននៅក្នុង Inscriptions du Cambodge របស់លោក G. Cœdès Tome 2.

៦– សិលាចារឹកក្នុងវត្តគគីទ្រេញ ក្នុងស្រុកបាភ្នំ (សតវត្សទី ៨ នៃគ.ស)(១)

## ២– អត្ថបទសម័យទី២ (សតវត្សទី ៦ ដល់ទី៩; គ.ស ៥៥០ ដល់ ៨០២) សម័យចេនឡា –

១– សិលាចារឹកភ្នំព្រះវិហារ (កំពង់ឆ្នាំង).គ.ស.៥៦១ ?) រជ្ជកាលព្រះបាទភវវរ្ម័នទី ១ ឬ ភវវរ្ម័នទី ២ ?

២– សិលាចារឹករបស់ព្រះបាទជ័យវរ្ម័នទី ១ (សតវត្សទី ៧) ដែលមាន

ក– សិលាចារឹកតាំងក្រាំង (ក្នុងខ័ណ្ឌជើងព្រៃ) ខេត្តកំពង់ចាម,

ខ– សិលាចារឹកទួលព្រះធាតុ ព្រៃវែង (ក្នុងខ័ណ្ឌកញ្ជ្រៀច) គ.ស. ៦៧៣ ។

៣– សិលាចារឹក ២ នៅភ្នំបាយ័ង្គ ក្នុងខេត្តតាកែវ គឺទី ១ ស.ស. ក្នុង គ.ស. ៦០៤ និង ៦២៤; និងទី ២ ក្នុងរជ្ជកាល

(១) នៅក្នុង Tome 5

ព្រះបាទ ឥន្ទ្រវរ្ម័ន[១]

៤– សិលាចារឹកជាន់ជុំ ជិតវត្តលើ ក្នុងស្រុកព្រាំង ខេត្តតាកែវ (គ.ស. ៦២០)

៥– សិលាចារឹកព្រះគុហាលួង នៅម៉ុ ខេត្តកំពត (គ.ស. ៦៧៤) សម័យព្រះបាទ ស្រីរុទ្រវរ្ម័ន (៥១៤–៥៤៥)

៦– សិលាចារឹកអង្គរបុរី (ក្នុងគ្រិស្តសតវត្សទី ៦–៧) (ប្រហែលក្នុង គ.ស. ៦១១)

៧– សិលាចារឹក ផ្កា ក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ (សតវត្សទី ៦–៧);

៨– សិលាចារឹកចំណោម ក្នុងស្រុកព្រៃក្របាស ខេត្តតាកែវ (សតវត្សទី ៧);

៩– សិលាចារឹកទួលអង្គ ក្នុងស្រុកបាទី (ឆ្នាំ?).

១០- សិលាចារឹកវត្តអង្គខ្នារ ក្នុងស្រុកបាទី ខេត្តតាកែវ ក្នុង

---

(១) អត្ថបទទី ១ ដល់ទី ៣ នេះមាននៅក្នុង Inscriptions du Cambodge របស់ G· Cœdès, Tome I·

...តវត្សទី ៧);

១– សិលាចារឹកទួលអង្គត្វោត ក្នុងស្រុកបាទី ខេត្តតាកែវ (គ.ស. ៦៨១);

២– សិលាចារឹកកំពង់ស្ពឺ (សតវត្សទី ៧);

៣– សិលាចារឹកស្វាយពល នៅភូមិស្វាយពល ក្នុងខេត្តព្រៃវែង (សតវត្សទី ៧);

៤– សិលាចារឹកនៅតាកែវ ឬ ហៅសិលាចារឹកព្រះបាទភវវរ្ម័នទី ២ (គ.ស. ៦៣៩)

៥– សិលាចារឹកនៅកំម្រះព្រៅ ក្នុងស្រុកកំស្រួច ខេត្តកំពង់-ស្ពឺ (សតវត្សទី ៧)

៦– សិលាចារឹកនៅថាញ់យៀង (ខេត្តតាយនិញ) កម្ពុជា-ក្រោម (ឆ្នាំ?)

៧– សិលា ារឹកប្រាសាទប្រាំល្វែង (គេឃើញនៅក្នុងវាលកក់ ក្នុងកម្ពុជាក្រោម, (សតវត្សទី ៧–៨)

៨ សិលាចារឹកសំបូរ (អន្លង់ប្រាង្គ) (គ.ស. ៦៩៣)

១៩– សិលាចារឹកសំបូរ (ត្រពាំងព្រៃ) (គ.ស. ៦៨៣)

២០– សិលាចារឹកល្បើកស្រុត (នៅប្រមាណជាជាង ៤០គ.ម. ពីក្រចេះ) (គ.ស. ៧៨១)

២១– សិលាចារឹកនៅលង្វែក (សរសេរទំនងជាអក្សរក្នុងសត-វត្សទី ៧)

២២– សិលាចារឹកវត្តដើមឯក នៅខាងត្បូងក្រុងភ្នំពេញ (សត-វត្សទី ៧)

២៣– សិលាចារឹកកូម៉ិកំរៀង (ក្នុងខេត្តកណ្តាល) គ.ស. ៦៨៩

២៤– សិលាចារឹកជ្រោយអំពិល (រកឃើញនៅលើភ្នំសុពណ៌-កាលី ចម្ងាយ ៤ គ.ម. នាត្រើយខាងស្តាំទន្លេមេគង្គ ក្នុងខេត្តស្ទឹងត្រែង (ដើមសតវត្សទី ៧)

២៥– សិលាចារឹកត្រពាំងធំ (ក្នុងខេត្តកំពត) (សតវត្សទី ៧)

២៦– សិលាចារឹកព្រៃមាន់ (ស្រុកត្រាំង, ខេត្តកំពត) (គ.ស. ៧២៦)

២៧– សិលាចារឹក ទួលគោកព្រះ ក្នុងឃុំកំពង់ឫស្សី ស្រុកព្រៃ

វែង (គ.ស. ៦៥៧)

៨– សិលាចារឹកត្រើបូលៈ នៅអណ្ដូងស្វាយ ក្នុងវត្តវិហារធំ ខេត្តកំពង់ចាម (ឆ្នាំ?)

៩– សិលាចារឹកបាសែត (ដំកល់នៅវត្តពោធិវាល ខេត្តបាត់ដំបង) (គ.ស. ៦៤៨–៦៥៧)

១០– សិលាចារឹកភូមិជ្រៃ ក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ (សកវត្សទី ៧)

១១– សិលាចារឹកទួលត្រមូង ក្នុងភូមិត្រាយត្រក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ (គ.ស. ៦៩៣)[១]

១២– សិលាចារឹកប្រាសាទតាកៀម (ឬតាគាំ) (គ.ស. ៧៩១)

១៣– សិលាចារឹកទួលកំណប់ ឋិតនៅខាងកើតខេត្តបាត់ដំបង (គ.ស. ៧០៤)

១៤– សិលាចារឹក វត្តប៉ោ ឬ អង្គប៉ោ ក្នុងរជ្ជកាលព្រះបាទ

(១) អត្ថបទទី ៤ ផល់ទី ៣១ នេះមាននៅក្នុង Inscriptions du Cambodge របស់ G. Cœdès, Tome II

ឥសានវរ្ម័នទី ១ (គ.ស. ៦៣៥)

៣៥– សិលាចារឹកក្តីអង្គ ក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង (គ.ស. ៦២៩)(១)

៣៦– សិលាចារឹកប្រាសាទ ព្រៃប្រាសាទ ក្នុងក្រុមល្វេស ឋិតចម្ងាយ ១៥០០ម៉ នាទិសអាគ្នេយ៍លវៃ ហើយនាទិសខាងឥសាន ព្រះគោ (គ.ស. ៧១៩)

៣៧– សិលាចារឹកប្រាសាទអូលោក (ឆ្នាំ?) ឋិតនៅប្រមាណជា ៣០០ម៉ ខាងលិចកំផែងប្រាសាទបាគង

៣៨– សិលាចារឹកបាពយណ៍ ខាងលិច (គ.ស. ៧១៣)(២)

៣៩– សិលាចារឹកវត្តព្រៃវែង ហៅសិលាចារឹក ស្វាយទោ ក្នុងខេត្តកណ្តាល ឋិតក្នុងភូមិស្វាយទោ (រជ្ជកាលព្រះបាទឥសានវរ្ម័ន) (គ.ស. ៦១០);

---

(១) អត្ថបទទី ៣២ ដល់ទី ៣៥ មាននៅក្នុង Inscriptions du Cambodge, របស់ G. Cœdès, Tome III.

(២) អត្ថបទទី ៣៦ ដល់ទី ៣៨ មាននៅក្នុង Inscriptions du Cambodge របស់ G- Cœdès, Tome IV.

៤០– សិលាចារឹកវត្តព្រៃវាល ក្នុងដំបន់បាភ្នំ ខ័ណ្ឌកំពង់ត្របែក (ខេត្តព្រៃវែង) (គ.ស. ៦៦៤)

៤១– សិលាចារឹកសោភាស ឬសោភារង្សី (ឆ្នាំ?) (គឺសម័យមុនអង្គរ)

៤២– សិលាចារឹក បាសែត រក្សាទុកនៅវត្តបទុមវតី (គ.ស. ៦៦៨ និង ៦៧៧)

៤៣– សិលាចារឹក វត្តបារាយណ៍ ក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ (គ.ស. ៦៧៦)

៤៤– សិលាចារឹក អ្នកតាតាំងកយ ក្នុងឃុំសណ្តែក ខ័ណ្ឌជើងព្រៃ ខេត្តកំពង់ចាម (សតវត្សទី ៧)

៤៥– សិលាចារឹក វត្តព្រះនិញាន ក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ (គ.ស. ៦៩៨)

៤៦– សិលាចារឹក ស្វាយសាច់ភ្នំ នៅវត្តបុស្សស្រុក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម (គ.ស. ៦៩៨)

៤៧– សិលាចារឹកប្រាសាទអ្នកបួស (គ.ស.៦៧៣និង៧៨០)

៤៨– សិលាចារឹក វត្តព្រៃចារឹក ក្នុងឃុំចាម ទ័ណ្ឌកំពង់ត្រ

បែក ខេត្តព្រៃវែង ក្នុងរជ្ជកាលព្រះបាទ ជ័យវរ្ម័នទី

(សតវត្សទី ៧)

៤៩– សិលាចារឹក វត្តថ្ងង បិតក្នុងខេត្តបូជុក ជិតភូមិគោក

ខាងត្បូងព្រែកជីកហាទៀង កម្ពុជាក្រោម (ឆ្នាំ ? )

៥០– សិលាចារឹក អង្គរបុរី (ឆ្នាំ )

៥១– សិលាចារឹក ព្រៃស្វា ក្នុងស្រុកបាទី (ឆ្នាំ ?)

៥២– សិលាចារឹក ភ្នំណោក បិតចម្ងាយ ៦ គ.ម. ខាង

កើត កំពត (ឆ្នាំ ?)

៥៣– សិលាចារឹក វត្តព្រះធាតុ បិតនៅត្រើយស្តាំ ព្រែកត្នោ

កណ្តាលស្ទឹង ខេត្តកំពង់ស្ពឺ (សតវត្សទី ៧ នៃគ.ស.

៥៤– សិលាចារឹក ព្រះធាតុខ្មាយវ៉ែន បិតនៅខាងត្បូងភូមិមៀ

(សតវត្សទី ៧)

៥៥– សិលាចារឹកប្រាសាទបេង ក្នុងដំបន់ភ្នំដែក (ឆ្នាំ ? )

៥៦– សិលាចារឹកប្រាសាទកំប៉ោង បិតចម្ងាយជាង ១ គ.

ពីប្រាសាទខ្នា (ឆ្នាំ ?)

៥៧- សិលាចារឹកក្ដីប្រុស (ពាក់កណ្ដាលសតវត្សរ៍ ទី ៧)

៥៨- សិលាចារឹកវត្តយាយទេព ក្នុងឃុំមោងរាវ ស្រុកក្បូង

ឃុំ ខេត្តកំពង់ចាម (ឆ្នាំ ?)

៥៩- សិលាចារឹកក្ដីព្រះលាន ឋិតក្នុងដំបន់ព្រៃទេព (ឆ្នាំ ?)

៦០- សិលាចារឹកវត្តពោធិ៍ពេង ក្នុងខេត្តតាកែវ (សតវត្សរ៍ទី ៧)

៦១- សិលាចារឹកតាលោ ទំណប់ទន្លាប់ ខេត្តតាកែវ (សត-

វត្សរ៍ទី ៧)

៦២- សិលាចារឹក ក្ដូមពេល ក្នុងតំបន់ក្ដីស្រួច ខេត្តកំពង់ស្ពឺ

(សតវត្សរ៍ទី ៧)

៦៣- សិលាចារឹកតពេល ក្នុងខេត្តតាកែវ (សតវត្សរ៍ទី ៧)

៦៣- សិលាចារឹក ខ្វាវ ក្នុងស្រុកបាទី ខេត្តតាកែវ (ឆ្នាំ ?)

៦៥- សិលាចារឹក ព្រះពុទ្ធវត្តឈ្មះ ស្រុកព្រៃក្របាស់ (ឆ្នាំ ?)

៦៦- សិលាចារឹក វត្តអង្គបែងចក ខេត្តកណ្ដាល (ឆ្នាំ ?)

៦៧- សិលាចារឹកវត្តអង្គពិសី (ឆ្នាំ ?) ក្នុងស្រុកគងពិសី

៦៨– សិលាចារឹក ប្រាសាទអង្គព្រះធាតុ ឃុំលាំងចក ខេត្ត
កំពង់ស្ពឺ (ឆ្នាំ ?)

៦៩– សិលាចារឹក វត្តអង្គព្រះពាយ នៅថ្ពល់ទទឹង (ឆ្នាំ ?)

៧០– សិលាចារឹក វត្តអង្គស្រី ស្រុកសំរោងទង (ឆ្នាំ ?)

៧១– សិលាចារឹកទួលមោង នៅថ្ពល់ទទឹង (ឆ្នាំ ?)

៧២– សិលាចារឹកអ្នកតាត្រស់ នៅថ្ពល់ទទឹង (ឆ្នាំ ?)

៧៣ - សិលាចារឹក ប្រាសាទពាំងរមាស (ដំបន់ និង ឆ្នាំ?)

៧៤– សិលាចារឹក ប្រាសាទឃ្លាំង ដំបន់ជីក្រែង បិតចម្ងាយ
៣០០ម៉ែត្រ ខាងជើងផ្លូវទៅកំពង់ធំទៅសៀមរាប (ឆ្នាំ?

៧៥– សិលាចារឹកទួលអង្គ រលាំងកែន ក្នុងស្រុកកណ្ដាល
ស្ទឹង ខេត្តកណ្ដាល (ឆ្នាំ?)

៧៦– សិលាចារឹក ព្រះពុទ្ធរូបនៃត្រពាំងវែង ក្នុងភូមិញីទៀ
ខេត្តត្រាយិញ (កម្ពុជាក្រោម) (ឆ្នាំ ?)

៧៧– សិលាចារឹក អ្នកតាស្វាយដពា ក្នុងស្រុកថ្ពល់ទទឹ
ខេត្តកណ្ដាល (ឆ្នាំ ?)

៨– សិលាចារឹកមេបុណ្យខាងលិច (ឆ្នាំ ?)

៩– សិលាចារឹកប្រាសាទ ភូមិប្រាសាទ ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ (គ.ស. ៧០៦)

០– សិលាចារឹក នៅនឹងសសបុកណង្គាន ហ៊ុនខាន ចម្ងាយប្រមាណជា ៤០ គ.ម. ខាងត្បូងក្ហ៊ក ក្នុងស្រុកប៉ាក ចុងមាយ (នៅដែនសៀម) (គ.ស. ៦៧៤ និង ៧០០)

៨១– សិលាចារឹកកាកោះ នៅវត្តធា ក្នុងភូមិកាកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ (សតវត្សទី ៨ នៃគ.ស.)

៨២– សិលាចារឹក ពោធិកា នៅក្នុងកំផែងមឿងរដ្ឋៈសីមា ការ បុរីដនក្ហ៊ក (ស្រុកសៀម សតវត្សទី ៧ នៃគ.ស)

៨៣– សិលាចារឹក ប្រាសាទតុកពង្រ នាខាងជើងអង្គរធំ (គ.ស. ៧៣៣)

៨៤– សិលាចារឹកប្រាសាទអំពិលរលំ (ឆ្នាំ ?) (ប្រមាណជា ក្នុង គ.ស. ៩០៨-៩១៧) នេះចំពោះផ្នែកវគ្គទី ១៦

៨៥– សិលាចារឹកទួលប្រាសាទ (រំដួល) សតវត្សទី៦នៃគ.ស.

៨៦– សិលាចារឹកកូមិតរ ក្នុងភូមិតាម ខាងឥសាន ស្រុកត្បូងឃ្មុំ (ខ្មុំ ?) (១)

៨៧– សិលាចារឹកហាន់ជ័យ ក្រើយខាងស្តាំទន្លេមេគង្គ (គ.ស. ៦៦៤-៦៦៧)

៨៨– សិលាចារឹក ពញាហោរ ក្នុងស្រុកត្រាំង ខេត្តតាកែវ (សតវត្សទី ៦) រជ្ជកាលព្រះបាទភវវរ្ម័ន

៨៩– សិលាចារឹក ភ្នំបន្ទាយនាង ឋិតនៅចម្ងាយ ៤គ.ម ខាងត្បូងអង្គរបុរី (តាកែវ) សតវត្សទី ៦

៩០– សិលាចារឹក វាលកន្តួល ក្នុងខេត្តសៀម ឈ្មោះទន្លេ ពៅ (សតវត្សទី ៦)

៩១– សិលាចារឹក បាយ័ង្គ ក្នុងខេត្តត្រាំង(តាកែវ)គ.ស.៦០៤ និង ៦២៤

៩២– សិលាចារឹក វត្តចក្រេត ក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង

---

(១) អត្ថបទទី ៣៩ ដល់ ទី ៨៦ មាននៅក្នុង Inscriptions du Cambodge, របស់លោក G. Coedès, Tome VI

(គ.ស. ៦៤៦)

៩៣– សិលាចារឹក ស្វាយចេ្ម គង់វត្តព្រៃវែង ជិតកំពេញ (សតវត្សទី ៦ នៃគ.ស.)

៩៤– សិលាចារឹក អង្គពៅ គង់ស្រុកត្រាំង ខេត្តតាកែវ (សត-វត្សទី ៦)

៩៥– សិលាចារឹក អង្គជំនឹក (ឬ វត្តគីអង្គ) នៅភូមិតាទ្រង ស្រុកកោះ ខេត្តបាភ្នំ ព្រៃវែង (គ.ស. ៦៤៨)

៩៦– សិលាចារឹក វត្តព្រៃវៀរ ស្រុកបាភ្នំ ព្រៃវែង(គ.ស ៦៦៤)

៩៧– សិលាចារឹក អង្គជំនឹក (គ.ស ៦៦៧) (ទី២)

៩៨– សិលាចារឹក វត្តព្រៃវៀរ (គ.ស. ៦៦៧) (ទី២)

៩៩– សិលាចារឹក បាពយណ៍ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ (គ.ស. ៦៧៦)(២)

១០០– សិលាចារឹក កុហ្កពៅ នៅស្រុកគងពិសី កំពង់ស្ពឺ

---

(១) អត្ថបទទី៨៣ដល់ទី៩៩ មានក្នុង Inscriptions sanskrites du Cambodge, របស់ M. Barth

(សតវត្សទី ៦)

១០១– សិលាចារឹក វត្ត ភូ (ទី១ ប្រហែលសរសេរក្នុងសម័យមុនអង្គរ; ទី២ សម័យព្រះបាទសូរ្យវរ្ម័នទី១ គ.ស១០០២-១០៤៩ និងទី ៣ សម័យព្រះបាទសូរ្យវរ្ម័ន ទី ២ គ.ស. ១១១២-១១៦២)

១០៣– សិលាចារឹក ធម្មលេខ បិតនៅក្នុងរូងភ្នំ ចម្ងាយ ១គ.ម ៥០០ នាខាងជើងវត្តភូ (សម័យមុនអង្គរ)

១០៣– សិលាចារឹក វត្តវិហារ ថ្រាំង ក្នុងស្រុកកណ្ដាលស្ទឹង (ឆ្នាំ ?)

១០៤– សិលាចារឹក នៅមេបញ្ជរទ្វារប្រាសាទតូច បិតចម្ងាយ ៣០០ម ខាងលិចឆៀងខាងជើងប្រាសាទព្រះស្រី ក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង (គ.ស.៦២០)

១០៥– សិលាចារឹក ថ្មក្រែ ក្នុងភូមិចំបក់មាស ឃុំសំបុក ខេត្តក្រចេះ (ឆ្នាំ ?)...ទី ១ ក្នុងឆ្នាំ ៦២៤ - ទី២ មិនច្បាស់; នាមអ្នកតែង គឺស្រី សង្ក្រះនារាយណៈ;

០៦– សិលាចារឹកនៅតំបន់ អាវញ្ញ គឺ ៖

ទី១– នៅ ខៅណូយ ក្នុងគ.ស. ៦៣៧

ទី២– នៅ ខៅកឹង ក្នុងគ.ស. ៦៣៩

០៧– សិលាចារឹកគុកព្រះគោជ ក្នុងខណ្ឌ ជើងព្រៃ ខេត្ត កំពង់ចាម (គ.ស. ៧៦១)

០៨– សិលាចារឹកគោករកា (រជ្ជកាលព្រះបាទឥសានវរ្ម័ន ទី ១ សតវត្សទី ៦ (ស្រុកគោគ្នាទឹងសំបូរព្រៃគុក) ក្នុង ខេត្តកំពង់ធំ

០៩– សិលាចារឹកត្រាំសសរ ខណ្ឌ បាទី ខេត្តតាកែវ (សតវត្សទី៧)

១០– សិលាចារឹក ព្រះធាតុព្រះស្រី បឹកនៅត្រើយពាយ័ព ទិសព្រះពិត ខណ្ឌត្បូងឃ្មុំ ខេត្តកំពង់ចាម (គ.ស.៧៧០)

១១– សិលាចារឹក ភូហ៊ុយ បានមកពីវត្តចាយតាលោ ក្នុង ភូមិ ភូហ៊ុយ ខេត្តផ្សាដែក កម្ពុជាក្រោម (គ.ស.៦៣៩)

១២– សិលាចារឹក ទួលអង្គព្រះធាតុ ស្រុកថ្មល់ខទឹង ខេត្ត

កណ្តាល (គ.ស. ៦៥១)

១១៣– សិលាចារឹក ប្រាសាទព្រះធាតុ នៅខាងកើតបឹងព្រះពិត រវាង គ.ស. ៦៤៨ និង ៦៥៧

១១៤– សិលាចារឹក វត្តគិរីវង្ស ខណ្ឌក្រឡាច ខេត្តតាកែវ (គ.ស. ៦៧០)

១១៥– សិលាចារឹក ស្រែអំបិល ស្រុកកៀនស្វាយ (គ.ស. ៦៧០)

១១៦– សិលាចារឹក ប្រាសាទព្រៃថ្លាល (ខាងត្បូង) ក្នុងស្រុកពួក ត្រើយខាងឆ្វេងស្ទឹងបានជិតភូមិខ្ទុង (គ.ស. ៦៨០)

១១៧– សិលាចារឹក ប្រាសាទនាងខ្មៅ (គ.ស ៦៧៨ ទៅ ៦៨៧)

១១៨– សិលាចារឹក សាលាស្រុករំដួល (គ.ស. ៦៤០-៦៨៧)

១១៩– សិលាចារឹក ទួលតាមនៅ អង្គរបូរី តាកែវ (ឆ្នាំ? )

១២០– សិលាចារឹក ប្រាសាទអកយ (គ.ស ៧០៤)

១២១– សិលាចារឹកវត្តបាពាយណ៍ ក្នុងខេត្តតាកែវ (ឆ្នាំ? )

១៦២–សិលាចារឹក បាដើម រក្សាទុកនៅវត្ត គគិញាកម ខេត្តស្ទឹងត្រែង បានមកពីជាតុបាដើម (សតវត្សទី ៧)

១៦៣– សិលាចារឹកប្រាសាទព្រៃគុក ឋិតចម្ងាយ ១៨ គ.ម នាខាងនិរតីម្លូព្រៃ (សតវត្សទី ៧)

១៦៤– សិលាចារឹកគោករកា នៅទួលប្រហារ ខេត្តកំពង់ធំ (សតវត្សទី ៧ ឬ ទី៨ នៃគ.ស)

១៦៥– សិលាចារឹក សំបួរ ក្នុងភូមិសំបួរ ខេត្តកណ្ដាល (ឆ្នាំ?)

១៦៦– សិលាចារឹក គេឃើញដោយឧកញ៉ា យោមកាជ ដឹឡូ-ប៉ែស (សតវត្សទី ៧) គេឃើញក្នុង ខែធ្នូ ឆ្នាំ ១៩៥២

១៦៧–សិលាចារឹក ទួលអ្នកតា បាក់ក ឃុំជក្កោរ ស្រុកក្ដុំពេញ ខេត្តកណ្ដាល (ឆ្នាំ ?)

១៦៨– សិលាចារឹក តាំងក្រាំង (សតវត្សទី ៧)

១៦៩– សិលាចារឹក ត្រពាំងថ្ម (សំបួរ) (សតវត្សទី ៨)

១៧០– សិលាចារឹក D56 នៅសារមន្ទីរភ្នំពេញ គ.ស៧៨១[១]

---

(១) អត្ថបទទី ១០ ដល់ទី ១៣០ នេះមាននៅក្នុង Inscriptions du Cambodge របស់លោក G. Cœdès, Tome5.

១៣១– សិលាចារឹក បន្ទាយព្រៃនគរ (ឆ្នាំ ?)

១៣២– សិលាចារឹក គុកព្រះកាជ័ កុនស្រុកជើងព្រៃ (គ.ស
៧៦១)

១៣៣– សិលាចារឹក វត្តស្អាង ស្រុកជើងព្រៃ (សតវត្សទី ៨)

១៣៤– សិលាចារឹក វត្តបាណក ស្រុកបាភ្នំយណ៍ (ឆ្នាំ ?)

១៣៥– សិលាចារឹក ព្រះធាតុ ព្រៃជើងស្រុក ឃុំចំងចា
ស្រុកស៊ីធរកណ្តាល (គ.ស. ៦៣៣)

១៣៦– សិលាចារឹក ទួលវត្តចាស់ ស្រុកលើផ្ទៃក (ឆ្នាំ ?)

១៣៧– សិលាចារឹក ព្រះពុទ្ធ ទួលព្រះធាតុ នៅរលាំងចក
ខេត្តកំពង់ស្ពឺ (ឆ្នាំ ?)

១៣៨– សិលាចារឹក នៅអង្គកម្រាល វត្តសំរោង ភូមិជុំផុក
ស្រុកបាភ្នំ ខេត្តព្រៃវែង (សតវត្សទី ៨)

១៣៩– សិលាចារឹក ខារស្រងែង (នៅការញ្ញ) (ឆ្នាំ ?)

១៤០– សិលាចារឹក នៅសារមន្ទីរជាតិ ក្រុងបាងកក (សតវត្ស
ទី ៦) រជ្ជកាលព្រះបាទ ភវវរ្ម័នទី ១

១៤១– សិលាចារឹក វត្តស៊ីថាតប្រាម័ញ្ញ នៅភូមិចម្បី ខេត្ត ឧដុង ស្រុកសៀម (ឆ្នាំ ?)

១៤២– សិលាចារឹក នៅខេត្តខុនកែន ស្រុកសៀម (ឆ្នាំ ?)

១៤៣– សិលាចារឹក នៅនឹងព្រះពុទ្ធរូប១អង្គនៅសារមន្ទីរនៅ កូក៉ត អង្គរាជ ស្រុកសៀម (ឆ្នាំ?)[១]

## អត្ថបទសម័យទី៣– សតវត្សទី ៩ ដល់ ១៤ (គ.ស. ៨០២–១៤៣២)

## សម័យមហានគរ

១– សិលាចារឹក នៅព្រះគោ (រជ្ជកាលព្រះបាទ ឥន្ទ្រវរ្ម័ន គ.ស. ៨៧៧)

២– សិលាចារឹក នៅបាគង (គ.ស. ៨៨១)

៣– សិលាចារឹក របស់បណ្ឌិត សិវសោម (នៅមេបញ្ញវែន បង្អួចប្រាសាទ កណ្ដាលដើម ខាងជើងចម្ងាយ ៣០០ម

(២) អត្ថបទទី ១៣១ ដល់ទី ១៤៣ មាននៅក្នុង Inscriptions du Cambodge របស់ G. Cœdès, Tome VII

ទៅខាងលិចកំផែង(ក្រៅប្រាសាទព្រះគោ) រវាង គ.ស.
៨៧៨ និង ៨៨៧

៤– សិលាចារឹក កោះកែរ (នៅប្រាសាទធំ) គ.ស. ៩២១

៥– សិលាចារឹក ប្រាសាទប្រែរូប (គ.ស. ៩៦១)

៦– សិលាចារឹក ៤ នៅប្រាសាទបន្ទាយស្រី (គ.ស. ៩៦៩)

៧– សិលាចារឹក ប្រាសាទកំភឹស (ក្នុងឃុំយាង) មុំព្រៃ បិតនៅ
ចម្ងាយ ១៦ គ.ម. ខាងត្បូងកំសន្ទុក ចម្ងាយ ២៥ គ.ម. ពី
កោះកែរ(ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៥ គ.ស. ៩៧៤)

៨– សិលាចារឹក ស្វាយប្រាំ (មុំល្វស) ក្នុងតម្បន់ ហរិហក-
ល័យ គ.ស. ៩៦៩

៩– សិលាចារឹក របស់ជ័យវីរៈវរ្ម័ននៅព្រះគោ គ.ស. ១០០៥

១០– សិលាចារឹក ប្រាសាទខ្នា (មុំព្រៃ) គ.ស. ១០៤១

១១– សិលាចារឹក ប្រាសាទស្រឡៅ (ក្នុងស្រុកពួក ត្រើយខាង
ត្បូងស្ទឹង ចម្ងាយ ៤ គ.ម. ខាងអាគ្នេយ៍ស្វាយចេក) ក្នុង
រជ្ជកាលព្រះបាទហសិវរ្ម័នទី ៣ គ.ស. ១០៦៥

១២– សិលាចារឹក នៅប្រាសាទទេវ ក្នុងតម្បន់វត្តកូ (គ.ស. ១១៨៩ ឬ ១១៩៥ រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧(១)

១៣– សិលាចារឹក នៅទួលមាស (ក្នុងគ្រិស្តសតវត្សប្រមាណទី ១១)

១៤– សិលាចារឹក ភ្នំជីសូរ (គ.ស. ១០១៩)

១៥– សិលាចារឹក ប្រាសាទនាងខ្មៅ ក្នុងស្រុកបាទី ខេត្តតាកែវ (ពាក់កណ្ដាលសតវត្សទី ៩)

១៦– សិលាចារឹក ដីក្រែង (គឺរកឃើញនៅចន្លោះប្រាសាទដីក្រែងខាងលិច និងប្រាសាទដីក្រែងខាងកើត) គ.ស. ៩៧០

១៧– សិលាចារឹក នៅបាសាក់ (រំដួល) ក្នុងស្រុករំដួល ក្នុងខេត្តស្វាយរៀង (ពាក់កណ្ដាលសតវត្សទី ១០)

១៨– សិលាចារឹក នៅកំពង់ធំ (គ.ស. ៩៧៤)

---

(១) អត្ថបទទី ១ ដល់ទី ១២ មាននៅក្នុង Inscriptions du Cambodge របស់ G. Cœdès, Tome I

១៩– សិលាចារឹក នៅហ៊ួថាម៉ូ ក្នុងខេត្តចាក់សេ ស្រុកលាវ របស់ព្រះបាទយសោវរ្ម័ន (គ.ស. ៨៨៩–៩០៨)

២០– សិលាចារឹក នៅថាបលឹក វៀន ក្នុងខេត្ត កំដយ៉ា កម្ពុជាក្រោម (គ.ស. ៨៩២)

២១– សិលាចារឹក សំបូរ (តាកឹង) គ.ស. ១០០១

២២– សិលាចារឹក សំបូរ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ (គ.ស. ១២០៤)

២៣– សិលាចារឹក កោះរកា នៅប្រមាណ ១២ គ.ម. ខាងត្បូងកំពង់ធំ (ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧)

២៤– សិលាចារឹក ទួលប្រាសាទ ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ (គ.ស. ១០០៣)

២៥– សិលាចារឹក វត្តគ្រៅឡើងកែង ស្រុកលង្វែក (សរសេរសម័យព្រះបាទយសោវរ្ម័ន គ.ស. ៨៨៩–៩០៨)

២៦– សិលាចារឹក គុកត្រពាំងស្រុក ក្នុងស្រុកជើងព្រៃ ខេត្តកំពង់ចាម (គ.ស. ១០០២)

២៧– សិលាចារឹក ភ្នំជីសូរ (គ.ស. ១១១៦)

២៨– សិលាចារឹក ប៉ាលហាល ឋិតនៅចម្ងាយ ៤០ គ.ម. ខាងត្បូងស្វាយជួនកៅ ស្រុកមោងឫស្សី ខេត្តបាត់ដំបង (គ.ស. ១០៦៩)

២៩– សិលាចារឹក បន្ទាយក្តី (សតវត្សទី ៩)

៣០– សិលាចារឹក ភិមានអាកាស (ក្នុងសម័យព្រះនាងជ័យរាជទេវីជាអគ្គមហេសីនៃព្រះបាទជ័យវរ្ម័នទី៧) គ.ស. ១១៨១

៣១– សិលាចារឹក ព្រះពិធូ នៅអង្គរធំ (សតវត្សទី ៩)

៣២- សិលាចារឹក បាយ័ន នៅជ្រុងឥសាន ថែវខាងក្រៅ (ដើមសតវត្សទី ១៤)

៣៣– សិលាចារឹក ភ្នំបន្ទាយនាង ឋិតចម្ងាយ ៣ គ.ម. ខាងអាគ្នេយ៍ មង្គលបុរី ខេត្តបាត់ដំបង (គ.ស. ៩៨២)(១)

៣៤– សិលាចារឹក នៅវត្តបាសែត ឋិតនៅចម្ងាយ ១៤ គ.ម.

---

(១) អត្ថបទទី ១៣ ដល់ ៣៣ នេះមាននៅក្នុង Inscriptions du Cambodge របស់ G. Coedès, Tome II ។

**នាភ្នំតាសាន** ខេត្តបាត់ដំបង (គ.ស. ១០៣៦) (ក្នុ
រជ្ជកាលព្រះបាទ សូរ្យវរ្ម័នទី ១)

៣៥– សិលាចារឹក ប្រាសាទភាកែពង (រជ្ជកាលព្រះបាទជ័យ
វរ្ម័នទី ៧)

៣៦– សិលាចារឹក វត្តឯក ឋិតនៅចម្ងាយ ៨ គ.ម. ខាង
ជើងបាត់ដំបង (ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១) គ
ស. ១០៣៧

៣៧– សិលាចារឹក ភាសេន ឋិតនៅចម្ងាយ ២០ គ.ម. ខាង
លិចបាត់ដំបង (រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១) (គ.ស
១០២៧)

៣៨– សិលាចារឹក នៅភ្នំព្រះនេត្រព្រះ ឋិតនៅជាប់ខ្លោះមង្គល
បុរី និង ក្រឡាញ់ (គ.ស. ៨៤៩ និង គ.ស. ១០០៥ ទេ
១០០៧)

៣៩– សិលាចារឹក ប្រាសាទសន្ទះ ឋិតនៅចម្ងាយ ៩ គ.ម. ខ
ខាងពាយ័ព្យស្រុកក្រឡាញ់ (គ.ស. ១០០២)

០– សិលាចារឹកបន្ទាយប្រាវ ឋិតនៅចម្ងាយ ៧ គ.ម. នាខាងពាយ័ព ស្រុកស្វាយចេក (គ.ស. ១០០២)

១– សិលាចារឹក ប្រាសាទតាសៀវ ឋិតក្នុងស្រុកស្វាយចេក (ស៊ីសុផុន) ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន (គ.ស. ៨៨៩–៩០៨)

២– សិលាចារឹក ថ្មពួក ក្នុងស្រុកស្វាយចេក សរសើរពីព្រះបាទជ័យវរ្ម័នទី ៥ (គ.ស. ៩៦៨)

៣– សិលាចារឹកបន្ទាយឆ្មារក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧

៤– សិលាចារឹក ភ្នំគង្វា (គ.ស. ៩៦៧)

៥– សិលាចារឹកប្រាសាទតាអង ឋិតនៅចម្ងាយ ៦ គ.ម. ខាងជើងស្រុកក្រឡាញ់ (ពាក់កណ្ដាលសតវត្សទី ១០)

៦– សិលាចារឹក គោក[illegible]កើង ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន គ.ស ៩៦១

៧– សិលាចារឹក ប្រាសាទក្រឡាញ់ ឋិតនៅចម្ងាយ ៨០០ម នាខាងត្បូងនៃវត្តមួយក្នុងភូមិក្រឡាញ់ (សរសេរក្នុងសត-

វគ្គទី ១០ ឬ ១១)

៤៨– សិលាចារឹក ប្រាសាទតាកែវធំ (គ.ស. ១០៦០ និ
១០៦៤)

៤៩– សិលាចារឹក ប្រាសាទក្រោល ក្នុងរជ្ជកាលព្រះបាទធរ
ណីន្ទ្រវរ្ម័នទី ១ (គ.ស. ១១០៩)

៥០– សិលាចារឹក ដំណាក់ស្តេច ក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័ន
(នៅចុងសតវត្សទី ៩)

៥១– សិលាចារឹក ប្រាសាទស្ពានយុន (គ.ស. ៩៤២)

៥២– សិលាចារឹក វត្តធិបតី បែកនៅចម្ងាយប្រមាណ ១៥ គ.ម.
ខាងជើងភូមិពួក (គ.ស. ៩១០) (រជ្ជកាលព្រះបាទ
ឥសានវរ្ម័នទី ២)

៥៣– សិលាចារឹក ភូមិដំដែង បែកនៅចម្ងាយ ៥ គ.ម. នាខាង
អគ្នេយ៍ ខេត្តបាត់ដំបង (រជ្ជកាលព្រះបាទ យសោវរ្ម័ន
គ.ស. ៨៨៩–៩០៨)

៥៤– សិលាចារឹក ប្រាសាទខ្ទុម បែកនៅចម្ងាយ ៥ គ.ម. នា

ខាងជើងស្វាយលេក (អក្សរក្នុងសតវត្សទី ១១ រជ្ជ-
កាលព្រះបាទជ័យវរ្ម័នទី ៤ គ.ស. ៩២. – ៩៤២ និង
ព្រះបាទសូរ្យវរ្ម័នទី ១ គ.ស. ១០០២–១០៥០)

៥៥– សិលាចារឹក ប្រាសាទលិច ឋិតនៅចម្ងាយ ៣០០ម. ខា
ងទិសអគ្នេយ៍ ភូមិមោង ស្រុកក្រឡាញ់ (គ.ស.១២០៦)

៥៦– សិលាចារឹក ព្រះភ្នំ ឋិតនៅតំបន់ប្រាសាទ លិច (គ.ស.
៩៣០)

៥៧– សិលាចារឹក ប្រាសាទបាសែត ក្នុងបុរាណដ្ឋានស្រី ជយ
ក្សេត្រ: ក្នុងរជ្ជកាលព្រះបាទឧទយាទិត្យវរ្ម័នទី ២ (គ.
ស. ១០៤៩–១០៦៦)

៥៨– សិលាចារឹក ប្រាសាទស្ទង់ ឋិតនៅខាងទីតើ ខេត្តបាត់
ដំបង (សតវត្សទី ១២)

៥៩– សិលាចារឹក ភ្នំសង្កបាន ឋិតនៅខាងទិសពាយ័ពខេត្ត
បាត់ដំបង (គ.ស. ៩៩២)

៦០– សិលាចារឹក ភ្នំអក្សរ ឋិតនៅខាងជើងស្រុកពួក រជ្ជកាល

ព្រះបាទសូរ្យវរ្ម័នទី ២ (គ.ស. ១១១៨)

៦១- សិលាចារឹក ភ្នំជីសូរ (គ.ស. ១០១៩ និង គ.ស.១១១៦)

៦២- សិលាចារឹក ព្រះលាន នៅគោកធំ (គ.ស. ១០០២ ឬ
១០០៣)

៦៣- សិលាចារឹក វត្តសសរមួយរយ នៅសម្បូរ (ខេត្តក្រចេះ)
(គ.ស. ៨០៣)

៦៤- សិលាចារឹក ភូមិដា ឋិតនៅទិសពាយ័ព្យ ដំបន់សំរោង-
សែន ខេត្តកំពង់ធំ (គ.ស ១០៥៤)

៦៥- សិលាចារឹក ត្រពាំងជូនអូន ឋិតនៅទិសពាយ័ព្យអង្គរធំ
នាចម្ងាយ ៥ គ.ម. ទិសពាយ័ពស្រុកប្រាសាទគោកប៉ោ
(គ.ស. ១០៥១)

៦៦- សិលាចារឹក បាយ័ន (សតវត្សទី ១៣)

៦៧- សិលាចារឹក កំមានអាកាស (ដើមសតវត្សទី ១០-ប្រ-
មាណជា ក្នុងគ.ស.៩១០)

៦៨- សិលាចារឹក ប្រាសាទឃ្នាំង (ដើមសតវត្សទី ១១)

៦៩- សិលាចារឹក អង្គរធំ (គ្រិស្តសតវត្សទី ១៤ ឬ ១៥)

៧០- សិលាចារឹក ទេពប្រណម្យ (គ.ស. ១០០៥ ឬ ១០១៥)(១)

៧១- សិលាចារឹក សំបូរ ព្រៃគុក (សតវត្សទី ១០ នៃគ.ស.)

៧២- សិលាចារឹក បាគង (រជ្ជកាលព្រះបាទឥន្ទ្រវរ្ម័ន គ.ស. ៨៧៧-៨៨៩)

៧៣- សិលាចារឹក ប្រាសាទស្រណៃ បែកចម្ងាយប្រមាណពី ២ ទៅ ៣០០ មុ ខាងកើតកំផែងក្រៅព្រះគោ គ.ស. ៨៨៣-៩៧៨ (រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៥)

៧៤- សិលាចារឹក ប្រាសាទក្កៃ ក្នុងក្រុមរលួស នាខាងលិចប្រាសាទអូរលោក (សតវត្សទី ៩ នៃគ.ស.)

៧៥- សិលាចារឹក ប្រាសាទព្រៃក្មេង បែកទៅខាងលិចបា-រាយណ៍ខាងលិច (គ.ស. ៨៦០ រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៣ និង គ.ស. ៨៩៥ រជ្ជកាលព្រះបាទយសោវរ្ម័ន)

---

(១) អត្ថបទទី ៣៤ ដល់ទី ៧០ នេះមាននៅក្នុង Inscriptions du Cambodge របស់ G. Cœdès, Tome III

៧៦– សិលាចារឹក ប្រាសាទគោកពង្រ ឋិតនៅផ្នែកខាងជើង
អង្គរធំ (រជ្ជកាលព្រះបាទយសោវរ្ម័ន)

៧៧– សិលាចារឹក ប្រាសាទក្រវ៉ាន់ (គ.ស. ៩២១)

៧៨– សិលាចារឹក ប្រាសាទនាគ ខាងលិចទ្វារចូល ខាងលិច
អង្គរធំ (គ.ស. ៩២៣)

៧៩– សិលាចារឹក ប្រាសាទហៃផ្កា ឋិតនៅ ១០ គ.ម. ខាងលិច
រលួស និងនា ៦ គ.ម. ៥០០ ខាងនិរតី ក្រុងសៀមរាប
(គ.ស. ៨៨៩)

៨០– សិលាចារឹក បក្សីចាំក្រុង (រជ្ជកាលព្រះបាទយសោវរ្ម័ន

៨១– សិលាចារឹក ប្រាសាទលាក់នាង ឋិតនៅទិសឥសានជិត
ប្រែរូប (គ.ស. ៩៦០)

៨២– សិលាចារឹក ភ្នំបាខែង (សតវត្សទី ១០ នៃគ.ស.)

៨៣– សិលាចារឹក វត្តព្រះឥន្ទ្រកោសីយ ឋិតនៅនាត្រើយ
ខាងកើតស្ទឹងសៀមរាប (គ.ស. ៩៦៨)

៨៤– សិលាចារឹក ប្រាសាទបារ ឋិតនៅចម្ងាយ ៤ គ.ម. ខ

ទិសឥសាន ក្រុមប្រាសាទគោកពោ៉ រជ្ជកាលព្រះបាទ ជ័យវរ្ម័នទី ៥ (គ.ស. ៩៧៩)

៨៥– សិលាចារឹក គល់ប្រាសាទកយរង នៃប្រាសាទត្រពាំងរពៅ ឋិតនាខាងត្បូងបារាយណ៍ខាងលិច (គ.ស.១០០២)

៨៦– សិលាចារឹក ប្រាសាទតាកែវ (រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១ គ.ស. ១០០២–១០៤៩) ដ៏មានអ្នកនិពន្ធឈ្មោះ យោគី ស្វរបណ្ឌិត នៃប្រទេសវរ្ក កំពូត ។

៨៧– សិលាចារឹក វត្តដំណាក់ (ខេត្តសៀមរាប) បានមកពីប្រាសាទមួយក្នុងដំបន់អង្គរ (រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១) (គ.ស. ១០០២–១០៤៩)

៨៨– សិលាចារឹក ប្រាសាទបក ឋិតនៅចម្ងាយ ២ គ.ម. ៧០០ នាខាងពាយ័ព ក្រុងសៀមរាប (រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ៣ គ.ស. ៨៥០)

៨៩– សិលាចារឹក គោកអូរជ្រឹង ឋិតនៅចម្ងាយ ៣ គ.ម. ៧០០ ខាងត្បូងក្រុងសៀមរាប និង ៨០០ម៉ ខាងកើតស្ទឹង

(គ.ស. ៩២២-១០៩៤)

៩០– សិលាចារឹក សំរោង ឋិតនៅខាងកើតប្រាសាទបារ និង ចម្ងាយជាង ១ គ.ម. ទិសនិរតីអង្គរធំ (គ.ស. ១០៩៤)

៩១– សិលាចារឹក ប្រាសាទផ្ទូស ឋិតនៅចន្លោះក្រុងសៀម-រាប និងបាគង (រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ គ.ស. ១១៦២–១២០១)

៩២– សិលាចារឹក ប្រាសាទជ្រុងអង្គរធំ (រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ គ.ស. ១១៦២–១២០១)(១)

៩៣– សិលាចារឹកវត្តត្រឡែងកែង ដំបន់លង្វែក (ក្នុងរជ្ជកាលព្រះបាទយសោវរ្ម័ន គ.ស. ៨៨៩–៩០៨)

៩៤– សិលាចារឹក គោកច័ននៅក្នុងខ្ទមអ្នកតាមួយនៃភូមិគោកច័ន ចម្ងាយជាង ១០ គ.ម. ខាងកើតរលួស (សតវត្សទី ១០ នៃ គ.ស.)

---

(១) អត្ថបទទី ៣១ ដល់ទី ៩២ មាននៅក្នុង Inscriptions du Cambodge របស់ G. Cœdès, Tome IV.

៩៥– សិលាចារឹក ភ្នំសន្ធុក ខាងខាងពាយ័ពៈកោះកែរ (ដើម សតវត្សទី ៩)

៩៦– សិលាចារឹក ក្រាំងស្វាយ ក្នុងខេត្តបាភ្នំ ចម្ងាយប៉ុន្មាន គីឡូម៉ែត្រខាងឥសានក្ដីអង្គជំនីក (គ.ស. ៩១៨)

៩៧– សិលាចារឹក ទួលប៊ី (នៅដំបន់កំពង់ចិន ឋិតនាត្រើយ ស្ទឹង ស្ទោង ខេត្តកំពង់ធំ) គ.ស. ៩២២

៩៨– សិលាចារឹក ពានភូតស ឋិតក្នុងវត្តតាវ៉ានគោកក្នុងភូមិ ពានភូតស ចម្ងាយប្រមាណជាជាង ១០ គ.ម. ខាងជើង ភូក៏ក (សតវត្សទី ១០ នៃ គ.ស.)

៩៩– សិលាចារឹក នៅមេប ញ្ញវែនបង្ហួចជើងអគ្គរ ឋិតនៅ ខាងឥសាន បន្ទាយព្រៃនគរ ក្នុងខណ្ឌត្បូងឃ្មុំ ខេត្តកំពង់ចាម (គ.ស. ៨៦២)

១០០– សិលាចារឹកប្រាសាទបេងវែង ក្នុងដំបន់ព្រំខេត ខេត្តកំពង់ធំ (សតវត្សទី ១០នៃគ.ស.) ប្រមាណក្នុង (គ.ស. ៩៤០)

១០១– សិលាចារឹក ប្រាសាទអន្ទង់ចារ ចម្ងាយប្រមាណ ២ គ.ម. នាខាងលិចទួលបន្ទាយចក្រី ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (គ.ស. ៩៤៩)

១០២– សិលាចារឹក ទឹកជុំ ជិតនៅត្រើយស្ទឹងសែន ? (គ.ស. ៩៤៩)

១០៣– សិលាចារឹក ក្ដីចារ នាខាងជើងកំពង់ធំ (គ.ស.៩៤១)

១០៤– សិលាចារឹក ភ្នំសន្ទុក (គ.ស. ៩៥៦)

១០៥– សិលាចារឹក មេបុណ្យនៃទ្វារក្ដី ឬ ទ្វារប្រាំបី (ខាងជើង ក្នុង គ.ស. ៩៥២) ហើយខាងត្បូងក្នុង គ.ស: ៩៥៧

១០៦– សិលាចារឹក អ្នកតាចារឹក ក្នុងតំបន់កោះកែរ នាខាងឥសានភ្នំក្រូច ខាងត្បូងភ្នំត្បែង (គ.ស. ៩៦២)

១០៧– សិលាចារឹក ត្រពាំងសំពោត ក្នុងស្រុកក្រាំង (គ.ស. ៩៦៤)

១០៨– សិលាចារឹក ជួនទ្រី ជិតនៅចម្ងាយប្រមាណ ១០ គ.ម. នាខាងឥសានមោង ខេត្តបាត់ដំបង (គ.ស. ៩៦៦)

១០៩– សិលាចារឹក នៅមេនៃទ្វារក្នុងដំបន់ព្រៃជុំ ក្នុងស្រុកត្បូងឃ្មុំ (សតវត្សទី ១០ នៃគ.ស.)

១១០– សិលាចារឹក មេបុណ្យខាងកើត (ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស. ៩៤៤–៩៦៨)

១១១– សិលាចារឹក សុរិន្ទ (នៅស្រុកសៀម) រជ្ជកាលព្រះបាទជ័យវរ្ម័នទី ៥ (គ.ស.៩៦៨-១០០២)

១១២– សិលាចារឹក ប្រាសាទអ្នកបួស (សតវត្សទី ១០ រជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន គ.ស. ៩៤៤-៩៦៨)

១១៣– សិលាចារឹក ប្រាសាទប្រាប់ទិស (គ.ស. ៩៦៩)

១១៤– សិលាចារឹក នៅទឹងបងមាស៊ឹងមោង (គ.ស.៩៧០)

១១៥– សិលាចារឹក ប្រាសាទដីក្រែងខាងកើត (គ.ស.៩៧២)

១១៦– សិលាចារឹក ទួលដងខ្ពស់ ក្នុងស្រុកស៊ីសុផុន ខេត្តបាត់ដំបង (គ.ស. ៩៧៤)

១១៧– សិលាចារឹក គោកប្រសៀ ឬអ្នកតាបាក់ក នៅខាងកើតកំគូលេខ (គ.ស ៩៧៤)

១១៨– សិលាចារឹក នៅមេបញ្ជរ នៃប្រាសាទថ្នល់ស្វាយ
ខាងជើង (បែកចម្ងាយ១២គ.ម នាខាងជើងឆៀងឥសាន
ស្រុកជាំខ្សាន្ត (គ.ស. ៩៧៩)

១១៩– សិលាចារឹក នៅមេបញ្ជរនៃប្រាសាទភូមិមៀន
ក្នុងដំបន់ព្រះធាតុព្រះស្រី ខាងត្បូងបឹងព្រះពិត (គ.ស.
៩០២ ឬ ៩១២)

១២០– សិលាចារឹក ប្រាសាទថ្នល់ឈូក បែកប្រមាណ ៩ គ.ម
នាអាគ្នេយ៍ . ជាំខ្សាន្ត (គ.ស. ១០០៦)

១២១– សិលាចារឹក ភ្នំម្រេច បែកនៅចាន្ទោះកោះកែរ ទិសព្រះ
ទ័ន ក្នុងស្រុកកំពង់ស្វាយ កំពង់ធំ (គ.ស. ៩៩៤)

១២២– សិលាចារឹក វត្តស៊ីធរ (វត្តស្រីស៊ីធរ) (ក្នុងខេត្តកំពង់-
ចាម) គ.ស. ៩៦៨

១២៣– សិលាចារឹក ប្រាសាទបេងខាងជើង ក្នុងដំបន់ដីក្រែង
ខេត្តកំពង់ធំ (សតវត្សទី ១០ នៃគ.ស)

១២៤– សិលាចារឹក ភ្នំក្រពាស ចម្ងាយ ៣០ គ.ម នាទិស

ពាយព្យ ព្រះវិហារ (សតវត្សទី ១០ ឬ ១១)

១២៥– សិលាចារឹក ប្រាសាទបារម៉ី តំបន់បាក់ប្រា ទីណាពាម សោមា ផ្នែកពាយព្យទន្លេសាប (មុនសតវត្សទី ១០ ឬ ដើម សតវត្សទី ១១ នៃគ.ស)

១២៦– សិលាចារឹក ប្រាសាទត្នោតជុំ ស្រុកបាកាយណ៍ (រជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន គ.ស. ៩៥២)

១២៧– សិលាចារឹក ប្រាសាទដំបូកខ្ពស់ ប្រមាណ ៨គ.ម ខាងទិសឥសាន គូលេន (គ.ស. ១០០៥)

១២៨– សិលាចារឹកបន្ទាយប្រាវ (គ.ស. ១០០២ ឬ ១០១២)

១២៩– សិលាចារឹក កំពែងកោន ឋិតនៅជិតភូមិលៀកអំពិល ក្នុងស្រុកសៀម នាខាងលិចបន្ទាយឆ្មារ និងខាងត្បូង ប្រកដើមគាគា (គ.ស. ១០០៧)

១៣០– សិលាចារឹក ប្រាសាទទ័ពសៀម ឋិតក្នុងដែនដីសៀម ចម្ងាយប៉ុន្មានគ.ម នាខាងជើងស្តុកកក់ធំ (សតវត្សទី១១ នៃគ.ស)

– សិលាចារឹក ប្រាសាទអ្នកបួស (ទាសតវត្សរ៍ទី ១១
គ.ស. ១០១៥ របស់ព្រះបាទសូរ្យវរ្ម័នទី ១)

៣២– សិលាចារឹក វត្តគណ្ដាល បាត់ដំបង (ចន្លោះ គ.ស. ១០១៨ និង ១០២៧)

១៣៣– សិលាចារឹក ប្រាសាទបេង ឬ ហៅប្រាសាទព្រៃបិទមាស នៅភ្នំស្រុក ស្រុកស៊ីសុផុន បាត់ដំបង (គ.ស. ១០២៦)

១៣៤-សិលាចារឹកភ្នំសន្ទុកព្រះបាទសូរ្យវរ្ម័នទី១(គ.ស១០៤១)

១៣៥– សិលាចារឹក កំពែងវៀង ជាប្រាសាទមួយបិតប្រមាណជា ២០ គ.ម. ខាងទិសឧត្តរ ស៊ីសាកេត (គ.ស ១០៤២)

១៣៦– សិលាចារឹក ព្រះវិហារ (គ.ស. ១០៤៧)

១៣៧– សិលាចារឹក អ្នកតាជិះគោ (រជ្ជកាល ព្រះបាទសូរ្យវរ្ម័នទី១)

១៣៨– សិលាចារឹក បាសាក់ (រំដួល) ក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស ៩៤៤-៩៦៨)

១៣៩-- សិលាចារឹក គុំកញ្ចន់ ក្នុងស្រុកក្បែងឃុំ ខេត្តកំពង់ចាម
(សតវត្សទី១១ នៃគ.ស)

១៤០– សិលាចារឹក កុអកម ជាប្រាសាទបុរាណមួយឋិតនៅ
ចម្ងាយប្រមាណជា ១០គ.ម នាខាងទិសឥសានសុវណ្ណ-
ភូមិ (សតវត្សទី ១១ នៃគ.ស)

១៤១– សិលាចារឹក ខោនឡាខោន (វត្តឈាំ) (ក្នុងដីសៀម)
គ.ស. ១០២៦)

១៤២– សិលាចារឹក លង្វែក (គេយកទុកនៅវត្តបទុមវតី) (ឆ្នាំ?)

១៤៣– សិលាចារឹកវត្តបាសិត (នៅកាលព្រះបាទសូរ្យវរ្ម័នទី១)

១៤៤– សិលាចារឹក នៅមេបញ្ជរទ្វារនៃប្រាសាទ ព្រះកេត្រ
នាអគ្នេយ៍ស្ពានទេព មាត់ស្ទឹងស្រែង (គ.ស ១០៦៦)

១៤៥– សិលាចារឹក នោមវ៉ាន ឋិតនៅនាប្រាសាទមួយចម្ងាយ
ប្រមាណ១០គ.ម ទិសឥសានកូ៉ក ស្រុកសៀម (គ.ស
១០៥៨)

១៤៦– សិលាចារឹក ភ្នំសន្ទុក សតវត្សទី ២ (គ.ស ១១០៧)

១៤៧–សិលាចារឹកវត្តស្វាគែត ខេត្តបាត់ដំបង (គ.ស១១៣៨ ឬ ១១៤៥)

១៤៨– សិលាចារឹក ភ្នំបន្ទាយនាង (រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១)

១៤៩–សិលាចារឹក នោនគុ នាខាងលិចប្រាសាទប្រាំ ស្រុក ត្វារ កំពង់ស្វាយ កំពង់ធំ (ឆ្នាំ ?)

១៥០– សិលាចារឹក ប្រាសាទប្រាប់ទិស នៅជីក្រែង កំពង់ធំ សតវត្សទី ១២ ឬទី ១៣

១៥១– សិលាចារឹក ស្រង់ នាខាងលិចវត្តពេជ គងពិសី (សតវត្សទី ១៣)

១៥២– សិលាចារឹក វត្តក្តីទេ ខេត្តសៀមរាប (ឆ្នាំ ?)

១៥៣– សិលាចារឹក វត្តព្រះកែវនៅបាងកក (គ.ស ១៣១៦)

១៥៤– សិលាចារឹក ព្រះគន្ធកោសីយ ក្នុងខេត្តសៀមរាប (១)

---

(១) អត្ថបទទី ៩៣ ដល់ ១៥៣ មាននៅក្នុង Inscriptions du Cambodge, G· Cœdés, Tome 2·, M. Barth

(គ.ស. ៩៦៨ និង ៩៧០)

១៥៥– សិលាចារឹក ព្រះកែវ ក្នុងស្រុកសៀម (គ.ស ១០០២-៨០៧ និង ១០០៧)

១៥៦– សិលាចារឹក ព្រះគោក នៅបាយ័ន អង្គរធំ (គ.ស. ៨០២-១០៥១ និង ១០៦៦)

១៥៧– សិលាចារឹក ប្រាសាទព្រះកៀក្រ . នាប្រាសាទបិត ខាងអាគ្នេយ៍ស្ពានចិត (នៅស្រុកសៀម) គ.ស. ១០៦៦ និង ១០៦៧ (១)

១៥៨– សិលាចារឹក វត្តភូ (រជ្ឈកាលព្រះបាទសូរ្យវរ្ម័នទី ១ និង ទី ២ មើលផ្នែកសិលាចារឹកសម័យទី ២ លេខ ១០១)

១៥៩– សិលាចារឹក វត្តស្រែវែង ក្នុងភូមិខ្ញា ស្រុកចាញ់ តាំ ដែនត្រើគុង ខេត្តបូជុក កម្ពុជាក្រោម (រជ្ឈកាលព្រះបាទរាជេន្ទ្រវរ្ម័ន គ.ស ៩៤៤-៩៦៨)

១៦០– សិលាចារឹក នៅ Musée de Brest (គ.ស. ៨៧៧)

---

(១) អត្ថបទទី ១៥៤ ដល់ ១៥៧ មាននៅក្នុង Inscriptions sanskrites du Cambodge, M. Barth

១៦១– សិលាចារឹក ប្រាសាទគុកប្រាសាក ខាងត្បូងភ្ន
ផិតមង្គលបូរី (គ.ស. ៨៩៦)

១៦២– សិលាចារឹក ប្រាសាទសសរស្តម្ភ នៅស្រុកពួក ខេ
សៀមរាប (រជ្ជកាលព្រះបាទយសោវរ្ម័ន) (គ.ស
៨៨៩-៩០៨)

១៦៣– សិលាចារឹក ទួលអង្គតា នៅភូមិកន្ទោក ខ័ណ្ឌពោ
ចិនតុង ស្រុកភ្នំពេញ (គ.ស. ៩៣៤)

១៦៤– សិលាចារឹក ប្រាសាទបឹងវៀន ក្នុងឃុំដំដែក ស្រុ
សូទ្រនិគម (រលួស) ខេត្តសៀមរាប គ.ស. ៩៤៤

១៦៥– សិលាចារឹក ភ្នំទ្រព្យ ខ័ណ្ឌជើងព្រៃ ខេត្តកំពង់ចាម
(គ.ស. ៩៥៣-៩៦០ និង ៩៦២)

១៦៦– សិលាចារឹក ប្រាសាទតាសេ់ នៅខាងខាងត្បូងប្រា
សាទ អ្នកបួស ចម្ងាយ ៧គ.ម ខាងកើតជាំខ្សន្ត
(គ.ស. ៩៥៤)

១៦៧– សិលាចារឹក ទួលតាប៉ែន ឃុំជាំដែក ខ័ណ្ឌក្រវែក

វិទ្រតៃព្រវ៉ន (គ.ស. ៨៩៦)

១៦៨-- សិលាចារឹក នៅមេបញ្ជាទ្វារវត្តក្តីស្មារ ក្នុងស្រុកកំពង់ ក្របែក វិទ្រតៃព្រវ៉ន (រជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន (គ.ស. ៩៤៤-៩៦៨)

១៦៩- សិលាចារឹក គុកសាវ៉គត នៅខាងត្បូងបាកយណ៍ ខាងលិចចម្ងាយប្រមាណ ១០ គ.ម. គឺខាងលិចជៀង ខាងពាយ័ព្យ ក្រុងសៀមរាប (សតវត្សទី១០)

១៧០- សិលាចារឹក ប្រាសាទកន្ទោប ក្នុងដំបន់ជាំក្សាន្ត នា ខាងត្បូងប្រាសាទតារស់ ចម្ងាយ ១៨០០ម. នាខាង. ជើងប្រាសាទចុល់ស្វាយ (សតវត្សទី ១០)

១៧១- សិលាចារឹក អូរដុល ចម្ងាយ ៨គ.ម ខាងនិរតីភូមិ កន្ទួត.ម្ចៃព្រ (គ.ស. ៩៦៨)

១៧២-- សិលាចារឹក ទួលគល ក្នុងស្រុកមោង នាខាងត្បូង ទន្លេសាប (គ.ស. ៩៦៨)

១៧៣– សិលាចារឹក ប្រាសាទក្ដុមពោធិ៍ ក្នុងឃុំដំដែក ស្រ

សូត្រនិគម (រលួស) គ.ស. ៩៦០-៩៦៦ និង ៩៦

១៧៤– សិលាចារឹក ប្រាសាទគោក (ខាងត្បូង) ក្នុងស្រ

សូត្រនិគម (រលួស) គ.ស. ៩៨៣

១៧៥– សិលាចារឹក ប្រាសាទផ្កាំង ឋិតនៅក្រោយខាងជ

ស្ទឹងផ្កាំង (នៅអង្គរក្នុងស្រុក គ.ស. ៩៨៨)

១៧៦- សិលាចារឹក D ៧៩ នៅសារមន្ទីរភ្នំពេញ (គ.ស ៩៩៣

១៧៧– សិលាចារឹក ប្រាសាទតុកប្រាសាទ នៅស្វាយចេ

(គ.ស. ៩៩៤)

១៧៨– សិលាចារឹក ប្រាសាទគោក ចម្ងាយប្រមាណ ១៥គ ម

ខាងកើតរលួស (ឆ្នាំ ?)

១៧៩– សិលាចារឹក ព្រះធាតុព្រះស្រី (ឆ្នាំ ?)

១៨០– សិលាចារឹក តុកអង្កាញ់ ក្នុងឃុំឆាឈូក ស្រុកពួក

សៀមរាប (សតវត្សទី ១០)

១៨១ - សិលាចារឹក នៅសារមន្ទីរ ស្រុកព្រៃនគរ មិនស្គាល់

ប្រកព (សតវត្សទី ១០)

១៨២– សិលាចារឹក វត្តមហា នៅខាងនិរតីសំបូរព្រៃគុក (សតវត្សទី ១០)

១៨៣– សិលាចារឹក ដំបន់ខ្ពស់នៃស៊ីងស្រេង (ប្រាសាទរៀន និងកុក) សតវត្សទី ១០ ឬ ១១

១៨៤– សិលាចារឹក ព្រៃយាង ក្នុងឃុំព្រៃជ្រូក ស្រុកពួក សៀមរាប (សតវត្សទី ១០ ឬ ១១)

១៨៥– សិលាចារឹក គោកជួង នៅល្វេស (គ.ស ១០០២)

១៨៦– សិលាចារឹក ពាំងមាស នៅខាងជើងសំបូរព្រៃគុក សតវត្សទី ១០ គ.ស. ១០០១

១៨៧– សិលាចារឹក ប្រាសាទត្រពាំងរុន នៅកំពង់ស្វាយ (គ.ស.១០០២ ឬ ១០១២)

១៨៨– សិលាចារឹក ប្រាសាទអំពិល នៅស្រុកជីក្រែង សៀម-រាប (គ.ស. ៩២៣)

១៨៩– សិលាចារឹក ស្ទឹងត្រាប ខណ្ឌមោង ខេត្តបាត់ដំបង

(គ.ស. ១០០៣)

១៩០– សិលាចារឹក ប្រាសាទត្រពាំងស្នោរ ឋិតនៅចំកណ្ដាល ផ្លូវវាង ភូមិទឹកលិច និងត្រពាំងថ្មដាច នាខាងពាយព័ បឹងមាលា (គ.ស. ១០០៣)

១៩១– សិលាចារឹក វត្តភូ (គ.ស. ១០០៦)

១៩២– សិលាចារឹក ប្រាសាទព្រះគោ (កំពង់ស្វាយ) រលួស គ.ស ១០០៣ ឬ ១០១៣)

១៩៣– សិលាចារឹក វត្តព្រះធាតុ នៅទឹកឆា ខ័ណ្ឌកំពង់សៀម ខេត្តកំពង់ចាម (គ.ស. ១០២៥)

១៩៤– សិលាចារឹក គុកព្រីងជ្រុំ ទំព្នា ផើងព្រៃ ខេត្តកំពង់ចាម (គ.ស. ១០២៨)

១៩៥– សិលាចារឹក ប្រាសាទស្នែង (អាងកើត) (ឋិតចម្ងាយ ៨គ.ម ខាងលិចបាណន់ ខេត្តបាត់ដំបង (គ.ស១០៤០)

១៩៦– សិលាចារឹក អ្នកតាជះគោ នៅត្រើយស្ដាំស្ទឹងស្រែង (រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១ គ.ស ១០០២-១០៤៩)

១៩៧- សិលាចារឹក ទួលតាពេជ ក្នុងខេត្តកំពង់ធំ ចម្ងាយ ៧ ឬ ៨គ.ម ពីភូមិបារាយណ៍ ស្រុកបារាយណ៍ (សតវត្សទី១១)

១៩៨- សិលាចារឹក ធម្មោ នៅភូមិម៉ុគី ខេត្តតាន់កាន កម្ពុជាក្រោម (រជ្ជកាលព្រះបាទឧទយាទិត្យវរ្ម័ន គ.ស១០៤៩ ១០៧៩)

១៩៩- សិលាចារឹក ថាប់មួយ នៅខេត្តផ្សារដែក កម្ពុជាក្រោម (សតវត្សទី ១១)

២០០- សិលាចារឹក វត្តគីរីរាំងចាស់ ខ័ណ្ឌកំពង់ត្របែក ខេត្តព្រៃវែង (សតវត្សទី ១១)

២០១- សិលាចារឹក ពង់តេងកង នៅភ្នំគូលេន (គ.ស. ១០៧៤) របស់បណ្ឌិតសិវសោម ។

២០២- សិលាចារឹក ភ្នំដា ដំបន់អង្គរបុរី (គ.ស. ១០៧២- ១១០៦)

២០៣- សិលាចារឹក គុកយាយហោម នៅវត្តសន្ទែ ស្រុកព្រៃឈរ ខេត្តកំពង់ចាម (សតវត្សទី ១១)

២០៤– សិលាចារឹកវត្តភូ ឬរបស់ព្រះបាទសូរ្យវរ្ម័នទី២ (គ.ស
១១១៣)

២០៥– សិលាចារឹក ភ្នំរុង ចំងាយ ៩០ គ.ម. ខាងកើ
នៅនឹងប្រាសាទ គូកែ (ស្រុកសៀមរាប) គ.ស. ប្រមាណ
១១១២–១១៦២ (ផ្ចុកាលព្រះបាទសូរ្យវរ្ម័នទី ២)

២០៦– សិលាចារឹក វត្តស្នាគូ ខាងកើតឧត្តុង្គ ស្រុកពញា
ខេត្តកណ្តាល (សតវត្សទី ១១)

២០៧– សិលាចារឹក ភ្នំស្រួច នៅភ្នំតូលេខ (សតវត្សទី ១២)

២០៨– សិលាចារឹក ពុទ្ធសាសនា នៅអង្គរធំរបស់ព្រះបា
ស្រីឥន្ទ្រវរ្ម័ន (គ.ស. ១២៩៥–១៣០៧)

២០៩– សិលាចារឹក គុម្ពស្វាយ ឃុំសរសេរស្តុក ស្រុកពួក ខេ
សៀមរាប (ឆ្នាំ?)(១)

២១០– សិលាចារឹក បាក់បែកនៅក្ដីអង្គ ឬ អង្គជំនិក ស្រុកបា

(១) អត្ថបទទី ១៥៧ និងទី ២០៩ នេះមាននៅក្នុង Inscriptions du
Cambodge របស់លោក G. Cœdès, Tome5.

(គ.ស.៩៦៦)

២១១- សិលាចារឹក ព្រះវិហារគុក (ឬវត្តចក្រេក)(គ.ស.៩១២)

២១២- សិលាចារឹក ក្រឡាញ់ធំ ស្រុកសុីធរស្ដាំ ឬពាក់ កណ្ដាលសតវត្សទី ១០

២១៣- សិលាចារឹក វត្តភ្លៅ ស្រុកសុីធរកណ្ដាល (ពាក់កណ្ដាល សតវត្សទី ១០)

២១៤- សិលាចារឹក ព្រែកក្រពៅ ស្រុកកំពង់សៀម (គ.ស. ៩៨១)

២១៥- សិលាចារឹក ព្រះធន់ ស្រុកជើងព្រៃ (គ.ស.១០០៣ ឬ ១១០៣)

២១៦- សិលាចារឹក ប្រាសាទកំបុត ស្រុកបាភ្នំ (គ.ស. ១៣០៧-១៣២៧)

២១៧- សិលាចារឹក ព្រះធាតុខ្នារ ស្រុកកំពង់ស្វាយ (សតវត្សទី ១៤)

២១៨- សិលាចារឹក នៅមេបញ្ជរទ្វារបាណន់ ក្នុងខេត្តបាត់ដំ-

បន៍ (រជ្ជកាលព្រះបាទភវេន្ទ្រវរ្ម័ន គ.ស. ៩៤៤-៩៦៨

២១៩– សិលាចារឹក ប្រាសាទស្ទួន នាខាងលិចបាណន់ ខេត្ត បាត់ដំបង (សតវត្សទី ១០)

២២០– សិលាចារឹក ទឹកជោ ក្នុងភូមិទឹកឈូ ខេត្តបាត់ដំបង (សតវត្សទី ៩)

២២១– សិលាចារឹក នៅមេបញ្ជរនៃទ្វារប្រាសាទលោះ ស្រុក ស៊ីសុផុន (គ.ស. ១០៤៩)

២២២– សិលាចារឹក ប្រាសាទតាសៀវ ក្នុងស្រុកស៊ីសុផុន (គ.ស. ១០១១)

២២៣– សិលាចារឹក វត្តខ្នាត ? (គ.ស. ៩៥២)

២២៤– សិលាចារឹក បានខោមោឃ នៅវត្តសុបតី ឧបុន (ស្រុក សៀម) រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី ១ (សតវត្ស ទី ១១)

២២៥– សិលាចារឹក តាមាន់ធំ ក្នុងខេត្តសុរិន្ទ ស្រុកសៀម (ចុងពាក់កណ្ដាលសតវត្សទី ១០)

២២៦– សិលាចារឹក ត្រពាំងក្រមល់ ក្នុងខេត្តគោកខណ្ឌ ស្រុក

សៀម (សតវត្សទី ១១)

៦២៧– សិលាចារឹក នោមវ៉ាន់ ? (គ.ស. ១០៥០–១០៥៧)

៦២៨– សិលាចារឹក នៅខេត្តជៃយាភូម (ស្រុកសៀម) (សត-វត្សទី ១១)

៦២៩– សិលាចារឹក ប្រាសាទព្រះក្សេត្រ (គ.ស. ១០៦៧)

៦៣០– សិលាចារឹក នៅខេត្តកលះសិម (ស្រុកសៀម) (ឆ្នាំ?)

៦៣១– សិលាចារឹក ផុតួន (គ.ស ៩៤៤–៩៦៨)

៦៣២– សិលាចារឹក ប្រាសាទចាន នៅកោះកែរ ចម្ងាយ ៣ គ.ម. ខាងពាយ័ពហាល (គ.ស. ៩៥៦)

៦៣៣– សិលាចារឹក នៅមេបញ្ជរនៃទ្វារប្រាសាទខាងត្បូង របស់ប្រាសាទត្រពាំងពៅ នៅជិតវាលយន្តហោះស្រុកសៀមរាប (គ.ស. ៩២១–៩៥៩–៩៦២)

៦៣៤– សិលាចារឹក បានណាគុថុង កងខេត្តឧបុន ស្រុកសៀម (គ.ស. ៩០០–៩២២ រជ្ជកាលព្រះបាទយសោវរ្ម័នទី ១)

៦៣៥– សិលាចារឹក ប្រាសាទ បេងខាងត្បូង បិតចម្ងាយ

ប្រមាណ ៣០០ម៉ ខាងអគ្នេយ៍ប្រាសាទបេង ខាង

(សតវត្សទី ១០–១១)

២៣៦– សិលាចារឹក នៅទឹងស័ន្ទធ្វើស្ពាន់ នៃប្រាសាទព្រះ

(គ.ស. ១១៩៦)

២៣៧– សិលាចារឹក ត្រពាំងដូនមាស ឃុំតាឈូក ស្រុក

ខេត្តសៀមរាប គ.ស. ១០១១

២៣៨– សិលាចារឹក កិម៉ាយ (ស្រុកសៀម គ.ស. ១០៤១)

២៣៩– សិលាចារឹក ខងចាំងកើយ នៅស្រុកសៀម (ក្នុងដៃ

ការេញ្ញ គ.ស. ៩៤១)

២៤០– សិលាចារឹក ប្រាសាទគោកឋក ប៉ែកនៅចម្ងាយ ៨០ គ

ម.. នាខាងជើងផ្លូវភ្នំពេញ ទៅសៀមរាប (គ ស.៩៤៧

២៤១– សិលាចារឹក នៅទឹងជើងទ្រកញ្ចក់ធ្វើពីស្ពាន់ នៅវត្ត

(សតវត្សទី ១៣)

២៤២– សិលាចារឹក នៅមេបញ្ជរនៃប្រាសាទបាពួន សត-

វត្សទី ១២

៦៤៣- សិលាចារឹក នៅព្រះវិហារ កំពង់ស្វាយ សតវត្សទី ១០-១១

៦៤៤- សិលាចារឹក នៅនឹងជើងទ្វារកញ្ចក់នៃប្រាសាទហ៊ុន គោកប្រាសាទ ក្នុងភូមិគោកធ្នុយ ? (គ.ស. ១១៩៦)

៦៤៥- សិលាចារឹក នៅនឹងជ្រុងជើង ៣ នៃវត្តបានណាសាម ក្នុងខេត្តសុរិន្ទ (ស្រុកសៀម គ.ស. ១៦០១)

៦៤៦- សិលាចារឹក ភ្នំឥតទ្វាកកាសីម (ស្រុកព្យយុព្យា) ស្រុកសៀម (គ.ស. ១៣៦៧)

៦៤៧- សិលាចារឹក ប្រាសាទបេង ស្រុកក្នុស្រុក គេយកទុកនៅវត្តពោធិ៍កល បាត់ដំបង (គ.ស. ១០០៧-១០០៨)

៦៤៨- សិលាចារឹក ប្រាសាទភូមិប៉ុន នៅសុរិន្ទ ស្រុកសៀម (សតវត្សទី ១០)

៦៤៩- សិលាចារឹក បានមកពីខេត្តប្រាចិនបុរី (សតវត្សទី ១១) នៅស្រុកសៀម

២៩០– សិលាចារឹក បានមកពីខេត្តសុខោទ័យ ស្រុក

(សតវត្សទី ១០)[1]

x x x

## សេចក្ដីបញ្ជាក់.–

ការដែលមានឈ្មោះសិលាចារឹកសុខោទ័យ ក្នុង

បញ្ជី នៃសម័យនីមួយ ៗ នេះ បណ្ដាលមកពីខ្ញុំស្រង់រៀង

សៀវភៅរបស់លោក G. Coedès ពីខ្សែ ១ ដល់ ៧ ដែល

ដូច្នេះដែរ ។

(១) អក្សរទី ២១០ ដល់ ទី ២៤៨ មាននៅក្នុង Inscriptions

Cambodge, របស់លោក G. Coedès, Tome VII ។

# ទី៤–សម័យកាលទី៤

## សម័យក្រោយអង្គរ គ.ស.១៣៣៦ ដល់សព្វថ្ងៃ

### ១– សេចក្ដីសង្កេត.–

សម័យកាលទី ៤ នេះ អាចចែកបានជា ៣ ផ្នែកគឺ :

ផ្នែកទី១:

សម័យលង្វែក Période de Lovék

គឺចាប់ពីចម្បាំងជាមួយសៀមមកដល់ការបាត់បង់លង្វែក (គ.ស. ១៣៣៦ ដល់ ១៥៩៣)

ផ្នែកទី២:

សម័យក្រុងឧដុង្គមានជ័យ Période de Oudong (គ.ស. ១៦១៨–១៨៥៩)

ផ្នែកទី ៣:

សម័យក្រុងភ្នំពេញ Période de Phnom-Penh (គ.ស. ១៨៥៩) មកដល់សព្វថ្ងៃ ។

## ផ្នែកទី ១:

# អក្សរសាស្ត្រសម័យលង្វែក
# គ.ស. ១៣៣៦ ដល់ ១៥៩៣

## ក– ក្សត្រសំខាន់ៗ.–

ព្រះមហាក្សត្រសម័យកាលទី៤ ផ្នែកទី១ នេះជា
ព្រះរាជវង្សនៃព្រះបាទត្រសក់ផ្អែម ។ ព្រះបាទត្រសក់
ឡើងសោយរាជ្យក្នុង គ.ស. ១២៩០ ហើយទ្រង់ទីវង្គ
គ.ស. ១៣០៧ ។ (១) រាជសម្បត្តិក៏ធ្លាក់ទៅលើព្រះរាជ
បួន ព្រះនាមព្រះនិពានបាទ គ.ស. ១៣៤០ ដល់ ១៣៤
កាលព្រះបាទនិពានបាទទ្រង់ទីវង្គតទៅ ព្រះអនុជព្រះ
ប៉ុន្តែទទួលរាជសម្បត្តិជាបន្ត គ.ស. ១៣៤៦ បានតែ ៦
ក៏សុគតទៅទៀត ។

– ព្រះស្រីលំពង្សរាជា (គ.ស. ១៣៤៧–១៣៥
រាជធានីអង្គរធំ

---

(១) តាមព្រះរាជពង្សាវតារប្រទេសកម្ពុជារបស់សម្តេចព្រះមាលិកា ។

-- ព្រះឧបរាជស្រីសុរិយោទ័យ គ.ស. ១៣៥៣

– ព្រះបាទស្រីសុរិយោវង្ស (គ.ស. ១៣៥៧-១៣៦៦)

– ព្រះបាទបរមរាមា (គ.ស. ១៣៦៦-១៣៧៣ រាជធានីអង្គរធំ

– ព្រះបាទធម្មាសោកា (គ.ស. ១៣៧៣-១៣៩៤)

– ព្រះបាទស្រីសុរិយោវង្សទី ២ (គ.ស. ១៤០១-១៤១៧)

– ព្រះបាទបរមសុខា (គ.ស. ១៤១៧-១៤២០)

– ព្រះបាទសម្តេចព្រះពញាយ៉ាត (គ.ស. ១៤២១-១៤៦២):

ទ្រង់គង់នៅនគរធំបាន ៥ ឆ្នាំ ក្នុង គ.ស. ១៤២៦ ស្ដេចយាទមកគង់នៅទួលបាសាន ស្រុកស្រីសន្ធរ បាន ១ ឆ្នាំ ក៏ទ្រង់ផ្លាស់ព្រះរាជធានីមកគង់នៅ ចតុមុខក្នុង គ.ស. ១៤២៧ ។

– ព្រះនារាយណ៍រាមាធិបតី (គ.ស. ១៤៦៤-១៤៦៧) រាជធានីចតុមុខ

– ព្រះធម្មរាជាទី ១ (គ.ស ១៤៧៤ ១៤៩៨)(១)

– ព្រះបាទស្រីសុគន្ធបទ (១៤៩៨-១៥០៤( គង់ជាទី...
ទួលបាសាន)

– ព្រះបាទអង្គច័ន្ទទី ១ (គ.ស. ១៥១៤ ១៥៥៥)(...
ទ្រង់លើករាជធានីមកតាំងនៅលង្វែកក្នុងឆ្នាំ ១៥២៨

– ព្រះបាទសម្ដេចព្រះបរមរាជា (គ.ស ១៥៥...
ដល់ ១៥៦៧) គង់ជានីលង្វែក

– ព្រះបរមមហិន្ទរាជា ឬព្រះសត្ថាទី១ (គ.ស ១៥៦...
១៥៧៥) គង់នៅលង្វែក

– ព្រះបាទជ័យជេដ្ឋាទី១ ឬព្រះជ័យចេស្ដា (គ.ស១៥៧៥...
១៥៩៣) ៖សៀមយកបន្ទាយលង្វែកបានក្នុង គ.ស. ១៥៩៣ ...

---

(១) ស្ដេចអង្គនេះ សោយរាជ្យតាំងពី គ.ស. ១៤៦៨ ម៉្លេះ ។ សម័យនោ...
មានក្សត្រ៣អង្គបែងចែកប្រទេសសោយរាជ្យជា ៣ ផ្នែក គឺព្រះធម្មរាជាគង់នៅ...
ចតុមុខ ព្រះស្រីរាជាគង់នៅបរិបូណ៌ អមរបុរៈនិងព្រះស្រីសុរិយោទ័យគង់នៅ...
ស្រីសន្ធរ ។

(២) មុនព្រះអង្គ គឺស្ដេចកនដែលធ្វើគុតព្រះសុគន្ធបទ ហើយសោយរាជ្យ...
១០ឆ្នាំ គឺ គ.ស. ១៥០៤-១៥១៤ ។

## ២– ព្រឹត្តិការណ៍សំខាន់ខ្លះ –

តាមប្រវត្តិសាស្ត្រ ក្នុងរយៈកាល ២៥៧ ឆ្នាំនេះ ប្រទេសកម្ពុជាយើងទទួលគ្រោះថ្នាក់ពីសៀមដែលប្រមាថ និងលើកទ័ពមករុករានក្បាតច្រើនគ្រាណាស់ ៗ ឧទាហរណ៍ :

១– នៅក្នុងរាជ្យព្រះបាទស្រីលំពង្សរាជា ស្តេចសៀមឈ្មោះឧត្តនលើកកងទ័ពមកវាយនគរធំ ប្រាថ្នានឹងយកខ្មែរឲ្យចំណុះវា ៗ សង្គ្រាមនេះធំណាស់ ៗ

២– ក្នុងរាជ្យព្រះឧបរាជស្រីសុរិយោទ័យ សៀមចន្ទចម្បាំង ហើយវាយនគរធំបានក្នុង គ.ស. ១៣៥៣ ។ សៀមទំលាយទ្វារនគរធំពីទិសខាងកើត រួចចូលលុកលុយប្លន់ទ្រព្យសម្បត្តិ ចាប់ខ្មែរជាឈ្លើយជិត ១ម៉ឺននាក់នាំទៅស្រុកវា ។ សៀមនេះកាន់នៅនគរធំរាំង ៤ ឆ្នាំ ពីគ.ស. ១៣៥៣ ដល់ ១៣៥៧ ដោយវាដាក់នាម៉ឺនសៀមឲ្យនៅគ្រប់គ្រងខេត្តខ្លះផង ។ ពេលសៀមលុក ពួកព្រាហ្មណ៍ចកេហាតបានបណ្តោះ យកគ្រឿងកកុធភណ្ឌបាន ។

៣– ព្រះស្រីសុរិយោវង្សទ្រង់គេណ្ហាសេនា រហូតដល
ស្រុកលាវ ក៏យកចាត់សៀមឲ្យចេញពីនគរធំបានក្នុង គ.ស
១៣៥៧ ។ ពេលនោះ ព្រំដែនខ្មែរខាងកើតដល់ដូនណៃ
ខេត្តបារៀ កូសាំងស៊ីន ខាងលិចតាំងពីខេត្តចន្ទរង្គអង្គរកេ
នានគ្ន័យ៍ខេត្តអង្គ្រកេជ រហូតដល់ឈូងសមុទ្រសៀម ហើយ
ខាងជើងដល់ស្ពាមខ្សាច់គោកខ័ណ្ឌ (ដែនទុបុន) ។

៤– នៅចុងរាជ្យព្រះបាទធម្មាសោកា គ.ស. ១៣៩៤
សៀមព័ទ្ធបន្ទាយនគរធំ ប្រាំពីរខែ ស្លាប់សេនាសៀមជាច្រើន
តែបរាជ័យយកពុំបានទេ ។ តែដោយមានមេកងទ័ពក្បត់ពី
នាក់ចូលគំនិតខាងសៀម ពួកបុននេះរំលាយទ្វារខាងលិចចូល
នគរធំបាន ។ ព្រះធម្មាសោកា ទ្រង់ទិវង្គតក្នុងសង្គ្រាមនេះ
នាគ.ស. ១៣៩៤ ។ សៀមក៏តាំងនៅនគរធំមួយទៀត ។

៥– នៅគ.ស.១៤០១ ក្នុងកាលព្រះបាទសុរិយោវង្សទី២
មានកើតចលាចលនៅប្រទេសសៀម ពួកតាបុនទ័ពក៏ដក
[illegible]យចេញអស់វិលទៅស្រុកវិញ ។

៦– នាកាលចុងរាជ្យព្រះបាទបរមសុខា គ.ស. ១៥២០
សៀមព័ទ្ធនគរធំម្ដងទៀត ។ ព្រះរាជាអង្គនេះទ្រង់សោយទិវង្គ
ត់យកនគរសមរភូមិ ។ សៀមរាំតាំងនៅនគរធំរហូតដល់ គ.ស.
៤២១ ។

៧– ព្រះបាទសម្ដេចព្រះពញាយ៉ាត ទ្រង់បានវាយកំចាត់
សៀមចេញបានពីគ.ស. ១៤២១ ហើយទ្រង់យាងមកគង់នៅ
លបាសាន ស្រុកស្រីសន្ធរបាន ១ឆ្នាំ ទើបផ្លាស់មកគង់នៅ
តុមុខ ភ្នំពេញ ។ ពេលនោះព្រះរាជាទ្រង់បានចងសម្ពន្ធមិត្រ
ងស្ដេចក្រុងចិន ។

៨– មុនរាជ្យព្រះបាទធម្មរាជាទី១ ប្រទេសត្រូវបែងចែក
ា ៣ គ្រប់គ្រងដោយក្សត្រ ៣ អង្គគឺ :

– ព្រះធម្មរាជា គង់នៅក្រុងចតុមុខ ។ ទ្រង់ជ្រើសរើស
បកផ្ទៃផនទីខាងលិចពីស្រុកសំពៅទង (គិតចំស្ពឺ) រហូតទៅ
ល់ឈូងសមុទ្រសៀម ខាងកើតនិងខាងត្បូងពីកោះស្លាកែត
ាះនោះផ្ទុកកណ្ដាលនៃទន្លេទាំង ២ គឺទន្លេក្រៅ (មេគង្គ)

ចាប់ពីស្រុកល្វាឯម រហូតដល់ព្រៃនគរ និងពាមកញ្ញើ (ជ
សមុទ្រខាងត្បូង) និងខេត្តកុង (ខេត្តពាសាក់ ឬមាត់ជ្រូ
ចាប់ពីត្រឹមក្រោមភ្នំពេញរហូតដល់សមុទ្រខាងត្បូង ។

— ព្រះស្រីធា គង់នៅស្រុកបរិបូណ៌ (អមរបុរៈ) គ្រ
ខាងលិចនៃទន្លេមេគង្គ ពីខេត្តកំពង់ឆ្នាំងទៅខាងលិចទល់
ប្រទេសសៀម ទៅខាងជើងដល់ខេត្តសុរិន្ទ (នាខាងជើ
ភ្នំដងរែក) ។

— និងព្រះសុរិយោទ័យ គង់នៅស្រុកស្រីសន្ធរ យ
ខេត្តផ្នែកខាងកើតទន្លេមេគង្គទាំងអស់ រហូតដល់ខេត្តជួនៃ
ចារៀ ទល់នឹងប្រទេសលាវ លើកលែងល្វាឯម និងព្រៃន
ចេញ ។

នាសម័យកាលដែលព្រះបាទនារាយណ៍រាមាធិបតីទ្រង់
វិគតទៅ (គ.ស. ១៤៦៧) ព្រះបាទស្រីធាទ្រង់ស្នងរាជ្យ
បានតែ ១ ឆ្នាំក៏ព្រះភាគិនេយ្យព្រះនាមសុរិយោទ័យនាំបះ
ពោរពេញរាជសម្បត្តិ ។ ពេលនោះសៀមក៏លើកទ័ពចូ

ពីទិសខាងលិច វាយអង្គរាជ ច័ន្ទបុរ និងអង្គរ ។ ព្រះបាទស្រីរាជាទ្រង់យាងទៅទប់ទឹងសៀម ទ្រង់ផ្ញើរាជសម្បត្តិនឹងព្រះអនុជព្រះធម្មរាជា ហើយទ្រង់ចាត់ឲ្យទៅច្បាំងនឹងព្រះសុរិយោទ័យ ។ លុះច្បាំងឈ្នះសៀមហើយ ទ្រង់យាងត្រឡប់មកវិញ ។ ព្រះធម្មរាជាពុំព្រមថ្វាយរាជសម្បត្តិ រួចក៏បែងចែកព្រះនគរជាពីរផ្នែក ។

ព្រះរាជាពីរព្រះអង្គនេះទ្រង់ពុំបានសេចក្ដីព្រមព្រៀងគ្នាយូរឆ្នាំទេ គឺគង់ជាសុខបានតែបីឆ្នាំ ក៏ព្រះធម្មរាជាទ្រង់សុំឲ្យសៀមជួយឧបត្ថម្ភដើម្បីផ្ដាច់យកផែនដីទាំងមូល ។ សៀមបានឱកាសក៏លើកកងទ័ពមកតទល់ព្រះបាទស្រីរាជា និងព្រះបាទសុរិយោទ័យនាំយកទៅប្រទេសវាទៅ ។

៩ — នៅគ.ស. ១៥០៥ នាយកនជាពលព្រះ គាប់នឹងព្រះបាទស្រីសុគន្ធបទណាស់ ដោយទ្រង់ប្រទានភរិយា (ប្អូនព្រះស្នំ) ចាប់ហ្នឹងសង្ស័យការក្រែតពលព្រះ ។ ប្អូនព្រះស្នំកនបះពាញ់ណោបរាក ។ នាម៉ឺនសព្វមុខមន្ត្រីកើតវិប្បដិ-

សារីកាកើឿនទឹងហ្វូនគន ដើម្បីសូមព្រះរាជាយកទោសផ
ជីវិត ៗ ហ្វូនគនគេចរត់រួច ក៏លើកទ័ពមកច្បាំង ហើយបា
ធ្វើគតព្រះសុគន្ធបទ រួចតាំងខ្លួនជាស្ដេចផែនដីដោយមាននា
ថា (ហ្វូនព្រះស្ដេចកន) សោយរាជ្យបាន ១០ ឆ្នាំ (ពីគ
ស. ១៥០៥ ដល់ ១៥១៥) ៗ

១០– នៅពេលដែលស្ដេចធ្វើគតនាយកនបានក្នុងគ.ស
១៥១៥ ព្រះបាទអង្គច័ន្ទទី ១ ជាព្រះអនុជព្រះបាទសុគន្ធបទ
ជាព្រះរាជបុត្រព្រះធម្មរាជាទី ១ ក៏ឡើងគ្រងរាជ្យ ៗ ពេល
នោះ សៀមបាត់សារឲ្យព្រះអង្គស្ដេចនាំដំរីសទៅឲ្យវា ៗ ព្រះ
រាជាពុំព្រមតាម ៗ ដូច្នោះសៀមក៏ខឹង ហើយលើកទ័ពមក
ច្បាំង តែបរាជ័យគ្រប់អន្លើ ហើយត្រឡប់ទៅស្រុកវិញអស់ក្នុង
គ.ស. ១៥២៨ ៗ

រំលង ៥ ឆ្នាំក្រោយមក សៀមនេះលើកទ័ពមកទៀត
តាមផ្លូវគោក ផ្លូវទឹក តែបរាជ័យទៀតក្នុងគ.ស. ១៥៣៣ ៗ
ដើម្បីដោយការពារសត្រូវ ព្រះអង្គច័ន្ទទី ១ លើកព្រះរាជ

ជាទីមកតាំងនៅលង្វែកវិញក្នុង គ.ស. ១៥២៨ ។

១១– នៅដើមរាជ្យព្រះបាទសម្ដេចបរមរាជា ស.គ. ១៥៥៧ ជាតិភូមាលើកទ័ពមកវាយសៀម ។ ព្រះរាជាទ្រង់ឆ្លៀតឱកាសល្អលើកទ័ពទៅព្រមានសៀម ដោយយកបាន ខេត្តខ្មែរខាងលិច មានច័ន្ទបុរនិងនគររាជជាដើម ព្រមទាំងកៀរយកគ្រួខ្មែរនិងសៀមបាន ៧០.០០០ នាក់ ។ ទ្រង់ដាក់ឲ្យសេនាសៀមទៅត្រួតត្រាខេត្តទាំងនោះ ។

ក្នុងរាជ្យព្រះអង្គ ព្រះបរមរាជាក៏បានយាងទៅវាយលាវបរាជ័យ ចាប់យកឈ្លើយច្រើនពាន់នាក់នាំមកនៅស្រុកបាភ្នំ (ខេត្តកំពង់ធំ) និងស្រុកជើងព្រៃ (កំពង់ចាម) ក្នុង គ.ស. ១៥៦០ ។

ក្នុង គ.ស. ១៥៦២ សៀមលើកកងទ័ពមកទៀតប្រាថ្នាចង់ដណ្ដើមយកទឹកដីខ្មែរនៅខេត្តខាងលិច តែព្រះបាទបរមរាជាទ្រង់លើកទ័ពទៅតទល់ ។ សៀមមិនបានសម្រេចផលប្រយោជន៍ វាក៏សុំព្រមសះជាក្នុង គ.ស. ១៥៦៤ ហើយសម្រេច

ធ្វើសន្ធិសញ្ញាសម្ពន្ធមិត្តក្នុងគ.ស. ១៥៦៧ ។

១២ - នៅពេលដែលព្រះបាទសត្ថា ១ គ្រងរាជ្យបាន
ពាណ ៤ ឆ្នាំនេះ មានជាតិភូមាក្រុងហង្សាវតី (ភគូន) ពេ
ចំពួកលុកប្រទេសសៀម ។ សៀមសុំកងទ័ពខ្មែរទៅជួយ
ដោយទ្រង់ឈ្វេងយល់នូវផលមេត្រីថា ។ នេះ ព្រះបាទស
ទ្រង់យល់ព្រម ហើយក៏ប្រោសឲ្យព្រះអនុជព្រះសុរិយោព
ជាមេពលលើកទ័ពទៅជួយសៀម ។ លុះជួយឈ្នះហើ
ស្តេចសៀមពុំមានកតញ្ញូធម៌ទេ តែបែរជាមើលងាយ ព្រ
មហាឧបរាជខ្មែរទុកដូចជាស្តេចចំណុះ ។

ក្រោយមកព្រះរាជាភូមាលើកទ័ពមកលុកសៀមទៀត
ព្រះសត្ថាបានឱកាស ក៏ទ្រង់លើកទ័ពទៅវាយខេត្តសៀមខ
កើតកៀរគ្រួខ្មែរសៀមបានមកវិញជាច្រើននាក់ ។

១៣- ក្នុងគ.ស. ១៥៧៨ ព្រះបាទសត្ថា ១ ប្រ
ដាក់រាជ្យថ្វាយព្រះរាជឱរសព្រះជេដ្ឋបុត្រច្បង ព្រះនាមជ័
ជេដ្ឋា ព្រះជន្មទើបនឹងបាន ១០ វស្សា ។ ទ្រង់ព្រះពល

ឋានន្តរៈ ព្រះរាជបុត្រអនុជបន្ទាប់ ព្រះនាមពញាតន់ព្រះជន្ម ៦ ព្រះវស្សាជាទីព្រះឧបរាជ, ព្រះមហាឧបរាជស្រីសុរិយោពណ៌ជាទីឧបយោរាជ ។ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យឋិតនៅក្នុងឋានៈជាទីព្រះឧបយោរាជ រាជានុសិទ្ធិវិញ ។

ការដាក់រាជ្យនេះ នាំឲ្យកើតទោមនស្សព្រុំពេញចិត្តនាម៉ឺនសព្វមុខមន្ត្រីជាច្រើន ទើបមានកើតអសន្តិសុខចលាចលក្នុងព្រះនគរ ។

សៀមបានដឹងថា ប្រទេសកើតចលាចលហើយ វាក៏ចៀតឱកាសលើកទ័ពមកបង្ក្រាបដល់លង្វែក តែវាបរាជ័យថយទៅវិញអស់នៅគ.ស.១៥៨៣ ។

ដប់ឆ្នាំក្រោយមក គ.ស. ១៥៩៣ សៀមលើកទ័ពធំបួលមកតាមជើងគោក និងតាមសមុទ្រ (កាលនោះដែនកូសាំងស៊ីននៅជារបស់ខ្មែរ គឺកម្ពុជាក្រោម) ។

ខ្មែរកេណ្ឌកងទ័ពដាក់ត្រៀមចាំគ្រប់កន្លែង ។ ព្រះឧប-រាជសុរិយោពណ៌ត្រៀមនៅបន្ទាយបរិបូណ៌ ។ ខ្មែរទាញ់

សៀមគេចអត្ទី ។

សៀមវាយផ្កាយទំសកានលិច បាត់ដំបង ពោធិសាត់ រហូតដល់បន្ទាយបរិបូណ៌ តែព្រះសុរិយោពណ៌ទ្រង់ដោះព្រះអង្គយានចូលមកព្រះភ្នំកាន់លង្វែកបាន ។

ព្រះបាទសត្ថា និងព្រះបាទជ័យជេស្ឋាទ្រង់ដោះព្រះអង្គផុតពីលង្វែកទៅគង់នៅស្រីសន្ធរ រួចទៅគង់ឯខេត្តស្ទឹងត្រែង ។

សៀមលើកទ័ពមកឡោមព័ទ្ធក្រុងលង្វែក បានវាយផ្តាយក្រុងនេះ ដោយចាប់បានព្រះសុរិយោពណ៌ និង ព្រះញាតិវង្សនាំទៅស្រុកសៀម ។ សៀមបង្ក្រើផុតបំផ្លាញផ្ទះ ចាប់មនុស្សពេញការ ៩ ម៉ឺននាក់ជាឈ្លើយទៅស្រុកវា ។

សម័យនោះ មហាប្រទេសត្រឡប់ទៅជាតូច ស្ទើរតែគេពុំស្គាល់នៅបុងបូព៌ាប្រទេស ។

## ៣– សេចក្តីសង្កេតចំពោះព្រឹត្តិការណ៍ទាក់ទងមកនឹងអក្សរសាស្ត្រ.–

យើងឃើញហើយថា ក្នុងផ្នែកទី ១ នៃសម័យកាលទី ៤

(គ.ស. ១៣៣៦ ដល់ ១៥៩៣) ប្រមាណជា ៣ សតវត្សនេះ
ប្រទេសជាតិមានការភាគគ្រាគ ក្លាយទៅជាចម្បាំងកំពីងដល់ជា
មួយពួកប្លន់ទឹកដី គឺសៀមនេះឯង ។ វិបត្តិកើតមានតាំងតែ
ពីឆ្នាំ ១៣៥៣ ហូតដល់ឆ្នាំ ១៥៩៣ ជាឆ្នាំបាត់បង់ក្រុង
បផ្នែក ។ ក្នុងរយៈពេល ២៤០ ឆ្នាំប្រទេសរងទុក្ខវេទនា ប្រ
ជាក្រស្តត់ទាត ហើយព្រះមហាក្សត្រព្រះអង្គខិតខំតទប់ទល់
បត្រូវដើម្បីរក្សាទឹកដី សម្បូរណភាព ឯករាជ្យជាតិគ្រប់ពេល
វេលា ។ វិស័យកសាងជាតិនានាត្រូវថយល្បឿន (ឧទាហរណ៍
ចជាការកសាងសម័ន្ធ មានបុរាណដ្ឋានព្រមទាំងវិស័យសេដ្ឋ
កិច្ច សង្គមកិច្ចជាដើម) ។ ដោយសារប្រទេសមានកយុទ្ធ-
យគ្រប់ពេលវេលាដូច្នេះ ការសិក្សាតែងនិពន្ធក្បួនខ្នាត ឬ ការ
ងក្រងកត់ត្រានូវព្រឹត្តិការណ៍ផ្សេង ៗ ក៏ថមថយ ៗ មនុស្សខ្វ
ទាំសល់នៅក្នុងសេចក្ដីទុក្ខភិតភ័យជានិច្ច ។ សេចក្ដីសង្ឃឹមគឺ
តែនៅលើជំនឿក្នុងត្រៃសរណគមន៍ជាគ្រឿងអះអាងជួយផ្ដល់
នូវសេចក្ដីសុខ ចំរើនសម្រាប់ជាតិជីតាបរលោក (ពីព្រោះ

ម្នាក់ៗ ពុំដឹងជាត្រូវស្លាប់ដោយចម្បាំងខ្មាំងសត្រូវ យាយ
ណាមួយមិនប្រាកដ) ។ មនុស្សស្រីៗតែងទៅនាំគ្នាធ្វើបុណ
សុន្ទរទាន (រហូតដល់ព្រះមហាក្សត្រជាដើម ដែលទ្រង់ស
ព្រះទ័យក្នុងការកុសល ឬ ការបន់ស្រន់ លាចំណាន់ សុំប្រា
សេចក្តីសុខក្សេមក្សាន្ត សន្តិភាពចំពោះប្រទេស និងក្រស្ត
កស្តុតាងនៅក្នុងសិលាចារឹកនានារបស់លោក ជ័យនន្ទនៅអង្គ
វត្តជាដើម ។

ដូចបញ្ជាក់ក្នុងផ្នែកទី ១ នេះ អក្សរសាស្ត្រខ្មែរបុរាណនៅជាបែ
២ យ៉ាងគឺ :

– សិលាចារឹក

– សាស្ត្រាល្បែង (តែងជាពាក្យកាព្យ) ។

## ឃ– អត្ថបទអក្សរសាស្ត្រ និងអ្នកនិពន្ធសំខា

## ធី ១– ផ្នែកសិលាចារឹក–

### សិលាចារឹកនគរវត្ត.–

សិលាចារឹកដ៏សំខាន់គឺ "សិលាចារឹកនគរវត្ត"

សិលាចារឹកនេះ ចែកជា ៣ ភាគ គឺ :

– សិលាចារឹកនៅ "ព្រះពាន់" ត្រង់ដែលមានព្រះពុទ្ធរូបច្រើន

– សិលាចារឹកនៅថ្នាក់លើបំផុតហៅថា "ៈបាកាណ"

– ទិនសិលាចារឹកលេខ ៣៨ នៅព្រះបៀនថ្នាក់ក្រោមពីខាងកើតត្រង់ ដែលមានព្រះចេតិយដោយថ្មបាយក្រៀម ។

ក. អ្នកនិពន្ធ.–

បណ្ឌិត ជ័យនន្ទ Pandita Jaya Nanda ជាអ្នកនិពន្ធជំល្បី ក្នុងរជ្ជកាលព្រះករុណាព្រះបាទធម្មរាជាទី១ (សតវត្សទី១៥ នៃគ.ស.) ឆ្នាំ ១៤៧៤–១៤៩៤ ។ លោកបានកត់ត្រារៀបរៀងនូវសិលាចារឹកជាច្រើននៅនាថេរអង្គរវត្ត ដែលជាអត្ថបទរៀបរាប់អំពីពាក្យស្តុតិ ការបួងសួងសុំនូវសេចក្តីថ្លាថ្នាសុខចំរើនសំរេចគ្គផលក្នុងការធ្វើកុសលផ្សេង ៗ ។

## ក-អត្ថបទដើម.– (១)

តាមសៀវភៅ "សិលាចារឹកនគរវត្ត" យើងអាចរាប់បាន
ចំនួនទាំងអស់ ៤០ សិលាចារឹក ។

ក– សិលាចារឹកលេខ ១៥ ទំព័រ ៣៦–៣៧ :

១– សព្វស្រុក ១៥៥៣ សកម្មមែ អ្នកខ្សែត្រ ខែហ
មាឃទ្រាំ (២) ថ្ងៃពេជ សុក្កោះសារ នាមឆ្នំអ្នកសំរេចអាវយ
សុជម្ពាមានចិ (៣) ត្រសាន្តាសាងព្រះពុទ្ធប្រតិមាមាសព្រះអង្គ
១ ព្រះពុទ្ធ ឈោហព្រះ (៤) អង្គ ៣៦ ទេព្វ អាកុមានិមនត
សកំម្រែតងសយំផោង មានអ្ន (៥) កសំរេចព្រះបឋមខិបូពិត្រ
អ្នកព្រះមហាមង្គល ឧបអ្នកព្រះពជរុចី (៦) ឧបអ្នកព្រះឥន្ទ្រក្សាស
អ្នកព្រះបរសេត្រា អ្នកព្រះមហាមោកគ (៧) លាន ឧបអ្នកព្រះពជ
សិលាចារម្ហា សយំកជបូពិត្រ ឥសសំ (៨) ម្តេចព្រះត្រូវថេពនុ-
ថេរភិក្ខុសយំផោងជាព្រះជានជា (៩) ព្យួញាណអ្នកព្រះអរិ

---

(១) សូមអានសៀវភៅ "សិលាចារឹកនគរវត្ត និងបទានុក្រម" ផ្សាយចេញពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។

សុធម្ម ប្រោសកាសូសុនេះឲ្យ (១០) រួចជាព្រៃយះហ្វងព្រ
ស្រលាះជ្រះឥតកុំម្តិងលេយថា បេមាន នាមួ (១១) យះយោក
កានេះជាខ្ញុំលេយ ព្រះអម្បាល ខ្សេច កំម្បី (១២) ប្រោសអ្នក
នោះលេយ តោះយោប្យកំម្រតែង មុក្ខមន្ត្រិ (១៣) ឯកាមួយ
បង្គាបហើរហឪយ ជាខ្ញុំមលេយ ឪយទៅវត្តន (១៤) នាចតុ
ពបាយកូម នាយសប្បុគាលហ្វេ នាមេទងនេះ (១៥) គៈគ
ប្រាកតាំងយ ព្រះពុំតាន ស្រលាះលេយ អ្នក (១៦) យោគ
យោកប្រាកបំពេញឪយមេនេះរួបភក្សព្រះហោង (១៧) ថា
បើហានទាមួយយោកមេនេះជាខ្ញុំលេយ នុ (១៨) យអ្នកនោះ
ទៅវនាបញ្ញាខន្តិរកនាយៈហាង ។

## គ) សេចក្តីប្រែ.–

(១) សព្ទមស្តុ ១៥៥៣ សកមមៃ នក្សត្រ ខែមាឃ
ច្រុំ (២) បំពេច សុក្រក់សោរនាដគំអ្នកសម្តេច អារ៉ូយសុធម៌
មានចិត្ត (៣) សទ្ធា សាងព្រះពុទ្ធបដិមាមាសមួយព្រះអង្គ
ព្រះពុទ្ធរូបឈើ ៣៦ ព្រះអង្គ (៤) ទើបអាការធាទិមន្តអស់

តម្កើងសង្ឃផង មានអ្នក (៥) សម្ដេចព្រះបឋមមុនីបពិត

ព្រះមហាមង្គល នូវអ្នកព្រះរាជវុធី (៦) នូវអ្នកព្រះឥន្ទកោ

អ្នកព្រះបវរសាស្ត្រា អ្នកព្រះមហាមោគ (៧) ល្មាន នូវអ្នក

រាជសីលាចារ្យមហាសង្ឃរាជមពិត្រអស់ (៨) សម្ដេចព្រះ

ថេរានុត្ថេរភិក្ខុសង្ឃផងជាប្រធាន ជា (៩) ពេជ្រញាណ អ្ន

ព្រះអរិយសធម្ម ប្រាសកាសួសនេះឲ្យ (១០) រួចជាព្រៃឡើ

ព្រះស្រឡះជ្រះឥតកំដឹងឡើយថា បើរណាមួយ (១១) យ

អានេះជាខ្ញុំឡើយ ព្រះអម្បាលខ្សាច់ កុំបី (១២) ប្រោសអ្ន

នោះឡើយ ទោះយោបីតម្កើងមុខមន្ត្រី (១៣) ឯណាមួយបន្ទា

ឬឲ្យជាខ្ញុំឡើយឲ្យទៅធ្អិន (១៤) នាចតុ រាជាយភូម នាយ

សព្វកាលហោង ៗ នាមេទងនេះ (១៥) ត្បិតយកប្រាក់ជន្លាយ

ព្រះពុំទាន់ស្រឡះឡើយ អ្នក (១៦) យកប្រាក់បំពេញឲ្យមេនេះ

រួចកញ្ញាព្រះហោង (១៧) ថាបើរណាមួយយកមេនេះជាខ្ញុំ

ឡើយ ឲ្យ (១៨) អ្នកនោះទៅនាបញ្ចានន្ត រកនាយហោង ៗ

## ឃ) អត្ថន័យទូទៅ .—

ក្នុងសិលាចារឹកសឹងតែទូទៅ យើងឃើញអ្នកនិពន្ធបញ្ជាក់កត់ត្រាអំពីគ្រឿងបូជាដង្វាយព្រះ ឬការកសាងព្រះពុទ្ធរូបនានាដើម្បីសន្សំកងកុសលផលបុណ្យ ។ ក្នុងការធ្វើកុសលកម្មយើងឃើញមានការត្រាប្រណីដោះលែងទាសាទាសីឲ្យទៅជាអ្នកជា មានសេរីភាព ហើយគេមិនញញើតនឹងប្តូរទោសដោយប្រទេចផ្តាសាចំពោះមនុស្សអាក្រក់ ដូចជាលួចគុរុភណ្ឌបំបាត់ប្រវ័ត្ត គេជាគាថ ៗ បញ្ហាបុណ្យបាប នរកសួគ៌មានរៀបរាប់ជាច្រើនភ្ជាប់ទៅនឹងជំនឿ សង្ឃឹម អស់សង្ឃឹមរបស់ប្រជាពលរដ្ឋគប់តាំងពីវណ្ណៈទាបរហូតដល់អភិជន ព្រះមហាក្សត្រ ៗ

## ង) របៀបតែង.—

ក្នុងវិធីសាស្ត្រនៃការតែង អត្ថបទនីមួយៗ មានរបៀបនិពន្ធត្រឹមត្រូវដោយ :

— គេបេះផ្ដើមប្រាប់សករាជ មហាសករាជ ទីកន្លែងនិង

គោរមងារស្នូកបញ្ចារប្រើគេឲ្យកត់ត្រាហេតុការណ៍សំខាន់ៗ

— ក្នុងដំណើរសេចក្ដី គេរៀបរាប់អំពីឈ្មោះគ្រឿងបូជ
ការកសាងពុទ្ធរូបជាដើម ។

— ក្នុងសេចក្ដីបញ្ចប់ គេប្រមូលបុញ្ញរាសីកើតអំពីកុសល
ផលបុណ្យឲ្យបានសំរេចសម្បត្តិសួគ៌ សម្បត្តិនិព្វាន ឬសុំឲ្យបាន
ជួបនឹងព្រះស្រីអារ្យមេត្រី (ក-សិលាចារឹកលេខ ២-៣-៤..) ។

## ប)- លក្ខណៈពិសេស៖.-

សិលាចារឹកនគរវត្ត កត់ត្រានូវសកម្មភាព និងជំនឿ
ស៊ុបសួនក្នុងព្រះពុទ្ធសាសនា ។ សឹងតែគ្រប់សិលាចារឹក
យើងឃើញថា ក្នុងសម័យនោះមានទំនៀមទម្លាប់តាំងព្រះ
សង្ឃឲ្យមានសមណសក្តិសំបូណ៌ហូរហៀរណាស់ ទាំងមាន
គោរមងារប្លែកៗ អំពីគោរមងារសព្វថ្ងៃនេះ ។

នៅសិលាចារឹកលេខ ៣៩ ឃើញមានសម្ដេចព្រះមហា
សង្ឃរាជដល់ទៅ ៩ អង្គ ជាហេតុគួរឲ្យឆ្ងល់ថា ម្ដេចក៏មាន
ច្រើនអង្គម្ល៉េះ ។

ខ— ដំណែងមហាសង្ឃរាជមាន ៩ នោះគឺ :

១— សម្តេចព្រះធម្មលិខិត   មហាសង្ឃរាជបពិត្រ

២— —ដ— ព្រះសុគុណ   —ដ—

៣— —ដ— ព្រះមហាមង្គល   —ដ—

៤— —ដ— ព្រះរាជវេថី   (មហាសម្ពុហ)—ដ—

៥— —ដ— ព្រះជោតិទេព   —ដ—

៦— —ដ— ព្រះឥន្ទវិព្យចក្ខុ   —ដ—

៧— —ដ— ព្រះឥន្ទកោលាស   —ដ—

៨— —ដ— ព្រះមោគ្គលាន   —ដ—

៩— —ដ— ព្រះរាជសុមង្គលសីលាចារ្យ   —ដ—

ឯដំណែងរាជាគណៈសាមញ្ញមានដូចតទៅ :

១— ព្រះមហាសង្ឃកម្ម

២— ព្រះមហា ទុម

៣— ព្រះមហា ត្តល (ឧត្តរ)

៤— ព្រះឧត្តលញ្ញាណ

៥— ព្រះឧត្តលធម្ម

៦— ព្រះឧត្តលជេដ្ឋ

៧— ព្រះ[illegible]ជគរី

៨— ព្រះរាជមុនី

៩– ព្រះភទ្ទមុនី

១០– ព្រះធម្មមុនី

១១– ព្រះធម្មសុធី (ធម្មវិសុទ្ធ)

១២– ព្រះធម្មអរិយ

១៣– ព្រះធម្មកាយ

១៤– ព្រះអរិយវង្ស

១៥– ព្រះអរិយបទុម

១៦– ព្រះអរិយសុខុម

[illegible]– ព្រះអរិយកិញ្ញាណ

[illegible] ព្រះពជសត្ថា

[illegible]– [illegible]ផុសត្ថា

[illegible]– ព្រះសាភារ

[illegible]– ព្រះសត្ថវង្ស

[illegible]– ព្រះមុនីសត្ថា

២៣– ព្រះមុនីសទ្ទម

២៤– ព្រះមុនីវេជ្ជ

២៥– ព្រះមុនីកោសល

២៦– ព្រះបវរគោឋាបាលី

២៧– ព្រះមហាបាលី

២៨– ព្រះសត្ថាបាលី

២៩– ព្រះត្រៃបាលី

៣០– ព្រះសំវរបាលី

៣១– ព្រះវិន័យធរ

៣២– ព្រះបញ្ញាវិន័យ

៣៣– ព្រះសមណវិន័យ

៣៤– ព្រះសមណធម្ម

៣៥– ព្រះសមណកិរ (សមណកិច្ច)

៣៦– ព្រះបញ្ញាពិទូរ

៣៧– ព្រះបញ្ញាសុធី (បញ្ញា-

វិសុទ្ធ)

៣៨– ព្រះបញ្ញានន្ទ

៣៩– ព្រះបញ្ញាជេដ្ឋ

៤០– ព្រះបញ្ញាឧទ័យ

៤១– ព្រះបញ្ញាលិខិត

៤២– ព្រះបញ្ញាកិញ្ញាណ

៤៣– ព្រះសុមេនបញ្ញា

៤៤– ព្រះសូរបញ្ញា

៤៥– ព្រះសមណបញ្ញា

៤៦– ព្រះឧទ័យបញ្ញា

៤៧– ព្រះបវរសត្ថា

៤៨– ព្រះបវរបញ្ញា

៤៩– ព្រះបវរទក្សិណ

៥០– ព្រះបវរពោធិ

៥១– ព្រះបវរទត្តិ

៥២– ព្រះបវរវិទូ

៥៣– ព្រះបវរវិន័យ

៥៤– ព្រះបវរធម្ម

៥៥– ព្រះបវរមុនី

៥៦– ព្រះវីរិយបារមី

៥៧– ព្រះសុមេធាបារមី

៥៨– ព្រះសុធម្មបាលី

៥៩– ព្រះធម្មសីលាបារមី

៦០– ព្រះគាថាបារមី

៦១– ព្រះព្រហ្មរតន៍

៦២– ព្រះពុទ្ធវង្ស

៦៣– ព្រះពុទ្ធកម

៦៤– ព្រះវរជេដ្ឋ

៦៥– ព្រះជេដ្ឋ សីលក្ខន្ធ

## ឃ២- ផ្នែកសាស្ត្រាល្បែង .–

នៅក្នុងសម័យលង្វែក អត្ថបទផ្នែកសាស្ត្រាល្បែង ក៏មានខ្លះដែរ ប៉ុន្តែដោយសារពុំទាន់រកឃើញ នូវឆ្នាំ កាលបរិច្ឆេទបញ្ជាក់ច្បាស់លាស់ ដូច្នោះយើងក៏ពុំអាចនាំយ មកនូវអត្ថបទណាមួយ មកបង្ហាញជាកស្តុតាងបាននៅឡើ យ (ការពិត មានរឿងនិងសាស្ត្រាល្បែងជាពាក្យកាព្យច្រើ ណាស់ដែលគ្មានឈ្មោះអ្នកនិពន្ធ គ្មានកាលបរិច្ឆេទច្បាក សឹងមានរក្សាទុកនៅ ក្នុងបណ្ណាល័យនៃវិជ្ជាស្ថានពុទ្ធសាស បណ្ឌិត្យ ហើយដែលលោកអ៊ុំ ញ៉ុក-ថែម បានរៀបរៀ ជាឯកសារសាស្ត្រា និងក្រាំងបុរាណ ហើយផ្សាយក្នុងទស្ស នាវដ្ដីកម្ពុជសុរិយាជាហូរហែមកតាំងពីលេខ ៨ ឆ្នាំ ១៩៦ មកទល់សព្វថ្ងៃនេះជាតាង(ស្រាប់) ។

## ង) យោបល់បំពោះអក្សរសាស្ត្រផ្នែកទី១នេះ.–

ទោះបីមានព្រឹត្តិការណ៍យ៉ាងលំបាក ដោយសារការពក ក្សាគរបស់សត្រូវ គឺសៀមដែលបង្កហេតុជាចម្បាំងច្រើនលើក

គ្រាមកលើប្រទេសកម្ពុជាក៏ដោយ ក៏អ្នកនិពន្ធ កវីបណ្ឌិតខ្មែរ ពុំបានលះបង់នូវសេចក្ដីព្យាយាម ចងក្រងនូវអត្ថបទរឿងរ៉ាវ កត់ត្រាលើផែនថ្ម សិលាចារឹក និងចារសរសេរក្នុងក្រាំង ឬស្លឹករឹតដើម្បីលាតត្រដាងនូវទឹកចិត្តរបស់ខ្លួន សំរាប់ជាកេរ្តិ៍មរតក និងជាវិភាគទានយ៉ាងធំក្នុងវិស័យវប្បធម៌ អរិយធម៌ជាតិផង ៗ ប្រហែលជានៅក្នុងសម័យលំបាក បាក់ទ័ព ក្លាយទីក្រុងដោយសារពួកពតត្បាតបរទេសនេះហើយ ទើបខ្មែរយើងបាត់បង់នូវឯកសារ ក្បួន ខ្នាត ខាងអក្សរសាស្ត្រដោយពួកឈ្លានពានប្លន់យកទៅទុកនៅប្រទេសគេ មានសៀមជាអាទិ៍ ។ តែជាកព្វ័ធំដែរ ដែលពួកឧត្បាតទាំងនេះពុំអាចប្លន់គាស់យកសិលាចារឹកដ៏សំខាន់ ៗ របស់យើងយកទៅបាន ។

# ៣– ផ្នែកទី ២

# អក្សរសាស្ត្រសម័យឧដុង្គឫជ័យ

# គ.ស ១៦១៨–១៨៥៩

## ក– សេចក្ដីបញ្ជាក់.–

សម័យឧដុង្គជាសម័យមាសនៃប្រវត្តិអក្សរសាស្ត្រខ្មែរ ។ ដោយសារព្រះប្រាជ្ញាញាណយ៉ាងធ្លុះធ្លាយ និង ការយកព្រះរាជហឫទ័យទុកដាក់ និង វិស័យវប្បធម៌អក្សរសាស្ត្រជាអាទិ៍ គឺ របស់ព្រះបាទសម្ដេចព្រះហរិរក្សរាមាព្រះអង្គ ឌួង ទើបក្បួនខ្នាតរឿងរ៉ាវផ្សេង ៗ ព្រមទាំងអ្នកនិពន្ធ បណ្ឌិត រាជកវី កើតឡើងយ៉ាងច្រើន ដូចជាផ្សិតត្រូវទឹកសន្សើម ហើយគង់វង្សមកដល់សព្វថ្ងៃ សំរាប់ការសិក្សាត្រិះរិះ អានកំសាន្តរបស់អនុជន ៗ.

### ១– ក្សត្រសំខាន់ខ្លះ.–

ព្រះមហាក្សត្រ ដែលមានព្រះបរមកិត្តិស័ព្ទល្បីល្បាញ ក្នុងវិស័យឧបត្ថម្ភវប្បធម៌ អក្សរសាស្ត្រនាសម័យឧដុង្គ មាន

ដូចតទៅ ៖

– ព្រះបាទជ័យជេដ្ឋាទី ២ គ.ស. ១៦១៨ ដល់ ១៦២០

– ព្រះបាទធម្មរាជារាជសម្ភារ (ព្រះពញាតូ) គ.ស ១៦២៩ ដល់ ១៦៣៤

– ព្រះបាទសម្តេចព្រះហរិរក្សរាមាព្រះអង្គដួង គ.ស ១៨៤១ ដល់ ១៨៦០ ។

## គ- ព្រឹត្តិការណ៍សំខាន់ខ្លះ៖—

ក្នុងរយៈពេលជាង ២៤០ ឆ្នាំនេះ សត្រូវរបស់ខ្មែរ គឺសៀម និងយួនពុំបានអនុញ្ញាតឲ្យខេមរជនរស់នៅដោយសោកសុខចំរើន ក្នុងវិស័យកសាងជាតិ និងកសាងសម្ភិទ្ធិសំខាន់សំរាប់ឡូនភាពរបស់ខ្លួនឡើយ ។ អស់ពីសៀមធ្វើទុក្ខម៉ុកម្នេញដោយរំលោភឈ្លានពាន គឺដល់វេនយួនចិត្តសាហាវប្រើឧបាយទក្រដ្ឋ លុកលុយទឹកដីខ្មែរ សង្កត់សង្កិនប្រជារាស្ត្របំផ្លិចបំផ្លាញភោគទ្រព្យ ផ្ទះសម្បែង និង កេរ្តិ៍ដំណែលខ្មែរជាញឹកញាប់ជងណាស់ ។

ឧទាហរណ៍:

១– ក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋាទី ២ (គ.ស. ១៦១
ដល់ ១៦២៨) ក្នុង គ.ស.១៦២៣ សៀមលើកទ័ព២ លើ
មកតយុទ្ធនឹងព្រះអង្គ តែត្រូវបរាជ័យទៅវិញជាដរាប ។

– ក្នុង គ.ស. ១៦២៣ ស្តេចយួនមានព្រះរាជសារមកស
ឲ្យជាតិយួនចូលមកតាំងនៅជាយខាងត្បូងប្រទេសកម្ពុជា
ព្រៃនគរ ។ យួនបានសុំកាន់កាប់មុខក្រសួងគយផ្ទាប់លើខ្លួ
ពទៀត ។

២– ក្នុងរាជ្យព្រះបាទរាមាធិបតីច័ន្ទ (គ.ស. ១៦៤២ដល
១៦៥៨) ស្តេចយួនចាត់មេទ័ពម្នាក់ឲ្យលើកទ័ពមកវាយប្រ-
ទេសកម្ពុជា ក្នុង គ.ស. ១៦៥៨ ។ វាចាប់ព្រះអង្គច័ន្ទយក
ទៅឃុំនៅស្រុកយួន ទ្រង់ក៏សោយទិវង្គតនៅទីនោះក្នុង គ.ស.
១៦៥៩ ទៅ ។

៣– ក្នុងរាជ្យព្រះបាទជ័យជេដ្ឋាទី ៤ (គ.ស. ១៦៧៥
ដល់ ១៧០៦) មាននាម៉ឺនម្នាក់ ឈ្មោះឧកញ៉ា នរិន្ទ អឹមទៅ

បបួលយួនលើកទ័ពមកច្បាំង ដោយប្រាថ្នានឹងបំផុតខត្តិយវង្ស ហើយក្បត់យករាជ្យសម្បត្តិ ។ ទ័ពព្រះរាជាមានជ័យលើកា ក្បត់ យួនក៏ថយទៅតាំងនៅជាប់ក្នុងខែត្រយ៉ាឌីញ ។ បារៀ បៀនហ្វា (ក្នុង គ.ស. ១៦៩៩) ។

៤– ក្នុងរាជ្យព្រះកែវហ្វា អង្គអិម ( រាជ្យទី ២ គ.ស. ១៧១០ ដល់ ១៧៤២ ) គឺក្នុង គ.ស. ១៧២២ ព្រះចៅសៀម ទ្រង់បានចាត់កងទ័ពធំមកច្បាំងនឹងព្រះកែវហ្វា ។ ទ្រង់បាន លើកកងទ័ពមានទាំងពលយួនជាពលបរិវារទៅតទប់សត្រូវដល់ ខត្តពោធិសាត់ ។ ដោយសារទ័ពសៀមច្រើនពេក ព្រះរាជា ទ្រង់ចាត់ព្រះរាជសារទៅថ្វាយស្តេចសៀម សូមឲ្យឃាត់ព្រះធម្ម រាជានិងព្រះរាជបុត្រទ្រង់ ព្រមទាំងអនុជមន្ត្រីគង់នៅប្រទេស សៀម ហើយទ្រង់សន្យាដាក់ប្រទេសខ្មែរជាចំណុះសៀម ។ ក្តែព្រះរាជកិច្ចសន្យានេះ នាំបណ្តាលឲ្យប្រជាជនកើតទោ- នស្សត្រូវចិត្ត ។ ព្រះកែវហ្វាក៏ទ្រង់ផ្ទេររាជ្យប្រទានមកព្រះ រាជបុត្រព្រះនាមអង្គជ័យ (ឬព្រះសត្ថាវិញ) ។

៥– ក្នុងរាជ្យព្រះសត្ថាទី២ (ព្រះអង្គជ័យ) (គ.ស.១៧២២ ដល់ ១៧៣៦) គឺក្នុងគ.ស. ១៧៣១ នៅភូមិព្រះសុត្ត ខេត្តស្វាយរៀង មានលាវម្នាក់អួតខ្លួនថាជាអ្នកមានបុណ្យ ហើយបានកេណ្ឌាកស្រ្តទៅកាប់សម្លាប់យួន ។ ព្រះបាទសត្ថា ទ្រង់ចាត់ព្រះរាជបំរើឲ្យទៅឃាត់ ។ យួនបានឱកាសក៏លើកទ័ពមក ២ លើក តែរាំងចាញ់ព្រះបាទសត្ថា ។ នៅពេលដែលលើកទ័ពមកជាន់ក្រោយ យួនបានមកតាំងជាប់នៅវិញឡុងនិងមីថរ ។

៦– ក្នុងរាជ្យព្រះបាទឧទ័យអង្គុតន់ (ព្រះឧទ័យទី២) (គ.ស. ១៧៥៨ ដល់ ១៧៧៥) យួនឡើងខ្លាំងណាស់ ។ ដើម្បីសេចក្តីសុខ ព្រះរាជាទ្រង់ព្រះរាជានុញ្ញាតឲ្យមកតាំងនៅក្នុងខែត្រត្រាំងត្រាវិញ ។ តែយួននៅមិនស្កប់ រាបេះតែរុករាននៅសាដែក (ខេត្តផ្សារដែក), គូឡោយាង (កោះតែង) និងចូវដុក (មាត់ជ្រូក) ទៀត ។ នៅឆ្នាំគ.ស.១៧៦៩ ពញា-តាក ស្ដេចសៀមបានញុះញង់ព្រះអង្គនន់ សូមឲ្យទ្រង់លើកកងទ័ពធំតាមដើរទឹក ដើរគោកចូលមកប្រទេសកម្ពុជា ។

ព្រះបាទឧទ័យអង្គនន់ ទ្រង់កៀសពីក្រុងឧដុង្គទៅគង់ឯព្រៃនគរ ។

៧– នៅក្នុងរជ្យព្រះបាទអង្គអេង (គ.ស. ១៧៧៩ ដល់ ១៧៩៦) ស្តេចសៀមឈ្មោះពញាតាកបានចាត់ឲ្យលើកកងទ័ពមកវាយគ្នាយដល់ឧដុង្គ ។ តែដោយពញាតាកនេះត្រូវអកក័ព្វគេលបសម្លាប់ ទ័ពសៀមក៏ថយទៅវិញអស់ ក្នុង គ.ស. ១៧៨២ ។

ដោយសារមានការក្បត់របស់នាម៉ឺនចិត្តអាក្រក់ ដូចជាចៅហ្វាបែនជាដើម (បានកាន់កាប់រាជការផែនដី ១១ ឆ្នាំ គឺពី គ.ស. ១៧៨២ ដល់ ១៧៩៣ ) សៀមវាត់អំណាច ហើយដាក់នគរខ្មែរជាចំណុះ ។ វាបានសុំយកខេត្តបាត់ដំបង និងសៀមរាប ដាក់ឲ្យចៅហ្វាបែន ត្រួតដោយឡើងផ្ទាល់ក្រុងសៀម (គ.ស. ១៧៩៤) ។

៨– ក្នុងរជ្យព្រះបាទអង្គច័ន្ទទី ២ (ព្រះឧទ័យរាជា គ.ស. ១៨០៦ ដល់ ១៨៣៤) យួនវាត់អំណាចកំហែងដាក់ប្រទេស

កម្ពុជាជាចំណុះ ស្ដេចអណ្ណាមឈ្មោះ យ៉ាឡុង ។ ចំណែ
សៀមវិញ ក្នុង គ.ស. ១៨១៤ បានលើកទ័ពចូលមកក្នុងខេ
មូលព្រៃ ទន្លេរពៅស្ទឹងត្រែង តាំងទីលំនៅ ៗ តំបន់នោះ
ក្នុង គ.ស. ១៨១៦ មេទ័ពយួនកេណ្ឌខ្មែរឲ្យជីកព្រែកមួយ
មាត់ជ្រូកទៅពាម (ហាទៀន) ។ យួនឲ្យឈ្មោះថាព្រែ
"វិញតេ" ខ្មែរហៅថា "ព្រែកជីក ឬព្រែកយួន" ។ ព្រែ
នេះយួនទុកជាព្រំប្រទល់ប្រទេសខ្មែរ និង យួន គឺខាងត្បូងព្រែ
យួនទុកជាដីវា ។ ក្នុងគ.ស. ១៨២៩ ស្ដេចសៀមចាត់
ញាបឌិន ជាមេទ័ពឲ្យលើកកងទ័ពនាំតាំងព្រះអង្គអិម និងព្រ
ឌួងចូលមកកម្ពុជា ។ សៀមឥតមានប្រកាសសង្គ្រាម
នទេ ស្រាប់តែវាយដល់ពោធិសាត់តែម្ដង ។ ព្រះអង្គច័
ទ្រង់ភៀសទៅគង់នៅខេត្ត លង់ហោ (វិញឡុង) ។ ទ័ពសៀ
ញតាមព្រះអង្គ តែរ៉ាបាញ់ទ័ពយួន ។ សៀមក៏ថយទៅវិញ

៩— សៀមនិងយួននេះ ប្រាថ្នាមួយតែនឹងបំបាត់ព្រះវ
ក្សត្រខ្មែរយើង ។

ក្នុងរាជ្យព្រះក្សត្រី អង្គម៉ី (គ.ស. ១៨៣៤ ដល់ ១៨៤១)
...ាចតាំងអស់នៅក្រោមដៃនៃភ្នាក់ងាររាជការយួន ៣ នាក់ គឺ
...ៀនមិញយ៉ាង, ផាំ វ៉ាំង-យ៉ាង និង ត្រឹងវ៉ាំង-ណាង ។ យួន
...ាស់ឈ្មោះស្រុក ខេត្ត ភ្នំពេញ ជាត្រឹងតាយ ឬ ណាំ-យ៉ាង ។
...ហ្វាយស្រុក ខេត្តមាននាយកយួនត្រួតត្រា ហើយវាបង្ខំឲ្យ
...ស្លៀកពាក់តាមយួន ។ វាបង្ខំឲ្យរាជការខ្មែររកអាហារចិញ្ចឹម
...ហានយួននៅក្នុងស្រុក ។ វាកាប់ដើមពោធិបំផ្លាញព្រះពុទ្ធ
រំលាយព្រះចេតិយ ដុតវត្តទោល នាំប្រជាជនខ្មែរឲ្យ
...ះបង់ពុទ្ធសាសនាទៅកាន់ពាហិរសាសនាវិញ ។ យួនរក
...ង នាំយកព្រះអង្គអឹមទៅបង្ខាំងទុកក្រុងហ្វេ ហើយនាំព្រះ
...ធីតាអង្គមី និងព្រះពង្សវង្សបង្ខាំងទុកនៅព្រៃនគរ ។
ប្រជាជនខ្មែរកើតក្ដីក្ដៅក្រហាយក៏បះពេញប្រទេស ។
...ខ្លះបានមកគ្នាជាសម្ងាត់ ហើយក្នុងសម័យមួយក៏លើកគ្នា
...ពិឃាតយួនគ្រប់កន្លែងរវាង ៨ ថ្ងៃ នៅសល់តែទីប្រជុំជន
...១ ។

១០— ក្នុងរជ្ជកាលព្រះបាទអង្គឌួង (គ.ស. ១៨
ដល់ ១៨៦០) រាជការយួនបានកេណ្ឌទ័ពចូលមកច្បាំងក
ទៀត ។ ខាងទ័ពខ្មែរ មានពញាបឌិន ជាមេបញ្ជាការ
ច្បាំងនេះយូរណាស់ជាប់៤ឆ្នាំ គឺពីគ.ស.១៨៤១ ដល់ ១៨
តែមិនមានចាញ់ឈ្នះឡើយ ។ ក្រោយបំផុត មេកងទ័ពទាំ
២ ខាងក៏ព្រមឈប់ លើកព្រះបាទសម្ដេចព្រះអង្គឌួងជាព្រ
នៅផែនដី ។ រាជការក្រុងសៀមនិងក្រុងអណ្ណាម សំរេចព្រ
សន្ធិសញ្ញា គ.ស. ១៨៤៦ ។ យួនព្រមបើកព្រះខត្តិយា
អង្គម៉ី ព្រមទាំងព្រះរាជវង្សានុវង្ស ខុននាមុឺនឲ្យយាងអញ្ជើញ
ត្រឡប់មកប្រទេសខ្មែរវិញ ។

នៅចុងរជ្ជព្រះអង្គឌួង គ.ស. ១៨៥៩ មានចាមនៅ
ត្បូងឃ្មុំ ដែលចង់បង្កើតខេត្តតាមជាចៅឯង ។ ទ័ពហ្លួងរាយ
ទ័ពតាមខ្ទាត់ខ្ទាយដល់មាត់ជ្រូក ។ យួនប្រុងនឹងជួយចាម តែ
ដោយអកុសលកម្ម យួនក៏ត្រូវបារាំងយកព្រៃនគរបានទៅ ។

ឃ) ផលវិបាកនៃព្រឹត្តិការណ៍ មកលើអក្សរសាស្ត្រខ្មែរ.–

ដោយអំពើឃោរឃៅតាមប្លន់ទឹកដី របស់សត្រូវជិតស្រុក គឺសៀមនិងយួនដែលនេះ ប្រទេសជាតិត្រូវរៀបចំខ្លួនតទប់ និងបង្ក្រាំងទ្រាំនឹងជាន់វិស័យស្ពាយនាជាតិនានា ។ វិស័យអក្សរសាស្ត្រខាងដើមសម័យកាល ពុំសូវមានសកម្មភាពឡើយ ។ ទើបតែនៅក្នុងសម័យកាលខាងចុង គឺក្នុងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្សរាមាព្រះអង្គឌួង (គ.ស ១៨៤១ ដល់ ១៨៦០) ដែលអ្នកនិពន្ធ កវី បណ្ឌិត្យ ផុះឡើងជាបន្តបន្ទាប់គ្នាកាន់តែច្រើនក្នុងរៀបរៀងនូវក្បួនខ្នាត រឿងរ៉ាវសំខាន់ៗ បង្កើតយុគថ្មីអក្សរសាស្ត្រ ។ ក្នុងសម័យឧដុង្គជ័យនេះ អក្សរសាស្ត្រលើថ្មពុំមានដូចជាពេលមុនទេ ។ យើងសម្បូរណ៍ឯកសាររឿងក៏ដែលមានកត់ត្រាក្នុងក្រាំង និងស្លឹករឹត ។

ង) លក្ខណៈទូទៅនៃអក្សរសាស្ត្រសម័យឧដុង្គ.–

## ១- អំពីអត្ថន័យនៃអត្ថបទ.-

សឹងតែទូទៅ រឿងរ៉ាវផ្សេងៗក្នុងសម័យឧដុង្គ មានលក្ខណៈជារឿងប្រឌិតចងក្រង តាមបែបមនោសញ្ចេតនា ។ អ្នកនិពន្ធជ្រើសរើសយករឿងក្នុងជាតកបែបបាលី (មានបញ្ញាសជាតក ឬជាតកក្នុងអដ្ឋកថានៃព្រះត្រៃបិដកជាដើម) មកច្នៃតែងផ្សំប្រមុំតាមចិត្តគំនិតរបស់ខ្លួន ដើម្បីសម្រេចទៅតាមជំនឿ បញ្ហាការរស់នៅ ជាសុខ ជាទុក្ខ ជាសប្បាយ និងជាព្រួយដែលព្រឹត្តការណ៍នៃសម័យកាលជម្រុញឲ្យ ។ គេឃើញមានរឿងផ្សងព្រេងដោយមានអច្ឆរិយហេតុផ្សេងៗ ដូចជាពួកអគ្គទេវៈ ខ្មោច យក្ស អារក្ស អ្នកតា ឬមនុស្ស ចេះមន្តអាគមហោះហើរពូកែខ្លាំងក្លាមកនិទាន ។ មនុស្សហាក់ដូចជាអស់សង្ឃឹមលើជីវិតផ្ទាល់របស់ខ្លួន ហើយប្រើមនោគតិគិតពិចិត្រជឿទៅលើហេតុភេទអស្ចារ្យ ដែលខ្លួនយល់ថាពូកែជាង អាចជួយរំដោះទុក្ខលំបាករបស់ខ្លួនក្នុងជាតិនេះ ឬទៅជាតិខាងមុខ ។ ក្នុងជាតិបច្ចុប្បន្ន គេជឿថា នឹងមានបុណ្យ

មកជួយរំដោះបញ្ហាការរស់នៅដ៏លំបាកច្រួលច្របល់របស់ខ្លួន ដើម្បីសំរេចនូវបរមសុខក្សេមក្សាន្ត ។ ទៅអនាគតជាតិ គេ ជឿថាមានគតិពីតាំងទួល ។ អ្នកធ្វើល្អ សន្សំកុសលផល បុណ្យពីជាតិបច្ចុប្បន្ន លុះធ្វើមរណកាលទៅ ទិនបានទៅបដិ សន្ធិសោយសុខនាវិមានសួគ៌ ត្រៃត្រឹងក្នុងទេវលោក ។ អ្នកធ្វើអាក្រក់ សាងតែអកុសលកម្ម ធ្វើទុក្ខបុកម្នេញ កាប់ សម្លាប់ផ្ទះជាន់បុនៈតរ៏រេងនាភ្នាម ៗ លុះស្លាប់ទៅក៏ទទួលក្តី លំបាកគឺ រហូតទៅជាតិមុខត្រូវធ្លាក់ចុះនរកអវិចី កើតជាប្រេត តិរច្ឆានសុីខ្ទះ សុីឈាមរកទីបំផុតគ្មាន ។ គឺងស្រនបែបនេះ ដែលកើតជាបញ្ហាល្អ អាក្រក់ បុណ្យ បាប ក្នុងកម្មផល ក្នុងអត្ថន័យនៃរឿងក៏ៈជាច្រើនមាសម័យខ្ពង្គ ទិនសម័យត មកទៀត ។

ការកើតមានឧ្ទបញ្ហាកម្មផលជាមូលហេតុ ក្នុងរឿងនៃ អក្សរសាស្រ្តបែបនេះ មានបុព្វហេតុមកតែពីសេចក្តីភិតភ័យ លំបាករងទុក្ខទោសយ៉ាន់ត្រណកម្មរបស់ប្រជាកស្រ្ត ដោយ

សាព្រឹត្តិការណ៍ចំបាំងកំពុងផល់ដំក្រៀង របស់ពួកសត្រូវឈ្លានពានប្ដូនទឹកដីនៃប្រទេសជិតខាងនេះឯង ។ មនុស្សប៉េកព្រួកទៀតឃើញតែការសម្លាប់ រត់ពួន អត់ឃ្លាន ភ័យភិតគ្មានល្ហែៗ ដូច្នេះ សេចក្ដីសង្ស័យចំពោះខ្លួនឯងសស់រលីង ។ ដើម្បីរំលាយនូវទុក្ខសោកពេកភ័យដែលញាំញីក្នុងសន្ដានចិត្តរបស់ប្រជាជនចំពោះហេតុការណ៍បែបនេះ មធ្យោបាយរំដោះ គឺត្រូវតែយកឱសថទាន់ផ្លូវចិត្តមកប្រើ ។ ឱសថបែបនេះគឺភាពអស្ចារ្យនិងបញ្ហាកម្មផលនេះឯង ។ អស្ចារ្យដោយបង្កើតតួអង្គមានសមត្ថភាពខាងផ្លូវកាយ ផ្លូវសម្ភារ ដើម្បីជួយអ្នករងទុក្ខ ។ ឧទាហរណ៍ ដូចជាតួអង្គពោធិសត្វដែលជួយផ្ចាញ់យក្សកាលម្រឹតដើម្បីរំដោះទុក្ខលំបាករបស់មនុស្សជាតិជាដើម ។ បញ្ហាកម្មផលដោយយកទស្សនៈ បុណ្យ បាប ល្អ អាក្រក់ សុខ ទុក្ខ មកធ្វើជាគោល បង្កើតជាបញ្ហា និងគំនិតថា "នរណាធ្វើល្អបានល្អ នរណាធ្វើអាក្រក់បានអាក្រក់" "កម្មសឲ្យផលស កម្មខ្មៅឲ្យផលខ្មៅ" ជាដើម ។ ដើម្បីជារង្វាន់ចំពោះមនុស្សល្អ

គេបង្កើតបានស្មូតិ ទេវលោកសំរាប់លើកទឹកចិត្ត ហើយដើម្បីផ្តន្ទាទោសចំពោះមនុស្សអាក្រក់ គេបង្កើតនរក ប្រេត អវចីសំរាប់បំភ័យឲ្យអនុជនខ្លាច ស្អប់អកុសលកម្ម ខិតខំកែប្រែចិត្តគំនិតបែរមកសខ្សំស្រឡាញ់កុសលកម្ម ឬអំពើល្អវិញ ។

គ្រប់តែរឿង ឬអត្ថបទនាសម័យឧដុង្គ អ្នកនិពន្ធបំបែរគោលដៅទៅរកការអប់រំ ការសម្រាលទុក្ខសោកពេកភ័យមួយចំណែកធំរបស់មនុស្សជាតិ ។ ដោយសារលក្ខណៈសំរាប់តែក្តីហត់នឿយ លំបាកចិត្ត គំនិតនៃអត្ថបទបែបនេះហើយ ទើបខេមរជនឲ្យឈ្មោះរឿងខ្លះទៅក្នុងសម័យឧដុង្គ និងក្រោយនេះថាជា "សាស្ត្រល្បែង" ពោលគឺសាស្ត្រអានទៅសម្រាប់បន្ធូរចិត្តទុក្ខព្រួយ ចិត្តលំបាកតឹងតែងឲ្យធូរស្រាល ។

## ២– អំពីអត្ថរូបនៃអត្ថបទ

ចំពោះវិធីតែង គេប្រើពាក្យជាមធ្យោបាយ ។ រឿងសឹងតែខ្លះទៅតែងឡើងជាកំណាព្យដ៏មានបទផ្សេង ៗ គ្នា មានបទកាកគតិ ព្រហ្មគីត ភុជង្គលីលា បន្ទោលកាក ឬ ពំនោលជា

ដើម ។ ការដែលយកពាក្យកាព្យមកប្រើបែបនេះជាមធ្យោបាយសម្របសម្រួលទៅតាមគោលបំណង ក្នុងឧត្តមគតិរឿងដែលចំពោះអារម្មណ៍ បន្ទរក្តីទុក្ខព្រួយឲ្យសោយនេះឯង ។

អត្ថបទនានាកត់ត្រាតែទៅលើឯកសារ ៣ បែបគឺ:

—បែបទី ១— កត់ត្រាលើក្រាំង ដែលមានសន្លឹកបើកបានសន្ធាន ៗ គេសរសេរដោយស្លាបប៉ាក្កាឬស្លាបសត្វ ដោយប្រើទឹកខ្មៅចិន ។ សន្លឹកក្រដាសនេះធ្វើឡើងក្នុងប្រទេស ហើយមានកម្រាស់ក្រាស់ ជាប់ អាចរក្សាទុកបានយូរលង់ ។

- បែបទី ២— កត់ត្រាលើក្រាំងដូចបែបទី ១ ដែរ តែក្រដាសមានពណ៌ខ្មៅ ហើយគេសរសេរដោយដីសថ្ម ។

—បែបទី ៣— កត់ត្រាលើស្លឹករឹតដែលចងទំលុះខ្សែតាមរៀងទំព័រ ហៅថា "សាស្ត្រា" :

ឯកសារទាំង ៣ បែបនេះងាយរក្សា ការពារទប់ទល់នឹងអាកាសធាតុបាន ។

ក្នុងរបៀបតែងអត្ថបទ ឯកសារសឹងតែទូទៅ មាន

លក្ខណៈដូចតទៅ :—

ទី ១ : គឺសេចក្តីផ្តើម មានជាបទនមស្ការ ព្រះរតនត្រ័យ រំលឹកគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ រំលឹកគុណព្រះមហាក្សត្រ មាតា បិតា គ្រូបាធ្យាយជាដើមៗ ខ្លះមានបញ្ជាក់ពេលវេលា ថ្ងៃខែឆ្នាំ នៃការតែង ៗ ឆ្នាំដែលប្រើ ច្រើនជាពុទ្ធសករាជ មហាសករាជជាដើម ៗ ខ្លះមានប្រាប់ឈ្មោះផង ឋានសក្តិ លំនៅឋានរបស់ខ្លួនជាអ្នកនិពន្ធ ៗ ខ្លះមានប្រាប់ប្រភពរឿងដែលខ្លួនបានដកស្រង់យកមកតែង រចនា ៗ ប៉ុន្តែរឿងមួយភាគធំបែរជាពុំមាន ឬបាត់នូវលក្ខណៈដូចរៀបរាប់មកហើយ (ដូចជាកាលបរិច្ឆេទ និងឈ្មោះអ្នកនិពន្ធជាដើម) ។

ទី ២ : គឺតួសេចក្តី ដែលជាដំណើររឿង ៗ អ្នកនិពន្ធប្រើពាក្យពេចន៍ធម្មតាលាយឡំនូវ ម.គធ ភាសា

ឬ ស៊ីស្រីគមន៍ចបន្តចតាមចំណោះបេះដូងរបស់ខ្មែរក្នុងការតែង រៀបរៀងរឿង ។

ទី ៣ : គឺសេចក្តីបញ្ចប់ វេលាការបំពេញការរឿងដោយ ការឧទ្ទិសប្រាថ្នាទូទៅ ។ល។ ជាបែបអធិដ្ឋាន ឬជា ការសជាតិ ប្រសិនបើរឿង នោះមានប្រភពចេញមក ពីពុទ្ធសាសនា ។

## ៣– អំពីអត្ថរសនៃរៈក្ខុបធ

ដោយសារជារឿងសំរាប់ខ្ញុំ ដូច្នេះត្រូវមានអត្ថរស្ម័យ ធម្មតា កំសត់ កំប្លែងដែលជាហេតុ ប្រែប្រួលទៅអត្ថរសទូទៅ របស់អត្ថបទ ។

## ប– អ្នកនិពន្ធ និងអត្ថបទរឿងក្នុងសម័យឧដុង្គ

ដើម្បីជាសក្ខីភាពនៃអក្សរសិល្ប៍ សម័យឧដុង្គ យើង លើកយកអ្នកនិពន្ធ និងស្នាដៃដែលមានលក្ខណៈច្បាស់លាស់ មកបញ្ជាក់តាមប្រភេទដូចតទៅ ៖(១)

(១) តាមលោកសាស្ត្រាចារ្យ កេង-វ៉ាន់-សាក់ នៃមហាវិទ្យាល័យ (ភ្ន)

## ទី១: សន្ទស្សន៍អក្សរសិល្ប៍ :

ក្នុងប្រភេទអក្សរសិល្ប៍នេះ យើងអាចលើកយកព្រះរាជ
ជសម្ភារមកបញ្ជាក់អំពីលក្ខណៈ ស្នាព្រះហស្ថរបស់ព្រះអង្គ
ដូចតទៅ :–

**ព្រះរាជសម្ភារ**

## កវីរាជក្នុងសតវត្សទី១៧ គ.ស. ១៦២៩-១៦៣០

---

ក្សរសាស្ត្រ និងមនុស្សសាស្ត្រ លោកបានចែកប្រភេទវិភាគនៃអក្សរសិល្ប៍ជា
បង្កាមគឺ :

ទី១ : សន្ទស្សន៍អក្សរសិល្ប៍=la littérature du genre narratif

គឺមាន

១– ពិពណ៌នាកថា : Description,

២– វណ្ណនាកថា : Narration

៣– បដិពិម្ពកថា : Portrait,

៤– និទានកថា : Récit,

៥– វុឌ្ឍកថា : Reportage

៦– សារកថា : lettre (genre épistolaire)

(ឆ្នាំ)

(ចង់សិក្សាព្រះរាជជីវប្រវត្តិ និងស្នាព្រះហស្តច្បាស់ សូមអាន "អ្នកនិពន្ធខ្មែរ ព្រះរាជសម្ភារ" របស់ លាង-ហាប់-អាន ផ្សាយក្នុងទស្សនាវដ្តីអក្សរសាស្ត្រខ្មែរ ឆ្នាំ ១៩៦៤ និងផ្សាយជាលើកទី ៣ ដោយបណ្ណាគារ សេង-ងួន-ហួត ឆ្នាំ ១៩៦៦)។

## ក) រាជជីវប្រវត្តិ:–

ព្រះរាជសម្ភារ ជាព្រះរាជបុត្រច្បងរបស់ព្រះបាទជ័យ-

---

ទី២ : ប្រលោមអក្សរសិល្ប៍ : La littérature du genre romantique គឺមាន

១– ប្រឌិត និងព្រេងកថា : Conte et légende

២ – វីរកថា : Epopée

៣-- និរកថា : Fable

៤ – ប្រលោមកថា : Roman

ទី ៣ : នាដកម្មអក្សរសិល្ប៍ : La littérature du genre théâtral

១– នាដ្យកថា : Le drame

២– ហាសកថា : Comédie

៣– ទារុណកថា : La tragédie

ទី ៤ : ឧបទេសអក្សរសិល្ប៍ : La littérature du genre didactique គឺមាន :

(ឆ្លង)

ជេដ្ឋា និងអ្នកម្នាង សុខ ។ ទ្រង់បានទទួលរាជាភិសេកក្នុង គ.ស. ១៦២៩ មានបរមនាមថា "ព្រះបាទសម្តេចស្តេចព្រះរាជឱង្ការ ព្រះស្រីធម្មរាជា រាមាធិបតី" ។ ពង្សាវតារកំណត់ព្រះនាមតែត្រឹម "ព្រះស្រីធម្មរាជា" ឬ "ព្រះរាជសម្ភារ" ។ ព្រះរាជាអង្គនេះជាក្សត្រទ្រង់ធម៌ ជាបណ្ឌិតរាជ ។ ដោយសារ

---

១– សុភាសិតកថា : Maximes et pensées

២– ទូន្មានកថា (ច្បាប់ប្រដៅផ្សេងៗ): Conseils généraux

៣– ល្បើកកថា : Fables,

៤– ឧបាលម្ភកថា : Satire.

៥– សុន្ទរកថា : Discours

ទី ៥ : ទិដ្ឋិអក្សរសិល្ប៍ : La littérature du genre à thèse

គឺមាន :

១– អត្ថាធិប្បាយកថា : Commentaire

២– ឧស្សាហ៍កថា : Essai

៣– វិវេចនកថា : Critique,

៤– សិក្សាកថា : Etude (littéraire)

៥– អក្សរសិល្ប៍កថា : Texte littéraire (de choix)

(ចង់ជ្រាបច្បាស់អំពីលក្ខណៈពិសេសនៃកថានីមួយៗនេះ សូមអានសៀវភៅសិក្សាអត្ថបទ "ភាគ១ និង ២" របស់ លាង-ហាប់-អាន) ។

មានតៃកុក្កុដនៅរៀនស្នេហាព្រះនាង អង្គតែ ជាមួយស្ដេចនា ព្រ
នាមព្រះបាទទុទ្ធំយ ព្រះអង្គភៀសខ្លួនទៅខេត្ត កញ្ចៈ (ខេ
ក្រចេះសព្វថ្ងៃ) ហើយក៏ត្រូវទ័ពបរទេសដេញតាម ហើយបា
ធ្វើគត់ទាំង ២ អង្គដោយគ្រាប់កាំភ្លើងទៅ ។

មុននឹងត្រូវបាក់ង (ឬពាក់ទុយគ្រោស) បាញ់ប្រហារព្រ
អង្គ ស្ដេចព្រះហស្ត មានព្រះតម្រាស់ថា :—

“បាក់ងអប្សលក្ខណ៍ រាដេញបាញ់អ្នក ព្រះរាជសម្ភា
ឡើងលើចុងភ្នាក ពុំគោគចេស្ដា អ្នកលើកហត្ថា កាំង
ឃាត់ទុក ។ ”

១– ស្នាព្រះហស្ត ទាំងឡាយដូចខាងក្រោមនេះ
មានឯកសារត្រឹមត្រូវតាមរាជតន្ត្រាការតំកល់នៅវិជ្ជាស្ថានពុទ្ធ
សាសនបណ្ឌិត្យ ព្រមទាំងចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយាគឺ :

១– ច្បាប់រាជនីតិ (១)

(១) មាននៅក្នុងសៀវភៅព្រះរាជសម្ភារ ផ្សាយដោយបណ្ណាគារ សេក-ម្អូត ១៩៦២ ទំព័រ ២៩ ដល់ ៣៧ ។

២– ច្បាប់ព្រះរាជសម្ភារ(១)

៣– លិខិតផ្ញើទៅថ្វាយព្រះម៉ែយួរវត្តី

៤– ពាក្យកាព្យប្រារព្ធដំកំពូលភ្នាក មុនពេលសុគត ដោយតាហា· ចាក់ឥតាញ់

៥– កណាព្យសរសើរហេមន្តមាស

៦– កំណាព្យ ''កន្ទងមាសមគ្គលថ្ងៃ''

៧– កំណាព្យ ''ព្រលឹងមាសអើយ''

៨– ច្បាប់ក្រម(២)

៩– ច្បាប់ហៃសាធុជន ឬ ច្បាប់ត្រីនេត្រ(៣)

## គ– លក្ខណៈស្នាដៃក្នុងប្រភេទសារកថា

ស្នាដៃទាំងឡាយគឺ : លិខិតផ្ញើទៅថ្វាយព្រះម៉ែយួរវត្តី ពាក្យកាព្យ បារព្ធដំកំពូលភ្នាក់, កំណាព្យសរសើរហេមន្ត-

(១)...ក...ក្នុងទំព័រ ៣៧ ដល់ ៤៥

(២)...ក...ក្នុងទំព័រ ៧០ ដល់ ៧៨

(៣)...ជ...ក្នុងទំព័រ ៧៩ ដល់ ៨៦ ដែលយើងនឹងយកទៅបញ្ចូល ក្នុងប្រភេទឧបទេស អក្សរសិល្ប៍ ។

មាស, កំណាព្យកន្ទន់មាសមង្គលថ្ងៃ, កំណាព្យព្រលឹងមាស-អើយ រាប់បានជាសារលិខិតថ្លែងនូវមនោសញ្ចេតនា ស្នេហាឥតពុក និងពាក្យសន្យាដែលព្រះរាជសម្ភារទ្រង់ផ្ញើទៅនាងម៉ែយ្យូរវត្តី ជាគូសន្យា ។

## ១ - លិខិតផ្ញើទៅថ្វាយព្រះម៉ែយ្យូរវត្តី(១)

### ក- សេចក្ដីផ្ដើម

“មិត្តស្នេហ៍ស្ងួន គូសាងនិងបង កាលកអវិជ្ជា· តែងគ្រាប់រគ្នាត់ក្នុងវដ្ដកញ្ញារ ឆ្លាស់ឆ្លងប្រហល តម្កើជលស័យ” ។

### ខ) តួសេចក្ដី·-

ព្រះករកណ៌រៀបរាប់ នូវអស់អនុស្សាវរីយ៍តាំងពីកុមារភាព និងការរំលឹកនូវបណ្ដាំផ្សេងៗរបស់ ព្រះនាងម៉ែយ្យូរវត្តី ដោយសេចក្ដីរលឹកសោកស្ដាយអាឡោះអាល័យគ្នាយ៉ាងខ្លាំង ។

### គ) សេចក្ដីបញ្ចប់·—

“បើបានដូចចិត្ត បំណងគំនិត មូលមួយហឫទ័យ តាំង

(១) អត្ថបទទាំងស្រុងនៅក្នុង “ព្រះរាជសម្ភារ„ របស់លោកហាប់អាន ទំព័រ ៨៦ ដល់ ៨៩ ។

ះហៅបុណ្យ ពីមុនក្រាស់ក្រៃ ទើបបានមូលមៃ ត្រឹមត្រូវ

រិបាល" ។

## –ពាក្យកាព្យចារលើកំពូលត្នោតមុនពេលសុគត(១)

### ១) អត្ថបទ.—

"សាធុសម្មាយ កុំបីភាយមាយ ខឹងក្ដីកាមា តែងឲ្យ

ទ្ធន គុណវុឌ្ឍសន្និភ្ជះ ស្លាប់ទៅកាលណា បានសោយតែ

ក្ខ ៗ ហេតុតែក្បត្រី ទាំងឲ្យអប្រិយ៍ ដូចត្រីក្នុងភក់ បើបុរស

ក បង់ឆ្លងនរក កុំធ្វើវក់ ដូចអញ្ចោះណា ៗ ពីព្រោះ

មេ ឥឡូវតាល់តែ ក្សិណក្ស័យមរណា សូវស្លាប់ទៅតាម

យជាប់ធម្មា សូមអស់ទេវតា ជួយជាទិព្វញាណ ៗ ទើប

ះភូមិ-ន្ទ្រាធិបតិន្ទ ទ្រង់អធិដ្ឋាន ពីនេះទៅមុខ ខ្ញុំសូមឲ្យ

ន ជាព្រះពុទ្ធញាណ នាំសត្វទាំងឡាយ ៗ ខ្ញុំអ្នកទាំង

ស ជាតាពានហ្វូន នាំយកទៅថ្វាយ ព្រះបិតុច្ឆា ទ្រង់ជ្រាប

---

(១) អត្ថបទនេះស្រង់មានចៅក្នុងព្រះរាជសម្ភារៈ របស់ ណង-ហាប់-អាន

ទី ៥០ ជិត: :.. ។

អធិប្បាយ កុំទ្រង់ភយមាយ និងក្តីកាមេ» ។

## ២- អត្ថន័យនៃអត្ថបទ.-

អត្ថបទនេះមិនគ្រាន់តែមាន ប្រយោជន៍សំរាប់លុបលា
នូវទោសកំហុសរបស់ទ្រង់ ក្នុងការរំលោភបំពានធម៌កាមេ
ប៉ុណ្ណោះទេ តែជាការប្រៀនប្រដៅព្រះបាទឧទ័យជាព្រះបិតុ
ច្ឆា ដែលប្រព្រឹត្តអំពើមិនគប្បី ពុំគោរពតាមពាក្យសន្យាផុតផ្ដា
ផ្តាំផ្ញើរបស់ព្រះបាទជ័យជេដ្ឋាដែលផ្សំផ្គុំជាស្រេច នូវទ្រង់និង
ព្រះនាងអគ្គវត្តីតាំងពីព្រះកុមារម្ល៉េះ ។ ពាក្យបណ្តាំនេះបញ្ជាក
ថា ទោសនៃកាមតណ្ហា និងការបំពានធម៌កាមេ ជាបាបកម្
មួយគួរអនុផនខ្លាច ហើយកុំសង្វាតឲ្យសោះ ។

## ៣- កំណាព្យសរសើរហេមន្តមាស (១)

ព្រះនិពន្ធពជទ្រង់បាឧប្រាថ្នា នូវស្នាព្រះហស្តនេះក្នុ
គោលបំណងថ្វែងនូវទុក្ខសោកខាងផ្លូវចិត្ត ចំពោះការព្រាត

---

(១) អត្ថបទទាំងស្រុងនៅក្នុង «ព្រះរាជសម្ភារ» របស់ លោក ហាប់ អា
ទំព័រ ៨៣ ដល់ ៨៦ ។

និភាសព្រះនាងមៃយូរវត្តី ។ កំណាព្យនេះតែងជាបទព្រហ្មគីតៈ

### ក) អត្ថបទ.–

"ដំណែនដំណើរនា សរសើរគ្រាហេមន្តមាស ត្រសៀកឯកាកាស សែនសាយល្ហេវទៅ ។ ស្រណោះបក្សាគរ ឯអម្ពរទ្រៀលធ្លាត់ស្ងៅ សំកុកសំកាំងនៅ សងសួរសានសព្ទយាសយំ ។ .................. ស្រណោះនៅខែប និត្យ គ្រេកគ្រូវចិត្តស្ទើរស្មោះសរ ប៉ិតប៉ានពនេចរ កបហ្ឫទ័យសោកស្នេហ៍ស្នាល" ។

### ខ) អត្ថន័យនៃអត្ថបទ.–

ព្រះកវីពណ៌រាប់រៀបធម្មជាតិ ទេសភាពតាមឧបមានវិធី និងការពិតទៅតាមកាលវេលា តាមរដូវ ដែលផ្តល់នូវអនុស្សាវរីយ៍ពោរពេញទៅដោយក្តីស្រណោះ អាលោះអាល័យ និងនឹកចិត្តជាប់ជំពាក់ស្នេហាយ៉ាងរំភើប ។ ព្រះកវីផ្ចង់ផ្ចុំ ស្មុនអារម្មណ៍ទៅលើទេវីជាគូរកំណាន់ពេកតាស់ ។

## ៤- កំណាព្យ "កន្លង់មាសមង្គលថ្លៃ".(១)

កំណាព្យនេះឋិតនៅក្នុងព្រះរាជសារដែលព្រះរាជសម្ភារ តែងផ្ញើទៅបណ្ដូលកល្យាណរបស់ព្រះអង្គ ។ កំណាព្យនេះ តែងជាបទកុដុគ្គលីលា ។

### ក- អត្ថបទ..

"កន្ទន់មាសមង្គលថ្លៃ ភ្លៀលធ្លាក់វិលវរ ទ្រហឹងខ្លាយខ្ចរ ។... កន្ទន់គ្រាប់គ្រន់ឫស្សី ដូចបងនិងស្រីរួមរស់ស្នេហា"។

### ខ. អត្ថន័យនៃអត្ថបទ

ព្រះកវីកជប្រៀបធៀប រូបទ្រង់ទៅនឹងកន្ទន់ដែលជាបាណកសត្វតូចបង្គួរតែងរស់នៃបុប្ផានានា ។ ទោះមិឋិតនៅក្នុងអាកាសដ្ឋានណាក៏ដោយ ឬទោះបីមានម្ចាស់ការពារ ឬជាកម្មសិទ្ធិរបស់ជនដែលណាក្ដី បុប្ផាជាចំណីតាមប្រាសើររបស់កន្ទន់ ។ ដូចេះភូមរីមិនដែលទេះនឿយណាយឬបំភ្លេចហោល បានឡើយនូវបុប្ផាដែលខ្លួនធ្លាប់ស្គាល់ ធ្លាប់ត្រើប ធ្លាប់ក្រេប

(១) អត្ថបទទាំងស្រុងនៅក្នុង "ព្រះរាជសម្ភារ" ទំព័រ ៥៨ ដល់ ៥៩ ។

ទេឡើយ ។

## ៥- កំណាព្យ ព្រលឹងមាសអើយ(១)

### ក. អត្ថបទ.-

"ព្រលឹងមាសអើយ ចូរចេញទៅព្រៃហើយ មន្ទាបស៊ូរិយា ស្រណោះសព្វសត្វ ធ្លៀលធ្លាក់វេហាស៍ ចុះចាប់ព្រឹក្សា សសិតស្លាបយំ ។ . . . មាសអើយផ្ចង់ ព្រលឹកឈស្រើន លាស់លូតមានផ្កា ស្គន់ស្គុះត្រកៀត ស៊ីកសៀតស្លាបតា ស្មោមស្លាបច្រវ៉ា កំពីងពួយពាស ។ មាសអើយកញ្ចែក សាកយអណ្ដែត យាប្ចង់ចូកធ្លាស់ . . . ។

### ខ. អត្ថន័យនៃអត្ថបទ-

កំណាព្យនេះបង្កើតនូវមនោរម្មណ៍ ដែលព្រះករុណា ផ្ដោតចិត្តទាំងស្រុងទៅលើ អតីតគូរសង្សារដែលព្រះអង្គទើប នឹងបានជួបវិញ ។ ការពើបពះក្នុងខណៈនេះធ្វើឲ្យព្រះករុណា

(១) អត្ថបទទាំងស្រុងនៅក្នុង "ព្រះរាជសម្ភារ" របស់លោកហាប់អាន ទំព័រ ៦០ ដល់ ៦៨ ។

តែក្តីណែនចុកដើមទ្រូង ព្រួយបារម្ភណ៍ គិតសព្វតែកត់
ភិតភ័យផង អរផង ព្រោះវិបត្តិខាងផ្លូវកាយនិងផ្លូវចិត្តមង
បំពានលើចម្រូងចម្រាស់ឧបសគ្គធំណាស់ ៗ

x x
x

## ទី២- ប្រលោមអក្សរសិល្ប៍

ក្នុងសម័យឧដុង្គ ប្រភេទអក្សរសិល្ប៍ផ្នែកនេះអាចឲ្យ
ឃើញនូវ:

ក- វីរកថា: ដែលជាស្នាដៃយ៉ាងច្រើនរៀបរៀងឡើង
ពាក្យកាព្យនិយាយអំពីសកម្មភាពផ្សងព្រេង ជំសិតស្វាញក្
ហានអង់អាចនៃវីរជនមានតួអង្គពោធិសត្វ ឬតួអង្គក្សត្រជំទាំ
ពូកែក្នុងការផ្ចាញ់យក្សមារ ដើម្បីរំដោះទុក្ខសោករបស់មនុស្
ជាតិ រំដោះគូស្នេហ៍ជាដើម ៗ រឿងបែបនេះខ្លះមានឈ្មោ
អ្នកនិពន្ធច្បាស់ តែគួរឲ្យស្តាយព្រោះអ្នកនិពន្ធទាំងនោះគេដឹ
ប្រវត្តិច្បាស់ប្រាកដពុំឃើញ ហើយរឿងខ្លះទៀតគ្មានឈ្មោះអ្ន
និពន្ធទេ ព្រមទាំងកាលបរិច្ឆេទពិតប្រាកដក៏គ្មានផងទៀត :

គទៅនេះ យើងលើកយកអត្ថបទដែលមានកាលបរិច្ឆេទត្រឹមត្រូវ ឬមាននាមអ្នកនិពន្ធខ្លះមកបញ្ជាក់ ៖

## ១– ផ្នែករឿងដែលមាននាមអ្នកនិពន្ធ និង កាលបរិច្ឆេទច្បាស់លាស់ ៖

### ១. អ្នកឧកញ៉ាចក្រីកែវ

អ្នកនិពន្ធរូបនេះ ពុំបានទុកជីវប្រវត្តិឡើយ ។ លោកបានទុកស្នាដៃមួយឈ្មោះ «សាស្ត្រាដាវរឿង» ។ ស្នាដៃនេះមានពញាវត្តកោសា «វិភង្គ» ជួយរៀបរៀងផង(១) ។

### សាស្ត្រា «ដាវរឿង»

អ្នកនិពន្ធរៀបរៀងរឿងនេះពីថ្ងៃសុក្រ ៧ កើត ខែផល្គុន ហេមន្តរដូវ ឆ្នាំរកា ព.ស. ២៣៨០ ម.ស. ១៧៥៩ ត្រូវនឹង គ.ស. ១៨៣៧ ។

អត្ថបទតែងជាពាក្យកាព្យ មានបទ កាកគតិ ពំនោល

---

(១) តាមឯកសារសាស្ត្រាស្លឹករឹតនិងក្រាំង ដែលមាននៅវិជ្ជាល័យពុទ្ធសាសនបណ្ឌិត្យ ដែលលោកញ៉ុកថែម ស្រាវជ្រាវរៀបរៀង ហើយដែលមានចុះក្នុងកម្ពុជសុរិយាចាប់ពីលេខ ៨ ឆ្នាំ ១៩៦៥ រៀងមក ។

ព្រហ្មគិត និងកុផគ្គលីណា ។

អ្នកនិពន្ធបានបញ្ជាក់ប្រភពថា ជារឿងជាតក គឺចៅពញា ស្រីអញ្ចិត "វង្សី" ដែលបាននាំយករឿងនេះមកអំពីស្រុក សៀម ។

ឯកសារនេះជាសាស្ត្រាស្លឹករឹតមាន ៨ ខ្សែ ចប់ ជុំជាតក ជាបេះគល់ទុកដោយបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ មានចំ[illegible] ចុះលេខ ៥៤៩-៥៥០ ។ ឯលក្ខណៈនៃអក្សរ [illegible]

សេចក្តីផ្តើម: ថា នេះបទកាកគតិ

"អហំនមោ នមក្ការោ អញ្ជលិយំ សុសិរសា ពុទ្ធសេដ្ឋំ លោកុត្តមំ គរុមោ ធុរោ ។ នមធម្មំ សុខាវហំ អរិយបថោ ទេវជនំ មោក្ខមគ្គោ សន្តិករោ និយ្យានិកំ ។ នមសង្ឃំ វរៈ វិសុទ្ធោ ទក្ខិណេយ្យំ សន្តិន្ទ្រិយ បញ្ញាកេតុ អគារស្ស សមិទ្ធិយោ ។

អហំវន្ទិ នមោបន្តិ នមស្សការោ ក្រញ្ញក្រាបនមស្ការ វន្ទាសេដ្ឋោ អញ្ជលិយោ លើកអញ្ជលី ។ សុសិរសោ ផ្គូផ្គ ហត្ថា ដាក់ដល់សិរសី ពុទ្ធសេដ្ឋោ វន្ទាព្រះស្រី សារពេជ្ជមុនី

ប្រសើរស្រស់សម ។ល។

សេចក្ដីបញ្ចប់ៈ ថា នេះបទព្រហ្មគីត

ភិក្ខុអើយរម្មូលគោត ក្រមៅនោតឆ្នុតគកតែ កន្ទ្រឹសប្ញស្សា

ត ជាទេវទត្តពុំឃ្លាតឃ្លា ។ វែនានសម្រិទ្ធិ បេរើនថ្វាត់

យានយកជាតិ ជាចិញ្ចាឯងអាច ប្រពន្ធទេវទត្តស្មោះ ។

ហៃហអស់ទាំងជនផង ចូរគ្រាប់គ្រងព្រះធម៌ថ្លៃ ព្រះធម៌

នះគាប់ត្រៃ ចូរមហាជនគន់គិតយក ។ និទាននេះរឿងទេ

នះខ្មែរបុរាណមក សំដែងថែងឹរវក តាមដោយបុណ្ណបទបាលី ។

រឿងកល់ផលចប់ បរិបូណ៌គ្រប់សព្វសេចក្ដី លុះដុំព្រះជាតិ

ហៅខ្មែរប្រាំបីសូរេចហោង ។

X

## ២. បណ្ឌិត កោ

សង្ខេបៈ

លោកសាស្ត្រាចារ្យ ញ៉ុក-ថែម បានធ្វើសេចក្ដីសង្កេត

ចំពោះរូបអ្នកនិពន្ធនេះថា(១) «នាមរបស់កវីនេះមិនអាចយល់

(១) ស្រង់ទាំងស្រុងពីការស្រាវជ្រាវរបស់លោក ញ៉ុក ថែម ចុះក្នុងកម្ពុជ-សុរិយាលេខ ៨ ឆ្នាំ ១៩៦៥ ទំព័រ ៨២៤ ។

បានច្បាស់លាស់ទេ ព្រោះអត្ថបទដើមដែលបញ្ជាក់នាមរបស់កវី ប្រើពាក្យបាលី ៗ ប៉ុន្តែជាកំណាព្យខ្មែរដូច្នេះ

"អហំគោនាម បន្ទុបត្តសកម្មគោ នាមេភជនោ សន្ទត់នាមហំ ៗ (ល្បើនប្រែសម្រួល : ខ្ញុំឈ្មោះ គោ សន្ទត់ហៅបន្ទុបត្ត) . . . ពីរឃ្លាទៀតមានន័យមិនសូវច្បាស់ ប្រហែលវិបត្តិដោយអក្ខរាវិរុទ្ធ ដោយការចារចម្លង ១ គ្នា ៗ

ស្នាដៃ:

បណ្ឌិត ទាវ. បានតែងរឿងឈ្មោះ "សាស្ត្រាជ័យទត្ត" កាលពីថ្ងៃពុធ ៧ កើត ខែមាឃ ឆ្នាំខាល នក្សត្រ "ម.ស. ? (១) ៗ អត្ថបទជាពាក្យកាព្យ មានបទកាកគតិ

---

(១) លោក អ៊ុំ ញ៉ុក-ថែម ធ្វើសេចក្ដីសង្កេតចំពោះកាលបរិច្ឆេទ ដូចតទៅ:—

"សុភមស្ដុ ស្ដស្តិស្រីសុ- ភមង្គលា ជយធរយោ វេពេវា វាទក្សត្រ មាឃមាសពារពុធ ប្រាកងទៀតទាត់ ប្រាំបីកេជរត្នបវរ សេង្កោ ។ . . . .,,

ត្រង់ឃ្លា "ឯកអាសប្បតា,, យើងគួរយល់ថា កវីចង់បញ្ជាក់អំពីសករាជ តើសករាជអ្វី ? តាមប្រពៃណីខ្មែរយើង កវី ឬអ្នកនិពន្ធអំពីបុរាណ ក្នុងសម័យអង្គរក្ដី សម័យខាងដើមនៃក្រុងចតុមុខមានជ័យក្ដី ច្រើនបញ្ជាក់អំពីមហាសករាជ។

(ត ៦)

ពាំនាល ព្រហ្មគិត និងកុជផ្គលីលា ។ គឺជារឿងដកស្រង់ប្រកតពីហារយជាតក៍ ឬ ៥០០ ជាតក៍ ។

ឯកសារមានជាសាស្ត្រាស្លឹករឹតចំនួន១០ខ្សែចប់ជុំជាតក៍ ។ ឯកសារសំខាន់ដកល់ទុកនៅបណ្ណាល័យ ពុទ្ធសាសនបណ្ឌិត្យ មាន ៣ គម្ពីរ លេខសាស្ត្រា ៣៦៣–៣៦៤ និង ៣៦៥ ។

---

មហាសករាជនេះកើតក្រោយគ្រិស្តសករាជ ៧៨ ឆ្នាំ ។ ដល់មកចុងសម័យឧដុង្គ និង ខាងដើមសម័យក្រុងភ្នំពេញយើងនេះ គេនិយមប្រើសករាជ៣ គឺពុទ្ធសករាជ មហាសករាជ និង ចុល្លសករាជ ឬ សករាជណាមួយ ប៉ុន្តែសម័យអាណានិគមបរទេស គេនិយមប្រើតែគ្រិស្តសករាជមួយជាផ្លូវរាជការទូទៅ រហូតដល់សព្វថ្ងៃនេះ ព្រោះសករាជនេះគេទុកជាសករាជសាកលទៅហើយ គេនិយមប្រើជាផ្លូវការទូទៅក្នុងវង់អន្តរជាតិ ។

ត្រង់ឃ្លា ''ទៀងទុកតំណ ឯកអាសប្បនា,, ចុងឃ្លាទីពីរមិនចប់ចុងចួននិងចុងឃ្លាទីមួយទេ ។ ដូច្នេះ ត្រង់ឃ្លាទីពីរនេះ គួរកែជា ឯកពាសប្តូន,, ឬ ‘ឯកទ្វារសប្តូន,, ទើបអាចចាប់ចុងចួន ត្រង់ឃ្លាទី ១ ''ទៀងទុកតំណ,, បានត្រឹមត្រូវតាមច្បាប់ពាក្យកាព្យបទភាគគតិ ។ ឃ្លានេះមានន័យថា ១២៧៦ នៃ ម.ស. ត្រូវនឹង គ.ស. ១៣៥៤ ។

ប៉ុន្តែ កាលបរិច្ឆេទនេះហាក់ដូចវែងឆ្ងាយពេក .—

(ឬគ)

តាមសេចក្ដីសង្កេតរបស់លោកសាស្ត្រាចារ្យ ញ៉ុក-ថែម

កាលបរិច្ឆេទនៃរឿងនេះ ប្រហែលប៉ិកក្នុងគ.ស. ១៧៥៤

ឯលក្ខណៈនៃអត្ថបទ មានដូចនេះ :-

**សេចក្ដីផ្ដើម** – ជា បទកាកគតិ

"អហំវន្ទៈ អញ្ជលីយៈ បគ្គយ្ហំ សិរសាបណៈ សព្ពញ្ញុ,

ត្ថំ បញ្ញាញាណំ វរនេនគោ ៗ ,, . . . . .

កិរកាលវេន្ទ ជាតិជាលវេន្ទ ខណ្ឌកប្បក៏បាំង យើង

---

ប្រសិនបើយើងយល់ថា អ្នកចារចម្លងតៗ គ្មានកច្រឡំអក្សរ "ធ" ជា "ន" ដូចចុងឃ្លានោះ គេអាចច្រឡំតួ "ធ" ជា "អ" វិញក៏បានដែរ ។ ដូច្នេះ ត្រូវថា "ឯកធសប្តធ" អានថា "ឯក.ធ-សាប់ ធ" មានន័យថា ម.ស. ១៦៧៦ ត្រូវនឹង គ.ស. ១៧៥៤ ។

យោបល់នេះ និតនំតកាលបរិច្ឆេទនៃរឿងខ្យងស័ង្ខដែលករិបានបញ្ជាក់ថា ក្នុង ម.ស. ១៦៥១ គឺថារឿងជ័យទត្តកើតក្រោយខ្យងស័ង្ខ ២៥ ឆ្នាំ ។ ដូច្នេះ គប្បីយល់ថា រឿងនេះកើតឡើងរវាងចុងសម័យលង្វែក ឬខាងដើមសម័យឧដុង្គ តាមយោបល់ផ្ទាល់ យល់ឃើញថា កាលបរិច្ឆេទនេះសមរម្យជាងខាងលើ ។ ស្រង់ពីន័យលក្ខណ៍កម្ពុជសុរិយាលេខ ៨ ឆ្នាំ ១៩៦៥ ទំព័រ ៨១៤ ដល់ ៨២៦ របស់ លោក អ៊ុំ ញ៉ុក ថែម ។

វីនដោយមាន ញេយ្យញ្ញាណពុទ្ធ ធម្មទេសន៍ គឺធម្មទេសនា ។

ពុទ្ធនុស្សឯង ប្រុះប្រាផ្សារល្អូន ដុំជាតិកិតតិកា វែរបើក

បន្ទូល ដោយបុណ្ណគាថា ប្រោសប្រស់អស់មហា ជនជាតិតាំង

ឡាយ ។ ...................,.. ។ល។ ...

សេចក្តីបញ្ចប់ ៖ ថា

"សរសើរកាលកំណើត ព្រះអង្គកើតដោយនន្ទន៍ ហៅ

ហារយជាតិកំហាង ហើងដឹងដោយព្រះគាថា ។ និទាន

ទះរៀបរាប់ ចងផ្ចិតចាប់ដោយកាព្យ ពីខ្សែប្រាំបួនប្រាកដ

បរិបូណ៌បទបាលី ។ ប្រកបប្រាកដហោង ដោយទំនង់ព្រះគម្ពីរ

បំផែងជាហាក៍ ហៅខ្សែដប់គ្រប់ចប់តែង ។ "

X

## ៣- បណ្ឌិតស្មាត ឬសំអាត (១)

អ្នកនិពន្ធរឿងនេះពុំបានទុកជីវប្រវត្តិឡើយ ។ លោកបានទុក

ស្នាដៃមួយឈ្មោះ "សាស្ត្រាមុចលិន្ទ" ឬរឿង "ចន្ទគោរព" ។

(១) តាមការស្រាវជ្រាវរបស់លោក ញ៉ុក-ថែម ចុះក្នុងកម្ពុជសុរិយាលេខ ៨

ឆ្នាំ ១៩៦៥ ទំព័រ ៨៣០-៩៣១ ។

## សាស្ត្រា “មុច្ចលិន្ទ”

បណ្ឌិត ឆ្វាត រៀបរៀងរឿងនេះ កាលពីថ្ងៃសុក្រ ៥ កើ
ខែអាសាឍ ឆ្នាំ ម្សាញ់ ព.ស. ២៣៧៦ (គ.ស. ១៨៣៣)
អត្ថបទតែងជាពាក្យកាព្យ “ មានបទកាកគតិ ពំនោ
ព្រហ្មគីត និង ភុជង្គលីលា” ។

គឺជារឿងមានប្រភពចេញមកពីបញ្ញាសជាតក៍ ឬ ហាសិ
ជាតក៍ “ប៉ុន្តែអ្នកនិពន្ធបានបញ្ជាក់ថា -ប្រែពីភាសាសៀម”

ឯកសារនេះមានក្នុងសាស្ត្រាស្លឹករឹត ចំនួន ៧ ខ្សែ
ដែលដំកល់ទុកនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យមាន ១ គុ
លេខ សាស្ត្រា ៥៧៧ ។ ឯលក្ខណៈនៃអត្ថបទមានដូចនេះ

**សេចក្ដីផ្ដើម** ថា នេះបទកាកគតិ

“ទសករផ្គុំ ស្មោះស៊ើបខ្ញុំ ផាក់ផល់សិរោ ច
សម្ដេច សារពេជ្ញពុទ្ធោ ប្រសើរឧត្ដមោ លើសលែងលោកា
ស្ដេចជាគ្រូគ្រប់ ខ្ញុំទាំងភូមិភព តាំងព្រះចេស្ដា ឥន្ទ្រព្រហ្មយ
យក្ខ ហ៊ឹនចក្រវាឡ មូលមកវន្ទា បង្គំភក្ដិ ..... ។

សកពជតាំងត ទោត្រីសកធ (១) មន្តលសួស្តី ម្យាញ់

នក្សត្រ វិឡាសិរី ភាសាធ មាសី សុក្រ ៥កើតជាក់ ។ នៃនាម

អញខ្ញុំ តាមដោយគោរម្យ ឧត្តមសិទ្ធិសក្តិ បណ្ឌិតសំភាគ

សង្ក្រាតស្រីសូរគ្យ ចិត្តបង់ស្មោះស្ម័គ្រ គាប់ភាពចិន្តា ។ .....

។ល។ ......

## សេចក្ដីបញ្ចប់ ជា បទព្រហ្មគិត

“និទាននេះទៀងគេ ពិតពីខ្សែប្រាំមួយខ្ទង់ តែឯតាមបទ

បាលី ដោយពាក្យស្រីនិយាយទេ ។ ទោះបីបើខាតខុសខ្វះលើស

លស់ពីពាក្យគេ កែគិតឡើងគ្រប់តែ ប្រាំពីរខ្សែសូរេបហោង” ។

## ៤- ព្រះអរិយគាមុនី ហ៊ុង (២)

អ្នកនិពន្ធរូបនេះពុំបានទុកប្រវត្តិឡើយ ។ ព្រះអង្គជា

---

(១) លោកអ៊ុំ ញ៉ុក ថៃម ធ្វើសេចក្ដីកត់សំគាល់ថា “យោបល់ត្រង់ពាក្យថា “សកពជតាំងត ទោត្រី សកធ ...” ប្រហែលជា “ទោត្រីសប្តធ វិញទេ ប្រសិនបើឲ្យចេះមែន មានន័យថា ២៣៧៦ នៃពុទ្ធសករាជ ។

(២) ស្រង់ពីក្នុងកម្ពុជសុរិយាលេខ ៩. ១៩៥៤ ជាអត្ថបទស្រាវជ្រាវរបស់ លោក អ៊ុំ ញ៉ុក ថៃម ផ្ដាំអត្ថបទដើម ។

ព្រះសង្ឃ មានឋានៈជាពជាគណៈសម័យក្រុងឧដុង្គមានជ័យ ។ លោកបានទុកស្នាព្រះហស្តឈ្មោះ "សាស្ត្រាជិនវង្ស" ។

## "សាស្ត្រាជិនវង្ស"

ព្រះអរិយគាមុនី ហ៊ុន រៀបរៀងឡើងនេះក្នុងឆ្នាំ រោង អដ្ឋស័ក ព.ស ២៣៩៩, ម.ស. ១៧៧០, ច.ស. ១២១៨ គ.ស. ១៨៥៦ (១) ។

អត្ថបទនៃរឿងជាពាក្យកាព្យ មានបទកាកគតិ ពំនោល ព្រហ្មគីត និងភុជង្គលីលា ។

គោលនិយម រឿងនិងសកម្មភាពរបស់តួអង្គនៃរឿងស្រប តាមគោលអក្សរសាស្ត្រព្រាហ្មណ៍និយម ប៉ុន្តែប្រហែលជាកវី បង់បោនរឿងឲ្យទៅជារឿងជាតកក្នុងគោលពុទ្ធនិយម បានជាទុកដាក់តួឯកថា ជាតួអង្គពោធិសត្វ ហើយបញ្ចប់រឿងដោយ [illegible]សជាតក ។

---

(១)លោក អ៊ុំ ញ៉ុក ថែម កត់សំគាល់ថា សករាជទាំង ៣ នេះ ហាក់ដូចជា [illegible]គ្នាទេ សូមជូនអ្នកសិក្សាស្រាវជ្រាវពិនិត្យថែមទៀតផងចុះ ។

ឯកសារនេះមានជាសាស្ត្រាស្លឹករឹត ចំនួន ១១ ខ្សែចប់
កសារខ្លះមាន ១៩ ខ្សែ) ។ គម្ពីរមាន ១១ ខ្សែមាននៅក្នុង
ាសនបណ្ណាល័យលេខសាស្ត្រា ៥៦០ ។ ឯគម្ពីរមាន ១៩ខ្សែ
ប់ លេខសាស្ត្រា ៥៦១ ។ មហាកំណាព្យ រឿងជិនវង្ស
ះជារឿងវែងបំផុតក្នុងចំណោមកំណាព្យ ដែលកើតឡើង
ាយស្នាដៃនៃកវីតែមួយរូប គឺព្រះអរិយគាមុនី ហ៊ីង នា
ម័យក្រុងឧដុង្គ ។ ច្បាប់បោះពុម្ពផ្សាយក្រោយខ្លះដាក់ឈ្មោះ
ង ខ្លះដាក់ថា ហ៊ីង ។ ប៉ុន្តែច្បាប់សាស្ត្រាស្លឹករឹត
ប១ ៥៦១ ដាក់ថា អ្នកភិក្ខុ ហ៊ីង ផាជាព្រះអរិយគាមុនី ។

ឯលក្ខណៈនៃអត្ថបទមានដូចនេះ :—

## សេចក្តីផ្តើម – ថា :

«បទកាកថ្ងៃនោះ ឆ្នាំរោងកាលណោះ អដ្ឋស័ក
ាសនា សករាជបពិត្រ សម្តេចព្រះមហា លោកនាថសាស្តា
ះយ៉ឺននេះក្លូវ ។ ទើបបានពីរពាន់ ពីរយគ្រប់គ្រាន់ វស្សា

និទគៅ សិបប្រាំបួនផង មហាសករាជ...(១) ឆ្នាំសោភកខួន
មួយពាន់ប្រាំបី (២) រយចិតសិបទ្វី ខែប្រាំបួនផង ទើបឯ
បុល្ស-សករាជគខួន មួយពាន់ឆ្នាំហាន ពីររយប្រាំបី ។ ផណ្ត
វស្សា គ្រានោះរាជមហា ក្សត្រាពិសីហ- វិក្រមា ឥស្សរ
បតី ចមហៅបុរី ឥន្ទបត្តជ្ជា ។ . . . . . . . . . ។ល

## សេចក្តីបញ្ចប់ ថា:

“សុវណ្ណវង្សា ជាព្រះបិតា ជិនវង្សនរបតី អន្ទោល
ជាតិមក យោនយកជាតិ ជាព្រះបាទស្រី សុទ្ធោទនរាជា ។
នាងជិនបុប្ផា ជាព្រះមាតា ជិនវង្សសម្ភារ អន្ទោលជាតិមក
យោនយកជាតិ ជាសិរីមាយា ពុទ្ធមាតាថៃ ។ . . . ។ល។

(១) ត្រង់នេះប្រហែលជាត់មួយឃ្លា ដោយអ្នកហរចម្លងរំលងចោលទេដឹង។

(២) លោក អ៊ុំ ញ៉ុក-ថៃម សង្កេតថា តាមន័យនៃអត្ថបទនេះជាកាលណោះ មហាសករាជកន្លងទៅបាន ១៨៧០ និង ៩ ខែប៉ុណ្ណោះ ។ កាលបរិច្ឆេទនេះមិនប៉ះសម្រុងនឹងពុទ្ធសករាជទេ ដូច្នេះពាក្យកាព្យនេះគួរកែជាមួយពាន់ប្រាំបី.... ។ សូមជូនអ្នកសិក្សាពិនិត្យ ស្រាវជ្រាវតទៅទៀតផងចុះ “ស្រង់ក្នុងកម្ពុជសុរិយា លេខ—៩ ឆ្នាំ ១៩៦៥ ទំព័រ ៩៥៦” ។

ទ្រង់ត្រាស់ទេសនា ប្រោសអស់នោះណា បានលុះ
ង បានចូលនិព្វាន ទៅអស់ហើយហោង នេះគឺចំនង
ីរសេចក្តី ។ ចែងចប់ពាក្យកាព្យ ពេចន៍អភិប្រាយ តែ
ងនៃ ដំណើរអំពី ព្រះសាងបារមី ពង្រួមស្រដី តែម្ល៉េះ
ហាង" ។

X

## ៥– ចៅពញារាជា ភក្តី
## ចៅពញាជំនិតក្សត្រី
## ចៅពញាស្រី អញ្ចិត(១)

អ្នកនិពន្ធទាំង ៣ រូបនេះពុំបានទុកជីវប្រវត្តិ ទិង នាម
ះប្រាកដឡើយ ។ លោករួមគ្នាតែងរឿងមួយឈ្មោះ
ស្ត្រ "បន្ទុយាត" ។

### "សាស្ត្រា "បន្ទុយាត" :–

រឿងនេះផ្តើមតែងនៅ ថ្ងៃព្រហស្បតិ៍ ៨ កើតខែជេស្ឋ

(១) តាមការសិក្សាស្រាវជ្រាវរបស់លោក អ៊ុំ ញ៉ុក-ថែម បម្រុងបុះភ្នំ
សុរិយា ។

ឆ្នាំមមី ព.ស. ២៥០១ (គ.ស. ១៩៥៨) ។ សេចក្ដីរឿងតែង

ជាពាក្យកាព្យ មានបទកាកគតិ ពំនោល ព្រហ្មគិត និង កុ

ជន្ដលីលា ។ ប្រភពរឿងស្រង់ចេញមកពីបាសិបជាតក ឬ

បញ្ញាសជាតក ។

ឯកសារជាសាស្ត្រាស្លឹករឹត មាន១០ខ្សែចប់ ជុំជាតក

ឯកសារនេះពុទ្ធសាសនបណ្ឌិត្យ បានចម្លងអំពីវត្តសំពៅ

ស្រុកកៀនស្វាយ ខេត្តកណ្ដាល យកមកតាំងតម្កល់ទុក

កាលពីគ.ស. ១៩៥៥ ។ ឯលក្ខណៈអក្សរមានដូចនេះ

សេចក្ដីផ្ដើម ថា:

''កាកបទា អត្ថទុក្ខ បឋមបទំ មបបញ្ញោ អកោសល

ធិរមាមំ គរហិតា ។ មយ់វន្ទេ មសម្ពុទ្ធេ សិសោសត

នសន្ធលិ បតិដ្ឋិតា អវបាទា លោកទាថោ ។ ...

មយំដើមបទ យើងទំលំអុត នូនអង្គអភី ផ្សផ្គាប់ផ្គត់

បញ្ចង្គប្រណី ក្រាបក្រោមបាទ វិសេសសុទ្ធសាស្ត្រ ។ ព្រះ

អង្គត្រៃគ្រប់ គ្រានត្រើយត្រៃភព ឯកអង្គនាថា ប្រោសប្រាណ

ប្រែប្រាស ហោកលះលែងលា ទុក្ខទៀសចោលអ – បាយ

បាបបង់ទៅ ។ . . . ។ល។ . . .

## សេចក្ដីបញ្ចប់ថា :

ចន្ទឃាតជា គតនិដ្ឋិតា និទានព្រះបាទ ចន្ទឃាតថ្លៃថ្លា

ក្នុងហាសិបជាតក៍ នៅក្នុងនិបាត ថែងចប់សេចក្ដី ។ និទាន

កាព្យ នេះនាមចៅពញា ជំនិតក្សត្រី លើកជាល្បើកថ្វាយ

បរិយាយសេចក្ដី ដោយបទបាទ្យ ជុំជាតក៍សព្វគ្រប់ ។ ជាតក៍

សេចក្ដី នេះខ្ញុំតាំងបី តែងតាំងថ្ងៃយប់ ដោយប្រាជ្ញាខ្លៅ ពុំ

ស្ទូវប្រសប់ តែងទៅតាំងថប់ ជួនចប់និទាន ។ ថ្ងៃពុធប្រាំបី

កើតស្រាពណ៍មាស ឆ្នាំមមីបាន សកពជសាសនា ព្រះអនា

វញ្ញាណ ឯខែនោះបាន ចតុមាសា ។ ថ្ងៃបានកំណត់

ប្រាំពីរថ្ងៃគត់ ឯឆ្នាំគណនា ពីរពាន់បួនរយ និងមួយវស្សា

សង្ខេបគាថា សូរេចម៉ោះហោង ។

## ២– ភិក្ខុធម្មបញ្ញា ម៉ែន(១)

គ្មានជីវប្រវត្តិទេ ។ ព្រះអង្គបានរៀបរៀងរឿ

"សាស្ត្រាពេជ្ជតា"

### សាស្ត្រា "ពេជ្ជតា"–

រៀបរៀងកាលពីថ្ងៃអង្គារ ៥ កើត ខែអាសាឍ ឆ្នាំម

ព.ស. ២៤០២ (គ.ស. ១៨៥៩) ។

អត្ថបទតែងជាពាក្យកាព្យ មានបទកាកគតិ ពំនោ

ព្រហ្មគីត កុជង្គលីលា និង បទពោលនាង ។

រឿងនេះមានទំនងជារឿងជាតកមួយដែរ ប៉ុន្តែគ

បញ្ជាក់អំពីការសជាតិ ដូចជាជាតកនានាទេ ។

ឯកសារជាសាស្ត្រាស្លឹករឹត ១ ខ្សែបមាន ៦៣ សន្លឹក

ពុទ្ធសាសនបណ្ឌិត្យបានឯកសារនេះមកពីវត្ត កងកាណ

ខេត្តកំពង់ចាម ចុះលេខសាស្ត្រា ៦១២ ។

---

(១) តាមការសិក្សាស្រាវជ្រាវរបស់លោក អ៊ុំ ញ៉ុក ថែម បង្រួមចុះផ្សាយ

ក្នុងកម្ពុជសុរិយា ។

សេចក្តីអត្ថបទមានដូចនេះ:-

**សេចក្តីផ្តើម:** ថា នេះបទកាកគតិ

"យើងខ្ញុំបង្គំ ក្រញូក្រាបប្រណម្យ ដោយដាក់សិរសា
ផ្ទាះស្មោះតម្រង់ ព្រះអង្គគតវ៉ា ក្រញូក្រាបវន្ទា ប្រក្រតីសព្វ
ថ្ងៃ ៗ ដ្បិតខ្ញុំនេះកាត់ ចិត្តខ្ជាំងពេកក្តាត់ លាក់លេសនៃ មក
បួសសំណាក់ ក្នុងពុទ្ធញាណញេយ្យ ឧស្សាហ៍សព្វថ្ងៃ តាម
ពុទ្ធវចនា ៗ ... ។ល។

**សេចក្តីបញ្ចប់** ថា :-

"ប្រពេចញីខឹង គុនគិតសញ្ជឹង សច្ចាប្តេជ្ញា មិនឲ្យ
ស្រដី និងប្រុសណា ៗ ដល់កើតជាតិជា មនុស្សស្រដី ៗ
ប៉ុន្តែប្រពេច ឈោលចិត្តមិនដាច់ ពីគ្នាឡើយនៃ សច្ចាឲ្យបាន
ឈ្មោះស្រីទីទៃ ទើបបានមូលមៃ ជាគូគ្នាវិញ ៗ ចប់មួយនិទាន
លោកប្រើឲ្យបាន ដឹងកាថ់នោះមិញ ទើបគិតលើកគ្នា ល្ងាក
ប្រែបែងចេញ ចប់និទានមិញ ទិដ្ឋិតស្បូរេច" ៗ

## ៧- អ្នកឧកញ៉ា ឧទេន (១)

គ្មានជីវប្រវត្តិទេ ។ លោកបានតែង "សាស្ត្រាមាឃ
មាណព" ។

### សាស្ត្រា មាឃមាណពៈ–

ជារឿងនិយាយអំពីព្រះឥន្ទ្រ និង កំណើតព្រះឥន្ទ្រតា
គោលពុទ្ធនិយម ។ អ្នកនិពន្ធតែងពីថ្ងៃសុក្រ ១៥ កើត ខែ
ពិសាខ ឆ្នាំកេឌ់តោស័ក "គ្មានសកពជទេ" ។ រឿងនេះប្រ
ហែលជាគេបានបកប្រែស្រង់ចេញពីគម្ពីរ ធម្មបទដកឋាកាគ
ត្រង់រឿងសត្តវត្តទេពជិន ។ ដូច្នេះ អត្ថបទនេះមិនទាន់បប់ត្រឹម
ខ្សែ ១ នេះទេ ។ តាមឯកសាររបស់ពុទ្ធសាសនបណ្ឌិត្យ ដែល
បានមកពីវត្តព្រែកកុយ ខេត្តកំពង់ចាម ចុះលេខ ៦៥០ បាន
បញ្ជាក់ថា កាលបរិច្ឆេទដែលខ្ញុំនពារចប់នៅថ្ងៃពុធ ៥ កេត
ខែកត្តិក ឆ្នាំខាលអដ្ឋស័ក ត្រូវនិងឆ្នាំ គ.ស. ១៩២៧ ។

---

(១) តាមការសិក្សាស្រាវជ្រាវរបស់លោក អ៊ុំ ញ៉ុក ថៃម បម្រុងចុះក្នុងកម្ពុជ
សុរិយា ។

អត្ថបទជាពាក្យកាព្យ បទកាកគតិ ព្រហ្មគិត ភុជង្គលីលា និងពំនោល ។

លក្ខណៈមានដូចតទៅ :–

សេចក្ដីផ្ដើម ថា: នេះបទកាកគតិ

“សុក្រវារេ វិសាខមាសេ បុណ្ណមិយា នាគសំវច្ឆរេ បច្ចុប្បន្នា ឧទេនធាយា កាព្យគរោ ។ . . .

សុគមស្តុ មង្គលាស្តុ ពហុចេស្តា បច្ចុប្បន្នថ្ងៃសុក្រ ខែពិសាខ ពេញបូណ៌មីណា ឆ្នាំរោងទោស័ក ។ . . . ។ល។

សេចក្ដីបញ្ចប់ ថា :

“ឯអស់ម្ដាយឪពុក ទូន្មានស្រុកញាតិកា សន្ដានគតិនាមា ហៅនាងនន្ទកល្យាណី ។ លុះនាងចំរើនធំ រូបរាងសមលើសលែងស្រី និត្យនៅនាលោកិយ កើតកបកាយគ្រប់លក្ខណា ។ ដោយគេជគេជៈសីល នាងពុំខ្ជិលខ្ជាប់រក្សា សព្វទិនរាត្រីណា ពិព្យាយាមអចិន្ត្រៃយ្យ ផលនោះបានសម្បត្តិ បាបបង់បាត់ពេញផ្ទាយក្រៃ ដូចចិត្តនាងសព្វថ្ងៃ ពិតពុំជាប់

គ្រង់សីលា" ។

X

## ៨- អ្នកឧកញ៉ាប្រាជ្ញាធិបតី ឬ បញ្ញាធិបតីកែវ(១)

គ្មានជីវប្រវត្តិទេ ។ លោកបានតែងរឿង ព្រះសមុទ្ទឃោសៈ

## សាស្ត្រាព្រះសមុទ្ទឃោសៈ-

រឿងនេះតែងកាលពីថ្ងៃសៅរ៍ ១០ កើត ខែពិសាខ ព.ស

២៣៦១ (គ.ស. ១៨១៨) ។

ប្រភពចេញមកពីបញ្ញាសជាតក ។ អត្ថបទតែងជាពាក្យ

កាព្យ មានបទ កាកគតិ ពំនោល ព្រហ្មគិត និង កុដ្ឋលីលា

ឯកសារជាសាស្ត្រាស្លឹករឹត មាន ២ ខ្សែ ។ ពុទ្ធសាសន

បណ្ឌិត្យបានឯកសារនេះមកពីវត្តកោះសុទិន ខេត្តកំពង់ចា

ចុះលេខសាស្ត្រា ៦៧១ ។

ឯរបៀបតែងមានដូចនេះ :--

**សេចក្តីផ្តើម** : ថា នេះបទកាកគតិ

(១) ស្រង់ពីកម្ពុជសុរិយាលេខ - ១០ ឆ្នាំ ១៩៦៥ ទំព័រ ១០៥៧ អត្ថប

ស្រាវជ្រាវ របស់លោក អ៊ុំ ញ៉ុក-ថៃម ។

“អហំនមា មិសិរសោ ចសម្ពុទ្ធោ តិលោកជេដ្ឋ វិសេដ្ឋ-សោ មហាបញ្ញោ បញ្ញាណំ ។ សត្ថាអគ្គោ លោកហិ-តោ ទិព្វលោកំ សព្វសេដ្ឋោ ជនេនាថ ទេវទេវំ ព្រហ្មព្រហ្មា ។ ...

សុភមស្តុ មង្គលពហុ–គិរេកសួស្តី ជយជយា វិកវី វរគី កិច្ចកាព្យសាស័ទ្ទ ។ សកកជតាំងថយ ពីរពាន់បីរយ ហុកសិបមួយគត់ វិសាខមាសេ សៅរ៍រេរោគ្ន ដប់កើតទៀន ពាក់ កធិកម៉ាសមាន ។ គោនុនាមា រំកែច គបបញ្ញា ធិបតី ជីនជាន ជីនជោយពុទ្ធដិកា ជាក់ជាប្រធាន ទើបខ្ញុំសួរ ...”

## សេចក្ដីបញ្ចប់: ថា

“ព្រះបាទខទុម្ពរ ដែលនៅនគរ កៃលាសមន្ទីរ ចេវិលរ័ទមក យោនយកជាតិ ចាប់ប្រតិសន្ធិ ជាព្រះមោគ្គល្លាន ។ ឯអង្គព្រះចន្ទ ចមចៅទេវិន្ទ ប្រសើរមែនមាន គុណនឹងពោធិ-សត្វវិសេសសាន្ត ក់ឡូវនេះបាន ជាអនុរុទ្ធា ។ រីទេពទេវី នាមនាងមណី វរមេខលា ក់ឡូវិលមក យោនយកជាតិជា ឧប្បលវណ្ណា មហាថេរ: ។ ឯអង្គព្រះមហា – ៈហេសីនាមា

ថ្ងៃមុខ បើវិលវិញមក យោនយកជាតិ គឺអង្គព្រះស្រី យសន្ធរ

ពេជ្របម្រុង — ហោរាភាវិសុទ្ធ គឺអង្គកថា — គតកាលនេះ

សម្ដេចធ្យា សូមបេចតាក ខិត្តិតបបហោង ។

X

## ៥– ឧកញ៉ា ព្រះឃ្លាំង «នង» (១)

## ជីវប្រវត្តិសង្ខេប

ថ្ងៃ ខែ ឆ្នាំ កំណើត ស្រុកកំណើតនិងនាមមាតាបិ
មិនប្រាកដ ។ លោកបានបួសរៀនភាសាបាលី ព្រះត្រៃបិដ
បេះដូងជ្រៅជ្រះ ហើយបានប្រឡងបាលីនៅក្រុងបាងក
ជាប់បានជាទីមហា ។ លោកបានជាចៅអធិការវត្តបត្តុម
នៅក្រុងឧដុង្គ និងទទួលសមណសក្តិជាទីមហាព្រហ្មមុនី បា

(១) ចង់ជ្រាបជីវប្រវត្តិពិស្តារ សូមរកទស្សនាវដ្ដីមិត្តសាលាបាលីលេខ
ឆ្នាំ ១៩៥១ ទំព័រ ៥៣ ដល់៦០ រៀបរៀងដោយលោកឧកញ៉ា មេត្តាធិបតី ឈឹ
[illegible] ។ មើលក្នុងរឿងភោគកុលកុមារ ផ្សាយចេញពីវិទ្យាស្ថានពុទ្ធសាស
[illegible] លើកទី២ ឆ្នាំ ១៩៦៦ ទំព័រ ង ដល់ ដ ។

ជាគ្រូព្រះរាជបុត្រព្រះបាទសម្តេចព្រះនារាយណ៍រាមាធិបតីទាំង ៤ ព្រះអង្គ គឺព្រះអង្គ **ចន្ទ** ព្រះអង្គ **ឌួង** ហើយជាឧបជ្ឈាយ៍បំបួសព្រះអង្គឌួង ជាសមណៈទៀតផង ។

ក្នុងឆ្នាំវក ចត្វាស័ក ព,ស. ២៣៥៥ លោកបានដង្ហែព្រះអង្គ **អិម** ជាទីសម្តេចព្រះស្រីជ័យជេដ្ឋា មហាឧបរាជ និងព្រះអង្គ **ឌួង** ស្តេចទៅក្រុងបាងកក ។

ពេលវិលមកវិញ លោកចាកសិក្ខាបទរស់នៅជាមួយព្រះអង្គឌួងនៅស្រុកមង្គលបុរី ខេត្តបាត់ដំបង ។ ភរិយាដំបូងឈ្មោះនាង **មាស** ។

កាលមុនសោយរាជ្យ ព្រះអង្គឌួងព្រះរាជទានអ្នកម្នាង ១នាក់ ឈ្មោះ **តួច** ឲ្យជាភរិយាទៀត មានបុត្រធីតា៩នាក់ គឺខាងនាងមាស ៦ នាក់ (ប្រុស១ ស្រី៤) នាងតួច ៣ នាក់ (ប្រុស ២ ស្រី១) ខាងនាងតួចស្លាប់កូនប្រុស១ ។ កូនប្រុសៗសុទ្ធតែបានធ្វើជាមន្ត្រីធំៗទាំងអស់ ។

នៅពេលបានគ្រងរាជ្យសម្បត្តិ នៅក្រុងឧដុង្គមានជ័យ

ព្រះករុណាព្រះអង្គឌួងទ្រង់ព្រះមេត្តាប្រោស យកអ្នកបណ្ឌិតមហាព្រហ្មមុនី **នង** មកតាំងជាអាចារ្យហ្លួង ងារជាឧកញ៉ាវង្សាក្សត្រីដំណែងក្រុមរាជបណ្ឌិត និងទ្រង់ព្រះរាជទានស្រុកកោះសូទិន ឲ្យជាស្រុកមួយទៀតឧកញ៉ាវង្សាក្សត្រី ដរាបលុះអស់អាយុ ។

ក្រោយមក លោកបានឡើងជាឧកញ៉ាវង្សាសារពេជ្ញ **នង** ជាប្អូនបង្កើតរបស់មាតានៃព្រះបរមជាតិស្ត្រី គឺសម្តេចព្រះវររាជជននីបរមបពិត្រ ដ៏ជាព្រះជននីនាថ នៃព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម** ។

## គោលគំនិត និងស្នាដៃ

លោកឧកញ៉ាវង្សាសារពេជ្ញ នង ជាអ្នកមានប្រាជ្ញាដ៏មុះមុតមានព្យាយាមជាប់ជានិច្ច លោកបានតែងរៀបរៀងសុភាសិត ដំបូន្មាន និងសាស្ត្រាផ្សេងៗ ជាច្រើន គឺ:

១– លោកនិយពាក្យកាព្យ ជារឿងជាតក តែងកាលនៅគ្រងងារជាឧកញ៉ាវង្សាក្សត្រី ។

២ ច្បាប់សុភាសិត ពាក្យកាព្យ ។

៣- ច្បាប់ស្រី មិនមែនច្បាប់ស្រីម័យបណ្ឌិតទេ ។

៤- ព្រះរាជពង្សាវតារក្រុងកម្ពុជា

មួយទៀត គេបានប្រទះឃើញឈ្មោះ ៣ គោរម្យងារ ជាឧកញ៉ាព្រះឃ្លាំង គឺ :

៤- សាស្ត្រាគោតកុលកុមារ

៦- បុញ្ញសារសិរសា ។

៧- ព្រះសម្បុត្រ ។

## ស្នាដៃផ្នែកប្រលោមអក្សរសិល្ប៍

## សាស្ត្រាបុញ្ញសារសិរសា (១)

រឿងនេះតែងឡើងនៅថ្ងៃសុក្រ ៨ កើត ខែអស្សុជ ឆ្នាំម្សាញ់ នក្សត្រ ព.ស២៣៤០ ម.ស ១៧១៩ គ.ស១៧៩៧ ។ ជាអត្ថបទពាក្យកាព្យ មានបទកាកគតិ ពំនោល ព្រហ្មគីត

---

(១) ស្រង់ក្នុងកម្ពុជសុរិយា អត្ថបទស្រាវជ្រាវរបស់លោក អុំ ញ៉ុក-ថៃម ប១ ៩ ឆ្នាំ ១៩៦៥ ទំព័រ ៩៦៦-៩៦៧ ។

ទិនកុជគ្គលីលា ។

ឯកសារដើមជាសាស្ត្រាស្លឹករឹត មាន ៣ ខ្សែ ចប់ជុំជាតក់ ៗ លេខ សាស្ត្រា ៥៩៣ គេរក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ។

លក្ខណៈតែងមានដូចនេះ :–

**សេចក្ដីផ្ដើម** : ថា –

"នមាមិហំ ពុទ្ធសេដ្ឋំ លោកជេដ្ឋា បរមសត្ថា ទេវមនុស្សា លោកុត្តមោ អនន្តញាណំ ។ ...

ទសករកំបង់ ឋទបាទនូវអគ្គ នូវអញ្ជលី មនោវចា កាយាវន្ទី បញ្ចប្រតិស្ឋានបិតអភិវាទ ។ ព្រះស្រីសម្មាសម្ពុទ្ធ សាស្តា ធម្មិកលោកនាថ ឯកឥតគុណិយំ ទេពតាធំលោកធាតុ ក្រាបក្រោមព្រះបាទ ព្រះបរមសារពេជ្ញ ។ .... ។ល។" ...

**សេចក្ដីបញ្ចប់** ថា :

"ខ្ញុំគិតគាព្យ កាលជាឧកញ៉ា វង្សាក្សត្រ ជាខ្ញុំព្រះបាទ នរោត្តមបត្រី ពយាធិបតី ទ្រង់កជម្ពើនថាន ។ សេចសោយ

ាល័យលុះផុត ពិធីតាកហែន ខ្ញុំសោគរវល់ ខ្វាយខ្វល់
ាន គិតកាព្យនេះទាន គិតពុំទាន់ចប់ ។ ដ្បិតលោកទៅ
ា-ខ្សោះជាតិជា បិតាធម៌ថប់ គាត់តែងមន្ត្រី សេនិយ
ាយសព្វ សង់មេរុមណ្ឌល ប្រាសាទវេចនា ។ ធ្វើបុណ្យសព្វ
ៀ ពេញពីរវស្សា ឲ្យមានទ្រព្យធន ពេកពន់មហិមា ទើប
ានបូជា ថ្វាយព្រះអគ្គី ។ ហើយលោកគន់គិត តែងឲ្យធ្វើ
ដ្ឋ សាងព្រះចេតិយ បញ្ចុះព្រះធាតុ ព្រះបាទចក្រី ធ្វើបុណ្យ
ក្រតី ឧទ្ទិសថ្វាយទៅ ។ លោករួមគ្រា ព្រះពជបុត្រា
ាំងបួនឧបមទៅ គ្រប់គ្រងធានី បុរីឥតសៅ អស់រាស្ត្រគង់
ៅ សឹងខុសសប្បាយ ។ លោកឲ្យសក្តា ខ្ញុំជាឧកញ៉ា
ព្រះឃ្លាំងទៅហ្វាយ ឃ្លាំងមរណីភ្ន ទើបគិតទូលថ្វាយ កាព្យ
ប្តូបរិយាយ តែងបងវេចនា ។ ទុកតជាគេ្គ ក្រោយក្រែង
ណោះ អនាគតា ក្រែងសោះសូន្យស្ងាត់ បទបាទបរិហារ
ាព្រះសិរសា បរមបក្រពិត្ត ។ ពាក្យខ្ញុំសុភាព ពុំពីរោះពប
ក្រែងភាំងក្រួបភ្ញាត់ ពិតពុំពាក់ទង គន្ធងបាមេត្ត អ្នកណាបេះ

ស្អាត់ តម្រង់ទៀនទាន ។ តំណាសាសនា ប្រាំពាន់វស្ស
ជាតិព្រះទ្រង់ញាណ ក្នុងមហាសិបជាតក៏ និបាតមែនមាន អស
កាព្យ៍និទាន និដ្ឋិតែងចប់" ។

## សាស្ត្រាព្រះសូមុត្រ[១]

ស្នាដៃនេះគ្មានកាលបរិច្ឆេទទេ ។ អត្ថបទជាពាក្យកាព្យ
ពាក្យ ៧ និង ពាក្យ ៩-១០ ។ ប្រកពរឿងចេញមកពីមហាសិប
ជាតក៏ ឬបញ្ញាសជាតក ។ ឯកសារជាសាស្ត្រាស្លឹករឹត មាន
៦ ខ្សែ ចប់ជុំជាតក៏ រក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ សាស្ត្រា
ចុះលេខ ១៣៧៣ ដែលបានមកពីវត្តប្រជុំនទី យកមកចារ
ចម្លងកាលពី ព.ស. ២៤៨៦ គ.ស. ១៩៤៣ ។

លក្ខណៈតែងមានដូចតទៅនេះ :-

## សេចក្តីផ្តើម -

"សព្វសព្ទោរក្ខសីលា យោជនាគាថានិបាតំ ទុំនាមខក

(១) ស្រង់ក្នុងកម្ពុជសុរិយា លេខ ១១ ឆ្នាំ ១៩៦៥ ទំព័រ ១១៦៣ អត្ថបទស្រាវជ្រាវ របស់លោក អ៊ុំ ញ៉ុក-ថៃម ។

ញ៉ាំងព្រះឃ្លាំង ឈ្មោះឆង កែងតាំងតកាព្យ ។ កាព្យ
កិច្ចលើកមុនកែបទពាក្យ មានបួនប្រាកដប្រាំពីរឃ្លា ពាំនោល
ព្រហ្មគិតសមសោភា ថ្វាយមហាក្សត្រាម្ចាស់ផែនដី ។ មហា
រាជនាមាព្រះអង្គឌួង គ្រប់គ្រងកម្ពុជាម្ចាស់សិរសី ព្រះអង្គ
ទ្រង់សព្វព្រះទ័យ ឲ្យកែសេចក្ដីជាថ្មីទៀត ។ ទ្រង់សព្វព្រះ
ទ័យពាក្យប្រាំពីរ បន្ថែរឃ្លាបួនបួនបន្ទៀត ហេតុនោះអញខ្ញុំ
ខំប្រឹងទៀត លើកទៀតដាក់ទុកទំនុកម្ចាស់ ។ ក្រែងជួនដាក់
ជ្រួសហួសសេចក្ដី រវែងខ្វីកាព្យខាតឃ្លាល្បះ ត្បិតខ្លួនខ្ញុំខ្លៅ
ឆៅខ្លាំងណាស់ ក្រែងខ្វះជួយប៉ះបំពេញផង ។ល។..."

សេចក្ដីបញ្ចប់. ថា :

" អហំឯកែគីអង្គអញ បានត្រាស់នេះមិញមិននរណា
ភិក្ខុអើយកាលនោះហៅអស្ចារ្យ គណនាពប់ជាតិកោដិកប្ប
ផង ។ ឯអស់ផៅពង្សពូជពង្សា ផ្លាស់ជាតិពល់គ្នាសក្យពជ
ហោង ចូរអស់ព្រាហ្មណ៍ព្រឹទ្ធាបណ្ឌិតផង គ្រាប់គ្រងត្រសង
សេអស់គាថា ។ អស់កាថ៌បរិយាយ បទបញ្ហាតាមដោយ

កថានេះឯងនៃ បរិបូណ៌បទអស់សព្វសេចក្តី សម្រេចហើយនៃ
ចប់ម្ល៉េះហោង» ។

## សាស្ត្រាភោគកុលកុមារ(១)

រឿងនេះតែងឡើងនៅក្នុង ព.ស. ២៣៤៧ ម.ស. ១៧២៦ ច.ស. ១១៦៦ គ.ស. ១៨០៤ ក្នុងរជ្ជកាលព្រះបាទអង្គច័ន្ទទី ២ ។ ជាអក្ខរបទពាក្យកាព្យ (មានបទកាកគតិ ព្រហ្មគីត ភុជង្គលីលា និងពំនោល ) ។

ឯកសារដើមជាសាស្ត្រាស្លឹករឹត មាន១ខ្សែចប់ជុំជាតក់ៗ លេខសាស្ត្រា ៦៣៧ មាន ៣ ខ្សែ និង ៦៣៨ មានតែ ១ ខ្សែចប់ គេរក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ។

សេចក្តីក្នុងផ្ទៃរឿងនេះមានទំនងជាជាតក៍មួយ ដូចជាតក៍ទាំងពួងដែរ តែមិនសង្គ្រោះចូល ៥០ ជាតក៍ទេ (បញ្ញាសជាតក៍) ឬក្នុងរឿង ៥០០ ជាតក៍ (ជាតកដ្ឋកថា) ទេ ។ ប្រ

(១) ការស្រាវជ្រាវផ្ទាល់ តាមឯកសាររបស់ពុទ្ធសាសនបណ្ឌិត្យ ។ សៀវភៅនេះបោះពុម្ពដោយពុទ្ធសាសនបណ្ឌិត្យ ចំនួន ២ លើកហើយ ។

ហែលជារឿងនេះ ជាជាតក៍មួយដោយឡែក ក្រៅពីក្រុមជាតក៍តាំងឡាយ ដូចជាលោកនយជាតក៍ (ហៅលោកន័យប្ប-ករណ៍) ។

លក្ខណៈតែងមានដូចនេះ :–

សេចក្ដីផ្ដើម : ថា

“អហំ នមោ នមក្ការេ អញ្ជលិយំ សុសិរសា ពុទ្ធសេដ្ឋំ លោកុត្តមំ គរមានុភេ ។ នមធម្មំ សុខាវហំ អរិយមថោ ទេវជនំ មោក្ខមគ្គោ សន្តិកេ និយ្យានិកំ ។ នមសង្ឃ វរវិសុទ្ធោ ទក្ខិណេយ្យំ សន្តិន្ទ្រិយំ បុញ្ញក្ខេត្តំ អនាសវំ សមិទ្ធសោ ។

អហំវន្ទំ នមោបដ្ឋំ ទមក្ការេ ក្រួញក្រាបនមស្ការ ពុទ្ធសេដ្ឋោ អញ្ជលិយោ លើកអញ្ជលី ។ សុសិរសា ផ្គូផ្គងហត្ថា ដាក់ដល់សិរសី ពុទ្ធសេដ្ឋោ វន្ទាព្រះស្រី សារពេជ្ញមុនី ប្រសើរស្ងួតស្គម ។ គរមានុភោ លោកុត្តមោ ព្រះអង្គឧត្តម លើសលែងមនុស្ស ទេវតាឥន្ទ្រព្រហ្ម បន្ទាបង់បំ– បាត់បាប

ទៅ ។ ...

មហាសក្ករាជកប់ ចូលជាឯកស័ក-ទោឝសក ដូបចូលវស្សាន សាវណ៍មាសា កុម្ភាក បុញ្ញមិយ៍(១) ។ នាមោមយា ឆ១ នាមជាតិជា ឧកញ៉ាព្រះឃ្លាំង គន់គិតកាព្យកិច្ច ពាក្យពេចន៍ទុកតាំង ជាកេរ្តិ៍តំណាង តំណសាសនា” ។

## សេចក្ដីបញ្ចប់ - ថា -

“សត្ថាត់ម៍ ធម្មទេសនំ អាហារិត្វា រីគាមគោជក មេស្រុកបុស្សា បេរវិលវឹងជា ទេវទត្តប្រែតគ្រាណ ។ ...

ហៃជនទាំងឡាយ ចូរស្ដាប់បរិយាយ ដំណើរទំនងភោគកុលកុមារ គ្រអាលចាំចង់ ស្ដរិះរៀនផង សេពមិថ្ងៃថ្វា ។ ទឹងបានមគ្គផល បរិបូណ៌បានដល់ ដូចក្ដីប្រាថ្នា ខ្ញុំថ្វៃឯសរសើរ ដំណើរកេតរ៉ ឥតិប្បកា-វេទិដ្ឋិត” ។

---

(១) ដូបចូលវស្សាន: គឺរដូវខែភ្លៀង ។ សាវណ៍មាសា: គឺខែស្រាពណ៍។ កុម្ភាក: គឺថ្ងៃអង្គារ ។ បុណ្ណមិយ៍: គឺក្នុងថ្ងៃពេញបូណ៌មី ១៥ កើត ។

# សាស្ត្រាលោកនយបករណ៍–[១]

រឿងនេះតែងឡើងក្នុងពេលដែលអ្នកនិពន្ធមានឋានន្តរសក្តិជាឧកញ៉ាវង្សាក្សត្រី ក្នុងព.ស. ២៣៣៧ គ.ស. ១៧៩៤ ក្នុងរជ្ជកាលនៃព្រះករុណាព្រះបាទសម្តេចព្រះនារាយណ៍ ពជាកមាធិបតីព្រះអង្គអេង ។

លោកនយបករណ៍នេះ ច្បាប់ដើមជាភាសាបាលី ជាគម្ពីរមានប្រស្នាគាថាកំបាំងជ្រាលជ្រៅណាស់ ។ អត្ថបទជាពាក្យកាព្យ (មានបទកាកគតិ ពំនោល ព្រហ្មគីត និង ភុជង្គលីលា) ។

ឯកសារដើមជាស្ត្រាស្លឹករឹតមាន ៤២ ខ្សែ[២] ចុះលេខសាស្ត្រា ១៦៤៧ រក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ។

លក្ខណៈតែងមានដូចតទៅនេះ :—

---

(១) តាមការស្រាវជ្រាវផ្ទាល់ក្នុងឯកសារនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ។

(២) ច្បាប់ដើមមានតែ ១៣ ខ្សែចប់ ។

## សេចក្តីផ្តើម: ៧–

“អហំនមា មិសិរសា សុសម្ពុទ្ធំ អនុត្តរេ សេដ្ឋ
តិលោកានំ លោកុត្តមោ ៗ ជិតមារៈ អសមោអ–នន្តញ្ញាណ
បភតវ៉ាបនាយកោ ទសពលោ បអតុលំ ៗ . . .

ខ្ញុំអរទុនអគ្គ លុតលើកករផ្ទួន់ ដាក់ដល់សិរសី អញ្ជូ
កាយំ អញ្ចន់ប្រជី–ស្ថានបិតអភី–វ៉ាទវៃបន្តំ ៗ ក្រាបក្រាប
កន៍បក្រ ព្រះបាទលាយលក្ខណ៍ សូមសរសើរសំ – ណាន់នៃ
ស្តេចស្តែន លើសលែនឥន្ទ្រព្រហ្ម ទេពតាំងយក្ខយម រាជ
វ្ញែញត្រាបទ្វុប ៗ . . . សករាជចូលម – ឯកស័ក្តឯកធ[1] ស័ក
នាលចំហុត ថ្ងៃដណ្តប់កេច រនោចពារពុធ ខែកម្រុបទ សាន្ត
សិរិទ្ធ ៗ កាលពង់ព្រះបាទ ព្រះបរមនាថ ព្រះនាមចក្រ នា-
រាយណ៍តជា រាមាធិបតី សម្តេចព្រះស្រី សុរយោពណ៌តន្យ ៗ
អញខ្ញុំនាម **ឆង** ជាតិជាខ្ញុំល្អន ធូលីបាទា ព្រះរាជទាន ប្រោស
ប្រាណករុណា ឲ្យជាឧកញ៉ា វង្សាក្សត្រីយ៍ ” ៗ

---

(១) ចូលម: គឺមហាសករាជ ។ ឯកស័ក្តឯកធ: គឺ ១៧០៦ ។

## សេចក្តីបញ្ចប់ ៖

"ព្រះអង្គទេសនា ធម៌ចតុ–រិយសច្ចបួនបទ ស្រេច
ព្រះសាស្ដា សម្មាសម្ពុទ្ធ ព្រះអង្គផ្គត់ ជុំជាតកថា ។ ហៃ
ភិក្ខុវេ ភិក្ខុអើយរឹង ឧដុកសេនា–បតីមិញមក នោះយក
ជាតិជា ទេវទត្តនោះនា ភូមិភ័យអប្រិយ ។ . . .

លោកនយ បករណ៍ វណ្ណនាទី–ដ្ឋិកាសរសើរ ដំណើរ
អំពី លោកន័យនី–មានទៀតថាចារ ។ ខ្មែរដប់បីបាន(១)
ដល់ដើមទិពាន ពីពន្សព្រះត្ពា ប្រជៅគ្រូធម្មា បេះថាគ្រប់គ្នា
បរិបណ្ណា និដ្ឋិតថៃនីចប់" ។ (២)

---

(១) ច្បាប់ដើមរក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ចុះលេខ ៦២៧ មាន ២២ ខ្សែ ។

(២) ឯសូត្រផ្សេងទៀតជាច្បាប់ និង ពង្សាវតារ នឹងបញ្ចូលនៅខាងក្រោយ ក្នុងផ្នែកឧបទេស និង ទិដ្ឋិអក្សរសិល្ប៍ ។

# ១០– ព្រះបាទសម្តេចព្រះអង្គឌួង (១)

## ព្រះរាជជីវប្រវត្តិសង្ខេប-

*ព្រះអង្គជាព្រះរាជបុត្រពៅនៃព្រះបាទសម្តេចព្រះអង្គអេង*
*គ.ស. ១៧៧៩ ដល់ ១៧៩៦ ។*

*ទ្រង់គ្រងរាជ្យនៅរាជធានីឧដុង្គមានជ័យ ពីគ.ស.១៨៤*
*ដល់ ១៨៦០ ។*

*ព្រះអង្គឌួង ទ្រង់ប្រកបដោយព្រះប្រាជ្ញាឈ្លាសវៃណាស់*
*សៀមសុំផ្តាច់យកខេត្តម្លូព្រៃ ទន្លេរពៅ និងខេត្តឯទៀតៗ ព្រ*
*អង្គមានព្រះតម្រាស់ថា "ខ្ញុំមិនឲ្យអ្វីទៅសៀមទាំងអស់" ។*
*សៀមខ្លាំងពូកែ ទ្រង់ឲ្យសៀមយកខេត្តណាដែលសៀមយក*
*បានពីមុនសិនចុះ ។*

*ព្រះមហាក្សត្រអង្គនេះ ទ្រង់ប្រកបដោយទសពិធរាជធម៌*

---

(១) ចង់ពិស្តារសូមអាន "អ្នកនិពន្ធខ្មែរ" ព្រះបាទអង្គឌួង របស់ លាងហាប
[redacted]ផ្សាយលើកទី ១ ក្នុងទស្សនាវដ្តីអក្សរសាស្ត្រឆ្នាំ ១៩៦៤ និងលើកទី
[redacted]គារ អ៊ឹង ហ៊ុន ឆ្នាំ ១៩៦៥ ។

ានប្រារព្ធសង្គ្រោះប្រទេសបាក់បែកដោយសង្គ្រាម ។ ទ្រង់ស្អប់សង្គ្រាមពន់ពេក ។

ព្រះអង្គបានកសាងសមិទ្ធិសំខាន់ៗ សំរាប់ប្រទេសជាតិគឺ:

– ព្រះអង្គបានកសាងព្រះវិហារនៅឧដុង្គ បានចាត់ការឲ្យបង្រៀនព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ។

– ទ្រង់បានកសាងសាលាតាន ។

– ទ្រង់ឲ្យអ្នកប្រាជ្ញរាជបណ្ឌិតផ្ទៀងកែ ព្រមទាំងតែងច្បាប់តាមសម័យនិយម ។

– ទ្រង់ជ្រើសនាម៉ឺនយកសុទ្ធតែមានចំណេះជ្រៅជ្រះ ។

– ទ្រង់បានបញ្ជាឲ្យកុមារទៅរៀននៅវត្ត ។

– ទ្រង់បញ្ញត្តិដាក់ទណ្ឌកម្មដល់នាម៉ឺនទុច្ចរិត ស៊ីសំណូក នដែលប្រព្រឹត្តអបាយមុខ មានជក់អាភៀនជាដើម ។

– ទ្រង់បញ្ញត្តិមិនឲ្យយកពន្ធលើសការុប និងចងការ ប្រាក់យកការធ្ងន់ពីប្រជារាស្ត្រឡើយ ។

– ទ្រង់ឲ្យធ្វើពុម្ពបោះប្រាក់តាយ ។

— ទ្រង់សាងផ្លូវមួយពីឧដុង្គទៅកំពត ហើយនិងសំពៅដំនួញមួយ ។

— ទ្រង់ចំណាយព្រះរាជទ្រព្យតាក់ឲ្យយុវជនខ្មែរ ទៅរៀនភាសាបរទេសនៅសិង្ហបុរី ។

រាជ្យព្រះបាទសម្តេចព្រះអង្គឌួង បានសុខក្សេមក្សាន្ត រហូតដល់ ១៨៥៩ ។ ទ្រង់ចូលទីវង្គតនៅឧដុង្គមានជ័យក្នុង គ.ស. ១៨៦០ ។

ព្រះអង្គមានព្រះរាជបុត្របីព្រះអង្គ ព្រះនាមតាមទីទៃគ្នាគឺ :

ទី ១– ព្រះអង្គរាជាវតី (ព្រះបាទនរោត្តម)

ទី ២– ព្រះអង្គស្រីសុវត្ថិ (ព្រះបាទស៊ីសុវត្ថិ)

ទី ៣– ព្រះអង្គជ័យវត្ថា (ព្រះអង្គស្រីវត្ថា ឬ ព្រះស៊ីវត្ថា) ។

## ស្នាព្រះហស្ថ :–

ពិតមែនតែទ្រង់មានព្រះភារកិច្ចយ៉ាងច្រើនចំពោះប្រទេស-ជាតិ ក៏ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គឌួង

ទ្រង់ប្រារព្ធនិពន្ធអត្ថបទរឿងក៏ច្បាប់ក្បួនសម្រាប់ទុកជា ព្រះកេរ្តិ៍ដំណែលទ្រទ្រង់អក្សរសាស្ត្រជាតិដែរ ។

ស្នាព្រះហស្តដែលគេឃើញសព្វថ្ងៃនេះមាន :

១– រឿងចម្ប៉ាថោង (ទ្រង់និពន្ធក្នុងគ.ស. ១៨១០ កាលនៅសិក្សាពុំទាន់ឡើងគ្រងរាជ្យនៅឡើយ) ។

២– រឿងកាកី (គ.ស. ១៨១៥) ទ្រង់និពន្ធក្នុងគ្រាដែលទ្រង់មានព្រះជន្ម ១៩ វស្សា ។

៣– ច្បាប់ស្រី (ទ្រង់និពន្ធក្នុង ម.ស. ១៧៥៩, ច.ស. ១១៩៩, ព.ស. ២៣៨០, គ.ស. ១៨៣៧ ក្នុងវេលាទ្រង់មានព្រះជន្ម ៤១ ព្រះវស្សា) ។

## រឿងផ្នែកប្រលោមអក្សរសិល្ប៍

## សាស្ត្រាល្បើកកាកី[១]

ព្រះរាជកវីទ្រង់តែងរឿងនេះពីថ្ងៃពុធ ១១ កើត ខែពិសាខ

---

(១) ស្រង់ក្នុងកម្ពុជសុរិយា អត្ថបទស្រាវជ្រាវរបស់លោកអ៊ុំ ញ៉ុក ថែមលេខ ៩ ឆ្នាំ ១៩៦៥ ទំព័រ ៩៦៨-៩៦៩ ។

ឆ្នាំកុរ សប្តស័ក ព.ស. ២៣៥៨, ម.ស. ១៧៣៧, ច.ស. ១១៧៧, គ.ស. ១៨១៥ ។

ជាអត្ថបទពាក្យកាព្យ (មានបទកាកគតិ ពំនោល ព្រហ្មគិត និងកុជង្គលីលា) ។ ប្រភពរឿងចេញមកពី៥០០ ជាតក់ៗ ឯកសារសាស្ត្រាស្លឹករឹត ១ ខ្សែ ចប់ជុំជាតក់រក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ចុះលេខសាស្ត្រា ៦៨១ ដែលបានមកពីវត្តសិរីបទុម ខេត្តកំពង់ចាម ។

អត្ថបទមានលំនាំតែងដូចនេះ :

**សេចក្តីផ្តើម** ថា នេះបទកាកគតិ

"អង្គអញត្រកូល ជាតិជាកំពូល កម្ពោជជាតិ នុជនាថ ចូឡជា បុត្រាជាតិ ក្នុងពងសុខ សុខុមខត្តិយា ។ បរពាក បុរី បុកណាវេណី ទៅឋិតនៅនា ក្រុងទេពនគរ កុលករចិន្តា តែងតាមបទបា–ឡីលោកសំដែង ។ ក្នុងប្រាំរយជាតក ចង ជាបទបាទ កិច្ចកាព្យតាយថែង ទុកជាគំណ តែងតអន្វេង ឲ្យអស់តម្លែង ជនជាតិដឹងជាន ។ . . ."

## សេចក្ដីបញ្ចប់ : ថា

–“ស្ដ្រីស្រីណាគាប់ កុំត្រង់ត្រាប់កែវកាកី គំនិតផិតក្បត់ប្ដី ពេលស្វាមីសេពសាហាយ ៗ កំពុងពេញស្នេហា ចិត្តពេស្យាទឹកនិរណាយ ផិតក្បត់ប្ដីទាំងឡាយ ព្រោះចិត្តពោរពង់សម្ពន្ធ ៗ ដំណើរនាងកាកី ប្រែសេចក្ដីសៀមភាសា ជាពាក្យខ្មែរកាព្យ សូរេចរឿងអម៉េះហោង” ៗ

## សាស្ត្រារឿងបម្ប៉ាហោង.–(១)

រឿងនេះព្រះរាជកវីទ្រង់ពុំបានបញ្ជាក់ថ្ងៃ-ខែ-ឆ្នាំនិពន្ធទេ ៗ (ពុទ្ធសាសនបណ្ឌិត្យមានឯកសារនេះ ដោយសារលោកឧកញ៉ាកក្ដីសាទេពវិភូនេត្រ និងអ្នកស្រី **ប៉ិវល** បានសាងទុកក្នុង ព.ស. ២៤៥២, គ.ស. ១៩០៦) ។ ជាអក្ខរបទពាក្យកាព្យ (មានបទភាគគតិ ព្រហ្មគិត ពំនោល និងបទកុជ្ជរលីលា) ៗ

តាមដំណើររឿង ហាក់ដូចជាការនិយាយពីជីវិតរបស់ពោធិសត្វដែលមានប្រភពចេញមកអំពីគម្ពីរជាតកមួយ (មាន

---

(១) តាមការស្រាវជ្រាវផ្ទាល់ តាមឯកសាររបស់ពុទ្ធសាសនបណ្ឌិត្យ ។

បញ្ចាសជាតក៍ ឬ ៥០០ ជាតក៍ជាដើម) ។ នៅទីបញ្ចប់ព្រះគរី
បញ្ជាក់ថា ជារឿងមួយ ក្នុងហាយជាតក៍ ។

ឯកសារដើមជាសាស្ត្រាស្លឹករឹតមាន ៨ ខ្សែចប់ជុំជាតក៍ៗ លេខសាស្ត្រា ១៦២៩ រក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ។

## លក្ខណៈតែងមានដូចនេះ –

### សេចក្តីផ្តើម: ថា នេះបទកាកគតិ

“យើងខ្ញុំបង្គំ គិតគួញពុទ្ធបាទ ក្រញូងក្រាបវន្ទា តាំង
ទសច្ចូលី គាំងភ្ជិបុស្សបារ បង្គំភគវា សារពេជជិនស្រី ។
ពោះតាំងព្រះធម្ម ប្រសើរអស់អាថ៌ បើកបទបាលី បែតម៉ុក
សែនពាន់ មានព្រះគម្ពីរ សោតសូន្យវន្ទី ជួញផង្គលើយោ ។
បង្គំព្រះសង្ឃ ប្រសើរសឹងទ្រង់ សីលសុទ្ធសេដ្ឋា ទុនអស់
អង្គា ហត្ថាសំពែ ក្រញូងក្រាបវន្ទី ទុកលើសិរសា ។ តម្រិត
ខ្ញុំនឹងថែង និទានថ្វាថ្វីង ជុំជាតិអត្ថា កាលព្រះពោធិ-
សត្វសោតកាលណោះ ភពភន្ត្រី កំបាំងសោកសោះ តំមុន
[illegible]នោះ ពហុជាតា ។ . . .”

សេចក្ដីបញ្ចប់ ថា :

"ជាកិច្ចរបរ កិច្ចកើយគម្ពីរ ក្រពើយើសយើង ទ្រឹស្ដ ទ្រស្ដប្រមាត់ យោរយាតមានហ្វង់ ឥឡូវនេះហោង បេរពិល រីងជា ។ ទៅទៅគ្នា គឺនាយគោ ទៅទត្ថបេក ឥតបាប់ នាម សូរ៉ាហ៍ ចងចារិកា ទៅទត្តកិរិយំ ។...

ក្នុងព្រះបាលី សម្ដេចព្រះស្រី សារពេជ្ជទេសនា សម្មាធាទី សិងជាតិកា តតិបក្ខក ទិដ្ឋតារ៉ៃចងបប" ។

(ឯច្បាប់ស្រីទីងបញ្ចាក់នៅខាងក្រោយក្នុងផ្នែកឧបទេស អក្សរសិល្ប៍)

## ១១– ឧកញ៉ាកោសាធិបតី កៅ

ឧកញ៉ាកោសាធិបតី កៅ មានឋានៈជាតាងហ្វាងយ៉ាំង មណីរ័ត្ន ក្នុងរជ្ជកាលព្រះករុណាព្រះបាទអង្គច័ន្ទទី ២ ។

អ្នកនិពន្ធបានតែងរឿងក្រុងសុភមិត្រ ក្នុងម.ស. ១៧២០ គ.ស. ១៧៩៨ ។

# រឿងក្រុងសុភមិត្រ .–

គឺជារឿងជាតកទី៩ ក្នុងរឿង ៥០ ជាតិ (បញ្ញាសជាតក)។ អ្នកនិពន្ធរៀបរៀងរឿងនេះជាពាក្យកាព្យ (មានបទកាកគតិ ព្រហ្មគិត ពំនោល និងភុជង្គលីលា) ។ អត្ថបទដើមជាសាស្ត្រាស្លឹករឹតមាន ៣ ខ្សែ រក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ចុះលេខ ៦២៣ និង ៦៥៦ ដាក់ថា "រឿងក្រុងសុភមិត្រ" ។

ឯអត្ថបទមានលក្ខណៈតែងដូចតទៅនេះ .–

**សេចក្តីផ្តើម** : ថា បទកាកគតិ :

"នមាមិហំ ពុទ្ធសេដ្ឋំ លោកុត្តមោ គុណគុណំ សរំ ធម្មោ វិយេជយោ មារសេនំ ។ នមាមិ សមោចីសិ ឥធ ធម្មំ លោកសេដ្ឋោ ធម្មោសរំ កតាញ្ញាណំ សទ្ធម្មោ ។ នមាមិហំ សុសាវកំ អនាសវេ សរមកំ សរំធម្មោ° គុណករេ កបាលិនំ ។

អញខ្ញុំអភិវាទនវន្ទីយ៍ ក្រញូំក្រាបសិរសំ សរសើរពុទ្ធគុណ អនន្តសេដ្ឋ ស្មគិសោឡសំ ប្រៀបផ្ទឹមពុំបាន ។ ...

សកពជជួបជួន ឯកស័ព្ទទោស្ទួន(១)ស្ទួស័ស្ត៌បារមី
រាសមាយវារពុធ ប្រាំកជប្រាំបី កេចរសំដី សំដែងកាព្យ ។
ញខ្ញុំឈ្មោះ ទៀវ បម្រើគាល់ហៅ ជាខ្ញុំក្សត្រា ព្រះរាជ
ានប្រោស ប្រាណករុណា ឲ្យជាឧកញ៉ា គោសាធិបតី ។
ក់ចៅហ្វាយឃ្លាំង មណីរ័ត្នកែងតាំង កាព្យកិច្ចទាំងនី. ពាន់ទង
ណើរ សរសើរពោធិ-សត្វសាងបារមី ក្នុងហាសិបជាតិ ។
បករាជព្រះសង្ស.ពជាឯកតាំង ប្រែពីទិបាត បញ្ញាសជាតក ។
ទៀនទុកជាភាគ ទើបនិសន្នាត សរឆ្លុតគិតគន់ ។...

សេចក្តីផ្តើមថា:

«ព្រះអង្គបាទត្រាស់ ជាពុទ្ធឲ្យធិប្បាស់ ផ្ទួបជុំជាតិទេសុ-
ាព្រះធម៌ នូវអាចថម្ពីរ បើកបទបារមី ត្រាស់ធម៌ទេសនា ។
រិក្ខុអើយអស់-កម្មត្រគំរប់ ជាតិចងវេក ចេះវិលវិលមក យោន
យកជាតិជា ទេវទត្តនៅនា នរកទាយនៃ ។ វែចាផយទត្ត

(១) ម.ស. ១៧២០ (បើគិតជាគ.ស. គឺ ១៧២០ + ៧៨=១៧៩៨)។
ត្រូវនឹងថ្ងៃពុធប្រាំបីកេច ខែមាឃ ម.ស. ១៧២០ ។

កុមារនោះគាត់ យកជាតិវិស័យ ទៅកើតជា មហាអានន្ទ
ផើរសំធម៌ថ្ងៃ ពីពុទ្ធទស្សា ។ ពីពោធិយសេន កុមារមិញ
ទៅកើតជា ព្រះមហារាហុល ផេរផុលប្រាជ្ញ មិនគិតរ
ឯទៀតឡើយនៃ ។ នាងកេសនី ជាតិជាកន្ទៀ ពន្ទុកសារ
ត្រាស់ត្រាច់ញាណវៃយ្យ នាងបានទ្រង់ត្រៃ-បិដកបែងចប់
ព្រះមាតា អង្គអញ្ញតថា-គតកើតសម្ពុទ្ធ បានជានាងមហា ម
យាគំរប់ មូលមកសព្វគ្រប់ លុះសារណគមន៍ ។ ព្រះបិ
បង្កើតតថា-គតគាប់ជាពំ នាមព្រះបាទស្រី-សុទ្ធោទនក្ស
បានមកជួបជុំ ជាពុទ្ធបិតា ។ ក្រុងសុកមិត្រ ពជបុត្របពិ
គឺអង្គតថា-គតឯងបានត្រាស់ ច្បងច្បាស់ប្រាជ្ញា នាំធម៌ទេស
ទូន្មានភិក្ខុផង ។ សាធុសម្មាយ ចូរចាំនិយាយ ដំណា
ចំនង ព្រះអង្គពោធិ៍-សត្វវិសេសហោង អស់អាថ៌នេះហោ
ស្ងួតបម្រើណា ។៕

X

## ២– ផ្នែករឿងដែលមាននាមអ្នកនិពន្ធ តែគ្មានកាលបរិច្ឆេទ

### ១- ភិក្ខុ បណ្ឌិត ខៀវ (១)

*អ្នកនិពន្ធរូបនេះពុំបានបញ្ជាក់កាលបរិច្ឆេទនៃការតែងស្នាដៃរបស់ខ្លួនឡើយ ។ លោកបានតែងរឿងឈ្មោះ សាស្ត្រា "បន្ទលីវង្ស" និង រឿងព្រេងឈ្មោះ "ពលក្ខន្ធ" ។*

### សាស្ត្រា "បន្ទលីវង្ស

*(តាមការពិនិត្យបញ្ជាក់របស់លោក អ៊ុំ ញ៉ុក-ថៃម)*

*សាស្ត្រា "បន្ទលីវង្ស" នេះ គ្មានបញ្ជាក់កាលបរិច្ឆេទក្នុងត្ថបទទេ មានតែកាលបរិច្ឆេទរបស់អ្នកចារចម្លងថា បានចារចប់នៅថ្ងៃព្រហស្បតិ៍.ខែផល្គុណ ឆ្នាំ រោង នក្សត្រ សម្រិទ្ធិ-ស័ក ពេលម៉ោងប្រាំបី ប្រាំបួនសំបុត្រ ។ ប៉ុន្តែសំនួនវោហារនាំឲ្យស្មានថា ប្រហែលនៅខាងចុងសតវត្សរ៍ ទី ១៩ ។*

*អត្ថបទសរសេរជាពាក្យកាព្យ មានបទ កាកគតិ ពំនោល*

---

(១) ស្រង់ពីក្នុងកម្ពុជសុរិយា លេខ-៩,ឆ្នាំ ១៩៦៥ ទំព័រ-៩៥៧-៩៥៨
ត្ថបទស្រាវជ្រាវរបស់លោក អ៊ុំ ញ៉ុក-ថៃម ។

ព្រហ្មគិត និងកុដង្គលីលា ។ ជារឿងស្រង់មកពីបញ្ញា
ជាតក៍ ។ ឯកសារជាសាស្ត្រាស្លឹករឹតមាន ៥ខ្សែបច់ ជុំជាត
រក្សាទុក នៅក្នុងបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ចុះលេ
សាស្ត្រា ៦៧៣ ។

ឯអត្ថបទ មានលក្ខណៈដូចនេះ .–

**សេចក្ដីផ្ដើម:** ថា/ នេះបទកាកគតិ

" ខ្ញុំសូមបង្គំ លុតលើកកំបង់ ព្រះមកុដនោមនាយ
ព្រះអង្គបានត្រាស់ ប្រោសសត្វសព្វសាយ ដាក់ដល់សួគ៌
នាយ បាននិព្វានពិត ។ . . .

បណ្ឌិត **ខៀវ** ខ្ញុំឧស្សាហ៍ខិតខំ រើះកាសា ល្បងល
កាព្យកិច្ច ។ ដោយល្បិចប្រាជ្ញ សង្វាតឧស្សាហ៍ ·តសាស-
នាព្រះ ។ សូមសុខសួស្ដី វិទ្ធីជោគជ័យ តេជាតបះ ជៀ
ជួយជ្រោមជ្រែង ខ្ញុំតែងរឿងព្រះ ខាំងខុសលើសខ្វះ បំពេញ
ឲ្យផង ។ . . . . . ។ល។

សេចក្តីបញ្ចប់ថា :-

«ឱ្យអស់ភិក្ខុផង គួររៀនចាំចង ព្រះធម៌ថ្ងៃថ្ងា ភិក្ខុ

ផងបង្គំ ប្រណម្យលើកដៃ ស្តាប់សើធម៌ថ្ងៃ បន្ទូលទេសនា ។

លន់លុះចប់ស្រេច ហើយព្រះអង្គស្តេច គោចរយាត្រា ចេញ

ពីព្រះធម៌ សភាសាលា ខ្សែប្រាំសាស្ត្រា ចន្ទលីវង្សនេះ ។

ភិក្ខុខ្ញុំគិតតែង រំពឹងគិតឈ្វេង ភាសារ៉ិះ សេចក្តីខ្សែប្រាំ

ជុំជាតក៏ទុកស្ទើះ បរិបូណ៌ប៉ុណ្ណោះ សូរេចម៉្លេះហោង» ។

X

## ២- ភវី ចន្ទ (១)

អ្នកនិពន្ធរូបនេះ បានតែងរឿងឈ្មោះ «សាស្ត្រា

ភិនសុវណ្ណ» ។

### សាស្ត្រា ភិនសុវណ្ណ

សាស្ត្រានេះគ្មានបញ្ជាក់កាលបរិច្ឆេទទេ ហើយរៀប

(១) ស្រង់ពីក្នុងកម្ពុជសុរិយា លេខ ៥ ឆ្នាំ ១៩៦៥ ទំព័រ ៦៥៨ និង ៦៥៩ ។ អត្ថបទស្រាវជ្រាវរបស់លោកអ៊ុំ [illegible] ខឹម ។

រៀនជាពាក្យកាព្យ (មានបទកាកគតិ ពំនោល ព្រហ្មគីត និ
កុជង្គលីលា) ។

ជារឿងមានប្រភពចេញមកពីរឿង ហាសិបជាតក៍
បញ្ញាសជាតក៍ ។

ឯកសារជា សាស្ត្រាស្លឹករឹត មាន ៦ខ្សែ ចប់ជុំជាត
រក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ មាន ២ គម្ពីរ លេខសាស្ត្រា
៦៧៥ និង ៦៧៦ ។

ដំអត្ថបទមានលក្ខណៈដូចនេះ :-

**សេចក្តីផ្តើម:** ថា នេះបទកាកគតិ

"ទើបទសករក៌ - បន់បត់បង្គំ ផាក់ដល់សិរសា ទៀនទៅ
ព្រះស្រី ត្រៃគតពរគត់ ព្រះអង្គជាតិជា កំពូលលោកផង ។
ព្រះព្រោងរស្មី ប្រាំមួយពណ៌ពី ព្រះអង្គគន្ធ ព្រះបាទលាយ
លក្ខណ៍ កង់ចក្រដួបផង ហេតុព្រះជាច្បង លើសលើកព
ត្រៃ ។ . . . ។ល។"

សេចក្ដីបញ្ចប់ ថា :

"ព្រះកិនសុវណ្ណ ប្រសើរសោភ័ណ លើសលើលោក គឺអញ្ជកជា-គតជាពុទ្ធ ត្រូវគ្រប់អស់ឯ ទៅតាមខុសផង ។ នេះគឺនិបាត ហៅហាសិបជាតក៍ ប្រសើរកន្ទង៍ ចន្ទះតាមះ អហាំបែនចង អនុជស្នេហ៍ស្នង៍ -តាចល្ងើកកាព្យ" ។

X

## ៣- បណ្ឌិត អោវ (១)

អ្នកនិពន្ធរូបនេះបានតែងរឿងឈ្មោះ "សាស្ត្រាព្រះស្វាំត" ។

## សាស្ត្រា "ព្រះស្វាំត"

សាស្ត្រានេះគ្មានកាលបរិច្ឆេទទេ (លោក អុំ ញ៉ុក-ថៃម បញ្ជាក់ថា ប្រហែលជាតែងនៅពាក់កណ្ដាលខាងដើមនៃសត-វត្សរ៍ទី ១៩ ទេដឹង ?) ។

គេសរសេរជាពាក្យកាព្យ មានបទកាគតិ ពំនោល

(១) ស្រង់ពីក្នុងកម្ពុជសុរិយា លេខ ៩ ឆ្នាំ ១៩៦៥ ទំព័រ ៩៦០ និង ៩៦១ ។ អត្ថបទស្រាវជ្រាវរបស់លោក អុំ ញ៉ុក-ថៃម ។

ព្រហ្មគិត និងកុជន្គលីលា ។

ជារឿងមានប្រភពនៅក្នុងហាសិបជាតក៍ ។

ឯកសារជាសាស្ត្រាស្លឹករឹត មាន ៤ ខ្សែចប់ជុំជាតក៍ គេរក្សាទុក១ចប់លេខសាស្ត្រា ៦៧៩ នៅពុទ្ធសាសនបណ្ឌិត្យ ។

ឯលក្ខណៈអក្ខបទមានដូចនេះ .—

## សេចក្តីផ្តើម ថា បទព្រហ្មគិត

"ខ្ញុំខំនអង្គអកី - រាំទន្ទី លុតលើកលើ សិរសីសូម សរសើរ ព្រះសម្មាសម្ពុទ្ធស្ស ។ ព្រះអង្គឯកឥស្សូរ ជាកំពូល លោកនាថច្បាស់ មារពុាយបីបាស់ បរិបូណ៌បានបាក់បែប បប ។ រួញរាកកតាញ់តាល ព្រះសក្តារខ្ញាំងខ្ពាចខ្ចប ប្រែប្រឹងប្រាសប្រាណប្រប លះលែងលាក់លុះត្រៃសរណ៍ ។ ...

"អហំ **នោ** នាមា បន្ទក្តាអង្គអំពល់ បំណោននឹងសល់ វាស់ ត្បិតសង្សារគេពន្ធ ។ ទើបរិះរួសសំដែង ចាយចាវែង [illegible] សរសើរព្រះគុណ កាលគន្ធីជាជាតោ ។ នៅជាពោធិសត្វ បុរស្សត្រៃថ្ងៃឧត្តមា បវរគ្គអគ្គា ឯកឥស្សូរក្បួ

គតក្រៃ ។ល។ ...”

## សេចក្តីបញ្ចប់ ថា ៖

«ហៃជនទាំងឡាយ ចូរចាំនិយាយ ដំណាលព្រះសូរ៉ាត ដោយក្រមពាក់ពន្ធ័ ទាំងខណ្ឌ័និបាត ហៅហោរយជាតក៍ គន្ធង ទៅហើយ ៗ នេះហៅរឿង កំណើតនៅនា វត្តសង្ក្រែហើយ ក្សិណាយល់ក្សិណប្រាស់ និពសឥតត្រើយ ទល់ទុក្ខឥតល្ហើយ ឥតពុំនាក់នៃ ៗ លុះផ្តាច់កិលេស ពកពេសនិទេស ទុំនឹង និរភ័យ ទុក្ខទោសនោះបាន គេក្សាមក្សាន្តប្រពៃ ហៃជនសព្វថ្ងៃ គួរគិតអនិច្ចា ៗ លុះសាងកុសល សង្វាតជាផល នានាំអាត្មា ឲ្យបានរំដោះ រង្គោះរឿង ទុក្ខទោសភ័យា នូវភ័យកិតផង ៗ

រីអាថ៌បរិយាយ និទានអភិប្រាយ អស់អាថ៌គន្ធង ដំណើរជុំ ជាតក៍ ព្រះសូរ៉ាតច្បាស់ច្បង បរិបូណ៌គន្ធង និដ្ឋិតោចៃចប់” ។

X

## ៤– ភី វ៉ៀម(១)

កវីនេះបានរៀបរៀង សាស្ត្រា "វិមានចន្ទ"

### សាស្ត្រា "វិមានចន្ទ"

កវីនេះបញ្ជាក់នាមរបស់ខ្លួនថា "អហំខ្ញុំ នាម វ៉ៀម សុខសម ប្រុះប្រាជ្ញយល់ ព្រះធម៌ទាន វិញ្ញាណខសពល ត្រាស់សាងកុសល ក្នុងជាតិពោធិ" ។

សាស្ត្រានេះ សរសេរជាពាក្យកាព្យ (មានបទកាកគតិ ពំនោល ព្រហ្មគិត និងភុជង្គលីលា) ។ ប្រកបរឿងមាននៅក្នុងបញ្ញាជាតក៍ ឬហាសិបជាតក៍ ។ ឯកសាររក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ចំនួន ៨ ខ្សែ ចប់ជុំជាតក៍ មាន ៣ ចប់ លេខសាស្ត្រា ៤៩០-៤៩១ និង ៤៩២ ។

ឯអត្ថបទមានលក្ខណៈដូចនេះ ៖ —

**សេចក្ដីផ្ដើម** ថា នេះបទកាកគតិ

---

(១) ស្រង់ក្នុងកម្ពុជសុរិយា អត្ថបទស្រាវជ្រាវរបស់លោក អ៊ុំ ញ៉ុក-ថែម លេខ ៩ ទំព័រ ៩៦៤-៩៦៥ ។

"អហំនមានមស្កាក សុសម្ពុទ្ធំ អនុត្តរេ សេដ្ឋគុណំ បុញ្ញក្ខេត្តំ បុញ្ញញាណោ ។ ធម្មគុណំ និយ្យានិកំ អរិយបរោ មោក្ខបទំ សង្ឃំគុណោ នមស្កាកេ–ត្តមោកាយំ ។

ខ្ញុំអរនុនអង្គ គិវន្ទុទៅត្រង់ ឆ្ពោះគុណពុទ្ធ ព្រះប្រាំព្រះអង្គ ស្រោចស្រង់ស្រិតស្រាំង សត្វសង្សារលោងបាបបង់។.។ល។"

## សេចក្តីបញ្ចប់: ថា –

"បានត្រាស់ច្បាស់ប្រាជ្ញ ទ្រង់ទេសនាក្តុំជាតក៍ សំដែងសេចក្តីទុក្ខ ឲ្យមហាជនផងត្រង់ត្រាប់ សូរេចអស់សេចក្តី តាមបាលីមិបាតច្បាប់ គំណាតសណ្តាប់ ពីប្រាំពីរខ្សែមកណា ។ ប្រាកដប្រែកបកាព្យ រឿងកវរៀបតាមគាថា ផ្គួចចប់ចូលចប់ជា ប្រាំបីខ្សែម៉ើះឯងហោង" ។

X

## ៥– អ្នកឧកញ៉ា ធម្មាធិបតី ចន្ទ (១)

ជាអ្នកនិពន្ធកំរជួកាលព្រះបាទសម្តេចព្រះអង្គឌួង (ក្រុង

---

(១) តាមការស្រាវជ្រាវរបស់លោក អ៊ុំ ញ៉ុក-ថៃម ចុះក្នុងកម្ពុជសុរិយា ។

ឧដុង្គ) ។ លោកបានតែង "សាស្ត្រា សុខមាណព" ។

## សាស្ត្រា "សុខមាណព"

អត្ថបទជាពាក្យកាព្យ (មានបទកាកគតិ និងព្រហ្មគីត) ។ គឺជារឿងជាតកមួយ ប៉ុន្តែគ្មានបញ្ជាក់ពីការសជាតិទេ ។ ឯផ្ទៃរឿង ដំណាលពីសកម្មភាព នៃព្រះពោធិសត្វសាងបារមី ដូចជាតកនានាដែរ ។

ឯកសារជាសាស្ត្រាស្លឹករិត ១ ខ្សែ មាន ១០សន្លឹក គេរក្សាទុកនៅពុទ្ធសាសនបណ្ឌិត្យ ចុះលេខ ១៣៧៦ បានមកពីវត្តវេឡុការាម ។

អត្ថបទនេះមានលក្ខណៈដូចនេះ : -

សេចក្តីផ្តើមៈ ថា នេះបទកាកគតិ

"តេជតេជៈខ្ញុំ សូមសរសើរស-ម្តេចគតព សូមលើកទិសទស សោឡសសួគ៌ា ចំរើនទីឃាយុយឺនឲ្យ ។ កាលរាជ្យក្សត្រា ព្រះនារាយណ៍រាមា-ធិរាជធិបតី ។ សុរិយោភាពង្ស ឯកអង្គចក្រី ចក្កវត្តិសិរី សុរិយាវង្ស ។ ... ។ល។"

សេចក្ដីបញ្ចប់ : ថា

"មាណពឮពាក្យ ជាងស្រដីហាក់ មានចិត្តសង្ស័យ គិតក្រែងពុំមាន ធនធានដល់ដៃ ទើបឆ្លើយថា ហៃ អ្នកជាងទាំងឡាយ ចាំខ្ញុំទៅយក មាសនាំវិលមក ឲ្យអ្នកចែកចាយ អស់អ្នកដែលធ្វើ កាប់ឈើនៅអាយ កុំអ្នកទាំងឡាយ បារម្ភទៀយណា ៗ ទើបជាងផ្លាស់ឆ្លើយ ថាហៃអ្នកអើយ .... បាត់...យកមកឲ្យខ្ញុំ ទោះអ្នកឯណា ត្រាប់យកតម្រា កុំបីឲ្យឆ្ងាយ តំណាទៅឯក្រោយ ជាសរសេរបម៉្វះហោង" ៗ

X

## ៦ ចៅពញា ភក្ដីសង្គ្រាម បាល (១)

គ្មានជីវប្រវត្តិទេ ៗ លោកបានតែងរឿង "សុភោគ" ៗ

សាស្ត្រា "សុភោគ" : –

រឿងនេះគ្មានបញ្ជាក់កាលបរិច្ឆេទទេ ៗ ជារឿងក្នុង

(១) ស្រង់ក្នុងកម្ពុជសុរិយា លេខ ១១ ឆ្នាំ ១៩៦៥ ទំព័រ ១១៦៣ អត្ថបទស្រាវជ្រាវរបស់ លោក អ៊ុំ ញ៉ុក-ថែម ។

ហាសិបជាតក៍ ឬ បញ្ញាសជាតក៍ ។ អត្ថបទតែងជាពាក្យកាព្យ (មានបទកាកគតិ ពំនោល ព្រហ្មគីត និងភុជង្គលីលា) ។ ជាអត្ថបទសាស្ត្រាស្លឹករឹត មាន៥ខ្សែចប់ ដំកល់ទុកនៅពុទ្ធសាសនបណ្ឌិត្យ លេខសាស្ត្រា ១៣៧៤ ។

លក្ខណៈអត្ថបទមានដូចនេះ :—

សេចក្តីផ្តើម : ថា នេះបទកាកគតិ —

"អញខ្ញុំនេះណា នុងអង្គនមស្ការ លុតលើកកំបង់ ប៉ាត់ប៉ាយបង្គំ ប្រណម្យឆ្ពោះត្រង់ ព្រះពុទ្ធព្រះសង្ឃ អម្បាល ខ្ជាប់ហោង ។ ទើបខ្ញុំបង្គំ ព្រះឥន្ទព្រះព្រហ្ម ជាធំកន្លង ទូវ អស់ទេព្តា តាកករផង ត្រៀតខ្ញុំបណាន់ ប៉ុនប៉ងប្រាថ្នា ។ ខ្ញុំ និងសរសើរ តាមដោយដំណើរ ពីព្រះករុណា កាលយោនយក ជាតិ កុងវង្សសង្សារ សូមអស់ទេព្តា ករុណាខ្ញុំផង ។...។ល។"

សេចក្តីបញ្ចប់ : ថា —

"វីងនាងលំអង ពុម្ពាហោងថ្ងៃសោភា ជាអង្គអគ្គជាយា ពុំឃាតឃ្វាជាតនៃ ។ បេរិតវេទយោនយក ជាតិនោះមក

ក្នុងកពាក្រៃ នាមនាងពិម្ពាថ្ងៃ ភិក្ខុនីថេរីហោង ៗ រីទៅពុទ្ធ សេន ពជនវេទ្រជាបុត្របង្ក ចេរវិលវិញមកហោង ពុំឃ្លាត ឃ្លាជាកហុល ៗ

រីនាងនាថបុត្រី កុមារីនិមិល សំណាងសាងជួបជល់ នឹង កុសលដល់និព្វាន ៗ ចេរវិលវិញយោនយក ជាតិនោះមក គេជះពាន សំណាងមកមាន ឈ្មោះឧប្បលពណ៌ាថេរី ៗ រីឯ ព្រះតាបស មានសប្បុរសរើសក្សត្រី ចេរវិលវិញមកខ្មី ជាព្រះ ស្រីអគ្គសារីបុត្រ ៗ រីឯអគ្គព្រះតាបស នៅជ្រោយកោះចុំង សមុទ្រ ចេរវិលវិញចំហុត ជាព្រះមោគ្គល្លានោ ៗ ដំណើរ សរសើរសព្វ ពាក្យពេចន៍បប់រឿងពុទ្ធ ធម្មា សង្ឃ្រាយោ ជាសូរបេចប់ម៉ីះហោង ៗ (១)

---

(១) អ្នកនិពន្ធ និងស្នាដៃបែបរឹកចាក្នុងផ្នែកទី ២ នេះ ប្រាកដជាមានខ្វះ ទៀតដែលយើងនឹងខិតខំស្រាវជ្រាវបន្ថែមនឹងបំពេញតទៅខាងមុខទៀត ។

X X X

## ៣– ផ្នែករឿងដែលគ្មាននាមអ្នកនិពន្ធ តែមានកាលបរិច្ឆេទ

## រឿងសាស្ត្រាខ្យងសង្ខ (១)

សាស្ត្រារឿងនេះ តែងដោយកវីម្នាក់ ប្រហែលជាក្នុងរជ្ជកាលព្រះបាទជ័យជេដ្ឋា ។

កាលបរិច្ឆេទនៃការតែង គឺថ្ងៃព្រហស្បតិ៍ ៨ កើត ខែពិសាខ ឆ្នាំរកា ម.ស. ១៦៥១ (គ.ស. ១៧២៩) ។

ជារឿងតែងដោយពាក្យកាព្យ មានបទកាកគតិ ពំនោលព្រហ្មគិត និងកុជង្គលីលា ។ ប្រកពស្រង់ចេញពីរឿងជាតក៍ ឯកសារទុកនៅពុទ្ធសាសនបណ្ឌិត្យមាន ៨ ខ្សែស៊ឹករ៉ែតបប់ ។ លេខសាស្ត្រា ៥៨៣ និង ៥៨៥ ។

ឯអត្ថបទមានលក្ខណៈដូចនេះ :–

**សេចក្តីផ្តើម** – ថា នេះបទព្រហ្មគិត

"សុភមស្តុសោ ត្ថិយោ មង្គលេ ជយោតិរេក ឯក

---

(១) ស្រង់ក្នុងកម្ពុជសុរិយា អត្ថបទលោកអ៊ុំ ញ៉ុក-ថែម លេខ ៩ ឆ្នាំ ១៩៦៥ ទំព័រ ៩៦៣ ។

ឆបញ្ចោត់ ។ ស័កក្កុដៈ នក្សត្រ ពៃសាខ អដ្ឋកេជសំ គរុពារ សុម្ភោ ។ . . . ។ល ។ ”

(បទកាក) ។ ស្រេចស្តេចត្រកាល ត្រាស់ឡអាចារ្យ ចងជាកាព្យ កាលពោធិសត្វ ឧប្បត្តិកន្នា ព្រះឧទក មាតា រ៉ាវ ។ . . . ។ល ។

## សេចក្ដីបញ្ចប់ ថា.–

«និទាននេះនៃ អាចអធ្យាស្រ័យ ស្រែកស្រាយស្រេច ស្រាប់ ដោយពុទ្ធនុស្ឋា ទេសនាប្រាយប្រាប់ ទូន្មានសណ្ដាប់ សំដែងបែងចប់ ។ នោះអ្នកណាស្ដាប់ នោះត្រេកត្រេងត្រាប់ សេចម្ហូគោរព អ្នកនោះនឹងបាន កេរ្មកក្សាន្តសួស្ដីសព្វលោកិយ គ្រាន់គ្រប់ ដល់បរលោកណា ។ ព្រោះពាក្យកាព្យពុំពីរោះ សារសេចក្ដី កិច្ចកលកាព្យ សូមអ្នកណាមាន ញាណព្យោយ ថ្វីថ្វា ជ្រោមជ្រែង . . . បរិបូណ៌បុណ្យហោង» ។(១)

---

(១) អត្ថបទក្នុងផ្នែកនេះព្រាកដជាមានទៀត ដែលយើងនឹងស្រាវជ្រាវ បំពេញថែមទៅថ្ងៃក្រោយ ។

នឹងមានតទៅភាគ ២ បញ្ចប់







សៀវភៅ «វិញ្ញាសាគ្រូយើង» សំរាប់សិស្សថ្នាក់ទី ៧ ក្នុងការប្រឡងប្រជែងចូលថ្នាក់ ទី ៦ ទំនើប នឹងសៀវភៅ GRAMMATICALE et LOGIQUE សំរាប់សិស្សថ្នាក់ទី ៦-៥ ទំនើប ដែលឧស្សាហ៍ងាយសំគាល់ នឹង ចំណាំពាក្យសៀវភៅទាំងពីរមុខនេះ ជាការចាំបាច់បំផុតរបស់សិក្សា នុសិស្ស ។

សូមកំភ្លេចរកទិញ នៅបណ្ណាគារ គិម-អេង លេខ ១២២ វិថីខេមរភូមិន្ទ នឹងនៅគ្រប់បណ្ណាគារទូរទៅ ។

តម្កល់ទុកតាមច្បាប់ លេខ ៧៩
ចុះថ្ងៃទី ២៥ - ១ - ឆ្នាំ ១៩៦៨
ប. ព. ទី ១ ចំនួន ១.៥០០ ក្បាល

រោងពុម្ព តាវរស្មី